ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ប្រវត្តិសាស្ត្រ និងសិទ្ធិមនុស្ស
- ក្បច់ទឹកទន្លេ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៥៧ ខែមករា ឆ្នាំ២០១៣

# ស្វែងរកការពិត

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៥៧ ខែមករា ឆ្នាំ២០១៣

## មាតិកា


◆ប្រវត្តិសាស្ត្រ និងសិទ្ធិមនុស្សនៅកម្ពុជា ....... ១

◆ជីវិតដើម្បីស្តាតម្លៃស្ត្រី  និងសូត្រខ្មែរ ....... ២

**ផ្នែកឯកសារ**

◆គំនុំវណ្ណៈ ....... ៤

◆ថ្កោង សិរិវុធ ហៅ វុន ប្រធានទូរស័ព្ទ ....... ៩

◆បញ្ជីឈ្មោះ និងរូបថតអ្នកទោសស-២១ ....... ១៣

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ការបាត់បង់ដែលមិនអាចយកមកវិញបាន ....... ១៧

◆ចេង ជីវ័ន្ត : ពុកស្លាប់ដោយសារជាមន្ត្រីគណនេយ្យ ....... ២១

**ផ្នែកច្បាប់**

◆សេចក្តីសម្រេចទៅលើការចោទប្រកាន់របស់ ....... ២៥

**វេទិកាពិភាក្សាសាធារណៈ**

◆កេរដំណែលផ្នែកច្បាប់  និងវប្បធម៌ ....... ២៩

◆ការចងក្រងឯកសារក្រោយពីអំពើឃោរឃៅកើតឡើង ....... ៣២

◆ការបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សនៅតំបន់ ....... ៤៤

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ក្បង់ទឹកទន្លេ  ខ្សែភាពយន្តជាប់ ....... ៥៦

◆ អតីតកាលដែលនឹកស្មានមិនដល់ ....... ៦០






## រក្សាសិទ្ធិ


មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩


រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ :** គ្រីស ឌៀវីង, អាន ហាញខុល, ចនឆរដីអាវី, ម៉ម កល្យាណី **អ្នកនិពន្ធនិងស្រាវជ្រាវ :** ទាវ សារៈមុទិន្ទ, ស៊ិន សុធីតា **អ្នកបកប្រែ :** នង ច័ន្ទមល្លិកា និង ភួង ច័ន្ទប្រណិត **និពន្ធនាយកទូទៅ :** ឆាំង យុ និង ញាណ សុជាតិ **ជំនួយការនិពន្ធនាយក :** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ :** សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ :** ឆេង វើង Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ប្រវត្តិសាស្ត្រ និងសិទ្ធិមនុស្សនៅកម្ពុជា

រយៈពេលជាងសាមសិបឆ្នាំបន្ទាប់ពីរបបខ្មែរក្រហម ប្រទេសកម្ពុជានៅតែតស៊ូកសាងមូលដ្ឋានរឹងមាំមួយសម្រាប់បញ្ហាសិទ្ធិមនុស្ស ។ អង្គការសហប្រជាជាតិ និងដៃគូអន្តរជាតិដទៃបានជួយកម្ពុជាដោះស្រាយបញ្ហានិទណ្ឌភាពរបស់ខ្មែរក្រហមនិងបង្កជាបរិយាកាសមួយដើម្បីជជែកពិភាក្សាអំពីប្រវត្តិសាស្ត្រ និងបញ្ហាសិទ្ធិមនុស្ស ។ ចំណាប់អារម្មណ៍ដែលផ្តោតមកក្នុងតំបន់សាជាថ្មីជាពិសេសដំណើរទស្សនកិច្ចរបស់លោកប្រធានាធិបតីសហរដ្ឋអាមេរិក បារ៉ាក់ អូបាម៉ា នាពេលថ្មីនេះ បានគូសបញ្ជាក់ពីឱកាសសម្រាប់ការវិវត្តនៅក្នុងបញ្ហានេះ ។

សិទ្ធិមនុស្ស និងប្រវត្តិសាស្ត្រមានទំនាក់ទំនងនឹងគ្នាទៅវិញទៅមកយ៉ាងជិតស្និទ្ធ ពីព្រោះការជជែកពីបញ្ហាសិទ្ធិមនុស្សមិនអាចជៀសមិនផុតពីការបកស្រាយប្រវត្តិសាស្ត្រនោះទេ ហើយការបកស្រាយប្រវត្តិសាស្ត្រក៏មិនអាចជៀសផុតពីការពិភាក្សាអំពីបញ្ហាសិទ្ធិមនុស្សវិញដែរ ។ ប្រការនេះគឺជាអ្វីដែលធ្វើឲ្យសាលាក្តីខ្មែរក្រហមកាន់តែមានតម្លៃ ។ តាមរយៈការពិភាក្សាជាចំហនូវផ្នែកដ៏ស្រួចស្រាវនិងចម្រូងចម្រាសនៃប្រវត្តិសាស្ត្រ ប្រជាជនកម្ពុជាត្រូវបង្ខំចិត្តប្រឈមទៅនឹងសំណួរអំពីសិទ្ធិមនុស្ស នីតិរដ្ឋនិងទំនាក់ទំនងរវាងរដ្ឋាភិបាលនិងប្រជាជន ។ ជំហានបន្ទាប់នៅក្នុងការជជែកពិភាក្សាថ្នាក់ជាតិនេះគឺដើម្បីអប់រំសិស្សានុសិស្សអំពីអំពើប្រល័យពូជសាសន៍ និងតួនាទីរបស់ច្បាប់ក្នុងសង្គមមួយដែលយុត្តិធម៌ ដើម្បីឲ្យមានការគោរពសិទ្ធិមនុស្សជាយូរអង្វែងសិទ្ធិនេះត្រូវបង្កើតចេញពីមូលដ្ឋាន ។

ប្រការនេះ មិនមានន័យថា យើងត្រូវឈប់ពាក់ព័ន្ធជាមួយនឹងថ្នាក់ដឹកនាំសេដ្ឋកិច្ច និងនយោបាយរបស់ប្រទេសនោះទេ ។ ការកសាងមូលដ្ឋានគ្រឹះសិទ្ធិមនុស្សដ៏រឹងមាំក្នុងប្រទេសកម្ពុជា និងតំបន់អាស៊ាន គឺជាគ្រឹះសម្រាប់ការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងការចូលរួមក្នុងសហគមន៍អន្តរជាតិ ។ ដំណើរទស្សនកិច្ចរបស់លោកប្រធានាធិបតីសហរដ្ឋអាមេរិក បារ៉ាក់ អូបាម៉ា មកកាន់ប្រទេសកម្ពុជាគឺជាផ្នែកដ៏សំខាន់នៃដំណើរការនោះដោយសារតែប្រជាជនកម្ពុជាជាច្រើនសម្លឹងមើលទៅប្រទេសអាមេរិកជាជាងប្រទេសណាៗទាំងអស់ ជាគំរូសម្រាប់បញ្ហាសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ព្រមទាំងជោគជ័យនៃរបបទីផ្សារសេដ្ឋកិច្ចសេរី ។

យើងមើលឃើញដំណើរទស្សនកិច្ចរបស់លោកប្រធានាធិបតីសហរដ្ឋអាមេរិក បារ៉ាក់ អូបាម៉ា មកកាន់ប្រទេសភូមា ថាជាឱកាសដ៏សំខាន់មួយក្នុងការជួយជំរុញឲ្យមានការផ្សះផ្សាជាតិនិងនីតិរដ្ឋក្នុងប្រទេសនោះ ។ ប្រទេសភូមា និងប្រទេសកម្ពុជាមានលក្ខណៈស្រដៀងគ្នាជាច្រើន ទាំងខាងសាសនា វប្បធម៌ និងនយោបាយ ។ វឌ្ឍនភាពខាងលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សរបស់ប្រទេសមួយនឹងអាចជួយផ្តល់ជាការលើកទឹកចិត្ត និងមគ្គុទ្ទេសក៍សម្រាប់ការកែលម្អប្រទេសមួយទៀត ។

ក្នុងករណីទាំងពីរនេះ ការជំរុញប្រទេសផ្សេងៗឲ្យគោរពសិទ្ធិមនុស្សពីថ្នាក់លើមកក្រោមទំនងជាពុំសូវមានប្រសិទ្ធភាពនោះទេ ។ យើងត្រូវការយុទ្ធសាស្ត្រថ្មីដ៏ជាក់លាក់មួយ ។ តំបន់មជ្ឈិមបូព៌ា និងអាហ្វ្រិកខាងជើងអាចផ្តល់ជាមេរៀនសំខាន់ ។ ព្រឹត្តិការណ៍ដែលបង្កឲ្យទៅជាបដិវត្តន៍នៅអារ៉ាប់បានបង្ហាញឲ្យឃើញថា ជារឿយៗ ការដាក់សម្ពាធការទូតដើម្បីឲ្យមានកំណែទម្រង់សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ហាក់ដូចជាពុំមានប្រសិទ្ធភាពដូចការអប់រំ និងការពង្រីកវិសាលភាពក្នុងការទទួលព័ត៌មាន ។

រដ្ឋាភិបាលទាំងឡាយ មានការវិវត្តទៅមុខយ៉ាងមាននិរន្តរភាព នៅពេលដែលរដ្ឋាភិបាលទាំងនេះ អនុវត្តតាមសំណើរបស់ប្រជាជន និងសង្គមស៊ីវិល ។ គំនិតផ្តួចផ្តើមក្នុងការអប់រំ និងការពិភាក្សាពីសង្គមតាមរយៈសារព័ត៌មាន គឺជាយានដ៏សំខាន់សម្រាប់ធ្វើឲ្យសាធារណជនទទួលបាននូវព័ត៌មានគ្រប់គ្រាន់ ហើយតាមរយៈនេះ នីតិរដ្ឋនឹងត្រូវបានជួយលើកស្ទួយ ។ នៅក្នុងប្រវត្តិសាស្ត្រ សន្ទុះជំរុញឲ្យមានការផ្លាស់ប្តូរសង្គម តម្រូវឲ្យមានអ្នកចូលរួមជាច្រើន ។ កិច្ចប្រជុំថ្នាក់រដ្ឋនិងរដ្ឋផ្តល់នូវឱកាសដើម្បីធ្វើឲ្យមានការកែប្រែ ប៉ុន្តែការផ្លាស់ប្តូរមួយដែលមាននិរន្តរភាពគឺត្រូវពឹងផ្អែកលើការពង្រឹងសមត្ថភាពអ្នកក្នុងស្រុកដើម្បីការពារសិទ្ធិជាមូលដ្ឋានសំខាន់ៗ ។ **ឆាំង យុ**

# ជីវិតដើម្បីស្ពានម្លៃស្ត្រី និងសូត្រខ្មែរ

## សេង តក្កនារី រៀបរាប់ពីបទពិសោធន៍នៃការច្នៃសូត្រខ្មែរ



សេង តក្កនារី

លោកស្រី សេង តក្កនារី បានលះបង់ពេលវេលាសម្រាប់ជីវិតរបស់លោកស្រីក្នុងការកសាងឯករាជ្យភាពខាងផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រីកម្ពុជានិងធ្វើឲ្យឧស្សាហកម្មច្នៃសូត្រខ្មែររស់ឡើងវិញ ។ ការងារនេះជាដំណើរផ្លូវវែងឆ្ងាយ ប៉ុន្តែលទ្ធផលទទួលបានគឺសមទៅនឹងការចំណាយកម្លាំងកាយចិត្តរបស់លោកស្រី ។

ស្ត្រីមានបន្ទុកយ៉ាងធ្ងន់ធ្ងរនៅក្នុងប្រទេសដែលទើបតែងើបពីសង្គ្រាម ។ ដោយសារស្ត្រីរងការប៉ះទង្គិចផ្លូវចិត្តតាមរយៈការបាត់បង់សាច់ញាតិ និងការខូះខាត ហើយជារឿយៗ ស្ត្រីត្រូវបង្ខំចិត្តតស៊ូយ៉ាងលំបាកដើម្បីកសាងអត្តសញ្ញាណថ្មីរបស់ខ្លួនឡើងវិញ ។ ការកសាងជីវិតថ្មីនៅក្នុងប្រទេសដែលហែកហួរដោយសង្គ្រាម និងអំពើប្រល័យពូជសាសន៍គឺជាការលំបាកមួយហើយ ប៉ុន្តែស្ត្រីប្រឈមភាពលំបាកផ្សេងបន្ថែមទៀត ក្នុងការតស៊ូជម្នះលើជំនឿចាក់ឫសគល់ អំពីតួនាទី និងឋានៈរបស់ខ្លួននៅក្នុងសង្គម ។ ភាពឆ្លាតវាងវៃ គំនិតដឹកនាំនិងគំនិតច្នៃប្រឌិតរបស់ស្ត្រី មិនត្រូវបានលើកតម្កើងឡើយ ក្រោមហេតុផលថាការពារ "តម្លៃ" ស្ត្រី ។

ដោយឡែកស្ត្រីខ្មែរបានជួបប្រទះនូវឧបសគ្គជាច្រើន ។ អំឡុងរបបខ្មែរក្រហមចន្លោះ(ឆ្នាំ១៩៧៥ - ១៩៧៩) សេដ្ឋកិច្ចនិងកេរមរតកខ្មែរទទួលរងនូវការបំផ្លិចបំផ្លាញ ។ ប្រជាជនរាប់លាននាក់ បានស្លាប់បាត់បង់ជីវិត ហើយមានមនុស្សជាច្រើនទៀតរងការប៉ះទង្គិចផ្លូវចិត្ត ។ លោកស្រី សេង តក្កនារី មិនត្រឹមតែបានពុះពារកសាងសេដ្ឋកិច្ចកម្ពុជាឡើងវិញនោះទេ លោកស្រីក៏បានជួយកសាងកេរមរតករបស់ប្រទេសកម្ពុជាឡើងវិញដែរ ។ ក្រៅពីនេះលោកស្រីបានលះបង់កម្លាំងកាយចិត្តផ្ទាល់ខ្លួនជួយស្ត្រីកម្ពុជាឲ្យស្វែងរកការទទួលស្គាល់ថ្មីមួយនៅក្នុងសង្គមនិងពិភពលោក ។

លោកស្រី សេង តក្កនារី គឺជាម្ចាស់ និងជានាយកគ្រប់គ្រងក្រុមហ៊ុនសន្តូសារ (SantoShaSilk) ជាក្រុមហ៊ុនសម្លៀកបំពាក់កែច្នៃសូត្រខ្មែរដ៏ជោគជ័យមួយ ជាប្រធានគណៈនាយកសមាគមសិប្បករកម្ពុជា ដែលជាអង្គការតំណាងផលិតករសិប្បកម្មច្នៃដោយដៃនៅទូទាំងប្រទេសកម្ពុជា និងជាប្រធានសមាគមសហគ្រិនស្ត្រីកម្ពុជា ដែលជាអង្គការបង្កើតឡើងដើម្បីជួយសហគ្រិនជាស្ត្រីឲ្យចាប់ផ្តើមបង្កើតអាជីវកម្មរបស់ខ្លួនក្នុងប្រទេសកម្ពុជា ។ សមាគមសហគ្រិនស្ត្រីកម្ពុជា គឺជាអ្នកតំណាងឲ្យសហគ្រិន ជាស្ត្រីដែលមានបំណងទាញចំណាប់អារម្មណ៍របស់រាជរដ្ឋាភិបាលកម្ពុជា សារព័ត៌មាន និងសហគមន៍ជំនួញសម្រាប់គោលបំណងយូរអង្វែងមួយក្នុងការលើកកម្ពស់បរិយាកាសជំនួញ និងជួយសម្របសម្រួល

ដល់សកម្មភាពជំនួញរបស់ស្ត្រីកម្ពុជា ។

ជាស្ថាបនិកក្រុមហ៊ុនសន្តុសារ លោកស្រី សេង តក្កនារី បានពុះពារតស៊ូអស់រយៈពេលជាង៨ឆ្នាំ ដើម្បីនាំយកមកនូវគំនិតជំនួញថ្មីៗដល់ឧស្សាហកម្មកែច្នៃសូត្រខ្មែរ ។ បច្ចុប្បន្ន លោកស្រីមានបុគ្គលិកជាអ្នកតម្បាញសូត្រនៅជនបទចំនួនជាង២០០នាក់ មកពី៦ខេត្តក្នុងប្រទេសកម្ពុជា ហើយលោកស្រីមានបុគ្គលិកជាជាងកាត់ដេរចំនួនជាង១០០នាក់នៅក្នុងរោងជាងកាត់ដេររបស់លោកស្រី ។

លោកស្រីបានសម្រេចជោគជ័យក្នុងការធ្វើទីផ្សារផលិតផលទាំងក្នុងស្រុក និងបរទេស ។ ក្នុងឆ្នាំ២០០៥ គំនិតច្នៃម៉ូតថ្មីដោយប្រើសូត្ររបស់លោកស្រីត្រូវបានទទួលស្គាល់នៅក្នុងប្រទេសជប៉ុននិងដោយធនាគារពិភពលោកដែលបានដាក់បញ្ចូលក្រុមហ៊ុនសន្តុសារចូលទៅក្នុងគម្រោងបណ្តាញសិប្បកម្មច្នៃដោយដៃ ។

ក្រៅពីការងារគ្រប់គ្រងក្រុមហ៊ុនសន្តុសារ លោកស្រី សេង តក្កនារី បានប្តេជ្ញាជួយលើកស្ទួយសហគ្រិនជាស្ត្រី ក្នុងប្រទេសកម្ពុជាដោយកសាងភាពជាដៃគូក្នុងតំបន់ និងសកលជាមួយនឹងដៃគូឧស្សាហកម្មនិងសហគ្រិនផ្សេងៗ ។ ជាប្រធានសមាគមសហគ្រិនស្ត្រីកម្ពុជា លោកស្រី សេង តក្កនារី បានធ្វើដំណើរទៅកាន់១៧ប្រទេសដើម្បីពង្រីកបណ្តាញផលិតផលសូត្រផលិតផលច្នៃដោយដៃ និងផលិតផលខ្មែរផ្សេងៗ ។ កាលពីខែមីនា ឆ្នាំ២០១២ លោកស្រីត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងសន្និសីទស្តីពី "ការផ្លាស់ប្តូរតួនាទីរបស់ស្ត្រីនៅអាស៊ី" នៅក្នុងទីក្រុងវ៉ាស៊ីនតោនឌីស៊ី សហរដ្ឋអាមេរិក ។

លោកស្រីសេងតក្កនារីបានស្វែងរកបាននូវក្តីសង្ឃឹមនិងសុភមង្គលក្នុងស្មារតីជាស្ត្រីខ្មែរ ។ តាមការពិត ឈ្មោះក្រុមហ៊ុនសន្តុសាររបស់លោកស្រី ចេញពីភាសាសំស្ក្រឹតមានន័យថាសុភមង្គលជាភាសាខ្មែរ ។ បើត្រឡប់ទៅមើលការខិតខំប្រឹងប្រែងនិងទស្សនវិស័យរបស់លោកស្រី យើងបាននឹកឃើញដល់សុន្ទរកថានៅពេលទទួលពានរង្វាន់ណូបែលសន្តិភាពរបស់មេដឹកនាំសិទ្ធិមនុស្សភូមា ដ៏អស្ចារ្យម្នាក់លោកស្រី អ៊ុងសាន សូជី ដែលបាននិយាយថា «យើងទាំងអស់គ្នាត្រូវរួបរួមបង្កើតពិភពលោកមួយមានសន្តិភាពដែលយើងអាចដេកលក់ស្កប់ស្កល់ដោយមិនព្រួយបារម្ភពីបញ្ហាសន្តិសុខ ហើយក្រោកពីគេងវិញប្រកបដោយសុភមង្គល» ។ លោកស្រី សេង តក្កនារី ប្រាថ្នាចង់ស្វែងរកសុភមង្គលមិត្តភាព និងភាពកក់ក្តៅ តាមរយៈការងារ និងជីវិតផ្ទាល់របស់លោកស្រី ។

**ឆាំង យុ**



# គំនុំខណ្ណៈ

## អត្ថបទសំណេរដើមទាំងស្រុងពីទស្សនាវដ្ដី «យុវជន យុវនារីបដិវត្តន៍» លេខ២៤ ឆ្នាំ១៩៧៣

ចាប់ពីដើមឆ្នាំ១៩៧៣មក ពិសេសចាប់ពីពេលមានកិច្ចព្រមព្រៀងឈប់បាញ់នៅវៀតណាមខាងត្បូង និងនៅលាវមក សមរភូមិកម្ពុជាបានក្លាយទៅជាសមរភូមិក្ដៅជាងគេនៅឥណ្ឌូចិន ក៏ដូចជានៅទូទាំងសកលលោក ។ នៅទូទាំងប្រទេសកម្ពុជា សមរភូមិជុំវិញភ្នំពេញជាសមរភូមិក្ដៅជាងគេបំផុត ។

កងកម្លាំងប្រជាជនប្រដាប់អាវុធ ប្រជាជនរំដោះជាតិកម្ពុជាយើងបានបើកយុទ្ធនាការវាយសម្រុកខ្លាំងយ៉ាងខ្លាំងក្លាបំផុត វាយកាត់ផ្ដាច់ផ្លូវយុទ្ធសាស្ត្រសំខាន់ៗដែលចូលមកកាន់ទីក្រុងភ្នំពេញទាំងអស់ ទាំងផ្លូវគោក ទាំងផ្លូវទឹក ធ្វើឲ្យទីក្រុងស្ថិតនៅឯកោ ខ្វះគ្រាប់រំសេវ ខ្វះស្បៀងអាហារ និងខ្វះរបស់របរជាចាំបាច់សព្វសារពើទាំងអស់ ។ បន្ទាប់មក គឺចាប់ពីខែមិថុនា ឆ្នាំ១៩៧៣ យើងបានសម្រុកចូលវាយកម្ទេចខ្សែការពារទីក្រុងភ្នំពេញដោយជោគជ័យទៀត ហើយបានសម្រុកចូលកៀកនឹងទីក្រុងកាន់តែជិតណាស់ហើយ ។ ខ្មាំងទាំងពួកអាក្បត់ភ្នំពេញ ទាំងចក្រពត្តិអាមេរិកភិតភ័យស្លន់ស្លោមែនទែន ។ ពួកអាក្បត់ភ្នំពេញខំប្រមូលទ័ពទីពីគ្រប់កន្លែងមកទប់ទល់ការពារភ្នំពេញ ។ រីឯចក្រពត្តិអាមេរិក វាប្រមូលយន្តហោះគ្រប់ធុនដែលបោះប្រចាំនៅអាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិកទាំងអស់មកវាយយើងយ៉ាងអស់ដៃនៅលើសមរភូមិជុំវិញភ្នំពេញ ទាំងយប់ទាំងថ្ងៃ ។ ពិសេស យន្តហោះយុទ្ធសាស្ត្រ «បេ-៥២» វាវាយ២៤ម៉ោងពេញ២៤ម៉ោង ។

ក្នុងសភាពការណ៍តានតឹង និងប្រកបទៅដោយគ្រោះថ្នាក់សម្បើមនេះ វីរយុទ្ធជននៃកងកម្លាំងប្រដាប់អាវុធយើងក៏បានពុះពារប្ដូរផ្ដាច់វាយសម្រុកទៅលើខ្មាំងវិញ ២៤ម៉ោងពេញ២៤ម៉ោងដែរ ។ ក្នុងឆាកប្រយុទ្ធយ៉ាងសាហាវឃោរឃៅ តឹងតែងយ៉ាងនេះ តែងតែមានពលិកម្ម និងរបួសជាធម្មតា ។ ដូច្នេះមន្ទីរពេទ្យនៅសមរភូមិក៏ត្រូវតែធ្វើការ២៤ម៉ោងពេញ២៤ម៉ោងដែរ ។

ម៉ោង៧រំលងអាធ្រាត្រទៅហើយ នៅក្នុងមន្ទីរពេទ្យសមរភូមិភ្នំពេញ គេឃើញយុទ្ធនារីម្នាក់កំពុងវះកាត់យកគ្រាប់ និងបំណែកគ្រាប់ពីក្នុងមុខរបួសយ៉ាងស្ទាត់ជំនាញបំផុត ដោយមានយុទ្ធជន និងយុទ្ធនារីបួនប្រាំនាក់ទៀតជាជំនួយការ នៅក្រោមពន្លឺភ្លើងពិលភ្លឺចិញ្ចាច ។ លុះវះកាត់ ដេរ និងរុំមុខរបួសរួចម្នាក់ហើយ យុទ្ធនារីពេទ្យចាប់ផ្ដើមធ្វើម្នាក់ទៀត ។ ម្នាក់ហើយម្នាក់ទៀត រហូតទាល់តែអស់អ្នករបួស ។ យុទ្ធនារីពេទ្យធ្វើការក្នុងសង្វាក់នេះរាប់ខែមកហើយ ពោលគឺចាប់តាំងពីពេលបើកយុទ្ធនាការវាយយ៉ាងខ្លាំងក្លានៅជុំវិញភ្នំពេញមក ។ យុទ្ធនារីយើងធ្វើការទាំងយប់ទាំងថ្ងៃ គ្មានស្គាល់ម៉ោងពេលសម្រាកទេ ។ មានអ្នករបួសមកដល់ថ្មើរណា យុទ្ធនារីយើងធ្វើការថ្មើរហ្នឹង ។ មិត្តយើងបានសម្រាកតែពេលហូបបាយ និងពេលដែលវះកាត់អ្នករបួសអស់ប៉ុណ្ណោះ ។ តែពេលនេះក៏ខ្លីដែរទេ ព្រោះនៅសមរភូមិមុខមានការប្រយុទ្ធគ្នាជាប់រហូត ។ ដូច្នេះអ្នករបួសក៏ត្រូវបញ្ជូនមកពេទ្យជាបន្តបន្ទាប់ដែរ ។ ពេលគេសែងបងប្អូនរបួសមកដល់ម្ដងៗ ទោះយប់ក្ដី ថ្ងៃក្ដី យុទ្ធនារីយើងមិនដែលដាំអែដំអក់មួយវិនាទីទេ មិត្តតែងតែស្ទុះចេញទៅពិនិត្យមើលភ្លាមៗ ហើយចាត់ចែងភ្លាមៗ ។ អ្នករបួសណាត្រូវបញ្ជូនទៅពេទ្យខាងសមរភូមិក្រោយ ក៏រៀបចំបញ្ជូនទៅភ្លាម ។ អ្នករបួសណាត្រូវជួយសង្គ្រោះជាបន្ទាន់នៅនឹងកន្លែងក៏ចាប់ផ្ដើមវះកាត់ភ្លាមដែរ ។ មិត្តយើងធ្វើការដោយសង្វាក់វាយសម្រុកជាប់ជានិច្ចដោយស្មារតីទទួលខុសត្រូវចំពោះអាយុជីវិតបងប្អូនរួមវណ្ណៈខ្ពស់បំផុត ។

ដូច្នេះហើយ បានជាក្នុងសភាពការណ៍តឹងតែងបំផុតដែលយន្តហោះចក្រពត្តិអាមេរិក ពិសេសយន្តហោះ «បេ-៥២» វាយទាំងយប់ទាំងថ្ងៃ និងក្នុងសភាពអត្តខាត់ដែលមានថ្នាំសង្កូវ និងសម្ភារមិនគ្រប់គ្រាន់យ៉ាងនេះក៏ដោយ ក៏ពេទ្យបដិវត្តន៍យើងដែលប្រចាំសមរភូមិប្រយុទ្ធនីមួយៗអាចជួយសង្គ្រោះអាយុជីវិតដល់បងប្អូនរួមវណ្ណៈបានជាអតិបរមាដែលពេទ្យក្នុងសង្គមចាស់ពុំអាចធ្វើបានមួយចំណិតឡើយ ។

ទោះបីជារវល់ញាប់ដៃញាប់ជើងយ៉ាងនេះក៏ដោយ ទោះជាត្រូវហត់នឿយទាំងយប់ទាំងថ្ងៃយ៉ាងណាក៏ដោយ ក៏យុទ្ធនារីយើងនៅតែមានទឹកមុខញញឹម អាកប្បកិរិយាទន់ភ្លន់ និងពាក្យសម្ដីផ្អែមល្ហែមទៅកាន់អ្នកជំងឺ ក៏ដូចជាទៅកាន់យុទ្ធមិត្តជំនួយការជានិច្ច ដោយមនោសញ្ចេតនាវណ្ណៈជ្រាលជ្រៅបំផុត ។ ក្នុងពេលវះកាត់ដើម្បីជួយបន្ថយនូវការឈឺចាប់ដល់បងប្អូនរបួស យុទ្ធនារីយើងតែងតែរករឿងពីនេះពីនោះមកនិយាយលួងលោម និងលើកទឹកចិត្តគេជានិច្ច ។ ជាមួយយុទ្ធមិត្តដែលនៅធ្វើការជាមួយ ពេលឃើញបងប្អូនធ្វើការហត់នឿយខ្លាំង ក៏យុទ្ធនារីយើងចេះនិយាយលើកទឹកចិត្តគេ និងចេះរករឿងនេះ រឿងនោះមកនិយាយលេងសើចជាមួយគ្នា ធ្វើឲ្យបរិយាកាសក្នុងមន្ទីរពេទ្យមានសភាពរីករាយ រាក់ទាក់ កក់ក្ដៅ និងជិតស្និទ្ធគ្នាជានិច្ច ។

មិត្តជាយុទ្ធនារីពេទ្យកងទ័ព ។ បច្ចុប្បន្ននេះ មិត្តទើបតែអាយុ ២១ឆ្នាំប៉ុណ្ណោះ ។ ថ្វីត្បិតតែមិត្តមានវ័យក្មេងយ៉ាងនេះក៏ដោយ តែមិត្តបំពេញភារកិច្ចដែលបក្សប្រគល់ឲ្យនេះបានជាអតិបរមា ។ នៅក្នុងក្រុមពេទ្យកងទ័ពនេះ មិត្តជាស្នូលខាងបច្ចេកទេសវះកាត់ផង ជាស្នូលដឹកនាំខាងនយោបាយសតិអារម្មណ៍ និងចាត់តាំងក្នុងការបំពេញភារកិច្ចដ៏ធ្ងន់ និងមមាញឹកនេះផង ។

ដោយមិត្តមានអាកប្បកិរិយាទន់ភ្លន់ រាបសាជានិច្ច ចំពោះបងប្អូនរួមវណ្ណៈ ទាំងស្រី ប្រុស ហើយយល់ដឹងសុខទុក្ខ និងចេះជួយយកអាសាដល់យុទ្ធមិត្តដងគ្នាក្នុងការងារ ក៏ដូចក្នុងពេលឈឺថ្កាត់គ្រប់ពេលវេលា គ្មានគិតគិតដល់ការលំបាក ឬការនឿយហត់ផ្ទាល់ខ្លួនឡើយ ម្ល៉ោះហើយយុទ្ធជន និងកម្មាភិបាលក្នុងអង្គភាពទាំងអស់តែងតែគោរពស្រឡាញ់ និងកោតសរសើរមិត្តគ្រប់ៗគ្នា ។ គេតែងតែនាំគ្នាជំណាលពីមិត្តដោយគោរព និងស្ងើចសរសើរថា មិត្តធ្វើការហាក់ដូចមិនចេះនឿយហត់សោះ មិនដឹងជាមានប្រភពកម្លាំងមកពីណាបានជាទ្រាំទ្រវះកាត់ទាំងយប់ ទាំងថ្ងៃយ៉ាងនេះបាន ។ មានមិត្តខ្លះលាន់មាត់ ចំពោះមុខមិត្តថាៈ «អាណិតមិត្តណាស់! មិនដឹងជាហត់យ៉ាងណាទេ បើធ្វើការទាំងយប់ ទាំងថ្ងៃយ៉ាងនេះ គ្មានឈប់ឈរសោះ!» ។

នៅចំពោះពាក្យទាំងនេះ យុវនារីយើងតែងឆ្លើយដោយញញឹមថាៈ«ការនឿយហត់របស់ខ្ញុំប៉ុណ្ណោះមិនទាន់ស្មើនឹងទុក្ខវេទនារបស់ប្រជាជនយើងទេ! ហើយការនឿយហត់របស់ខ្ញុំនេះ ក៏មិនទាន់ធ្ងន់ធ្ងរស្មើនឹងការនឿយហត់របស់បងប្អូនយោធាដែលប្រយុទ្ធស្លាប់រស់ក្រោមគ្រាប់រំសេវទាំងយប់ទាំងថ្ងៃ រាប់ខែឆ្នាំមកហើយ គ្មានសម្រាកសោះនោះដែរ ។ ខ្ញុំធ្វើការសព្វថ្ងៃនេះ គ្រាន់តែរួមចំណែកតូចមួយក្នុងមហាចលនាបដិវត្តន៍រំដោះប្រទេសជាតិ និងរំដោះប្រជាជនឲ្យចាកផុតពីទុក្ខវេទនាសព្វបែបយ៉ាងតែប៉ុណ្ណោះ» ។

មានមិត្តខ្លះទៀត ដោយឃើញយុទ្ធនារីយើងស្ទាត់ជំនាញខាងវះកាត់ដូច្នេះ ក៏នឹកស្មានថា មិត្តនារីយើងប្រហែលជាចេញពីសាលាពេទ្យជាន់ខ្ពស់ណាមួយហើយមើលទៅ ។ ថ្ងៃមួយមានមិត្តយើងសួរមិត្តអំពីរឿងនេះ ។ មិត្តផ្ទុះសំណើចតែម្ដង រួចនិយាយរ៉ាយរ៉ាប់ប្រាប់មិត្តយើង ដោយទឹកមុខស្រងូតស្រងាត់ថាៈ

«ខ្ញុំជាកូនកំព្រាបងស់ក្នុងគ្រួសារកសិករក្រមួយ នៅឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។ ខ្ញុំកំព្រាឪពុកម្ដាយនៅតែជាមួយជីដូនតាំងពីតូចម្ល៉េះ ។ ដូច្នេះខ្ញុំពុំចាំមុខឪពុកម្ដាយខ្ញុំយ៉ាងម៉េចទេ ។ រឿងរ៉ាវក្នុងគ្រួសារខ្ញុំទាំងប៉ុន្មាន គឺបានដឹងអំពីជីដូនខ្ញុំ និងបងប្អូនប្រជាជនក្នុងភូមិទាំងអស់ ។ នៅចុងឆ្នាំ១៩៥៤ គឺបន្ទាប់ពីចុះកិច្ចព្រមព្រៀងសន្តិភាពនាក្រុងហ្សឺណែវហើយភ្លាម ពួកវណ្ណៈកាន់អំណាចប្រតិកិរិយាក៏ចាប់ផ្ដើមធ្វើការរាតត្បាតយ៉ាងឃោរឃៅព្រៃផ្សៃនៅតាមជនបទស្រែចម្ការភ្លាមដែរ ។ ពួកវាធ្វើការចាប់ចងកាប់សម្លាប់ប្រជាជនស្លូតត្រង់ស្នេហាជាតិដែលបានចូលរួមក្នុងចលនាតស៊ូវាយបណ្ដេញអាណានិគមបារាំងទាំងអស់ដោយគ្មានការជំនុំជម្រះឡើយ ។ នៅចំពោះមុខស្ថានការណ៍តឹងតែង ដូច្នេះឪពុកខ្ញុំ ក៏ដូចបងប្អូនប្រជាជនតស៊ូជាច្រើនទៀតដែលបានគេចចេញពីផ្ទះបាត់ទៅ ។ ប្រហែលជាមួយខែក្រោយមក ខ្មាំងបានមកហ៊ុមព័ទ្ធភូមិ ហើយឡើងរុករើឆែកឆេរក្នុងខ្ទមខ្ញុំ ដើម្បីរកចាប់ឪពុកខ្ញុំមែន ។ ក្រោយពេលដែលវាឆែកឆេរក្នុងខ្ទមខ្ញុំ និងខ្ទមជាច្រើនផ្សេងទៀតក្នុងភូមិ ហើយរកមិនឃើញឪពុកខ្ញុំ វាក៏មកចាប់ម្ដាយខ្ញុំចងបណ្ដើរយកទៅ ។ ពេលនោះខ្ញុំអាយុ២ឆ្នាំ ទើបចេះដើរ ចេះរត់បន្តិចៗ ។ នៅពេលដែលខ្មាំងវាមកចាប់ម្ដាយខ្ញុំ ម្ដាយខ្ញុំបានបេះខ្ញុំពីទ្រូងហុចទៅឲ្យជីដូន ហើយផ្ដាំថាៈ «ម៉ែចិញ្ចឹមកូនឲ្យខ្ញុំផង ! ដល់វាធំឡើងឲ្យវាធ្វើបដិវត្តន៍សងឈាមឪពុកម្ដាយវិញ!» ថាបានតែប៉ុណ្ណោះ ពួកអាធាហានឃោរឃៅវាធាក់ម្ដាយខ្ញុំដួលទាំងជិហរ ។

រូប វាដេញចាប់ប្រមូលបងៗខ្ញុំទាំង៥នាក់ ដែលនៅពេលនោះនៅតូចៗដែរទេ ។ ជីដូនខ្ញុំ ក៏ឆក់ខ្ញុំរត់ចេញទៅបាត់ដោយស្រែកដេរប្រទេចផ្តាសាខ្មាំងយ៉ាងក្រេវក្រោធសម្បើម ។ ខ្មាំងក៏ចាប់ចងម្តាយខ្ញុំ និងបងតូចៗខ្ញុំទាំង៥នាក់ដាក់ឡានយកទៅបន្ទាយអស់ ។ នៅក្នុងបន្ទាយវា ខ្មាំងបានធ្វើទារុណកម្មយ៉ាងសាហាវព្រៃផ្សៃបំផុតលើរូបរាងកាយម្តាយខ្ញុំ ។ ព្រមជាមួយនេះ វាក៏បានធ្វើទារុណកម្មខាងផ្លូវចិត្តយង់ឃ្នងណាស់ដែរ ដើម្បីឲ្យម្តាយខ្ញុំសារភាពវា ព្រមឆ្លើយប្រាប់អំពីកន្លែងដែលឪពុកខ្ញុំ និងកម្មាភិបាលមួយចំនួនទៀតលាក់បំពួនខ្លួននៅដោយវាចាប់បងៗតូចៗខ្ញុំទៅវាយដំប្រំធាក់ កាច់ដៃ កាច់ជើងនៅមុខម្តាយខ្ញុំ ។ តែនៅចំពោះមុខទារុណកម្មយ៉ាងសែនឃោរឃៅទាំងផ្លូវកាយ ទាំងផ្លូវចិត្តរបស់ខ្មាំង ម្តាយខ្ញុំគ្មានតក់ស្លុត គ្មានចុះចាញ់ ឬសារភាពខ្មាំងមួយម៉ាត់ឡើយ ។ ហើយផ្ទុយទៅវិញ គាត់មានតែស្រែកដេរប្រទេចផ្តាសាដោយភ្លើងកំហឹងពុះកញ្ជ្រោលជាប់រហូតថា៖ « ពួកអាឯង ជាពួកក្បត់ជាតិ ក្បត់ប្រជាជន! ពួកអាឯងកំសាកណាស់ គ្មានហ៊ានវាយអាណានិគមបារាំងដែលឈ្លានពានប្រទេសជាតិទេ! ពួកអាឯងបែរជាមកកាប់សម្លាប់ប្រជាជនស្លូតត្រង់ជាខ្មែរគ្នាឯងឯណោះទៅវិញ! ពួកអាឯងហ៊ានតែចាប់ចងវាយដំប្រំធាក់ស្ត្រី និងកូនក្មេងមិនទាន់ដឹងអីប៉ុណ្ណោះ! ពួកអាឯង មិនបាច់សួរនាំអីអញទេ! អញមិនត្រូវការអី និយាយឆ្លើយឆ្លងជាមួយពួកអាក្បត់ជាតិទេ! អញមិនខ្លាចស្លាប់ទេ! ស្លាប់អញ ស្លាប់កូនអញប៉ុន្មាននាក់នេះទៅ ក៏នៅប្រជាជនកម្ពុជាទូទាំងប្រទេសដែលនឹងក្រោកឡើងវាយកម្ទេចក្បាលពួកចោរក្បត់ជាតិឯងរាល់គ្នា ក្នុងថ្ងៃណាមួយមិនខានឡើយ!» ។

ខ្មាំងធ្វើទារុណកម្មម្តាយខ្ញុំជាងដប់ថ្ងៃហើយ តែវាពុំអាចយកការណ៍ពីម្តាយខ្ញុំបានមួយម៉ាត់សោះឡើយ ។ ខ្មាំងទាល់ប្រាជ្ញសុញគំនិត ចាញ់ចំណេះហើយ! វាក្តៅណាស់! វានិយាយថា វាកាច់បំបាក់មីអ្នកស្រែម្នាក់នេះមិនបានសោះ! ទីចុងបំផុត វាយកម្តាយខ្ញុំ និងបងតូចៗខ្ញុំទាំង៥នាក់ទៅជីកកប់ទាំងរស់ ។ ពេលវាកំពុងកាយដីកប់ វាសាកល្បងសំឡុតស្មារតីម្តាយខ្ញុំម្តងទៀត ឲ្យឆ្លើយសារភាពវា វាថា បើឆ្លើយប្រាប់ វាទុកឲ្យរស់ទាំងម៉ែទាំងកូន ។ តែម្តាយខ្ញុំឆ្លើយតបវាវិញដោយនិយាយថា៖ “កូន! យើងសុខចិត្តស្លាប់ទាំងអស់គ្នាជាជាងរស់នៅក្រោមការជិះជាន់របស់ពួកអាក្បត់ជាតិ! យើងស្លាប់ទៅ គង់នៅប្រជាជនកម្ពុជាទូទាំងប្រទេស តស៊ូវាយកម្ទេចក្បាលពួកអាក្បត់សងឈាមយើងវិញទៅថ្ងៃក្រោយមិនខានឡើយ!» ពេលដែលវាកប់ដីម្តាយខ្ញុំដល់ដើមទ្រូងម្តាយខ្ញុំថប់ដង្ហើមស៊ើរដាច់ខ្យល់ហើយ តែគាត់ខំស្រែកជ័យឃោសទីចុងបំផុតថា ៖ “ជយោបដិវត្តន៍កម្ពុជាដ៏រុងរឿង! បដិវត្តន៍កម្ពុជាពិតជាឈ្នះ! ពួកអាក្បត់ជាតិ ក្បត់ប្រជាជនមុខជានឹងវិនាសអន្តរធានអស់ពីទឹកដីកម្ពុជាមិនខានឡើយ!» នេះជាសម្រែកចុងក្រោយបំផុត និងជាជំនឿជឿជាក់លើជ័យជម្នះទីអវសានរបស់ម្តាយខ្ញុំ ។

ម្តាយខ្ញុំបានចូលជាសមាជិកជនបដិវត្តន៍កម្ពុជាក្នុងឆ្នាំ១៩៥៣ ។ គាត់មាននាទីជាអ្នកនាំសារ និងប្រមូលស្បៀងឧបត្ថម្ភកងទ័ព ។ ម្តាយខ្ញុំបានរក្សាជំហរបដិវត្តន៍វាយសម្រុកខ្មាំងរហូតដល់ដង្ហើមចុងក្រោយបំផុត ។

ក្រោយមក ពេលដែលបានដំណឹងថា ខ្មាំងវាយកម្តាយខ្ញុំ និងបងតូចៗខ្ញុំទាំង៥នាក់ ទៅជីកកប់ទាំងរស់ ជីដូនខ្ញុំក៏បាននាំខ្ញុំមកនៅភូមិវិញ ។ គាត់គ្មានសម្រក់ទឹកភ្នែកមួយដំណក់ទេ តែគាត់ឆ្អួតតាំងពីពេលនោះមក ។ មួយថ្ងៃៗ គាត់គិតតែដេរប្រទេចខ្មាំង ។ ពេលណាក៏ដោយឲ្យតែឃើញខ្មាំង ជាទាហានក្តី ប៉ូលីសក្តី ដើរតាមផ្លូវ ឬចូលភូមិ គាត់យកដំបងដេញវាយវា ហើយស្រែកដេរ និងទាមទារឲ្យវាសងកូនសងចៅគាត់មកវិញ ។ តែក្រៅពីនេះ គាត់ពុំដែលរករឿងរកហេតុជាមួយបងប្អូនប្រជាជន ក្នុងភូមិណាម្នាក់ទេ ។ ចំពោះរូបខ្ញុំជាចៅគាត់ស្រឡាញ់ថ្នាក់ថ្នម និងខំចិញ្ចឹមបីបាច់ខ្ញុំល្អជានិច្ច ។ យើងខ្ញុំទាំងពីរនាក់ជីដូនចៅត្រូវបានប្រជាជននៅម្តុំនោះជួយទំនុកបម្រុងសព្វបែបយ៉ាង តាំងពីជួយភ្ជួររាស់ ដកស្ទូង ច្រូតកាត់ បោកបែនរហូតដល់ជួយផ្តល់ម្ហូបអាហារទៀត ។ ក្រៅពីនេះ ដូចជាបុកអង្ករ រែកទឹក រកអុសដាំបាយ ជីដូនខ្ញុំធ្វើបានទាំងអស់ ។ រីឯខ្មាំងវិញ វាតែងដេរជីដូនខ្ញុំថា៖ “មីកញ្ចាស់ឆ្កួត” ។ យើងរស់នៅដូច្នេះរហូតដល់ឆ្នាំ១៩៦៨ ។ ពេលនោះ ខ្ញុំមានអាយុ១៦ឆ្នាំហើយ ខ្ញុំអាចធ្វើការជំនួសជីដូនខ្ញុំបានទាំងអស់នៅក្នុងផ្ទះ ហើយរួមធ្វើស្រែប្រវាស់ជាមួយប្រជាជនក្នុងភូមិផង ។ ឆ្នាំនោះ ក៏ជាឆ្នាំដែលប្រជាជនយើង ក្រោមការដឹកនាំនៃអង្គការបដិវត្តន៍កម្ពុជាក៏អង់អាចក្លាហានចាប់ផ្តើមតស៊ូអាវុធវិញដែរ ។ យុវ័នក្នុងភូមិខ្ញុំ ភាគច្រើនក៏បានរត់ចូលព្រៃតស៊ូអស់ ។ ពេលនោះ ខ្មាំងក៏ធ្វើការរាតត្បាត ចាប់ចងកាប់សម្លាប់ប្រជាជនតាមមូលដ្ឋានភូមិឃុំទាំងយប់ទាំងថ្ងៃដែរ ។ តែកងទ័ពប្រជាជនយើង

បានចេញពីព្រៃមកឆ្មក់វាយខ្មាំងជាញឹកញាប់ ធ្វើឲ្យវាស្លាប់ និងរបួសស្ទើរគ្មានលោះថ្ងៃណាទេ ។

ចំពោះជីដូនខ្ញុំ ពេលនោះមានការចម្លែកណាស់ ព្រោះធម្មតាគាត់មិនដែលចេះនិយាយអីទេ ក្រៅពីជេរខ្មាំងទេ ។ តែនៅពេលដែលឮស្នូរកាំភ្លើងផ្ទុះរាល់ដង គាត់តែងសើចដោយរំភើបរីករាយណាស់ ហើយលាន់មាត់ថាៈ «ឱ! នេះកាំភ្លើងកូនចៅអញ បាញ់ក្បាលខ្មាំងហើយ!» ខ្ញុំចេះតែឆ្ងល់ តែគាត់ក៏មិនដែលនិយាយអីប្រាប់ខ្ញុំដែរ ។

នៅចុងឆ្នាំ១៩៦៨ ការប្រយុទ្ធគ្នាមានកាន់តែញឹកញាប់ឡើង ។ ខ្មាំងបានកេណ្ឌកៀរ ប្រមូលប្រជាជនឲ្យមកនៅជិតបន្ទាយប៉ុស្តិ៍ប៉មវា ហើយធ្វើការត្រួតពិនិត្យយ៉ាងតឹងរឹង ទាំងយប់ ទាំងថ្ងៃ ។ ចំពោះភូមិខ្ញុំដែលនៅជាប់នឹងផ្លូវស្រាប់ វាគ្រាន់តែឲ្យទាហានមកដេកយាមមួយយប់ បួន ប្រាំនាក់ ប៉ុណ្ណោះ ហើយវាគំរាមថាៈ «បើពីណាហ៊ានយកបាយឲ្យខ្មែរក្រហមស៊ី វានឹងសម្លាប់អស់មួយពូជ សូម្បីតែកូនខ្ចីក្នុងអង្រឹងក៏វាមិនទុកដែរ!» ។

ថ្ងៃមួយ ខ្ញុំឃើញជីដូនខ្ញុំហាលស្រូវច្រើនខុសពីធម្មតា ។ ខ្ញុំសួរគាត់ថាៈ«ហាលស្រូវធ្វើអីច្រើនម្ល៉េះ?» គាត់គ្រាន់តែឆ្លើយថាៈ «កុំនិយាយទៅណា! ចៅខំបុកស្រូវនេះឲ្យអស់ក្នុងថ្ងៃនេះណ៎!» ខ្ញុំធ្វើតាមការណែនាំរបស់ជីដូនខ្ញុំជានិច្ច ។ លុះខ្ញុំបុក អុំស្មែបានជាអង្ករស្រេចហើយ ជីដូនខ្ញុំជញ្ជូនលាក់ទុកអស់ ។ រវាងបីថ្ងៃ ឃើញជីដូនខ្ញុំហាលស្រូវច្រើនម្តង ។ ខ្ញុំចេះតែឆ្ងល់ តែមិនហ៊ានសួរគាត់ ។ យប់មួយ ខ្ញុំដេកចាំពិនិត្យមើលជីដូនខ្ញុំ ឃើញគាត់ចេះតែគ្រេះគ្រុះៗ ពេលឃើញគាត់រៀបចេញដំណើរទៅ ខ្ញុំក៏សួរគាត់ថាៈ «យាយចេញទៅណា? ឲ្យខ្ញុំទៅផង!» គាត់ស្ទុះមកឱបខ្ញុំ ហើយនិយាយខ្សឹបៗដាក់ត្រចៀកខ្ញុំថាៈ «បើដឹងអី ឮអី ឃើញអី កុំនិយាយទៅណាឲ្យសោះ ធ្វើតែមិនដឹង មិនយល់ទៅបានហើយ!» រួចហើយគាត់ហៅខ្ញុំឲ្យជួយស្ពាយអង្ករកន្ទះការ៉ុង គាត់យកកន្ទះការ៉ុង ហើយនាំគ្នាចេញលបៗ ដោយស្ងាត់ស្ងៀមក្នុងយប់ងងឹតសុង ។ កន្លែងខ្លះយើងត្រូវលូនផងក្រាបផង ។ មួយសន្ទុះធំក្រោយមកទើបទៅដល់មាត់ព្រៃ ។ នៅទីនោះ ខ្ញុំឃើញមនុស្សមួយក្រុមកំពុងចាក់អង្ករផ្ទេរអង្ករ ហើយនិយាយខ្សឹបគ្នារអ៊ុះៗ ។

ចាប់ពីពេលនោះមក ខ្ញុំយល់បន្តិចម្តងៗហើយ ។ ហើយចាប់ពីពេលនោះមកជីដូនខ្ញុំ ក៏ខស្សាហ៍និយាយអំពីប្រវត្តិតស៊ូរបស់ឪពុកម្តាយខ្ញុំ និងការដែលខ្មាំងវាសម្លាប់ឪពុកម្តាយខ្ញុំ និងបងតូចៗ៥នាក់ ។ ពេលនោះខ្ញុំស្រក់ទឹកភ្នែក តែជីដូនខ្ញុំបានលួងលោមខ្ញុំ ហើយចង្អុលបង្ហាញផ្លូវដែលខ្ញុំត្រូវដើរដោយនិយាយថា ៈ «ចៅកុំយំ! ការស្លាប់រស់របស់មនុស្សជាការធម្មតាទេ! តែសំខាន់គឺចៅត្រូវដើរតាមគន្លងរបស់ឪពុកម្តាយចៅ! ចៅត្រូវបន្តវេនបដិវត្តន៍នេះជារៀងរហូតទៅ ដើម្បីសងឈាមឪពុកម្តាយ និងបងៗចៅទាំងអស់! ឥឡូវស្នូរកាំភ្លើងបដិវត្តន៍ បានផ្ទុះលាន់កងរំពងនៅសព្វទិសទីហើយ! នេះហើយជាផ្លូវដែលចៅត្រូវដើរដើម្បីកសាងខ្លួន និងកសាងអនាគតរបស់ចៅ ក៏ដូចអនាគតរបស់បងប្អូនកសិករក្រីក្រយើងទាំងអស់ដែរ!» ។

ចាប់ពីពេលនោះមកទើបខ្ញុំយល់ថា ជីដូនខ្ញុំមិនមែនឆ្កួតទេ ។ គំនុំវណ្ណៈចំពោះខ្មាំងបានដក់ជាប់ក្នុងដួងចិត្តជីដូនខ្ញុំជាង១០ឆ្នាំហើយ ។ គាត់ធ្វើជាឆ្កួតដើម្បីបានជេរខ្មាំង តាមកំហឹងចិត្តគាត់ និងដើម្បីចិញ្ចឹមអប់រំខ្ញុំឲ្យបន្តវេនបដិវត្តន៍ សងឈាមឪពុកម្តាយខ្ញុំ និងសងឈាមដូនប្រជាជនយើង ។ ខ្ញុំរឹតតែគោរព និងស្រឡាញ់ជីដូនខ្ញុំទ្វេថែមទៀត ។ ព្រមជាមួយនោះ ភ្លើងកំហឹងវណ្ណៈក៏ឆេះរោលរាលក្នុងទ្រូងខ្ញុំទាំងយប់ ទាំងថ្ងៃ ។ សម្រែកទារបំណុលឈាម ក៏ចេះតែលាន់ឮក្នុងត្រចៀកខ្ញុំជាប់ជានិច្ច ។ ខ្ញុំបានស្នើសុំចូលព្រៃទៅបម្រើកងទ័ពពីរ បីដងហើយ តែអង្គការបានឆ្លើយប្រាប់វិញថា មិនទាន់មានលក្ខណៈសម្បត្តិនឹងយកខ្ញុំទៅទេ! ហើយស្នើឲ្យខ្ញុំនៅភូមិសិនដើម្បីជួយផ្តល់ស្បៀង ។ ចំពោះជីដូនខ្ញុំ គាត់គ្មានរាំងរាខ្ញុំទេ គាត់មានតែនិយាយលើកទឹកចិត្តខ្ញុំទៀតថា កុំឲ្យគិតគូរអីដល់គាត់ ខ្លួនគាត់មួយមិនខ្វះប្រជាជនគេជួយចិញ្ចឹមទេ ។

ពេលនោះ ទោះបីជាខ្មាំងវាគាបត្បៀតតឹងរឹងមិនឲ្យប្រជាជនទាក់ទងជាមួយបងប្អូនតស៊ូក្នុងព្រៃយ៉ាងណា ទោះវាគំរាមថា យកបាញ់ចោលអស់មួយពូជយ៉ាងណា ក៏យើងខ្ញុំទាំងពីរនាក់ជីដូនចៅព្រមទាំងបងប្អូនប្រជាជនម្តុំនោះ នៅតែលបលួចបញ្ជូនអង្ករផ្តល់ឲ្យកងទ័ពក្នុងព្រៃបានជាបន្តបន្ទាប់ ។ អ្នកខ្លះរហូតដល់ទៅលួចធ្វើនំអន្សមនំកន្តំ នំក្រូច នំអាកោ ផ្ញើជូនកងទ័ពក្នុងព្រៃបានទៀតផង ។ ការនេះបញ្ជាក់ឲ្យឃើញនូវមនោសញ្ចេតនាវណ្ណៈដ៏ជ្រាលជ្រៅរបស់ប្រជាជនក្រីក្រយើង ចំពោះបដិវត្តន៍ ហើយហ៊ានលះបង់អ្វីៗទាំងអស់ដើម្បីបដិវត្តន៍ដោយគ្មាននឹកស្តាយស្រណោះ ឬគ្មាននឹកគិតដល់គ្រោះថ្នាក់

អាយុជីវិតខ្លួនបន្តិចសោះឡើយ ។ មនោសញ្ចេតនាវណ្ណៈនេះ ជ្រៅសែនមហាជ្រៅ ជ្រៅជាងទឹកសមុទ្រទៅទៀត ជ្រៅគ្មានអ្វីអាចវាស់ស្ទង់បានឡើយ ។ ការនេះធ្វើឲ្យខ្ញុំរឹតតែស្រឡាញ់រឹតតែគោរព ហើយរៀនសូត្រអំពីប្រជាជនយើងជារៀងរហូតមក ។

កណ្តាលឆ្នាំ១៩៦៩ ទើបខ្ញុំបានចូលទៅនៅក្នុងព្រៃ ។ ពេលនោះខ្ញុំមាននាទីជាអ្នកដាំបាយបម្រើកងទ័ព ។ ខ្ញុំរីករាយនឹងពេញចិត្តនឹងភារកិច្ចនេះណាស់ ព្រោះម៉្យាងខ្ញុំយល់ថា ភារកិច្ចដាំបាយនេះ ក៏ជាការរួមចំណែកវាយកម្ទេចខ្មាំងដែរ ហើយម៉្យាងទៀត វាសមស្របនឹងលទ្ធភាព និងសមត្ថភាពរបស់ខ្ញុំដែលអាចបំពេញបានជាអតិបរមា ។ ជារៀងរាល់ថ្ងៃ ខ្ញុំតែងដើរស្វះស្វែងក្នុងព្រៃរកជីកដំឡូង ជីកក្តួច និងបេះបោចផ្លែឈើ ស្លឹកឈើព្រៃមកលាយបាយ និងដណ្តាំស្លឲ្យបានច្រើន ជូនពូៗកងទ័ពហូបឲ្យបានឆ្អែតដើម្បីមានកម្លាំងវាយកម្ទេចខ្មាំងកាន់តែច្រើនឡើង ។

ពេលថ្ងៃៗ ឬយប់ៗទំនេរ ពូៗកងទ័ពតែងយកចិត្តទុកដាក់ជួយបង្ហាត់បង្រៀនអក្សរ និងលេខដល់ខ្ញុំ ព្រោះខ្ញុំមិនទាន់ចេះអក្សរមួយតួសោះ ។ ខ្ញុំក៏បានខិតខំព្យាយាមរៀនលេខ និងអក្សរតាមការណែនាំរបស់ពូៗជានិច្ច រហូតដល់ចេះអាន ចេះសរសេរ ចេះគិតលេខស្ទាត់ជាបន្តរដូចមិត្តឃើញសព្វថ្ងៃ ។ ព្រមជាមួយនេះ អង្គការបដិវត្តន៍ក៏បានយកចិត្តទុកដាក់អប់រំបណ្តុះបណ្តាលខ្ញុំ ទាំងនយោបាយ សតិអារម្មណ៍ និងចាត់តាំងយ៉ាងទៀងទាត់ដែរ ។ មិនយូរប៉ុន្មាន ខ្ញុំបានប្រែក្លាយខ្លួនពីយុវនារីកំព្រាឯកោអនាថា និងកម្សត់ទុរគតមកជាយុវនារីបដិវត្តន៍ម្នាក់ដែលមានកំហឹងវណ្ណៈពុះពោរមានទស្សនៈ និងគោលជំហរបដិវត្តន៍ច្បាស់លាស់ ចេះស្គាល់មិត្ត ស្គាល់សត្រូវ ហើយរស់នៅក្នុងមហាគ្រួសារបដិវត្តន៍យ៉ាងសែនកក់ក្តៅ ។ ក្រោយមកពូៗកងទ័ពបានបង្រៀនខ្ញុំឲ្យចេះចាក់ថ្នាំ និងរុំរបួស ។ ខ្ញុំក៏បានបំពេញភារកិច្ចជាអ្នកដាំបាយផង ជាពេទ្យផងសម្រាប់បម្រើកងទ័ព ។

ក្រោយរដ្ឋប្រហារ ១៨ មិនា ឆ្នាំ១៩៧០ ចលនាបដិវត្តន៍យើងបានរីកចម្រើនលោតផ្លោះ ទាំងគ្រប់ផ្នែក ។ នៅដើមឆ្នាំ១៩៧១ អង្គការបដិវត្តន៍បានបញ្ជូនខ្ញុំឲ្យទៅរៀនទ្រឹស្តី និងបច្ចេកទេសពេទ្យប្រាំមួយខែបន្ថែមទៀត ។ នៅសាលាពេទ្យបដិវត្តន៍ដែលបើកបង្រៀនក្នុងព្រៃ ។ លុះពេលចេញពីសាលាពេទ្យមកវិញ ខ្ញុំបានខិតខំរៀនសូត្រក្នុងការអនុវត្តជាក់ស្តែង នៅលើសមរភូមិជាប់ជាមួយពូៗកងទ័ពរហូតមក ហើយក៏មានពិសោធខ្លះៗខាងមុខជំនាញពេទ្យនេះ ទោះបីជាមិនទាន់ខ្ពស់ មិនទាន់គ្រប់គ្រាន់ ក៏អាចបម្រើសមរភូមិជាបន្ទាន់បានខ្លះដែរ ។ ព្រៃ និងសមរភូមិនេះ ហើយដែលជាសាលាជាន់ខ្ពស់របស់ខ្ញុំ ។ ខ្ញុំបានប្តេជ្ញាខិតខំទុំទាំងកម្លាំងកាយ ចិត្ត បញ្ញា ខិតខំទាំងសាច់ឈាម អាយុជីវិតខ្ញុំ ជូនចំពោះអង្គការបដិវត្តន៍ដើម្បីរួមចំណែកក្នុងបុព្វហេតុរំដោះប្រទេសជាតិ ប្រជាជន និងរំដោះវណ្ណៈក្រីក្រ និងដើម្បីធ្វើឲ្យជំនឿដ៏មុតមាំរបស់ឪពុកម្តាយខ្ញុំចំពោះបុព្វហេតុដ៏ឧត្តុងឧត្តមនេះបានទៅជាការពិត១០០ភាគរយ ។

ឥឡូវនេះខ្លួនខ្ញុំដែលជាអ្នកបន្តវេនបដិវត្តន៍ ពីម្តាយឪពុកខ្ញុំបានឃើញច្បាស់ផ្ទាល់ភ្នែក ថាពាក្យសម្តី និងជំនឿជឿជាក់របស់ម្តាយខ្ញុំទាំងប៉ុន្មានកំពុងតែប្រែក្លាយទៅជាការពិត ហើយកំពុងចេញជារូបរាងយ៉ាងច្បាស់ក្រឡែតហើយ ។ ទាំងអស់នេះហើយដែលជាប្រភពផ្តល់កម្លាំងកាយចិត្តឲ្យខ្ញុំធ្វើការទាំងយប់ទាំងថ្ងៃ គ្មានចេះនឿយហត់សោះឡើយ ។

ឪពុកម្តាយខ្ញុំបានបង្កើតរូបកាយខ្ញុំមក ។ ជីដូនខ្ញុំនិងប្រជាជនបានចិញ្ចឹមបីបាច់ខ្ញុំឲ្យបានធាត់ធំ ។ តែអង្គការបដិវត្តន៍ និងបដិវត្តន៍បានអប់រំ កសាង និងបណ្តុះបណ្តាលខ្ញុំខាងចិត្ត គំនិត ទស្សនៈ និងគោលជំហរធ្វើឲ្យខ្ញុំទៅជាយុទ្ធនារីបដិវត្តន៍មួយរូបដែលមានឧត្តមគតិឧត្តុងឧត្តម និងមានអនាគតភ្លឺស្វាង ។ ដូច្នេះខ្ញុំមានសុភមង្គលក្រៃលែងក្នុងការបំពេញភារកិច្ចតូច ធំ សព្វបែបយ៉ាងដែលអង្គការបដិវត្តន៍ប្រគល់ឲ្យខ្ញុំ ។

ប្រវត្តិ និងពាក្យសម្តីរបស់យុវនារីយើងចុងក្រោយនេះ ធ្វើឲ្យយុទ្ធមិត្តទាំងអស់ដែលរួមរស់នៅធ្វើការងារជាមួយរឹតតែស្រឡាញ់គោរព និងកោតសរសើរយុទ្ធមិត្តខ្លួនណាស់ទៀត ។ គេទាំងឡាយនាំគ្នាប្តេជ្ញាចិត្តរៀនសូត្រ និងកសាងខ្លួនតាមគំរូជាក់ស្តែងរស់រវើកនេះជារៀងរហូតទៅ ។

◆ **និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា**

◆ **រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍**

# ថ្កោង សិរីវុធ ហៅ វុន : ប្រធានទូរស័ព្ទមន្ទីរស-៨

**ដកស្រង់ចេញពីឯកសារJ00៧៨**

ថ្កោង សិរិវុធ គឺជានិស្សិតខ្មែររៀននៅប្រទេសបារាំង និងត្រឡប់មកប្រទេសកម្ពុជាវិញនៅឆ្នាំ១៩៥៥ ។ ក្រោយមក សិរិវុធ បានចូលរួមជាមួយចលនាបដិវត្តន៍ខ្មែរក្រហម រហូតដល់ទទួលជ័យជម្នះនៅឆ្នាំ១៩៧៥ ដោយពេលនោះគាត់ទទួលតួនាទីជាប្រធានប៉ុស្តិ៍ទូរស័ព្ទនៅមន្ទីរស-៨ ក្រសួងសាធារណការ ។ រហូតដល់ចុងខែមីនា ឆ្នាំ១៩៧៧ សិរិវុធ ត្រូវបានចាប់ខ្លួនបញ្ជូនមកទួលស្លែងតែម្តង ។

ចម្លើយសារភាពរបស់ សិរិវុធ សរុបទាំងអស់ចំនួន៥៩ទំព័រ ដែលចុះហត្ថលេខា និងផ្តិតមេដៃដោយសាមីខ្លួននៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៧ ដោយមាន គេង ជាអ្នកសួរចម្លើយ ។ ប៉ុន្តែយើងមិនដឹងថាចម្លើយសារភាពនោះពិតប្រាកដណានោះទេ ។ ខាងក្រោមនេះ គឺជាការដកស្រង់ចេញចម្លើយសារភាពរបស់ សិរិវុធ៖

ខ្ញុំឈ្មោះ ថ្កោង សិរិវុធ ហៅ វុន អាយុ៤៦ឆ្នាំ ភេទប្រុស ស្រុកកំណើតនៅភូមិឫស្សីព្រៃ ឃុំកំពង់ចម្លង ស្រុកស្វាយរៀង ខេត្តស្វាយរៀង ។

ខ្ញុំមានប្រពន្ធឈ្មោះ គីម វារី ហៅ សិត អាយុ៣៦ឆ្នាំ ជាំបាយឲ្យក្មេងរៀននៅការដ្ឋានគិរីរម្យ ក្រសួងសាធារណការ ។ ខ្ញុំមានកូនបួននាក់ ទី១) ឈ្មោះ ថ្កោង ម៉ានី ហៅ ម៉ាន (ស្រី) អាយុ ១៧ឆ្នាំ ទី២) ឈ្មោះ ថ្កោង កូលម៉ា ហៅ គីម (ប្រុស) អាយុ១៤ឆ្នាំ ទី៣) ឈ្មោះ សារ (ស្រី) អាយុ៨ឆ្នាំ និងទី៤) ឈ្មោះ ស្រួច (ប្រុស) អាយុ២ឆ្នាំ ។




ចម្លើយសារភាពរបស់ ថ្កោង សិរិវុធ ដែល ឌុច ផ្ញើជូនទៅគណៈមជ្ឈិម

នៅឆ្នាំ១៩៤០ ខ្ញុំចូលរៀននៅសាលាបឋមសិក្សាក្នុងឃុំកំពង់ចម្លង ចាប់ពីថ្នាក់ទី១២ ដល់ថ្នាក់ទី១០ ។ បន្ទាប់មក នៅឆ្នាំ១៩៤៤ ខ្ញុំបានប្តូរមករៀននៅសាលាបឋមសិក្សាស្វាយរៀងក្រុង ចាប់ពីថ្នាក់ទី៩ ដល់ថ្នាក់ទី៧ ។

នៅឆ្នាំ១៩៤៧ ខ្ញុំមករៀនបន្តនៅវិទ្យាល័យព្រះស៊ីសុវត្ថិ ក្រុងភ្នំពេញ ពីថ្នាក់ទី៦ ដល់ថ្នាក់ទី៣ ហើយនៅឆ្នាំ១៩៥២ ខ្ញុំបានប្រលងជាប់ទៅរៀននៅប្រទេសបារាំង ខាងផ្នែកទូរស័ព្ទវិទ្យុ រយៈពេល៤ឆ្នាំ ។

នៅឆ្នាំ១៩៥៤ ខ្ញុំបានចូលចលនាគស៊ីនៅបារាំងដោយមាន ហ៊ូ យន់ និង ម៉ី ម៉ាន់ ជាអ្នកនាំចូលអង្គការសម្ងាត់ ឬហៅថា ក្រុមភាសា ដែលមាន អៀង សារី អ្នកដឹកនាំ ។ ក្រុមនេះរៀនពីទ្រឹស្តីម៉ាក្សលេនីន,

លទ្ធិកុម្មុយនីស្ត និងចលនាតស៊ូអន្តរជាតិ ។ នៅទីនោះ ខ្ញុំត្រូវបង់វិភាគទានប្រចាំខែ និងត្រូវចូលរួមប្រជុំជីវភាព១៥ថ្ងៃម្តងដោយមាននិស្សិត និងសាស្ត្រាចារ្យជាច្រើនមកចូលប្រជុំជាមួយ ។

នៅឆ្នាំ១៩៥៥ ខ្ញុំបានត្រឡប់មកប្រទេសកម្ពុជាវិញ និងចូលធ្វើការនៅប៉ុស្តិ៍ខ្សែលួស ប៉ុន្តែខ្ញុំនៅបន្តទាក់ទងជាមួយ អៀង សារី ដដែល ។

នៅឆ្នាំ១៩៥៨ ឈឹម តៃហេង (វិស្វករសំណង់) ដែលធ្លាប់រៀននៅស្រុកបារាំងជាមួយខ្ញុំ បានអូសទាញខ្ញុំឲ្យស្រឡាញ់លោក សេរី តាមរយៈការឲ្យខ្ចីលុយកាក់ ឲ្យបាយទឹក និងសម្ភារ ។ រហូតដល់ឆ្នាំ១៩៦០ តៃហេង រៀបចំបញ្ចូលខ្ញុំក្នុងអង្គការ សេ.អ៊ី.អា ដោយមាន អ៊ឹង គៀត (នាយកក្រសួងសាធារណការ) និង ដួន សៅឌី (វិស្វករនៅក្រសួងកសិកម្ម) ធ្វើជាប្រធានកិត្តិយស និង ចៅ សេងអ្នួ អ្នកធានា ។ តៃហេង បានឲ្យខ្ញុំគោរពទង់អាមេរិក និងឲ្យសច្ចាប្រណិធានថា ត្រូវស្លាប់រស់ និងស្មោះត្រង់ចំពោះអាមេរិកលុះអវសានជីវិត ។ តមក អ៊ឹង គៀត និង ដួន សៅឌី បានផ្តែផ្តាំខ្ញុំឲ្យប្រឆាំងនឹងលទ្ធិកុម្មុយនីស្តនៅគ្រប់ទិសទី និងសកលលោក ដែលជាការបញ្ចប់កម្មវិធី ។

នៅចុងឆ្នាំ១៩៦០ ឈឹម តៃហេង បានហៅសមាជិក សេ.អ៊ី.អា មកប្រជុំនៅផ្ទះគាត់ស្ថិតនៅខាងត្បូងផ្សារអូឡាំពិក រួមមានៈ

១) គាត់ (ឈឹម តៃហេង)

២) ចៅ សេងអ្នួ

៣) ឌួង សារិន សាស្ត្រាចារ្យឧត្តមសិក្សា ភ្នំពេញ

៤) សូ យ៉ាន់ដារា លេខាក្រសួងការបរទេស

៥) រស់ សារិន វិស្វករអាកាសចរណ៍ស៊ីវិល

៦) ទួន សុខដល្លា វិស្វករសំណង់ក្នុងក្រសួងសាធារណការ

៧) នួ ពីណាំងតូ ភ្នាក់ងាររដ្ឋការ ក្នុងក្រសួងរទេះភ្លើង

៨) អែម ធុល នាយកផ្នែក នៅក្រសួងទេះភ្លើង

៩) ជី គឹមអាន នាយកក្រសួងភូមិសាស្ត្រ

១០) ម៉ុល ភូរិក នៅសាលាក្រុងភ្នំពេញ ផ្នែកលម្អក្រុង

១១) ម៉ី ផាត់ វិស្វករសាធារណការ

១២) ខ្ញុំ (ថ្កោង សិរិវុធ)

ពីឆ្នាំ១៩៦១ ដល់ឆ្នាំ១៩៦២ ខ្ញុំបានបញ្ជូនឈ្មោះ រស់ ឃិន, ដុង ឡាមឿន, តាន់ បៀន, សេង គឹមគួន, សូ ព្រំ, អោក ពឹម ឲ្យទៅ ឈឹម តៃហេង ដើម្បីជ្រើសរើសឲ្យទៅរៀននៅអាមេរិក ដោយក្នុងរយៈពេលពីរឆ្នាំនេះក្រុមយើងជ្រើសរើសបានមនុស្ស ៣០នាក់ឲ្យទៅរៀន ។

នៅឆ្នាំ១៩៦៣ ក្រុមខ្ញុំបានសរសេរខិត្តប័ណ្ណបរិហារពីបញ្ហារត់ពន្ធនៅតាមព្រំដែន, បញ្ហាពុករលួយ, ការសុំជំនួយពីអាមេរិក ដើម្បីឲ្យសម្តេច សីហនុ ខ្វល់ជាមួយនឹងក្រុមចម្រើន ។

នៅឆ្នាំ១៩៦៤ ឈឹម តៃហេង បានប្រជុំក្រុម សេ.អ៊ី.អា ដោយមានខ្លឹមសារ ៖ បំផុសអ្នករដ្ឋការឲ្យធ្វើសំបុត្រដកការទុកចិត្តពីអ្នកតំណាងរាស្ត្រខាងចំរើន មាន ហ៊ូ យន់, ហ៊ូ នឹម និង ខៀវ សំផន ។ ចំណែកអ្នករដ្ឋការខាង សេ.អ៊ី.អា ដែលមានអ៊ឹង គៀត និង កែវ អន ក្រុមយើងដាក់ឲ្យនៅអែប សម្តេច សីហនុ ។

នៅឆ្នាំដដែល អ្នកដែលទៅសិក្សានៅអាមេរិកបានត្រឡប់មកវិញ ដូច្នេះ អ៊ឹង គៀត ត្រូវបានផ្លាស់ចេញពីក្រុមខ្ញុំ ឲ្យទៅគ្រប់គ្រងខ្សែដែលទើបមកដល់ថ្មីនោះវិញ ។

នៅឆ្នាំ១៩៦៥ យើងបានជ្រើសរើសអ្នករដ្ឋការឲ្យទៅរៀននៅសហរដ្ឋបន្ថែម ដែលរួមមានៈ

១) មាស គាភរុន រៀនខាងផ្នែកវិទ្យុទាក់ទងក្នុងស្រុក

២) ក្លែប ស៊ុន រៀនខាងផ្នែកវិទ្យុទទួលសំឡេង

៣) អ៊ុង វឿងរិត រៀនខាងផ្នែកអគ្គិសនី

៤) សោម សឹម រៀនខាងផ្នែកខ្សែលួស

៥) សេង ពីទឹន រៀនខាងផ្នែកវិស្វករទូរស័ព្ទ

៦) ប៉ែន ហាន រៀនខាងផ្នែកម៉ាស៊ីនភ្លើង

៧) សួស សារិន រៀនខាងផ្នែកម៉ាស៊ីនម៉ូទ័រ

៨) ប៊ុន សៃ រៀនខាងផ្នែកម៉ាស៊ីនទូរលេខ

នៅឆ្នាំ១៩៦៦ ដួន សៅឌី បានហៅសមាជិក១០នាក់ រួមទាំងខ្ញុំទៅប្រជុំនៅផ្ទះ ជី គឹមអាន នៅទួលគោក ដែលមានខ្លឹមសារដូចតទៅ

- ត្រូវបំបែកកម្លាំងដែលស្និទ្ធនឹងសម្តេច សីហនុ ។
- ឃោសនាសម្ងាត់ ដើម្បីទាក់ទងជាមួយអាមេរិក ។
- ជ្រើសរើសដៃស្តាំរបស់ លន់ នល់ ឲ្យឡើងក្តាប់ក្នុង

ក្រសួងនីមួយៗ និងបន្តប់ខ្លួនក្នុងបដិវត្តន៍ខ្មែរក្រហម ។

មួយឆ្នាំក្រោយមក គឺនៅឆ្នាំ១៩៦៧ និស្សិតដែលទៅរៀននៅជប៉ុន២១រូប ក៏ត្រឡប់មកវិញដែរ ពេលនោះ អ៊ីង គៀត ក៏បានប្រគល់ឲ្យឈ្មោះ ចៅ សេងអ្វ អ្នកទទួលដឹកនាំខ្សែថ្មីនោះទៀត ។ ប៉ុន្តែក្រុមយើងមិនបានទាក់ទងសមាជិកទេគឺជួបតែមេៗប៉ុណ្ណោះ ។

ចាប់ពីឆ្នាំ១៩៦៧ ដល់ឆ្នាំ១៩៦៩ អ៊ីង គៀត បានហៅសមាជិកក្រុមប្រជុំជាញឹកញាប់ ដើម្បីបំផុសឥទ្ធិពល លន់ នល់ និង សហរដ្ឋអាមេរិក, បំផុសពីបញ្ហាធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុ, និងបំផុសថាខ្មែរក្រហមជាខ្ញុំយួនយៀកកុង ។

នៅខែមិថុនា ឆ្នាំ១៩៧០ អ៊ីង គៀត បានហៅសមាជិកប្រាំបួននាក់មកប្រជុំនៅក្រសួងកសិកម្ម ដោយគាត់បានរៀបចំចាត់តាំងកម្លាំងប្រាំនាក់ឲ្យទៅបន្តប់ខ្លួនក្នុងតំបន់រំដោះ រួមមានៈ ខ្ញុំ (សិរិវុធ), ជី គឹមអាន, ទូន សុខដល្លា, ម៉ី ផាត់ និង សាញ់ អឿន ។

នៅខែកញ្ញា ឆ្នាំ១៩៧០ ជី គឹមអាន ត្រូវចេញទៅតំបន់រំដោះមុនខ្ញុំ គឺទៅភូមិភាគពិសេស ដោយគាត់ធ្វើការខាងផ្នែកនិពន្ធនៅមន្ទីរអមលាំង ។ នៅទីនោះ គឹមអាន បានទៅទាក់ទងជាមួយ ថាវ ថៅកែម៉ាស៊ីនស្រូវ នៅទីប្រជុំជនសំរោង ស្រុកកំពង់ត្រឡាច ដើម្បីរួមផែនការក្បត់ ។

មួយខែក្រោយមក អ៊ីង គៀត ក៏បញ្ជូនខ្ញុំឲ្យទៅនៅជាមួយ ជី គឹមអាន ទៀត ។ ខ្ញុំ និង ជី គឹមអាន រស់នៅជាមួយគ្នាបានមួយខែ គាត់ក៏ខ្ទេសនាមខ្ញុំឲ្យស្គាល់ឈ្មោះ ថាវ ។

ក្រោយមក អង្គការបានរៀបចំដកខ្ញុំឲ្យទៅនៅភូមិភាគឧត្តរវិញ ដោយពេលនោះ ជី គឹមអាន ប្រាប់ខ្ញុំថា បើឯងទៅត្រូវទាក់ទងនឹង ទីវ អុល ហៅ សោម រួចគាត់សរសេរសំបុត្រមួយច្បាប់ឲ្យខ្ញុំយកទៅឲ្យ ទីវ អុល ដោយផ្ទាល់ដៃ ។

នៅឆ្នាំ១៩៧១ ខ្ញុំបានទៅដល់មន្ទីរភូមិភាគឧត្តរ ពេលនោះ ទីវ អុល បានរកកន្លែងឲ្យខ្ញុំសម្រាក ហើយខ្ញុំក៏ឲ្យសំបុត្រទៅគាត់ ។ ក្រោយពេលហូបបាយល្ងាចរួច ទីវ អុល បានយកអង្រឹងមកចងជិតខ្ញុំ រួចនិយាយលេង សួរខ្ញុំពីនេះពីនោះ រួចគាត់និយាយថា រវល់បន្តិច ចាំទៅជួបគ្នានៅមន្ទីរស-៣១ ។ ក្នុងអំឡុងស្នាក់នៅទីនោះ ខ្ញុំបានស្គាល់ យួន (កុយ ធួន), ខឿន និង ឈឿន ។

នៅខែកុម្ភៈ ឆ្នាំដដែល ទីវ អុល បានហៅសមាជិកទៅប្រជុំនៅមន្ទីរស-៣១ មាន១) ទីវ អុល អតីតសាស្ត្រាចារ្យ (ធ្វើការនៅក្រសួងឃោសនាការ) ២) ហ៊ូ យន់ សាស្ត្រាចារ្យច្បាប់ ៣) ប៉ុក ដឹកុមារ ហៅ ប៉ាច ក្រសួងធនាគារជាតិ និងខ្ញុំ ។ ខ្លឹមសារប្រជុំមានដូចជា

◆ រៀបចំកម្លាំង

◆ បំភ្លៃមាគ៌ាបក្ស

◆ ទាក់ទាញទឹកចិត្តមហាជន និងទាក់ទងខ្សែឧត្តរ និងបូព៌ា ។

នៅខែមីនា ឆ្នាំ១៩៧១ ក្រោយពីប្រជុំចប់ ទីវ អុល និង ហ៊ូ យន់ មានភារកិច្ចចេញទៅក្រៅ ដោយទុកឲ្យខ្ញុំ និង ប៉ុក ដឹកុមារ ដឹកនាំការងារជំនួស ។

នៅខែសីហា ឆ្នាំ១៩៧២ ទីវ អុល និង ហ៊ូ យន់ ក៏ត្រឡប់មកមន្ទីរវិញ ហើយបានប្រាប់ ថា ជី គឹមអាន ចងកស្លាប់ហើយ ។ ប៉ុន្តែគាត់ទាំងពីរនាក់បានជួបនឹង សៀង ប៉ោសែ ហៅ នាគ នៅមន្ទីរសេដ្ឋកិច្ចភូមិភាគពិសេសដែរ ដែលដឹកនាំការងារជំនួសពី ជី គឹមអាន ។

នៅខែមករា ឆ្នាំ១៩៧៣ អង្គការតម្រូវឲ្យខ្ញុំចុះទៅភូមិភាគពិសេសម្តងទៀត ដោយមុនពេលចេញដំណើរ ទីវ អុល និង ហ៊ូ យន់ បានហៅខ្ញុំទៅប្រាប់ថា បើ វុន ឯងទៅត្រូវទាក់ទងជាមួយ សៀង ប៉ោសែ និងយកសំបុត្រឲ្យគាត់ផ្ទាល់ដៃ» ។ ខ្ញុំបានទៅដល់ភូមិភាគពិសេស ដោយមានក្រុមសេដ្ឋកិច្ចមកទទួលទៅមន្ទីរ សៀង ប៉ោសែ ហើយគាត់ក៏បានរកកន្លែងឲ្យខ្ញុំសម្រាក ។

ក្រោយមក ខ្ញុំត្រូវផ្លាស់ទៅធ្វើការនៅមន្ទីរ៣០៥ ហើយពេលនោះ សៀង ប៉ោសែ ក៏បានហៅខ្ញុំទៅ ប្រជុំនៅផ្ទះក្បែរមន្ទីរ ដែលរួមមានៈ

១) គាត់ សៀង ប៉ោសែ នៅក្រសួងដែនទី

២) ទូន សុខដល្លា ហៅ គឿន ក្រសួងសាធារណការ

៣) ថាវ ថៅកែម៉ាស៊ីនស្រូវ

៤) ម៉ែន នីថូ ហៅ ដន អគ្គិសនីកម្ពុជា

៥) ម៉ែន ហៅ នង វិស្វករសាលាបច្ចេកទេសខ្មែរសូវៀត (នៅមន្ទីរស-៨)

៦) ខ្ញុំ

នៅក្នុងខ្លឹមសារប្រជុំ សៀង ប៉ោសែ ណែនាំឲ្យស្គាល់

សមាជិកនៅក្នុងក្រុម, រៀបចំផែនការប្រមូលកម្លាំងក្នុងមន្ទីរ, ស៊ើបការណ៍ពីបដិវត្តន៍, ពង្រឹកកម្លាំង និងរៀបចំទទួលកម្លាំងរត់មកពីភ្នំពេញ ដោយពេលនោះ ក្រុមទាក់ទងខ្មែរបានបួននាក់មកពីភ្នំពេញ គឺ ទី១) ឈ្មោះ ប៉ុម កូនរបស់ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ថាច ទី២) ឈ្មោះ វិត ទាហានពាក់សក្តិមួយ ទី៣) ឈ្មោះ លាក់ និស្សិតបុរាណវិជ្ជា និងទី៤) ឈ្មោះ នួន ឃឿន ប្រធាននិស្សិតនៅភ្នំពេញ ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៤ សៀង ប៉ោសែ បានហៅសមាជិកមកថ្មី និងចាស់សរុបទាំងអស់១០នាក់ មកប្រជុំ ដោយលើកឡើងពីការរៀបចំកម្លាំងឡើងវិញ ដោយមាន ហាក់ ជាអ្នកដឹកនាំនៅភូមិភាគពិសេស ព្រោះអង្គការបានដកកម្លាំងមួយចំនួនចេញអស់ហើយ ។ ក្រោយពីប្រជុំរយៈពេលពីរម៉ោង យើងបានរៀបចំពិធីជប់លៀងលាគ្នា ។

ចាប់តាំងពីពេលនោះមក សៀង ប៉ោសែ បានរៀបចំប្រជុំដាក់ផែនការ និងអូសទាញកម្លាំង បានជាបន្តបន្ទាប់ដូចជា ម៉ូន រឿង អតីតក្រសួងសហករណ៍រដ្ឋ, ព្រំឡាយ ហៅ ឡេង គ្រូបង្រៀន, សុត អតីតសិស្សវិទ្យាល័យ, ម៉ុក សូវង្ស អតីតវិស្វករបុរាណវិជ្ជា, ប៉ែន សំផន ហៅ សំ ទាហានសក្តិ៥ខាងរណសិរ្ស និង សឿន អតីតទាហាន ។

នៅខែឧសភា ឆ្នាំ១៩៧៥ សៀង ប៉ោសែ បានហៅខ្ញុំ និង ផន ទៅប្រជុំទៀត ព្រោះកម្លាំងមួយចំនួន អង្គការបញ្ជូនទៅព្រះវិហារហើយ ។ ប៉ោសែ បញ្ជាក់ថា អង្គការដកគាត់ឲ្យចូលក្រុងភ្នំពេញមុន ចំណែកអ្នកផ្សេងទៀតគាត់មិនដឹងថាអង្គការដកយកទៅភ្នំពេញដែរឬយ៉ាងណានោះទេ ។

មកដល់ខែមិថុនា ឆ្នាំ១៩៧៥ ខ្ញុំក៏ត្រូវអង្គការហៅឲ្យចូលភ្នំពេញទៀត ដោយឲ្យនៅខាងផ្នែកប៉ុស្តិ៍ខ្សែលួស មន្ទីរស-៨ ។ នៅខែសីហា អង្គការបានចាត់តាំងឈ្មោះ សំបូរ ហៅ ប៊ូ ឲ្យមកនៅខាងប៉ុស្តិ៍ជាមួយខ្ញុំទៀត ។

ក្រោយមក តាមរយៈ ទីវ អុល នៅក្រសួងឃោសនាការ បានលើកឡើងពីការផ្តាំផ្ញើសួរសុខទុក្ខពី ឃួន និងផ្តាំឲ្យខិតខំប្រមូលកៀងគរកម្លាំង, ឲ្យប្រើប្រាស់សម្ភារខ្ជះខ្ជាយ ហើយប្រសិនបើខូចខាតរបស់របរ ត្រូវទៅរកនៅទីចាត់ការពាណិជ្ជកម្មតាមរូបភាពស្របច្បាប់ ។

នៅខែធ្នូ ឆ្នាំ១៩៧៥ ឃួន បានហៅខ្ញុំ, ទីវ អុល, សៀង ប៉ោសែ, ចាប ហៅ ឈឿន និង មី ទៅហូបបាយ នៅកន្លែងគាត់ ។ បន្ទាប់ពីហូបបាយរួច ឃួន បាននិយាយមកខ្ញុំថា ខ្ញុំធ្វើការនៅ ខាងប៉ុស្តិ៍ខ្សែលួសនេះនៅជាប់របងគាត់ដែរ ដូច្នេះយើងអាចទាក់ទងគ្នា បានយូរអង្វែង ។

ចាប់ពីខែមិថុនា ឆ្នាំ១៩៧៦ ខ្ញុំលែងបានជួប ឃួន និង ទីវ អុល ហើយ ហើយពេលទៅទាក់ទងការងារនៅក្រសួងពាណិជ្ជកម្ម ខ្ញុំសួរទៅ ឈឿន ថា បង ឃួន ទៅណា? គាត់ឆ្លើយ ថាមិននៅទេ ហើយឥឡូវ មានបង ឌឿន មកជំនួសទាំងក្នុងខ្សែ និងក្រសួងវិញ ។

នៅខែសីហា ឆ្នាំ១៩៧៦ ឌឿន បានស្នើឲ្យសមាជិកទាំងអស់ប្រជុំឡើងវិញ ដោយឲ្យបន្តសកម្មភាពចាស់, បំបែកកម្លាំងដើម្បីងាយស្រួលដឹកនាំ និងត្រូវប្រុងប្រយ័ត្ន ។

នៅខែមករា ឆ្នាំ១៩៧៧ សៀង ប៉ោសែ ធ្វើការនៅក្រសួងផែនទី បានហៅខ្ញុំមកប្រាប់ពីការបាត់ខ្លួនសមាជិកជាបន្តបន្ទាប់ ។

ចុងខែមករា ឆ្នាំដដែល អង្គការបានដក តូច ភឿន ចេញពីក្រសួងសាធារណការ ។ ព្រឹត្តិការណ៍នេះធ្វើឲ្យខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំង ។ ពេលនោះ សៀង ប៉ោសែ ក៏បានលើកឡើងដែរថា ការដកនេះមុខតែកើតមានទៀត ។ មួយខែក្រោយមក គឺនៅខែកុម្ភៈ ខ្ញុំបានសួរទៅ ប៉ោសែ ថាបើព្រឹត្តិការណ៍កាន់តែចង្អៀតយ៉ាងនេះ តើទៅមុខយើងមានច្រកចេញទេ? គាត់ថា បើខ្សែយើងនៅតែធ្លុះធ្លាយយើងមានលទ្ធភាពតិចណាស់ ព្រោះការងារក៏រួញ ហើយគេចខ្លួនទៅណាក៏មិនរួចដែរ ។ ចំណែកខាងពាណិជ្ជកម្ម អង្គការបានដក ឌឿន និង ឈឿន ព្រមជាមួយនោះ ខ្សែខ្ញុំក៏ត្រូវអង្គការដកចេញទៀត ។

នៅខែមីនា ឆ្នាំ១៩៧៧ អង្គការបានដកខ្ញុំចេញពីប៉ុស្តិ៍ខ្សែលួស រួចហើយឲ្យទៅដាំបន្លែ នៅទំនប់បូមទឹក ជិតក្បាលថ្នល់ ។ នៅទីនោះ ខ្ញុំបានជួប ប៉ោសែ រយៈពេលខ្លី ដោយគាត់បានប្រាប់ថា ខ្សែយើងបាត់អស់ហើយ ហើយបញ្ជាក់ថាត្រូវប្រយ័ត្នខ្លួនព្រោះ ប្រាកដជាដល់វេនយើងមិនខាន ។

ខ្ញុំនៅទីនោះរហូតដល់ចុងខែមីនា ឆ្នាំ១៩៧៧ អង្គការចាប់ខ្លួនខ្ញុំតែម្តង ។

**សោម ប៊ុនថន**

# បញ្ជីឈ្មោះនិងរូបថតអ្នកទោសមន្ទីរស-២១ដែល ទទួលបាននៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១២

**អ្នកកត់ត្រា ៖ ឆាំង យុ, ញាណ សុជាតិ និង ស៊ីរ៉ិ សាវីណា**

**(តពីលេខមុន)**

| លរ | ឈ្មោះ | ភេទ | លេខរូបថត | រឿងរ៉ាវទាក់ទងនឹងប្រវត្តិរូបសង្ខេប |
|---|---|---|---|---|
| ២១០ | ទូច ប្រិល សាយ) | ប្រុស | ១៨ | យ. ១០.៨ (?) |
| ២១១ | ម៉ាន់ ធូ | ប្រុស | ? | ១៧០ |
| ២១២ | ឃឹម យុន (ផាត) | ប្រុស | ១៤ | ពាណិជ្ជកម្ម |
| ២១៣ | ផន ទូចកត់ | ប្រុស | ១៣ | អនុរ,ត កងពល១៧០ |
| ២១៤ | ប៉ាក អូន | ស្រី | ២៧ | ប្រពន្ធ សាំង សៀន ១៩.១០.៧៦ |
| ២១៥ | គង់ វ៉ាន់ថា | ស្រី | ១៥ | ប្រពន្ធ សំ ហម ៨.១១.៧៦ |
| ២១៦ | នង ហាងរុធី | ប្រុស | ១ | ១៧០ |
| ២១៧ | សៅ ឆេង | ប្រុស | ១៩ | ប្រជាជន |
| ២១៨ | ហ៊ុល កាប (ភាន់) | ប្រុស | ៣ | មុនធ្វើការនៅរទេះភ្លើង |
| ២២៩ | ស្រី នុន | ស្រី | ១៧ | ប្រពន្ធ ឡុប ឈុន |
| ២២០ | សួន ផល្លី | ស្រី | ២២ | ប្រពន្ធ ឆើយ ណារ៉ុង ២៨.១០.៧៦ |
| ២២១ | ស្រី ភី | ស្រី | ៧ | កង១៤ |
| ២២២ | ម៉ក់ ខុម (មន) | ប្រុស | ៣ | យុទ្ធជន ២៧០ (?) |
| ២២៣ | កៅ សៀង | ស្រី | ៤ | ប្រពន្ធ ប៉ាត ប៊ុន ២៩.១០.៧៦ |
| ២២៤ | តាំង សេងវ៉ា | ប្រុស | ? | ? |
| ២២៥ | មេស ប៊ិន | ប្រុស | ? | កងហា កងពល៣១០ |
| ២២៦ | នៀម យិន | ប្រុស | ២ | ណាត កម្មកររទេះភ្លើង |
| ២២៧ | ប៉ែ ចេីន (ធី) | ប្រុស | ៦ | មេពួក ៥០២ |
| ២២៨ | គឹម ប៉ាវ | ប្រុស | ៧ | កម្មករចាស់ ២៨.១០.៧៦ |
| ២២៩ | ជិន សុង | ប្រុស | ៣០ | ប្តី ផេង គឹមហួយ ២៩.១០.៧៦ |
| ២៣០ | ជឹម ជឿន | ប្រុស | ៣៣ | កង ១៣ថ្មី |
| ២៣១ | មឿង ហេង | ស្រី | ១៤ | ប្រពន្ធ អាមាន |
| ២៣២ | សុក អច | ប្រុស | ៦ | យុទ្ធជន ៨.១១.៧៦ |
| ២៣៣ | ទូច សាយ | ប្រុស | ១៣ | កម្មករចាស់ ២៤.១០.៧៦ |
| ២៣៤ | ហ៊ឹម វ៉ាន | ប្រុស | ៧ | កងពល ១៧០ |

| | | | | |
|---|---|---|---|---|
| ២៣៥ | អាន អឿន | ប្រុស | ៣ | ៣១០ |
| ២៣៦ | ចាន់ អួន | ប្រុស | ១០ | សុរិន |
| ២៣៧ | កៀន វណ្ណា | ប្រុស | ២៥ | ប្រពន្ធ អ៊ុក វុទ្ធី ២៨.១០.៧៦ |
| ២៣៨ | កាយ នូ៊វ (ភ៉ាន់) | ប្រុស | ១១ | ដ១ |
| ២៣៩ | ហួត ឆេង | ប្រុស | ១៤ | កម្មកររទេះភ្លើង |
| ២៤០ | ជា ឡូ | ប្រុស | ១៦ | យុទ្ធជន១៣ ស-២១យ |
| ២៤១ | ឃិន ធឿន | ប្រុស | ៤ | អនុក្រុម ៨.១១.៧៦ |
| ២៤២ | សាំង សម្បត្តិ | ស្រី | ២៨ | ប្រពន្ធ ញ៉ក់ សារុន |
| ២៤៣ | គង់ គុន | ប្រុស | ? | ឃ្លាំងរដ្ឋ |
| ២៤៤ | ឆេង យ៉ាន | ប្រុស | ? | អនុហា |
| ២៤៥ | សិត | ស្រី | ? | ១៣ (រូបថតស្អាត) |
| ២៤៦ | ស៊ុំ វត្តណា | ប្រុស | ៨ | ប្រពន្ធ ខៀវ នូសិត ៨.១១.៧៦ |
| ២៤៧ | ឈុន ហាង | ប្រុស | ៧ | ១៣? |
| ២៤៨ | ឈួន រ៉េន (ឈិន) | ប្រុស | ? | ស្នងការកងហា |
| ២៤៩ | ប៊ុន សុផង | ប្រុស | ១ | ស្នងការកងរយ |
| ២៥០ | សុខ ពៅ | ប្រុស | ១៣ | អនុកងរយ |
| ២៥១ | នួន នឹម (រី) | ប្រុស | ? | មន្ទីរស្រុកតំបន់ ១.៩.៧៦ |
| ២៥២ | ជិន លុន | ប្រុស | ? | មេពួក |
| ២៥៣ | ខឹម សុខុម | ប្រុស | ២ | ប្រធាន២ |
| ២៥៤ | អ៊ឹង ប៊ុនលីវ | ប្រុស | ៤ | គ្រឿងដែក |
| ២៥៥ | នួន ផល្លា | ប្រុស | ? | កង១១ |
| ២៥៦ | ព្រាប អាន | ប្រុស | ? | កងពល១៧៣ |
| ២៥៧ | ទេព ថាវីណៃ | ស្រី | ៨ | កង១៤ |
| ២៥៨ | ខៀវ រុំ | ប្រុស | ? | ជាងថត ៥០២ |
| ២៥៩ | ព្រុំ ដួង | ប្រុស | ២ | យុទ្ធជន កងពល១៧០ ៣.៩.៧៦ |
| ២៦០ | ជុំ សាវិន | ប្រុស | ? | កងពល ១៧០ |
| ២៦១ | វិន ជិនហួត | ប្រុស | ? | យុទ្ធជន បន្ទប់៤ |
| ២៦២ | ហ៊ួរ ហុក | ប្រុស | ? | កង១១ថ្មី សេដ្ឋកិច្ច ១០.៨.៧៦ |
| ២៦៣ | ចាន់ វុធ | ប្រុស | ៣ | កូនសិស្ស |
| ២៦៤ | គិន ភា | ប្រុស | ១ | ជាងម៉ាស៊ីន ប្រ,ជ |
| ២៦៥ | ញ៉ែម សុភាន | ប្រុស | ? | បាលឯកម៉ារីន |
| ២៦៦ | ភ៉ា សារេន | ប្រុស | ? | អនុកងធំ |

| | | | | |
|---|---|---|---|---|
| ២៦៧ | ប៉ាត ប៊ុន | ប្រុស | ២២ | កម្មករចាស់ ២៩.១០.៧៦ |
| ២៦៨ | ព្រេះ ហ៊ិង | ប្រុស | ៥ | យុទ្ធជន ១៧០ |
| ២៦៩ | ប៉េង ហាណារិន | ប្រុស | ? | កងពល១៧៣ (រូបថតញញឹម) |
| ២៧០ | យូ ចេង | ប្រុស | ? | កងពល ១៦០ |
| ២៧១ | ដង់ លី | ប្រុស | ១ | មេពួក ២៨.៩.៧៦ |
| ២៧២ | សេង វ៉ាត | ប្រុស | ? | សេង ហាន យុទ្ធជន ៤៥០ |
| ២៧៣ | សេង ឡឿន | ប្រុស | ២៩ | ប្តី ប៊ុត រ៉េត ២៩.១០.៧៦ |
| ២៧៤ | សោម វ៉ាត | ប្រុស | ? | សាមីន អនុក្រុម |
| ២៧៥ | មាន ជឿន | ប្រុស | ១៣ | សុង ពាណិជ្ជកម្ម |
| ២៧៦ | អ៊ុន អឿន | ប្រុស | ? | អ៊ុន សៀន កំពង់ដែកំពង់សោម |
| ២៧៧ | សួន ស៊ឺន | ប្រុស | ៥ | គណៈសាលាកងពល ១.៩.៧៦ |
| ២៧៨ | ខាក់ សាខន | ប្រុស | ១៤ | ជំនួយ វ,ធ |
| ២៧៩ | ហឿ ឆេងគួយ | ប្រុស | ៤ | ទាហានស័ក្តិមួយ |
| ២៨០ | ទុំ ខេន | ប្រុស | ១ | យុទ្ធជន ១៧០ |
| ២៨១ | សៀន សាតសំនារី | ស្រី | ? | ប្រពន្ធ ពេជ សារ៉េត |
| ២៨២ | ណន បូ (រឿន) | ប្រុស | ២ | ចក្រអង្រែ ៤.៨.៧៦ |
| ២៨៣ | ចក់ ហៀប | ប្រុស | ? | រទេះភ្លើង ២៨.១០.៧៦ |
| ២៨៤ | វិ ឆៃ | ប្រុស | ? | គ្មានព័ត៌មាន |
| ២៨៥ | សៅ ឈន (ដន) | ប្រុស | ? | ក្រសួងថ្នាំបំពុល ផ្ទះ០៨ |
| ២៨៦ | សាន់ ខ្មៅ | ប្រុស | ? | ស-២១យ ៣.៨.៧៦ |
| ២៨៧ | ញ៉ែម សំបូរ | ប្រុស | ? | មេពួក ៦.៩.៧៦ |
| ២៨៨ | សេង សារ៉េត | ប្រុស | ? | កងចាស់ ១៧០ ៣.៨.៧៦ |
| ២៨៩ | អ៊ិន សារឿន | ប្រុស | ? | ចក្រអង្រែ ៤.៨.៧៦ |
| ២៩០ | ប៊ុន រ៉េត | ស្រី | ៣ | ប្រពន្ធ សេង ឡឿន ២០.១០.៧៦ |
| ២៩១ | នង យ៉ាន | ស្រី | ៧ | ប្រពន្ធ ហែម ដៃ ៣០.១០.៧៦ |
| ២៩២ | សៀង វ៉ានថន | ប្រុស | ? | ចក្រអង្រែ ៤.៨.៧៦ |
| ២៩៣ | គួម អែម (ភាព) | ប្រុស | ? | ទូរពុម្ព |
| ២៩៤ | យោគ សាំង | ប្រុស | ១១ | អនុកងរយ |
| ២៩៥ | ញ៉ែម ចាន់ណា | ប្រុស | ៣ | យុទ្ធជន ៥០២ |
| ២៩៦ | ជុំ ប៊ុនណាក់ | ស្រី | ២ | កូន ជុំ ឡាន ៣០.១០.៧៦ |
| ២៩៧ | ពៅ សុភា | ប្រុស | ២ | កង១៧០ |
| ២៩៨ | នាំ ប៊ុនរឿង | ស្រី | ៤ | កូនកម្មករ **(នៅមានត)** |

# ទីតាំងឧក្រិដ្ឋកម្មបន្ថែមក្នុងសំណុំរឿង០០៤នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ខេត្តបាត់ដំបង

◆ ***មន្ទីរសន្តិសុខធិបតី*** និង ***ការដ្ឋានទួលម្ទេស*** ស្ថិតនៅឃុំធិបតី ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ។

◆ ***ភ្នំត្រដាក់ចិត្ត*** និង ***អន្លង់វិលប្រែង*** ស្ថិតនៅភូមិឫស្សីព្រះ ឃុំឆ្នាល់មាន់ ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ។

◆ ***មន្ទីរសន្តិសុខតំបន់១*** និង ***កន្លែងសម្លាប់បាណាក់រាំង*** ស្ថិតនៅភូមិបាណន់ ឃុំកន្ទឺ ស្រុកបាណន់ ខេត្តបាត់ដំបង ។

## ខេត្តពោធិ៍សាត់

◆ ***រណ្តៅទួលសេះញ៉ូវ*** និង ***វាល ពិឃាតព្រៃក្រពៅ*** ស្ថិតនៅឃុំរំលេច និង ឃុំខ្នារទទឹង ស្រុកបាកាន ខេត្តពោធិ៍សាត់ (ការប្រព្រឹត្តទៅលើខ្មែរក្រោម) ។

◆ ***គុកភូមិវាល*** ស្ថិតនៅឃុំតាឡូ ស្រុកបាកាន ខេត្តពោធិ៍សាត់ (ការប្រព្រឹត្តទៅលើខ្មែរក្រោម)

◆ ***គុកស្វាយជ្រុំ*** ហៅ ***គុកភូមិថ្កោល*** និង ***គុកបឹងបាតកណ្តាល*** ហៅ ***ក្រាំងក្រោល*** ស្ថិតនៅឃុំបឹងបាតកណ្តាល ស្រុកបាកាន ខេត្តពោធិ៍សាត់ (ការប្រព្រឹត្តទៅលើខ្មែរក្រោម) ។

◆ ***ទីតាំងសម្លាប់ វត្តច័ន្ទរង្សី-រណ្តៅសាកសពរួម*** និង អណ្តូងសាកសពរួមនៅភូមិកូនត្នោត ឬភូមិចាម ស្ថិតនៅឃុំរំលិច ស្រុកបាកាន ខេត្តពោធិ៍សាត់ (ការប្រព្រឹត្តទៅលើប្រជាជនជម្លៀសពីភូមិភាគបូព៌ា) ។

◆ ***កន្លែងសម្លាប់វាលបាក់ចិញ្ចៀន*** ស្ថិតនៅឃុំស្រែស្តុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ (ការប្រព្រឹត្តទៅលើប្រជាជនជម្លៀសពីភូមិភាគបូព៌ា) ។

## ខេត្តតាកែវ

◆ ***"កន្លែងសម្លាប់ព្រៃសុខុន"*** និង ***"មន្ទីរឃុំឃាំងវត្តអង្គសិរីមុនី"*** ស្ថិតនៅភូមិស៊ីស្លា ឃុំធ្លាប្រជុំ ស្រុកកោះអណ្តែត ខេត្តតាកែវ (ការប្រព្រឹត្តទៅលើខ្មែរក្រោម) ។

◆ ***ព្រៃភូមិស្វែង វត្តអង្គញ កន្លែងសម្លាប់ភូមិព្រាល*** និង




***ភូមិសោម*** និង ***គុកវត្តសុបិន*** ស្ថិតនៅឃុំគោក ព្រេច និងឃុំកំពែង ស្រុកគីរីវង្ស ខេត្តតាកែវ (ការប្រព្រឹត្តទៅលើខ្មែរក្រោម) ។

◆ ***មន្ទីរសន្តិសុខប្រធាតុ*** ស្ថិតនៅក្នុងឃុំគោកព្រេច ស្រុកគីរីវង្ស ខេត្តតាកែវ (ការប្រព្រឹត្តទៅលើខ្មែរក្រោម) ។

◆ ***មន្ទីរសន្តិសុខក្រាំងតាចាន់*** ស្ថិតនៅស្រុកត្រាំកក់ ខេត្តតាកែវ (ការប្រព្រឹត្តទៅលើខ្មែរក្រោម និងជនជាតិដទៃទៀត) ។



អដ្ឋិធាតុជនរងគ្រោះនៅមន្ទីរឃុំឃាំងក្រាំងតាចាន់ថតនៅឆ្នាំ១៩៩៧

## ខេត្តកំពង់ធំ

◆ ***"គុកសម័យអាណានិគមនៅកំពង់ធំ"*** ស្ថិតនៅទីរួមខេត្តកំពង់ធំ ខេត្តកំពង់ធំ (ការបោសសម្អាតភូមិភាគកណ្តាល) ។

## ខេត្តកំពង់ចាម

◆ ***"កន្លែងសម្លាប់ថ្មល់បែក"*** ស្ថិតនៅឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម (ទាក់ទងនឹងមន្ទីរសន្តិសុខវត្តបារាយជាន់ដែក) ។

# ការបាត់បង់ដែលមិនអាចយកមកវិញបាន

នៅក្នុងដំណើរពីខេត្តសៀមរាបមកចូលរួមដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អោម ផន់ បានរៀបរាប់រឿងរ៉ាវជាច្រើនពីក្រុមគ្រួសាររបស់គាត់ ព្រមទាំងបានបង្ហាញពីអារម្មណ៍សោកសង្រេង និងក្តុកក្តួលនៅពេលរំឭកឡើងពីការបាត់បង់កូនរបស់គាត់ពីរនាក់នៅថ្ងៃដំបូងដែលខ្មែរក្រហមជម្លៀសក្រុមគ្រួសារគាត់ចេញពីទីក្រុងភ្នំពេញ ។

ផន់ មានអាយុ៦៨ឆ្នាំ មានស្រុកកំណើតនៅភូមិស្រះស្រង់ជើង ឃុំនគរធំ (អតីត ឃុំអំពិល) ស្រុកបន្ទាយស្រី ខេត្តសៀមរាប ។ ផន់ មានបងប្អូនបួននាក់ និងមានឪពុកម្តាយជាកសិករ ។ គាត់បានចូលរៀននៅវិទ្យាល័យក្នុងក្រុងសៀមរាប ។ នៅឆ្នាំ១៩៦៧ ផន់ បានដាក់ពាក្យប្រលងជាប់ចូលធ្វើការនៅក្រសួងកសិកម្ម ហើយគាត់ត្រូវឡើងមករៀនបន្តរយៈពេលមួយឆ្នាំនៅសាលាអភិវឌ្ឍសហករណ៍ ដែលមានទីតាំងនៅម្តុំអង្គស្នួល ខេត្តកណ្តាលតាមបណ្តោយផ្លូវជាតិលេខ៤ ។

ក្រោយពីបញ្ចប់វគ្គបណ្តុះបណ្តាល ផន់ ត្រូវបានក្រសួងចាត់តាំងឲ្យទៅធ្វើការនៅខេត្តព្រៃវែងដោយមានមុខងារជាមន្ត្រីការិយាល័យកសិកម្មរបស់ខេត្ត ។ គាត់ធ្វើការនៅខេត្តព្រៃវែង រហូតដល់ខែមេសា ឆ្នាំ១៩៧០ ទើបក្រសួងកសិកម្មដែលពេលនោះមាន ស៊ិន សុង ជារដ្ឋមន្ត្រីបានផ្លាស់ប្តូរគាត់ឲ្យទៅធ្វើការនៅការិយាល័យសហករណ៍ជាតិខេត្តកំពត ក្រោមការគ្រប់គ្រងរបស់មន្ទីរកសិកម្មនិងសហករណ៍ខេត្ត គឺ សុខុន ។ ការិយាល័យរបស់ ផន់ មានបេសកកម្មចុះទៅបង្រៀនកសិករឲ្យចេះប្រើប្រាស់ជីទៅតាមប្រភេទស្រូវក្រោមជំនួយឧបត្ថម្ភរបស់ប្រទេសបារាំង នៅតំបន់មុំបី គឺ (ត្រាំខ្នារ រការ និងព្រៃទទឹង) ជាតំបន់ដែលមានព្រំប្រទល់ជាប់គ្នារវាងខេត្តកំពតកំពង់ស្ពឺ និងតាកែវ ។ ធ្វើការក្នុងខេត្តកំពតបានមួយរយៈ ផន់ ក៏បានស្រលាញ់ និងរៀបការជាមួយនារីម្នាក់ដែលមានស្រុកកំណើតនៅស្រុកទូកមាស ។


អោម ផន់ ថតពេលសម្ភាសន៍នៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង (អតីមន្ទីរស-២១) កាលពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២

ជាទម្លាប់ពេលធ្វើការងារ ផន់ តែងសុំយោបល់ពីប្រធានមន្ទីររបស់គាត់ទាក់ទងនឹងការងារដែលត្រូវអនុវត្ត និងលើកពីការងារនៅថ្ងៃខាងមុខពេលដែលខ្មែរក្រហមទទួលជ័យជម្នះ ព្រោះគាត់នៅតែមានការជឿជាក់ និងសង្ឃឹមថានៅពេលចប់សង្គ្រាមខ្មែរក្រហមនឹងដឹកនាំប្រទេសបានរីកចម្រើន ។ ប៉ុន្តែនៅពេលនោះ សុខុន ជាប្រធានមន្ទីរបានគ្រវីក្បាល ដោយការមិនទុកចិត្ត និងតបមកគាត់វិញថា «យើងប្រាកដជាមិនបានសុខទេ!» ហើយគាត់ក៏បានធ្វើកាតសម្គាល់ខ្លួនជាភាសាបារាំងឲ្យ ផន់ ចំនួនពីរ ដោយមួយបញ្ជាក់ថា ជាមន្ត្រីការិយាល័យសហករណ៍ជាតិ និងមួយទៀតជាកម្មករឃ្លាំង ដើម្បីប្រើប្រាស់ ។

រហូតដល់ឆ្នាំ១៩៧៤ ពេលដែលមានការវាយប្រយុទ្ធគ្នាកាន់តែខ្លាំងឡើងៗរវាងយោធាខ្មែរក្រហម និងកងទ័ព លន់ នល់ នៅខេត្តកំពត ផន់ ក៏បាននាំប្រពន្ធ និងកូនទៅកំពង់សោម ដើម្បីជិះយន្តហោះបន្តមកភ្នំពេញ ព្រោះផ្លូវគោកពីខេត្ត

មកកាន់ទីក្រុងភ្នំពេញត្រូវខ្មែរក្រហមកាន់កាប់ស្ទើរទាំងអស់ហើយ ។ ជន់ និងក្រុមគ្រួសារបានមកដួលផ្ទះស្នាក់នៅបណ្តោះអាសន្ននៅម្តុំផ្សារដើមគ ។

នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានផ្លោងគ្រាប់កាន់តែច្រើនចូលមកជិតផ្ទះដែល ជន់ រស់នៅ ដោយពេលនោះគាត់បាននាំក្រុមគ្រួសារចូលទៅពួនក្នុងលេណដ្ឋាន ។ ដោយសារការតក់ស្លុត និងការភ័យខ្លាច នៅព្រឹកថ្ងៃបន្ទាប់ ជន់ បានយកកង់ដឹកប្រពន្ធ និងកូនទាំងពីរនាក់មកពេទ្យចិន ដើម្បីគេចពីគ្រាប់ផ្លោង ដោយមានតែសម្លៀកបំពាក់ម្នាក់មួយបន្លាស់ប៉ុណ្ណោះ ។ នៅទីនោះគាត់បានជួប សុខុន ប្រធានមន្ទីរកសិកម្មខេត្តកំពត និងមន្ត្រីរដ្ឋការរបស់ លន់ នល់ ជាច្រើនរូបទៀត ។ ក្រោយពីដាក់ប្រពន្ធ និងកូនឲ្យចុះនៅពេទ្យចិនរួច ជន់ ក៏ជិះកង់ត្រឡប់ទៅយកអីវ៉ាន់ពីផ្ទះដួលមកថែមទៀត ប៉ុន្តែស្រាប់តែពេលគាត់ទៅដល់ជិតផ្សារដើមគ ត្រូវយោធាខ្មែរក្រហមឃាត់មិនឲ្យចូលផ្ទះ និងបញ្ជាឲ្យគាត់ចាកចេញជាមួយប្រជាជនតាមផ្លូវស្ទឹងមានជ័យ ។

ចំណែកប្រពន្ធរបស់គាត់បានសុំយោធាខ្មែរក្រហមស្នាក់នៅពេទ្យចិនមួយយប់ដើម្បីរង់ចាំគាត់ត្រឡប់មកវិញ ។ នៅព្រឹកថ្ងៃទី១៨ ខែមេសា ខ្មែរក្រហមបានបញ្ជាប្រពន្ធ និងកូនគាត់ចាកចេញតាមផ្លូវជាតិលេខ១ ឆ្លងកាត់ស្ពានព្រះមុនីវង្ស ។ ដោយអស់កម្លាំង ប្រពន្ធគាត់បានឈប់សម្រាកនៅលើស្ពានមួយរយៈ ហើយកូនស្រីច្បងរបស់គាត់ឈ្មោះ ឡុ លីពុទ្ធី ក៏ដេកលក់នៅទីនោះ ។ ក្រោយមក ដោយមានមនុស្សប្រជ្រៀតគ្នាច្រើន ស្រាប់តែបាត់កូនស្រីគាត់ ចាប់តាំងពីពេលនោះមក គឺនៅសល់តែកូនប្រុសអាយុបីឆ្នាំ ឈ្មោះ ឡុ លីឡាំដា ។ ប្រពន្ធរបស់ ជន់ ត្រូវខ្មែរក្រហមជម្លៀសឲ្យទៅឈប់នៅគគីរធំ ក្នុងស្រុកកៀនស្វាយ ខេត្តកណ្តាល ។ រីឯ ជន់ បានធ្វើដំណើរកាត់តាមរោងចក្រកែវចម្ការដូង រួចបន្តទៅដល់កំពង់ទួល ស្ថិតនៅក្នុងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ប៉ុន្តែដោយសារនឹកប្រពន្ធ និងកូនខ្លាំងពេក ជន់ បានដើរវាងមកតាមរកប្រពន្ធនៅតាមបណ្តោយផ្លូវជាតិលេខ១ ព្រោះគាត់បានដឹងមុនថាខ្មែរក្រហមនឹងជម្លៀសក្រុមគ្រួសារទៅតាមផ្លូវនេះ ។

ជន់ បានដើររយៈពេលបួនថ្ងៃ ទើបជួបប្រពន្ធគាត់នៅគគីរធំ ។ ប៉ុន្តែអ្វីដែលគាត់រន្ធត់ និងសោកស្តាយបំផុត គឺនៅពេលដែលប្រពន្ធគាត់ប្រាប់ថា បាត់កូនស្រីម្នាក់ ។ បន្ទាប់ពីជួបជុំគ្នារួចហើយ ជន់ បាននាំក្រុមគ្រួសារធ្វើដំណើរសំដៅទៅផ្លូវជាតិលេខ២ ហើយពេលគាត់ដើរហួសស្ទឹងបានបន្តិច ក៏បានជួបនឹងមេបញ្ជាការខ្មែរក្រហមឈ្មោះ ញឹម អតីតជាអ្នកដើរទិញខស និងលក់ស្លឹក និងមានស្រុកកំណើតភូមិព្រៃរងៀង សង្កាត់អង្គពពេល (ខេត្តកំពង់ស្ពឺ) ដែលគាត់ធ្លាប់ស្គាល់ពេលធ្វើការនៅក្នុងការិយាល័យសហករណ៍ជាតិ ។ ញឹម ដែលមានកាំភ្លើងខ្លីពីរដើមពាក់ជាប់នឹងខ្លួន បានស្រែកហៅ ជន់ ថា «លោកគ្រូៗ!» រួចហើយបានផ្តែផ្តាំគាត់ថា «លោកគ្រូត្រូវទៅរស់នៅកន្លែងណាដែលខ្មែរក្រហម មិនស្គាល់ប្រវត្តិលោកគ្រូ» ។ ជន់ បានដើរទៅដល់ភូមិក្រាំងអាអួត ឃុំក្រាំងរការ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ និងបានស្នាក់នៅទីនោះមួយរយៈ ។ នៅទីនោះ កូនប្រុសរបស់ ជន់ ចាប់ផ្តើមកើត ជំងឺរាកមូលធ្ងន់ធ្ងរ ហើយដោយគ្មានថ្នាំ និងពេទ្យព្យាបាល កូនរបស់គាត់ក៏បានស្លាប់ទៅ ។ កូនរបស់ ជន់ ត្រូវបានប្រជាជនក្នុងភូមិជួយយកទៅបញ្ចុះនៅវត្តព្រៃខ្លា ។ តែមួយរយៈខ្លីប៉ុណ្ណោះ ជន់ បានបាត់បង់កូនអស់ពីរនាក់ ដែលធ្វើឲ្យគាត់អស់សង្ឃឹម និងលែងខ្វាយខ្វល់អ្វីទាំងអស់ ។ បៃដន្យបន្ទាប់ពីកូនប្រុស ស្លាប់ ជន់ ក៏បានជួបនឹងក្រុមគ្រួសារបងថ្លៃរបស់គាត់ទាំងអស់ ដែលភាគច្រើនជាមន្ត្រីរដ្ឋការក្នុងរបប លន់ នល់ ជម្លៀសទៅពីភ្នំពេញតាំងពីមុនពេលដែលគាត់ទៅដល់ទីនោះម្ល៉េះ ហើយបានបបួលប្រពន្ធគាត់ឲ្យទៅរស់ស្រុកកំណើតនៅខេត្តកំពតវិញ ប៉ុន្តែប្រពន្ធគាត់បានបដិសេធ ។ ក្រោយមក ជន់ បាន ទទួលដំណឹងថា គ្រួសារបងថ្លៃរបស់គាត់ទាំងអស់ត្រូវខ្មែរក្រហមចាប់ចង និងសម្លាប់ចោលទាំងអស់ ។

នៅភូមិក្រាំងអាអួតមួយរយៈ ខ្មែរក្រហមបានបញ្ជាឲ្យគ្រួសារ ជន់ ទៅនៅខេត្តបន្ទាយមានជ័យ ដោយពេលនោះគាត់ត្រូវដើរអស់រយៈពេលមួយព្រឹកទើបឡើងទៅដល់ផ្លូវថ្នល់ជាតិលេខ២ ដោយនៅទីនោះ គាត់ឃើញមានរថយន្តចតរង់ចាំជាស្រេច ។ ជន់ និងប្រពន្ធបានមកស្នាក់នៅខេត្តពោធិ៍សាត់ រយៈពេលពីរយប់ ទើបខ្មែរក្រហមបញ្ជាឲ្យឡើងជិះរទេះភ្លើងបន្តទៅស្វាយស៊ីសុផុន ។ គ្រួសារ ជន់ ត្រូវបានខ្មែរក្រហមដឹកយកទៅដាក់នៅភូមិកណ្តាល ឃុំទឹកជោរ ស្រុកព្រះនេត្រព្រះ តំបន់៥ ដោយគាត់បានទៅស្នាក់ផ្ទះជាមួយប្រធានកងធំឈ្មោះ ខន ។ ពេលនោះ ជន់ ក៏បានឃើញ

គ្រួសារជនជាតិចាមប្រមាណប្រាំបីគ្រួសារ ដែលជម្លៀសទៅពីម្តុំប្រាំងចំរេះ ក្រុងភ្នំពេញ ឲ្យមករស់នៅក្នុងភូមិនោះដែរ ។

នៅទីនោះ ប្រធានភូមិបានចាត់តាំង ជន់ ឲ្យធ្វើការនៅកងចល័ត ។ ថ្ងៃមួយ កងចល័តរបស់ ជន់ ត្រូវចុះទៅធ្វើស្រែនៅព្រៃរនាម ហើយដោយពេលនោះជារដូវទឹកឡើងគាត់ក៏បានជិះទូកទៅ ។ ប៉ុន្តែសំណាងអាក្រក់ទូករបស់គាត់បានប៉ះនឹងឈើ ហើយគាត់ក៏ធ្លាក់ទៅបុកនឹងដង្កត់ឈើចំឆ្អឹងជំនី ។ ដោយសារការឈឺចាប់ក្រោយពីត្រឡប់មកដល់ផ្ទះវិញ ជន់ បានពឹងពាក់ ឃួន ក្មួយរបស់ ខន (ជាប្រធានកងធំ) ឲ្យទៅសុំប្រេងកូឡាពី ខន ដើម្បីយកមករឹតបំបាត់ការឈឺចាប់ ។ ក្រោយពីដឹងរឿងនេះ ខន បានស្រែកឡើងថា "អ្នកភ្នំពេញ កុំចង់ផាប់ពេក!" ប៉ុន្តែគាត់មិនបានមករករឿង ជន់ ទេ ។

នៅទីនោះ ជន់ បានលាក់ប្រវត្តិរូបរបស់គាត់ ដោយគាត់ហែកកាតសម្គាល់ខ្លួនជាមន្ត្រីការិយាល័យសហករណ៍ជាតិចោល ហើយទុកតែកាតសម្គាល់ខ្លួនជាកម្មករឃ្លាំងប៉ុណ្ណោះដើម្បីបង្ហាញដល់អ្នកមកសួរពីប្រវត្តិរូប ។ ម្យ៉ាងទៀត ដោយសារកាតរបស់គាត់សរសេរជាភាសាបារាំង ហើយអ្នកមកធ្វើប្រវត្តិរូបក៏មិនចេះភាសាទៀតនោះ ទើបគេមិនបានសួរដេញដោលគាត់ ។

ក្រោយមក ដោយសារមិនមានអ្នកចេះអក្សរដើរធ្វើប្រវត្តិរូប ទើបប្រធានភូមិឈ្មោះ ហូ បានប្រជុំចាត់តាំង ជន់ ឲ្យដើរធ្វើប្រវត្តិរូបប្រជាជនប្រមាណ៨០គ្រួសារ ។ រៀងរាល់ថ្ងៃក្រោយសម្រាកពីការងារនៅពេលយប់ ជន់ បានដើរស្រង់ប្រវត្តិរូបប្រជាជននៅតាមផ្ទះ ដើម្បីឲ្យដឹងតើក្នុងមួយផ្ទះមានប្រជាជនប៉ុន្មានគ្រួសាររស់នៅ ។ ជន់ ដើរស្រង់បញ្ជីនេះរហូតដល់ម៉ោង១០យប់ទើបឈប់ ហើយរបាយការណ៍ដែលគាត់ស្រង់បានត្រូវបញ្ជូនបន្តទៅឲ្យប្រធានភូមិ ។ នៅពេលចុះទៅធ្វើកិច្ចការនេះ ជន់ បានជួបនឹងសាស្ត្រាចារ្យ និងមន្ត្រីរដ្ឋការមួយចំនួនដែលគាត់ធ្លាប់ស្គាល់ពីមុនមក ។ ប៉ុន្តែទោះបីជាមានការបញ្ជាឲ្យមានការកត់ត្រាប្រវត្តិរូបឲ្យបានច្បាស់លាស់ក៏ដោយ ក៏ ជន់ មិនដែលកត់ត្រាពីមុខងារ និងតួនាទីពិតប្រាកដរបស់អ្នកទាំងនោះដែរ ព្រោះគាត់ដឹងថានឹងអាចបណ្តាលឲ្យមានគ្រោះថ្នាក់ដល់អាយុជីវិតប្រសិនបើថ្នាក់លើដឹង ។

ក្រៅពីការងារដើរស្រង់ប្រវត្តិរូប ជន់ ត្រូវធ្វើការងារនៅក្នុងកងចល័ត និងឃ្វាលគោ ប៉ុន្តែក៏ទទួលបានរបបអាហារដូចប្រជាជនដែរ គឺបបរ ។ មានប្រជាជនជាច្រើននៅក្នុងភូមិបានស្លាប់ដោយសារអត់អាហារ ពិសេសជនជាតិចាម ចំណែកប្រជាជនដែលធ្លាក់ខ្លួនឈឺមួយចំនួនបានសុំអនុញ្ញាតពីប្រធានភូមិទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ ដោយសង្ឃឹមថានៅទីនោះនឹងទទួលបានអាហារហូបគ្រប់គ្រាន់ ។ ក្រោយពីដឹងរឿងនេះ ជន់ បានដើរទៅប្រាប់ប្រជាជនដែលស្នើសុំទាំងនេះ ឲ្យខំតស៊ូរស់នៅក្នុងភូមិបន្តទៀត ដោយគាត់បានសន្យានឹងលួចផ្តល់អាហារតិចតួចឲ្យទៀតផង ព្រោះគាត់ដឹងច្បាស់ថា អ្នកដែលទៅមន្ទីរពេទ្យអង្គការនឹងយកទៅសម្លាប់ចោលមិនខាន ។ ពេលនោះ មានជនជាតិចាមប្រមាណជា៨០គ្រួសារ ដែលជម្លៀសទៅពីឃុំទឹកជោរ នៅឆ្នាំ១៩៧៥ មានតែបីគ្រួសារប៉ុណ្ណោះដែលនៅរស់ក្រោយពីរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩ ។

ដោយសារស្ថានភាពរស់នៅលំបាកដូច្នេះ ទើបមានសាស្ត្រាចារ្យចំនួនបីនាក់នៅក្នុងភូមិរបស់ ជន់ ដែលគាត់ធ្លាប់ស្គាល់ និងប្រជាជនមួយចំនួនទៀតបានរត់ភៀសខ្លួនទៅប្រទេសថៃ ប៉ុន្តែ ជន់ មិនបានដឹងពីវាសនារបស់អ្នកទាំងនោះទេ ព្រោះបានបាត់ដំណឹងរហូត ។

នៅប្រហែលអំឡុងឆ្នាំ១៩៧៨ ជន់ បានដឹងថាមានការចាប់ខ្លួនប្រជាជន និងកម្មាភិបាលថ្នាក់ភូមិឃុំកាន់តែច្រើនឡើងៗ ព្រោះខ្សែដែលគាត់ទុកសម្រាប់ចងគោទាំងប៉ុន្មាន ត្រូវខ្មែរក្រហមយកទៅឆ្អេរឲ្យទន់ដើម្បីទុកចងមនុស្សទៅវិញ ។

នៅថ្ងៃមួយពេល ជន់ ទៅកាប់ចម្ការនៅព្រៃរនាម ស្រាប់តែខ្មែរក្រហមប្រាប់ប្រពន្ធរបស់គាត់ឲ្យតាមរកគាត់ ។ ប្រពន្ធ ជន់ ភិតភ័យ និងតក់ស្លុតយ៉ាងខ្លាំងពេលឮដំណឹងនេះ ព្រោះគិតថាប្តីគាត់នឹងត្រូវចាប់ខ្លួនមិនខាន ។ ប៉ុន្តែផ្ទុយទៅវិញ អង្គការចាត់តាំង ជន់ ឲ្យទៅនៅខាងអាជីវកម្មនេសាទត្រី រកត្រីឲ្យអ្នកកាប់ចម្ការហូប ដោយនៅពេលនោះគាត់មានសមាជិកបីនាក់ នៅជាមួយតា យន់ ។ ជន់ ដែលពីមុនមិនចេះនេសាទ និងហែលទឹកស្ទាត់ជំនាញ ពេលនោះគាត់អាចមុជទឹករហូតដល់ទៅប្រមាណជាង៩ម៉ែត្រ ហើយចាប់តាំងពីនោះមកគាត់បានហូបគ្រប់គ្រាន់ ។

ជន់ និងប្រពន្ធ បានរស់នៅឃុំទឹកជោររហូតដល់ឆ្នាំ ១៩៧៩ ខណៈពេលដែលសភាពការណ៍កាន់តែប្របូកប្របល់ខ្លាំង ។ នៅពេលនោះ កងឈ្លបខ្មែរក្រហមជាច្រើនបានរត់គេចចេញពីភូមិ ដោយមានអ្នកខ្លះបានកៀរប្រជាជនទៅជាមួយផង ។ ចំណែក ជន់ ក៏សម្រេចចិត្តនាំប្រពន្ធ និងកូនស្រីម្នាក់ ដែលអាយុទើបកន្លះខែធ្វើដំណើរត្រឡប់មករស់នៅស្រុកកំណើតនៅខេត្តសៀមរាបវិញ ។

នៅទីនោះ ជន់ បានចូលធ្វើការនៅក្នុងមន្ទីរកសិកម្ម ខេត្តសៀមរាប ហើយក្រោយពេលគាត់ចូលនិវត្តន៍ នៅឆ្នាំ២០០០ ប្រជាជនក៏បោះឆ្នោតឲ្យគាត់ធ្វើជាចៅសង្កាត់នគរធំរហូតដល់ឆ្នាំ ២០១២ ទើបមានការផ្លាស់ប្តូរមេឃុំថ្មីមកជំនួស ។

រហូតមកដល់សព្វថ្ងៃ ទោះបីពេលវេលាបានកន្លងផុតទៅយូរហើយ និងមានការងារជាច្រើនបានមកបន្ទប់អារម្មណ៍របស់ជន់ ក៏ដោយ ក៏គាត់នៅតែនឹកឃើញរឿងរ៉ាវដែលបានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហម និងនៅតែសោកស្តាយ និងរន្ធត់នៅពេលរំឭកពីរឿងក្រុមគ្រួសាររបស់គាត់ ។

ជន់ បានបញ្ជាក់ថា ទោះបីនៅពេលនេះគាត់បានមកចូលរួមដំណើរការកាត់ទោសមេដឹកនាំ ជាន់ខ្ពស់ខ្មែរក្រហមដោយផ្ទាល់ និងបានដឹងព័ត៌មានខ្លះពីអង្គជំនុំជម្រះវិសាមញ្ញក៏ដោយ ក៏ការកាត់ទោសនេះ មិនស្មើទៅនឹងការឈឺចាប់ដែលនៅជិតជាមក្នុងអារម្មណ៍របស់គាត់ដោយការបាត់បង់កូនទាំងពីរនាក់ ។

**សោម ប៊ុនថន**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://dccam.org/Projects/Magazines/Magazine_Searching.htm ។ ព័ត៌មានបន្ថែម សូមទាក់ទង ញាណ សុជាតិ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាមានកម្មវិធីសំឡេងអំពើប្រល័យពូជសាសន៍ៈ យុត្តិធម៌ និងការអត់ឃ្លាន ផ្សាយតាមវិទ្យុជាតិកម្ពុជា AM៩១៨MHz វិទ្យុខេត្តកំពតFM៩៣.២៥ វិទ្យុខេត្តបាត់ដំបង FM១០៣.២៥ និងវិទ្យុខេត្តព្រះវិហារFM៩៩ ។ ***សូមអរគុណ!***



អោម ជន់ និយាយពីរឿងរ៉ាវជីវិតក្នុងរបបខ្មែរក្រហមរបស់គាត់ ប្រាប់ដល់លោក សោម ប៊ុនថន នៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង

# ចេង ជីវ័ន្ត : ពុកស្លាប់ដោយសារធ្វើជាមន្ត្រីគណនេយ្យ

ចេង ជីវ័ន្ត ហៅ ឡូញ អាយុ៤៨ឆ្នាំ មានស្រុកកំណើតនៅក្រុងកំពង់ធំ ខេត្តកំពង់ធំ ។

ឡូញ មានឪពុកឈ្មោះ ចេង ហៃហាក់ មានស្រុកកំណើតនៅភូមិត្រពាំងវែង ឃុំស្រយ៉ូវ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ នៅសម័យសម្តេច សីហនុ ឪពុករបស់ ឡូញ ធ្វើជាមន្ត្រីនៅក្នុងមន្ទីរអប់រំខេត្តកំពង់ធំ ហើយបានស្រឡាញ់ និងរៀបការជាមួយម្តាយគាត់ឈ្មោះ ហៀក ម៉េងជូ ដែលធ្វើជាគ្រូបង្រៀនសាលាបឋមសិក្សា នៅឃុំបញ្ញាជី ស្រុកសន្ទុក ។ ក្រោយពេលរៀបការរួចឪពុក របស់ ឡូញ បាននាំគ្រួសារមករស់នៅទីរួមខេត្តកំពង់ធំ ។

រហូតដល់ឆ្នាំ១៩៧០ ដោយសារនៅខេត្តកំពង់ធំមានអសន្តិសុខ ទើបឪពុករបស់ ឡូញ បាននាំម្តាយរបស់គាត់ និងកូនប្រាំមួយនាក់មករស់នៅទីក្រុងភ្នំពេញ ។ ឪពុកម្តាយ ឡូញ បានមកជួល ផ្ទះមួយកន្លែងស្ថិតនៅខាងជើងផ្សារទួលគោករស់នៅ ។

ក្រោយមក ឡូញ ក៏បានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សាពៅអ៊ីដែរ ដែលនៅទីនោះ គាត់តែងតែទទួលការបង្អាប់ពីមិត្តភក្តិដោយសារតែឈ្មោះ និងរូបរាងរបស់គាត់ ។

ឡូញ មិនសូវបានជួបមុខឪពុកម្តាយទេ ព្រោះគាត់ទាំងពីរនាក់ជាប់រវល់ធ្វើការ ដែលពេលនោះ ឪពុករបស់គាត់បានផ្លាស់ការងារពីមន្ត្រីអប់រំមកធ្វើការជាមន្ត្រីគណនេយ្យនៅក្រសួងអភិវឌ្ឍជនបទ ដែលទទួលជំនួយពីប្រទេសអាមេរិក និងមានទីស្នាក់ការ (សព្វថ្ងៃនៅខាងកើតដេអិន) ។ ចំណែកម្តាយគាត់បានផ្លាស់មកធ្វើជាគ្រូបង្រៀននៅសាលាបឋមសិក្សានាគវ័ន្ត ។

ឪពុកម្តាយ ឡូញ បានជួលផ្ទះស្នាក់នៅរហូតដល់ដើមឆ្នាំ១៩៧៥ ទើបក្មួយប្រុសខាងឪពុករបស់គាត់ដែលធ្វើជានាយកធនាគារ ហៅគ្រួសារ ឡូញ ឲ្យទៅស្នាក់នៅ និងជួយថែរក្សាផ្ទះវីឡា (ដែលស្ថិតនៅទល់មុខនឹងផ្ទះជួលនោះ) ព្រោះក្មួយប្រុសឪពុកគាត់



(រូបទីមួយរាប់ពីស្តាំ) ចេង ជីវ័ន្ត, (រូបទីបួននិងទីប្រាំ) ប្រពន្ធ និងកូន របស់ ជីវ័ន្ត ថតនៅក្នុងពិធីមង្គលការ

ជាប់អាហាររូបករណ៍ទៅរៀនបន្តនៅប្រទេសបារាំង ដោយត្រូវយកប្រពន្ធ និងកូនទៅរស់នៅជាមួយដែរ ។ ឡូញ មិនបានស្នាក់ផ្ទះវីឡានោះយូរទេ ដោយសារខ្មែរក្រហមបានផ្លោងគ្រាប់ចូលមកស្ទើររៀងរាល់ថ្ងៃ ព្រោះទួលគោកជាកន្លែងដែលមានក្រុមគ្រួសារមេទាហាន និងមន្ត្រីធំៗរស់នៅ ហើយគាត់តែងតែពុទ្ធានស៊ីវ៉ែនចេញចូលតំបន់នោះមិនដាច់ ។

នៅប្រហែលខែមីនា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានផ្លោងគ្រាប់មកចំរបងផ្ទះរបស់ ឡូញ ផ្នែកខាងក្រោយ ។ ពេលនោះ ឡូញ បានពុស្សំឡេងថ្ងូរគួរឲ្យរន្ធត់របស់ជនរងគ្រោះស្រែកឲ្យជួយ ប៉ុន្តែសំណាងល្អគ្រាប់ផ្លោងនេះមិនបណ្តាលឲ្យគ្រួសារគាត់រងរបួសទេ ។ ដោយសារការភ័យខ្លាច ឪពុកម្តាយ ឡូញ បាននាំកូនទាំងប្រាំមួយនាក់ និងឥវ៉ាន់បន្តិចបន្តួចមកស្នាក់នៅបណ្តោះអាសន្នជាមួយក្មួយប្រុសរបស់ឪពុកគាត់ម្នាក់ទៀតធ្វើជាទាហានពាក់សក្តិ៥ ដែលមានផ្ទះស្ថិតនៅខាងក្រោយដេអិន ជា បន្ទាយទាហានរបស់ លន់ នល់ ។

នៅពេលយោធាខ្មែរក្រហមចូលមកដល់ក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ ឪពុករបស់ ឡូញ បាននាំក្រុមគ្រួសាររួមទាំងសាច់ញាតិ និងក្មួយធ្វើដំណើរទៅឈប់នៅវត្តបុស្សីជ្រោយ ។ ឪពុក ឡូញ បាននិយាយថា នឹងមិនត្រឡប់ទៅស្រុកកំណើតវិញទេ ព្រោះខ្មែរក្រហមប្រាកដជាស្គាល់គាត់ ជាមន្ត្រីបម្រើការងារឲ្យរបប លន់ នល់ ហើយគាត់ក៏ដកយកឯកសារគណនេយ្យ និងនាមប័ណ្ណសម្គាល់ខ្លួនរបស់គាត់ពីវ៉ាលីមកដុតចោល ។ ស្រាប់តែពេលនោះ ក្មួយប្រុសៗដែលធ្វើទាហាន និងបងប្អូនគាត់ ផ្សេងទៀតនិយាយថា «លោកពូមិនបាច់ដុតវាចោលទេ ខ្មែរក្រហមនឹងមិនទៅរករឿងពូដោយសារតែឯកសារទាំងអស់នេះទេ» ។

បន្ទាប់មក បងប្អូន និងក្មួយៗរបស់គាត់បានចេញដើរលេងនៅតាមភូមិក្បែរៗនោះអស់ ចំណែកឪពុករបស់ ឡូញ មិនបានចេញទៅជាមួយទេ ព្រោះគាត់ខ្វាយខ្វល់នឹងក្រុមគ្រួសារដែលមានកូនប្រាំមួយនាក់នៅក្នុងបន្ទុក ។ រហូតដល់ពេលរសៀល ឪពុក ឡូញ បានដើររកខសមកដុតដាំបាយ និងចម្អិនម្ហូបឲ្យកូនៗហូប ប៉ុន្តែមិនទាន់ទាំងឆ្អិនផង កងឈ្លបខ្មែរក្រហមក៏ដើរមកឆែកវ៉ាលីរបស់គាត់ ឃើញឯកសារគណនេយ្យរួចហើយក៏កត់ឈ្មោះរបស់គាត់ទុក ។ គ្រួសាររបស់ ឡូញ ស្នាក់នៅវត្តបុស្សីជ្រោយមួយយប់ក៏បន្តធ្វើដំណើរទៅមុខទៀត ប៉ុន្តែស្រាប់តែទៅដល់ព្រែកពោធិ៍ កម្មាភិបាលខ្មែរក្រហម នៅទីនោះបានហៅឈ្មោះឪពុក បងប្អូនគាត់ និងអតីតមន្ត្រីរដ្ឋការក្នុងរបប លន់ នល់ ជាច្រើនរូបទៀតឲ្យទៅរៀនសូត្រ ហើយចាប់តាំងពីនោះមកគាត់បាត់ដំណឹងឪពុកគាត់រហូត ។

ចំណែកម្តាយ និងបងប្អូនគាត់ ខ្មែរក្រហមបានដកយកសម្ភារប្រើប្រាស់ទាំងអស់ រួចបញ្ជូនទៅព្រែកសណ្តែក ក្នុងស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ។ ខ្មែរក្រហមបានដាក់គ្រួសារ ឡូញ នៅក្នុងមន្ទីរឃុំឃាំង ដែលជាអគារថ្មសង់ផុតពីដី (អតីតមន្ទីរពេទ្យក្នុងសង្គមចាស់) រួមជាមួយគ្រួសារមេម៉ាយផ្សេងទៀតដែលប្តីត្រូវបានចាប់ខ្លួន ។ នៅទីនោះ ក្មេងៗបានធ្លាក់ខ្លួនឈឺ និងស្លាប់ជាច្រើននាក់ ដោយសារតែខ្វះអាហារ និងអនាម័យព្រោះប្រធានយោធាខ្មែរក្រហមដែលគ្រប់គ្រងនៅទីនោះ បានឲ្យគ្រួសារអ្នកមេម៉ាយទាំងនោះរស់នៅប្រមូលផ្តុំគ្នានៅក្នុងបន្ទប់មន្ទីរពេទ្យដែលបង្ខំ-ទ្វារបិទជិត និងមានយោធាយាមទាំងយប់ទាំងថ្ងៃ ។ គ្រួសាររបស់ ឡូញ ត្រូវយោធាខ្មែរក្រហមហៅថា «ឈ្លើយសឹក» ហើយសូម្បីតែប្រជាជនដែលរស់នៅក្នុងមូលដ្ឋាននោះក៏មិនហ៊ាននិយាយជាមួយគាត់ដែរ ព្រោះខ្លាចជាប់ទោស ។ នៅពេលម្តាយ ឡូញ ចេញទៅកាប់ខស និងធ្វើការនៅវាលស្រែ ក៏មានកងយោធាទៅយាមដែរព្រោះខ្លាចម្តាយគាត់លួចរត់ ។

ពីមួយថ្ងៃទៅមួយថ្ងៃ ដោយសារចំនួនអ្នកស្លាប់ចេះតែកើនឡើងមិនឈប់ ទើបមានកម្មាភិបាល ខាងតំបន់ចុះមកត្រួតពិនិត្យ រួចហើយហៅប្រធានយោធាដែលគ្រប់គ្រងនៅទីនោះមកព្រមាន និងឲ្យទទួលខុសត្រូវលើការស្លាប់មនុស្សទាំងនេះ ។ ចាប់ពីពេលនោះមកទើបការរស់នៅរបស់ ឡូញ និងអ្នកជម្លៀសផ្សេងទៀត បានប្រសើរជាងមុន ដោយខ្មែរក្រហមអនុញ្ញាតឲ្យបើកបង្អួច និងបើកទ្វារវិញ ។

ឡូញ រស់នៅព្រែកសណ្តែកអស់រយៈពេលប្រាំមួយខែ ទើបខ្មែរក្រហមបញ្ជូនក្រុមគ្រួសារគាត់ឲ្យទៅរស់នៅតាណេក ស្ថិតនៅចម្ងាយប្រមាណ៤០គីឡូម៉ែត្រពីទីនោះ ដែលជាកន្លែងលត់ដំ និងមានវិន័យតឹងរ៉ឹងជាងមុន ។ ខ្មែរក្រហម បានឲ្យគ្រួសារគាត់ទៅរស់នៅអគារមួយខ្នងសង់ពីឈើប្រក់ក្បឿង ដែលជាអតីតសាលារៀនពីសង្គមចាស់ ។ ខ្មែរក្រហមបានឲ្យម្តាយ ឡូញ ដឹក

ប្រទ្បាយ ប្រូតស្រូវ កាប់ឆ្ការព្រៃ ហើយពេលយប់ត្រូវបុកស្រូវថែមទៀត ចំណែក ឡូញ និងបងប្អូនគាត់ខ្មែរក្រហមឲ្យដើររកខសប្រមូលស្លឹកឈើ និងឃ្វាលគោ ។ នៅទីនោះមានការខ្វះខាតរបបអាហារយ៉ាងខ្លាំង ដូច្នេះថ្ងៃមួយ ម្តាយរបស់ ឡូញ បានលួចទៅនិយាយជាមួយចុងភៅឲ្យដួសបបរឲ្យគាត់ឲ្យខាប់នៅពេលបើករបបជាថ្នូរនឹងការដែលម្តាយគាត់ដេរខោឲ្យ ។ ស្រាប់តែក្រោយមកឈ្លបខ្មែរក្រហមបានស៊ើបដឹងរឿងនេះ រួចហើយក៏ចោទម្តាយគាត់ថា ក្បត់សមូហភាព និងបានព្រមានកុំឲ្យរឿងនេះកើតឡើងជាថ្មីទៀត ។ ចំណែក ពូម្នាក់ដែលជាប់ឃុំនៅទីនោះ ដោយសារតែស្រេកឃ្លានខ្លាំងពេក បានទៅលួចគាស់យកស្ទួតសត្វសេះងាប់ដែលខ្មែរក្រហមកប់ចោលមកស្ងោរហូប ក៏ត្រូវឈ្លបខ្មែរក្រហមតាមទាន់ ។ ក្រោយពេលធ្វើការចប់នៅពេលយប់ អ្នកគ្រប់គ្រងបានហៅអ្នកជាប់ឃុំនៅទីនោះទាំងអស់មកប្រជុំ រួចហៅអ្នកលួចហូបស្ទួតសេះឡើងបង្ហាញខ្លួន បន្ទាប់មកយោធាវាយទាត់ធាក់បុរសនោះយ៉ាងឃោរឃៅ ធ្វើឲ្យអ្នកចូលរួមរន្ធត់គ្រប់គ្នា ។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានបញ្ជូនគ្រួសាររបស់ ឡូញ តាមកប៉ាល់ និងរទេះភ្លើងឲ្យទៅរស់នៅភូមិស្ទឹងចាស់ ឃុំតាប៉ុនស្រុកសង្កែ ខេត្តបាត់ដំបង ដោយដំបូងខ្មែរក្រហមឲ្យគ្រួសារគាត់ទៅរស់នៅវត្តសម្តេច ។ ប្រធានសហករណ៍ឈ្មោះ សៀ និងប្រពន្ធឈ្មោះ ហុង បានចាត់ម្តាយគាត់ឲ្យទៅធ្វើការ នៅវាលស្រែឆ្ងាយពីភូមិ ចំណែកបងប្អូនគាត់ឲ្យធ្វើការនៅកងចល័ត ។ ដោយសាររបបអាហារមិនគ្រប់គ្រាន់ ឡូញ និងបងប្អូនគាត់តែងតែទៅលួចអាហារនិងលួចបូតស្រូវមកឲ្យម្តាយគាត់ដាំបាយហូប ។ ប៉ុន្តែថ្ងៃមួយ កងឈ្លបខ្មែរក្រហមក៏ចាប់គាត់ និងបងស្រីមកព្រមាន ។ ក្រោយមកពេលចេញទៅលួចបូតស្រូវម្តងៗ ឡូញ មិនដែលឲ្យបងស្រីគាត់ទៅជាមួយទេ ព្រោះខ្លាចយោធាខ្មែរក្រហមធ្វើបាប ។

នៅរដូវប្រូត ឡូញ និងបងស្រី បានទៅវាលស្រែជាមួយម្តាយគាត់ ហើយក្រោយពេលប្រូត ហើយកងចល័តជាច្រើននាក់បានលួចបូតស្រូវមកបុកដាំបាយហូប ។ ចំណែកម្តាយរបស់ ឡូញ មិនហ៊ានប្រព្រឹត្តដូចគេទេ ព្រោះខ្លាចជាប់ទោស ។ ពេលដើរលើភ្លឺស្រែជាមួយម្តាយ ឡូញ និងប្អូនស្រី ឃើញគួរស្រូវវែងៗក៏កាច់បានប្រាំមួយគួរកាន់នៅនឹងដៃ ស្រាប់តែយោធាខ្មែរក្រហមដែលលួចមើលពីលើចុងត្នោត ឃើញក៏ចុះមកភ្ជង់កាំភ្លើងម្តាយគាត់ ។ ម្តាយ ឡូញ បានខិតខំនិយាយអង្វរយោធានោះគ្រប់បែបយ៉ាងដើម្បីកុំឲ្យយកទោសពៃរ៍ ប៉ុន្តែយោធានោះបានបដិសេធ រួចហើយក៏បណ្តើរគាត់ទៅដាក់នៅដំរិលត់ដំនៅកំពង់ព្រះ ។

នៅទីនោះ យោធាខ្មែរក្រហមឲ្យម្តាយ ឡូញ ទៅកាប់ឆ្ការព្រៃ នៅឆ្ងាយពីភូមិ ហើយត្រូវដេក នៅក្រោមដើមពុទ្រាក្នុងព្រៃតែម្តង ។ ដោយសារមានការលំបាកដូច្នេះ ម្តាយ ឡូញ បានលួចទៅសុំអង្វរប្រធានយោធាដើម្បីត្រឡប់មកជួបកូននៅភូមិស្ទឹងចាស់វិញ ប៉ុន្តែត្រូវបានបដិសេធ ។ ព្ទដូច្នេះ ម្តាយ ឡូញ ក៏សូមឲ្យបញ្ជូនកូនទាំងបួននាក់នៅក្នុងភូមិស្ទឹងចាស់មករស់នៅជាមួយគាត់វិញ ប៉ុន្តែត្រូវបានបដិសេធម្តងទៀត ។ អស់វិធីអង្វរ ម្តាយ ឡូញ បានពិភាក្សាជាមួយគ្រួសារអ្នកមេម៉ាយម្នាក់ទៀត លួចរត់ដោយឲ្យ ឡូញ ទៅជាមួយគ្រួសារនោះមុន ហើយគាត់ទៅតាមក្រោយ ។ ប៉ុន្តែពេល ឡូញ ចេញទៅផុត អ្នកដែលរស់នៅក្បែរគ្នាទៅរាយការណ៍ប្រាប់យោធាថា ម្តាយ ឡូញ លួចមាសគាត់ ទើបយោធាឃាត់ម្តាយគាត់ទុក ។

ឡូញ ដើរតាមភ្លឺទំនប់រហូតមកដល់ភូមិស្ទឹងចាស់ ហើយបានជួបជុំបងប្អូនគាត់វិញ ។ ចំណែកម្តាយគាត់មានការបារម្ភយ៉ាងខ្លាំង ព្រោះមិនដឹងថា ឡូញ ទៅដល់ទីណាទេ ។ ប៉ុន្តែរយៈពេលប្រាំខែក្រោយមក ពេលយោធាខ្មែរក្រហមដោះលែងម្តាយគាត់ឲ្យត្រឡប់មកភូមិវិញទើបម្តាយគាត់ដឹងថា ឡូញ បានមករស់នៅជាមួយបងប្អូន ។

នៅឆ្នាំ១៩៧៨ កម្មាភិបាលភូមិភាគនិរតីបានចូលមកគ្រប់គ្រង និងចាប់ប្រធានសហករណ៍របស់គាត់ និងកម្មាភិបាលជាន់ខ្ពស់ភូមិភាគពាយ័ព្យជាច្រើនរូប ។ ស្របពេលនោះ របបអាហារក៏កាន់តែខ្វះ ខាតខ្លាំងដែរ ហើយសូម្បីតែបន្លែ និងដំឡូងដែលគ្រួសារគាត់លួចដាំទុកហូប ក៏យោធាដែលមកដល់ថ្មីទាំងនោះមកដកយកទៅដាក់រួមទាំងអស់ ។ ថ្ងៃមួយយោធាខ្មែរក្រហម បានដើរកាត់ផ្ទះរបស់ ឡូញ ស្រាប់តែឃើញអង្កាមរាយប៉ាយពេញមុខផ្ទះ យោធានោះក៏ចោទគ្រួសារគាត់ថា លួចហូបឯកជន រួចហើយបន្តុតរបបគ្រួសារគាត់ទាំងអស់គ្នា ។

រហូតដល់ចុងឆ្នាំ១៩៧៨ សភាពការណ៍កាន់តែច្របូល



ម្តាយរបស់ ជីវិន្ត (ហៀក ម៉េងជូ)

ប្របល់ខ្លាំង ពេលនោះយោធាខ្មែរក្រហមក៏កៀរគ្រួសារ ឡូញ ឲ្យទៅនៅកាច់រទេះ ។ នៅតំបន់នោះ មានអាហារច្រើន ពិសេសត្រី ។ ប៉ុន្តែមិនមានអំបិលហូបទេ ព្រោះយោធាខ្មែរក្រហមបានប្រមូលទុកសម្រាប់ធ្វើប្រហុក និងត្រីងៀត ។ ពេលទៅដល់ដំបូង ឡូញ មានរូបរាងស្គមស្គាំង ដូច្នេះហើយអ្នកភូមិមិនហ៊ានឲ្យគាត់ហូបបាយច្រើនទេព្រោះខ្លាចធ្លាយក្រពះ គឺឲ្យគាត់ហូបបបររយៈពេលមួយអាទិត្យ ។

គ្រួសារ ឡូញ នៅកាច់រទេះបានមួយរយៈ កូនប្រុសរបស់អ្នកមូលដ្ឋានម្នាក់ដែលធ្លាប់ធ្វើជាជាងជួសជុលកង់ឲ្យខ្មែរក្រហម បានស្រឡាញ់បងស្រីរបស់ ឡូញ រួចហើយស្នើប្រធានភូមិនៅទីនោះ រៀបការ ។ ពិធីរៀបការរបស់បងស្រី ឡូញ មិនធ្វើធំដុំទេ គឺមានតែឪពុកម្តាយទាំងសងខាងដឹងឮ និងបបរស្ករហូបប៉ុណ្ណោះ ។ បន្ទាប់ពីរៀបការរួច ខ្មែរក្រហមកៀរគ្រួសារ ឡូញ និងគ្រួសារអ្នកភូមិឲ្យទៅភ្នំធិបតី ព្រោះកងទ័ពវៀតណាមវាយចូលមកកាន់តែកៀកហើយ ។ គ្រួសារ ឡូញ ធ្វើដំណើរទៅស្នាក់នៅស្វាយដូនកែវមួយរយៈ ។ ក្រោយមកដោយដឹងថា ខ្មែរក្រហមមានគម្រោងជម្លៀសបន្តទៅទឹកពុះ ទើបនៅពេលព្រលប់គ្រួសារគាត់ និងគ្រួសារអ្នកជម្លៀសប្រមាណ១០០គ្រួសារផ្សេងទៀតលួចរត់កាត់ភ្លៀងត្រឡប់ទៅកាច់រទេះដែលវៀតណាមរំដោះបានវិញ ។ ប៉ុន្តែត្រូវកងឈ្លបខ្មែរក្រហមតាមស្ទាក់បាញ់សម្លាប់អស់ប្រមាណដប់គ្រួសារ ។

នៅឆ្នាំ១៩៧៩ ម្តាយ ឡូញ បាននាំកូនទាំងអស់ទៅនៅអូរអំបិល ក្រុងសេរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ ដោយទុកតែបងស្រីគាត់ម្នាក់ឲ្យរស់នៅជាមួយប្តី និងឪក្មេកនៅកាច់រទេះ ។ នៅទីនោះ ម្តាយរបស់ ឡូញ បានធ្វើនំឲ្យ ឡូញ និងបងស្រីរបស់គាត់ដើរលក់ដើម្បីផ្គត់ផ្គង់គ្រួសារ ។ ក្រោយមក ម្តាយគាត់បានចូលធ្វើគ្រូបង្រៀននៅសាលាបឋមសិក្សាអូរអំបិល ដោយពេលនោះគាត់ទទួលបានរបប អង្ករ ពោត សាប៊ូ និងប្រេងកាត ។

នៅឆ្នាំ១៩៨២ ម្តាយ ឡូញ បាននាំកូនរបស់គាត់ទាំងអស់មកនៅជាមួយបងប្អូនជីដូនមួយ នៅម្តុំផ្សារអូរឫស្សី ក្រុងភ្នំពេញ ហើយ ឡូញ ក៏បានចូលរៀនបន្តនៅវិទ្យាល័យ ។ បច្ចុប្បន្ន ឡូញ ជាមន្ត្រីកាំកុងត្រូលនៅខេត្តព្រះសីហនុ ។

ឡូញ បញ្ជាក់ថា គាត់នៅតែនឹកឃើញពីរឿងរ៉ាវរបស់ក្រុមគ្រួសារ និងឪពុកដែលគាត់ មិនទាំងអាចចំណាំមុខបានរហូតមកដល់សព្វថ្ងៃនេះ ។ **សោម ប៊ុនថន**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthsocheat@dccam.org*

*Home page: www.dccam.org*

# សេចក្តីសម្រេចនៅលើការចោទប្រកាន់របស់មេធាវី ការពារក្តីចំពោះភាពមិនប្រក្រតីនៅក្នុងដំណើរការស៊ើបអង្កេត

ក្រុមមេធាវីការពារក្តីករណី០០២ នៅអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាបានលើកឡើងដដែលៗអំពីភាពមិនប្រក្រតីនិងភាពមិនស៊ីសង្វាក់នៃវិធីសាស្រ្តថតសំឡេងបទសម្ភាសន៍របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតចំពោះមុខអង្គសវនាការ ។ កាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញផ្សាយជាសាធារណៈនូវសេចក្តីសម្រេចចំពោះសំណើចំនួនបួនរបស់ ក្រុមមេធាវី អៀង សារី ដែលចូលរួមពីក្រុមមេធាវីការពារក្តីផ្សេងៗទៀតនៅក្នុងករណី០០២ ដូចខាងក្រោមៈ

សំណើសុំឲ្យអ្នកបកប្រែភាសាដែលមានវត្តមាននៅក្នុងអំឡុងពេលដែលការិយាល័យសហចៅក្រមស៊ើបអង្កេតធ្វើបទសម្ភាសន៍ជាមួយ ភី ភួន មកផ្តល់សក្ខីកម្ម ពីព្រោះ «ខ្សែអាត់សំឡេងរបស់សាក្សី ភី ភួន ជាលើកទី២នោះមានលេចចេញនូវដំណាក់កាលដែលបទសម្ភាសន៍ត្រូវបានរៀបចំជាមុនចំពោះសំណួរ និងចម្លើយ ដោយយោងទៅលើការសម្ភាសន៍ដោយមិនមានថតសំឡេងកាលពីលើកមុន ដោយគ្រាន់តែអានដាក់ក្នុងប្រដាប់ថតសំឡេងដើម្បីបង្កើតឡើងនូវរូបភាពថា ការថតសំឡេងនោះវាឆ្លុះបញ្ចាំងអំពីការសម្ភាសន៍ជាក់ស្តែង ។

សំណើសុំឲ្យមានការបញ្ជាក់ពីសំណាក់ការិយាល័យសហចៅក្រមស៊ើបអង្កេតថា តើមានខ្សែអាត់សំឡេងនៅថ្ងៃទី១នៃបទសម្ភាសន៍ជាមួយសាក្សីឈ្មោះ អឿន តន និង នង សុផង ដោយក្រុមអ្នកស៊ើបអង្កេតដែរទេបើសិនជាមិនមាន តើដោយសារមូលហេតុអ្វី? ក្រុមមេធាវីការពារក្តីចង់ដឹងទៀតថា តើនរណាខ្លះមានវត្តមាននៅក្នុងអំឡុងពេលធ្វើបទសម្ភាសន៍នោះ ហើយតើបទសម្ភាសន៍នោះ មានរយៈពេលប៉ុន្មាន និងមានឯកសារអ្វីខ្លះដែលក្រុមអ្នកស៊ើបអង្កេតបានបង្ហាញសាក្សីទាំងនោះ ។

សំណើសុំ «បើកសវនាការជាសាធារណៈដើម្បីស៊ើបអង្កេតទៅលើការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលអនុវត្តការសម្ភាសដោយមិនមានថតសំឡេងជាមួយសាក្សី ។ បញ្ហានេះវាអាចប៉ះពាល់ដល់សេចក្តីថ្លែងការណ៍ និងការផ្តល់សក្ខីកម្មរបស់សាក្សីនៅក្នុងអង្គសវនាការ» ដោយហេតុថា ក្រុមមេធាវីការពារក្តីបានរកឃើញចំណុចបន្ថែមមិនប្រក្រតីចំនួន១២ ចំពោះការមិនមានថតសំឡេងសម្ភាសន៍សាក្សីនៅក្នុងសេចក្តីថ្លែងការណ៍ ។ សហព្រះរាជអាជ្ញាក៏បាននិយាយបញ្ហានេះជំនួសឲ្យសក្ខីកម្មសាក្សី ។

ក្រុមមេធាវី អៀង សារី បានសំអាងអំពីភាពមិនត្រឹមត្រូវរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្ត «ការជួបប្រជុំមិនផ្លូវការជាមួយសាក្សី ដើម្បីស្តាប់សាក្សីត្រូវនិយាយអ្វីខ្លះ មុននឹងថតសំឡេងសម្ភាសន៍ជាផ្លូវការ» ។ បញ្ហានេះវាបានទប់ស្កាត់កូនក្តីរបស់ពួកគេអំពីភាពតទល់គ្នាប្រកបដោយ «មូលដ្ឋាននៃភាពស្មើគ្នាចំពោះមុខច្បាប់ សិទ្ធិក្នុងការពិនិត្យមើលភស្តុតាងប្រឆាំងនឹងជនជាប់ចោទ និងការរៀបចំដើម្បីការពារខ្លួន ។

ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានបដិសេធថាការិយាល័យសហចៅក្រមស៊ើបអង្កេត មិនមានកាតព្វកិច្ចថតសំឡេងរាល់បទសម្ភាសន៍ ឬក៏រាល់បទសម្ភាសន៍ទេ ។ សហព្រះរាជអាជ្ញាក៏បានសង្កត់ធ្ងន់ថា ក្រុមមេធាវីការពារក្តីមានឱកាសគ្រប់គ្រាន់ដើម្បីលើកឡើងនូវការខ្វះចន្លោះនិតិវិធីនៅក្នុងអំឡុងពេលស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ។ វិធានផ្ទៃក្នុងនៅតុលាការខ្មែរក្រហមមិនអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តីលើកឡើងអំពីបញ្ហានេះនៅចំពោះមុខអង្គជំនុំជម្រះដែរ ។ ជាងនេះទៅទៀត ក្រុមមេធាវីការពារក្តីមានឱកាសដើម្បីសួរដេញដោលចំពោះសាក្សីចំនួនបីនាក់នៅក្នុងអង្គសវនាការ «ទាំងខ្លឹមសារសក្ខីកម្មរបស់សាក្សី និងនិតិវិធីដែលការិយាល័យសហចៅក្រម

ស៊ើបអង្កេតបានសម្ភាសន៍សាក្សី» ។ មិនមានសញ្ញាណាមួយលើកឡើងអំពីភាពមិនត្រឹមត្រូវដែលប្រព្រឹត្តដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ឬក៏ភាពមិនស៊ីចង្វាក់គ្នាទៅ លើការផ្តល់សក្ខីកម្មរបស់សាក្សីទាំងនោះទេ ។ ម្យ៉ាងទៀតក្រុមមេធាវីការពារក្តីអាចលើកបញ្ហាប្រឈមចំពោះការសម្រេចអំពីតម្លៃនៃសេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតដែលត្រូវទទួលយកធ្វើជាភ័ស្តុតាងជំនួសដល់ការផ្តល់សក្ខីកម្មផ្ទាល់មាត់ ។

នៅក្នុងសេចក្តីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ជាថ្មីថា មិនមានខ្សែអាត់សំឡេង ឬក៏វីដេអូ មានចែងនៅក្នុងបញ្ញត្តិច្បាប់នៃការសម្ភាសសាក្សីឡើយ ហើយក៏មិនមានចែងថាការថតសំឡេង បទសម្ភាសន៍នោះមានលក្ខណៈស្តង់ដាដោយតុលាការអន្តរជាតិដែរ ។ ទោះជាយ៉ាងណាក៏ដោយ តុលាការអន្តរជាតិមិនមានលក្ខណៈដូចគ្នាទាំងស្រុងទៅនឹងតុលាការខ្មែរក្រហមទេ ។ អង្គជំនុំជម្រះសាលាដំបូងទាញហេតុផលសំអាងថា តុលាការអន្តរជាតិមានភាគីដឹកនាំដំណើរការស៊ើបអង្កេតមួយនឹងមានឱកាសសម្រាប់ផ្ទៀងផ្ទាត់ដ៏វែងមាំនៅក្នុងអង្គសវនាការ ។ ផ្ទុយទៅវិញ នៅ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចស៊ើបអង្កេតឲ្យបានម៉ត់ចត់ស៊ើរតែទាំងស្រុង ។ ចំណែកឱកាសប្តឹងចោទប្រកាន់នៅចំពោះមុខអង្គជំនុំជម្រះគឺមានកម្រិត ។ ដូច្នេះភាពត្រឹមត្រូវនៃដំណើរការនិតិវិធី គឺពឹងផ្អែកយ៉ាងខ្លាំងទៅលើភាពឯករាជ្យ និងភាពមិនលម្អៀងរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ។ ជាងនេះទៅទៀត អង្គជំនំជម្រះសាលាដំបូងកត់សម្គាល់ថា «ការធានានីតិវិធីត្រូវបានអនុវត្តតាំងពីដំណាក់កាលស៊ើបអង្កេតមិនមានការបង្វែរ ឬពង្វាងឲ្យចេញពីភាពឯករាជ្យ និងភាពមិនលម្អៀងរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតឡើយ» ។ បញ្ហានេះវាកើតឡើងព្រមគ្នា ពីព្រោះសេចក្តីថ្លែងការណ៍ សាក្សីត្រូវរៀបចំស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហចៅក្រមស៊ើបអង្កេត ដោយ «ធានាអំពីភាពត្រឹមត្រូវតាមច្បាប់ និងភាពគួរឲ្យជឿទុកចិត្តបាន» ។ សហចៅក្រមស៊ើបអង្កេតត្រូវ «ទទួលបានសិទ្ធិអំពីការសន្មត់ទុកជាមុននៃភាពគួរឲ្យជឿទុកចិត្តបាន» ។ «ការប្រឆាំងជំទាស់ទាល់តែមានហេតុផល សមរម្យដែលត្រូវផ្តល់ដោយភាគីដែលគាំទ្រដោយភ័ស្តុតាងច្បាស់លាស់ថាសេចក្តីថ្លែងការណ៍នោះ ត្រូវចោទជាសំណួរថា មានភាពមិនគួរឲ្យទុកចិត្ត និងមិនមានភាពត្រឹមត្រូវ» ។

ទោះជាការថតជាខ្សែអាត់សំឡេង ឬក៏ថតជាវីឌីអូនៃសេចក្តីថ្លែងការណ៍សាក្សីមិនមែនជាបទបញ្ញត្តិដែលបានចែងនៅក្នុងវិធានផ្ទៃក្នុងរបស់តុលាការខ្មែរក្រហមតម្រូវឲ្យបំពេញក៏ដោយ «ក៏ការសរសេរកត់ត្រាគួរតែត្រូវធ្វើនូវរាល់ការសម្ភាសន៍» ពីព្រោះការិយាល័យសហចៅក្រមស៊ើបអង្កេតមិនបានធ្វើប្រតិចារិតចេញពីបទសម្ភាសន៍សាក្សីឡើយ ប៉ុន្តែជំនួសមកវិញការិយាល័យសហចៅក្រមស៊ើប អង្កេតបានសរសេរជាសង្ខេបនូវបទសម្ភាសន៍ និងអានសេចក្តីសង្ខេបនោះឲ្យសាក្សីពិនិត្យបញ្ជាក់ឡើងវិញ ។ ទោះជាបទសម្ភាសន៍នោះថតជាខ្សែអាត់សំឡេង ឬក៏ថតជាវីឌីអូ គឺវាមិនអាចប្រាប់រាល់ការទាក់ទងព័ត៌មានអំពីការសម្ភាសន៍មួយ ឬក៏ការសម្ភាសន៍មួយចំនួនដែលបានបញ្ចូលទៅក្នុងសេចក្តីថ្លែងការណ៍របស់សាក្សីឡើយ ។ ការជជែកឲ្យហេតុផលនេះ គឺរាល់នីតិវិធីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត វាជាប់ជាមួយនឹងភាពមិនល្អដែលនាំមកទៅរកការប្រព្រឹត្តខុស ទោះជាអចេតនាក៏ដោយ ។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ និងរំឭកឡើងវិញថា រាល់បញ្ហាប្រឈមចំពោះនីតិវិធីស៊ើបអង្កេតត្រូវតែយកមកនិយាយនៅក្នុងដំណាក់កាលស៊ើបអង្កេត ។ នៅក្នុងការសម្រេចចិត្តថ្មីៗរបស់អង្គជំនុំជម្រះបានបញ្ជាក់ឲ្យឃើញម្តងទៀតថា សំណុំរឿងដែលមានរាល់ភ័ស្តុតាងគឺជាអ្វីដែលត្រូវតែមាននៅក្នុងដៃរបស់ក្រុមមេធាវីការពារក្តី និងភាគីផ្សេងៗទៀត និងមាន «ឱកាសមួយចំនួនដើម្បីត្រួតពិនិត្យមើលព័ត៌មានដែលបានប្រមែប្រមូលមកនៅអំឡុងពេលស៊ើបអង្កេត» ដូចជាការស្នើសុំស៊ើបអង្កេតបញ្ហាប្រឈម និងការស្វែងរកនូវការទុកជាមោឃៈ «ផ្នែកខ្លះនៃដំណើរការស៊ើបអង្កេត» និងការអំពាវនាវរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតប្រាប់ទៅអង្គបុរេជំនុំជម្រះ ។ ដោយសារតែរាល់ «ទម្ងន់នៃ ការធានានីតិវិធីនោះ» វិធានផ្ទៃក្នុង៧៦(៧) ហាមគ្រប់ភាគីមិនឲ្យលើកឡើងបញ្ហាប្រឈមដែលទាក់ទងនឹងការខ្វះចន្លោះ ឬខុសនីតិវិធីនៅអំឡុងពេលស៊ើបអង្កេតនៅចំពោះមុខអង្គសវនាការ ។

ដូច្នេះអង្គសវនាការសាលាដំបូង គឺមិនបាន «គិតថា»

និងពិនិត្យមើលនូវភាពត្រឹមត្រូវតាមនីតិវិធីនៃការស៊ើបអង្កេត ឬក៏ពិនិត្យមើលឡើងវិញនូវការសម្រេចរបស់អង្គបុរេជំនុំជម្រះនោះឡើយ ។

តាមការពិតនៅអំឡុងពេលស៊ើបអង្កេតនោះ ក្រុមមេធាវី នួន ជា បានប្រឆាំងជំទាស់ទៅនឹង អង្គបុរេជំនុំជម្រះថា «វិធីដែលសហចៅក្រមស៊ើបអង្កេតសម្ភាសន៍សាក្សីធ្វើឲ្យមានការសៅហ្មង ដោយកំហុស និងភ្ញាំងភ្ញាត់ចំពោះបញ្ហាមួយចំនួនដែលនាំឲ្យមានការបរាជ័យក្នុងសេចក្តីថ្លែងរបស់សាក្សីអំពីប្រភពនៃចំណេះដឹង» និងការផ្តល់ព័ត៌មានអំពី «លក្ខខណ្ឌផ្សេងៗដែលត្រូវអនុវត្តក្នុងការធ្វើបទសម្ភាសន៍» រួមមាន តើឯកសារណាខ្លះត្រូវបានផ្លាស់ប្តូរ ។ ក្នុងនោះក៏បានសង្កត់ធ្ងន់ផងដែរនូវការលំបាកដែលបានជួបប្រទះនៅក្នុងការធ្វើឲ្យមានភាពសុក្រឹតផ្សេងៗនៃសេចក្តីសង្ខេបរបស់សាក្សី ដោយសារតែខ្វះការធ្វើប្រតិចារិកពីខ្សែអាត់សំឡេង ។ នៅក្នុងចំណោមវិធីដែលត្រូវដោះស្រាយបញ្ហាទាំងនេះ គឺគួរតែមានការសម្ភាសន៍សាក្សីខ្លះឡើងវិញ ។ ដោយសារតែការពិនិត្យមើលរបស់ក្រុមមេធាវីការពារក្តីនៅក្នុងអង្គសវនាការ គឺសម្ភាសន៍ខ្លះវាមិនមានលក្ខណៈត្រឹមត្រូវគ្រប់គ្រាន់សម្រាប់ការសម្រេចអំពីភាពគួរឲ្យជឿជាក់បានចំពោះសាក្សីដែលផ្តល់សក្ខីកម្ម និងកែតម្រូវនូវកំហុសនៅក្នុងសេចក្តីថ្លែងការណ៍ «នៅដំណាក់កាលស៊ើបអង្កេត» ។ ទោះបីជាយ៉ាងណាក្តី អង្គបុរេជំនុំជម្រះបានយល់ស្របជាមួយសហចៅក្រមស៊ើបអង្កេតថា ការស្នើឲ្យធ្វើសម្ភាសន៍សាក្សីឡើងវិញគួរតែត្រូវបដិសេធ ។ «នៅដំណាក់កាលអង្គសវនាការសាលាដំបូងនេះ គឺជាវេទិកាបន្ថែម និងឆ្លាស់សម្រាប់ក្រុមមេធាវីការពារក្តី ជំទាស់អំពីភាពគួរឲ្យជឿជាក់បាននៃភស្តុតាង ។

សេចក្តីសម្រេចថ្មីៗរបស់អង្គជំនំជម្រះសាលាដំបូងកត់សម្គាល់ចំពោះការិយាល័យសហចៅក្រមស៊ើបអង្កេត គឺ «ដើម្បីលើកយកមកពិចារណាឡើងវិញទៅលើបញ្ហាប្រឈមជាក់ស្តែងចំពោះបទសម្ភាសន៍សាក្សី» អង្គជំនុំជម្រះសាលាដំបូង គ្រាន់តែលើកឡើងថានេះជាផលវិបាកមួយដែលអង្គជំនំជម្រះនឹងអនុញ្ញាតដូចខាងក្រោមៈ

> *ភាពប្រឈមដាក់ស្តែង និងហេតុផលនៃការប្រឈម*
>
> *គឺការផ្តល់សក្ខីកម្មរបស់សាក្សីនៅក្នុងអង្គសវនាការដែលជាប់ពាក់ព័ន្ធនឹងភាពមិនស៊ីចង្វាក់គ្នារវាងការកត់ត្រាចេញពីខ្សែអាត់ និងខ្សែអាត់សំឡេងសម្ភាសន៍នៅក្នុងរយៈពេលធ្វើការស៊ើបអង្កេតត្រូវបានចោទប្រកាន់ ដែលត្រូវបានផ្តល់ថា គ្រប់ភាគីមិនមានឱកាសដើម្បីរកឲ្យឃើញភាពមិនប្រក្រតីមុនពេលអង្គសវនាការចាប់ផ្តើមធ្វើការងារ និងអ្វីដែលជាភាពមិនស៊ីសង្វាក់គ្នាដែលទាក់ទងទៅនឹងភាពមានតម្លៃក្នុងការវិនិច្ឆ័យដ៏ត្រឹមត្រូវចំពោះភស្តុតាង ឬក៏ភាពចាំបាច់ដើម្បីធានាភាពស្មើគ្នានៃដំណើរការនៅក្នុងអង្គជំនុំជម្រះ ។*

ទោះបីជាការសម្រេចជាផ្លូវការបានផ្តល់ឱកាសតិចតួចដល់ក្រុមមេធាវីការពារក្តីសម្រាប់លើកបញ្ហាប្រឈមនេះ ។ ជាពិសេសជាងនេះទៅទៀត អង្គជំនុំជម្រះបានបដិសេធការចោទប្រកាន់នៅពេលដែលមិនមានថតជាសំឡេងដោយមានបាត់ផ្នែកខ្លះៗនៅក្នុងឯកសារសរសេរដែលក្រុមមេធាវី អៀង សារី កំពុងចោទសួរអំពីបញ្ហានេះ ។ លើសពីនេះទៅទៀត អង្គជំនុំជម្រះហាមមិនឲ្យចោទសួរអំពីភាពមិនប្រក្រតីនេះ ។ តាមពិតទៅ មានការកត់សម្គាល់ ឬរកឲ្យឃើញបញ្ហានេះតាំងពីមុនការបើកសវនាការទៅទៀត ។ ជាថ្មីម្តងទៀត វាបានគ្រប់ដណ្តប់រាល់បញ្ហាប្រឈមដែលត្រូវក្រុមមេធាវីលើកឡើង ជាពិសេស អង្គបុរេជំនុំជម្រះបានពិភាក្សាអំពីការលើកឡើងខាងលើដោយនិយាយថា គ្រប់ភាគីអាចលើកឡើងបញ្ហាប្រឈមនេះឡើងវិញដោយផ្អែកទៅលើការផ្តល់សក្ខីកម្មរបស់សាក្សីនៅអង្គជំនុំជម្រះ ប៉ុន្តែ ពេលដែលក្រុមមេធាវីការពារក្តីស្នើសុំការត្រួតពិនិត្យឡើងវិញនោះត្រូវបានបដិសេធដោយអង្គបុរេជំនុំជម្រះ ។

ជំនួសដល់ការអនុញ្ញាតឲ្យមានការជំទាស់ ចំពោះការជឿទុកចិត្តចំពោះការចោទសួរសេចក្តីថ្លែងការណ៍របស់សាក្សី អង្គជំនុំជម្រះនឹងពិចារណារាល់ភាពមិនប្រក្រតីនៅក្នុងបទសម្ភាសន៍ពេលដែលតាំងចិត្តនៅក្នុងដំណាក់ការសម្រេចអំពីតម្លៃ និងទម្ងន់នៃភស្តុតាង ។ កាលពីលើកមុនអង្គជំនុំជម្រះ បានរកឃើញថាទោះជាសាក្សីម្នាក់ផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ប៉ុន្តែ

សិទ្ធិទទួលបានចំពោះសេចក្តីថ្លែងការណ៍សាក្សីរបស់សហចៅក្រមស៊ើបអង្កេតប្រហែលជាត្រូវ "មានតម្លៃតិចតួច ប្រសិនបើការសម្រេចថា តម្លៃ និងទម្ងន់នៃសេចក្តីថ្លែងការណ៍សាក្សីដែលបានដាក់ជូនសការផ្តល់សក្ខីកម្មផ្ទាល់មាត់នោះមានតម្លៃទាបខ្លាំង" ។ ការសម្រេចរបស់អង្គសវនាការថ្មីៗលើកយកគោលសំខាន់ៗអំពីឱកាសរបស់ក្រុមមេធាវីការពារក្តីសួរសំណួរទៅលើសាក្សីបីនាក់ចំពោះការិយាល័យសហចៅក្រមស៊ើបអង្កេតសម្ភាសន៍នៅអំឡុងពេលដែលសាក្សីទាំងនោះផ្តល់សក្ខីកម្មនៅអង្គសវនាការ និងកត់ត្រាថា មិនត្រឹមត្រូវ ឬទទួលយកបាន ត្រូវបានលើកឡើង ។

យោងតាមខ្សែអាត់សំឡេងរបស់លោក ភី ភួន ដែល "ស៊ីសង្វាក់គ្នារវាងអ្នកស៊ើបអង្កេត និងសាក្សីអានការសរសេរចម្លងចេញពីបទសម្ភាសន៍" ។ អង្គសវនាការបានយល់ស្របជាមួយនឹងក្រុមមេធាវីរបស់ អៀង សារី ថាវា "ជាការស្មុគស្មាញ និងបរាជ័យក្នុងគោលបំណងដើម្បីបង្កើតខ្សែអាត់សំឡេងមួយនៃការសម្ភាសន៍សាក្សី" ។ យ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ភាពមិនត្រឹមត្រូវគួរតែត្រូវលើកឡើងនូវដំណាក់កាលស៊ើបអង្កេតនៃដំណើរការនីតិវិធី ។ ដាងនេះទៅទៀត មិនត្រូវ "ធ្វើឲ្យខូចខាតដល់សមភាពនៃដំណើរការនីតិវិធី" ដូចដែលគ្រប់ភាគី និងសាក្សីបានពិភាក្សានៅក្នុងអង្គសវនាការ ។ ជាផលវិបាកអង្គសវនាការសាលាដំបូងបានបដិសេធនូវសំណើសុំឲ្យអ្នកបកប្រែភាសាដែលមានវត្តមាននៅអំឡុងពេលធ្វើបទសម្ភាសន៍មកធ្វើការសច្ចាថា ហេតុអ្វីបានជា "មានភាពសាំញ៉ាំ" តើត្រូវបានធ្វើតាមនីតិវិធីទេ ឬក៏ត្រូវស្តីបន្ទោស ។ ក្រុមមេធាវី អៀង សារី សុំឲ្យ "ស៊ើបអង្កេត" លើកបញ្ហានេះ ដោយនិយាយចំៗទៅលើសាក្សី "សំខាន់ៗ" មួយចំនួន ។

ទោះបីជាក្រុមមេធាវីការពារក្តីបានសួរសំណួរដល់សាក្សីបីនាក់អំពីការដែលសហចៅក្រមស៊ើបអង្កេតសម្ភាសន៍សាក្សីនៅចំពោះមុខអង្គសវនាការសាលាដំបូង ប៉ុន្តែក្រុមមេធាវីការពារក្តីមិនអាចសួរសំណួរសាក្សីអំពីថេរវេលានៃការសម្ភាសន៍បានទេ ដោយរយៈពេលផ្តល់សក្ខីកម្មនោះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចកាត់ម៉ោងក្រុមមេធាវីការពារក្តីក្នុងការចោទសួរដោយផ្ទាល់មាត់ឡើងវិញទៅលើសាក្សី ។ ក្រុមមេធាវីកាពារក្តីខំប្រឹងស្វែងរកព័ត៌មានបន្ថែមទាក់ទងនឹងនីតិវិធីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដោយចាត់ទុកថាការិយាល័យសហចៅក្រមស៊ើបអង្កេតមានចេតនាមិនត្រឹមត្រូវក្នុងការស្វែងរកជួបសាក្សីឡើងវិញ "ដោយប្រើនីតិវិធីមិនត្រឹមត្រូវ" ។ វាជាផលវិបាកដែលក្រុមមេធាវីការពារក្តីនិយាយថា ការបណ្តឹងជំទាស់របស់ខ្លួននោះមិនមានឱកាសគ្រប់គ្រាន់ ដើម្បីលើកបញ្ហាប្រឈមចំពោះការគ្មាននីតិវិធីសម្ភាសន៍ និងភាពគួរឲ្យទុកចិត្តនៃលទ្ធផលនៃការផ្តល់សក្ខីកម្ម ។ **អាន ហាញឌុល**

# ដំណឹងស្វែងរកសាច់ញាតិ

ឪពុករបស់ខ្ញុំឈ្មោះ ទៀ ទៀង តុង កើតនៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជាពីចន្លោះឆ្នាំ១៩៥៦ ដល់ឆ្នាំ១៩៦២ ។ សព្វថ្ងៃឪពុករបស់ខ្ញុំរស់នៅប្រទេសបារាំង ហើយគាត់មិនដែលត្រឡប់មកស្រុកកំណើតវិញទេ ។ គាត់បានបាត់បង់សមាជិកគ្រួសាររួមមាន ៖ ១) អ៊ុង ហ៊ុយ ត្រូវជាឪពុក ២) ទៀ សៀក ហ៊ួយ ត្រូវជាម្តាយ ៣) ទៀ ទៀង គ្រួន (ប្រុស) ៤) ទៀ ទៀង វេង (ប្រុស) ៥) ទៀ ហាយ ហួយ (ស្រី) ៦) ទៀ ហាយ ហុង (ស្រី) ។

***សូមបញ្ជាក់ថា*** ៖ ឈ្មោះទាំងអស់នេះខ្ញុំចាំមិនច្បាស់លាស់ទេ ។

ប្រសិនបើបើបងប្អូនណាស្គាល់ឈ្មោះដូចបានរៀបរាប់នេះ សូមមេត្តាទាក់ទងមកខ្ញុំបាទ តាមរយៈទូរស័ព្ទលេខ ៖ (+៣៣) ៦៦៤ ៨៩៦ ៤០០ ឬ អ៊ីម៉ែល ៖ tea.amelie@yahoo.fr, ១១០ គួរ ហ្វូរៀល, ៤២១០០ សាំង អេតែន, ប្រទេសបារាំង ។

***សូមអរគុណ!***

# កេរដំណែលផ្នែកច្បាប់ និងវប្បធម៌



ប៉ាំង ខាត់

គរុសិស្សស្រីវ័យក្មេងមួយរូប កំពុងបង្កើតប្រវត្តិសាស្ត្រនៅក្នុងវិធីជាច្រើនជាងអ្វីដែលគរុសិស្សរូបនេះអាចស្រមៃឃើញ ។ ផ្អែកទៅលើអាកប្បកិរិយារបស់គាត់តែមួយ អ្នកនឹងគិតថា គាត់ក៏មានអារម្មណ៍បែបនេះដែរ ។ ដោយបង្វិលប៊ិចសរសេរនៅដៃរបស់គាត់ហើយដើរទៅដើរមកនៅចំពោះមុខមិត្តភក្តិដទៃទៀតនៅក្នុងថ្នាក់រៀន គាត់ក្តាប់ប៊ិចណែននៅក្នុងដៃ ទប់ដង្ហើម ហើយដើរទៅចំកណ្តាលនៃថ្នាក់រៀន ។ សំឡេងជជែកគ្នានៅក្នុងថ្នាក់ បានចាប់ផ្តើមខ្សោយទៅៗ ហើយថ្នាក់ទាំងមូលបានត្រៀមខ្លួនរួចរាល់ដើម្បីចាប់ផ្តើមមេរៀនបាន ។ ស្ថិតក្នុងសម្លៀកបំពាក់អាវពណ៌លឿងខ្ចី និងសំពត់ពណ៌ខៀវវែង ជាមួយនឹងស្បែកជើង ប៉ាំង ខាត់ ដែលជាគរុសិស្សវ័យ២១ឆ្នាំ កំពុងឲ្យនិយមន័យនៃកេរដំណែលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

នៅក្នុងឆ្នាំ២០០៧ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដែលបានក្លាយទៅជាឯកសារគោលនៃកម្មវិធីសិក្សាអំពីអំពើប្រល័យពូជសាសន៍ថ្មីមួយ នៅក្នុងថ្នាក់មធ្យមសិក្សា ។ ខណៈពេលដែលគម្រោងនេះត្រូវបានកសាងឡើងជាមួយនឹងទ្រឹស្តីអប់រំ វាក៏ត្រូវបានទាញចេញពីយុត្តិធម៌អន្តរកាលដែរ ។ យុត្តិធម៌អន្តរកាលអាចត្រូវបានរៀបរាប់ថាជាដំណើរការ និងសកម្មភាពពេញលេញមួយដែលសង្គមមួយអាចទទួលយកដើម្បីដោះស្រាយជាមួយនឹងការរំលោភបំពានទាំងឡាយ នៅក្នុងអតីតកាល និងអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរបន្ទាប់ពីជម្លោះ ឬភាពចលាចលនយោបាយ ។ ដំណើរការដ៏អស្ចារ្យមួយនៅក្នុងទស្សនៈនេះ គឺការបង្កើតឲ្យមាននីតិរដ្ឋ ។

នីតិរដ្ឋគឺជាទស្សនៈ និងជាគោលការណ៍នៃអភិបាលកិច្ច ហើយនៅក្នុងនាមជាទស្សនៈមួយ នីតិរដ្ឋពឹងផ្អែកទៅលើប្រព័ន្ធតម្លៃជាក់លាក់មួយដែលពឹងផ្អែកទៅលើវប្បធម៌និងការអប់រំតាមមូលដ្ឋាន ។ ខណៈពេលដែលតុលាការ និងគណៈកម្មការស្វែងរកការពិតបានក្លាយទៅជាឧបករណ៍ទូទៅសម្រាប់សម្របសម្រួលទស្សនៈនេះ នៅក្នុងសង្គមក្រោយជម្លោះមួយ យន្តការទាំងនេះនៅមានកម្រិត ចំពោះលទ្ធភាព នៅក្នុងការអប់រំ និងការផ្លាស់ប្តូរ ។ នៅក្នុងន័យនៃសុទិដ្ឋិនិយម តុលាការអាចជាគំរូដ៏មានឥទ្ធិពលមួយ និងជាដំណាក់កាលមួយសម្រាប់ពន្យល់ និងលើកជាឧទាហរណ៍នូវចំណុច និងដំណើរការសំខាន់ៗ ដើម្បីសម្រេចឲ្យបាននូវយុត្តិធម៌ ការពិត និងនីតិរដ្ឋនៅក្នុងសង្គម ។ ប៉ុន្តែយើងត្រូវកត់សម្គាល់ថា ការបង្ហាញរបស់តុលាការត្រូវបានបំបែកចេញពីវប្បធម៌ដែលមានឥទ្ធិពល ។

គម្រោងស្តីអំពីការអប់រំ ទោះបីមិនមែនជាថ្នាំកែរោគគ្រប់មុខ មានលទ្ធភាពដើម្បីដោះស្រាយចន្លោះប្រហោងនេះបាន ។ គម្រោងស្តីអំពីការអប់រំអាចជំរុញឲ្យមាននីតិរដ្ឋដោយមិនត្រឹមតែបង្កើតឡើងនូវតម្លៃនិងដំណើរការដ៏សំខាន់ ដែលបង្កើតឡើងនូវគោលការណ៍ចម្បងសម្រាប់វិស័យយុត្តិធម៌អន្តរកាល ប៉ុន្តែថែមទាំងស្វែងរកនូវសំណួរស៊ីជម្រៅជាងមួយដែលតុលាការ និងគណៈកម្មការស្វែងរកការពិតមិនបានដោះស្រាយ ។ ជាពិសេស ការកាត់ក្តីតាមផ្លូវប្រវត្តិសាស្ត្រ ដោះស្រាយអ្វីដែលការកាត់ក្តីតាមផ្លូវតុលាការមានភាពខ្វះខាត ។

ចាប់តាំងពីឆ្នាំ២០០៩ ក្រសួងអប់រំ យុវជន និងកីឡា ដោយមានកិច្ចសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ចាប់ផ្តើម

ដាក់បញ្ចូលឡើងវិញ នូវប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងសាលារៀននិងសាកលវិទ្យាល័យ នៅទូទាំងប្រទេស ។ កម្មវិធីនេះត្រូវបានពង្រីកជាបន្តបន្ទាប់ ទៅដល់គរុសិស្សដូចជា ប៉ាំង ខាត់ បានចាប់ផ្តើមសាកល្បងបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅចំពោះមុខមិត្តភក្តិ និងគ្រូឧទ្ទេស ។ នេះគឺជាលើកទីមួយដែលប៉ាំង ខាត់ បង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ហើយតាមពិតគាត់បានរៀនប្រវត្តិសាស្ត្រនេះតែម្តងគត់នៅថ្នាក់ទី១១ ។ ទោះជាយ៉ាងនេះក្តី គាត់ត្រូវបានរំពឹងថា នឹងរៀនឲ្យបានច្រើនជាងការបង្រៀនប្រវត្តិសាស្ត្រនេះ ។ កម្មវិធីនៃវគ្គបណ្តុះបណ្តាលមានច្រើនណាស់ ។

គរុសិស្សមិនត្រឹមតែត្រូវសិក្សា ហើយក្លាយទៅជាអ្នកជំនាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ គរុសិស្សទាំងនេះក៏ត្រូវបានលើកទឹកចិត្តឲ្យបង្រៀនប្រវត្តិសាស្ត្រថ្មីនេះដោយប្រើប្រាស់វិធីសាស្ត្រដែលមានភាពខុសប្លែកអំពីវិធីសាស្ត្រដែលខ្លួនបានទទួលកាលពីអតីតកាល ។ ជាជាងរាយរ៉ាប់ទៅកាន់សិស្ស គ្រូត្រូវបានលើកទឹកចិត្តឲ្យផ្តល់សកម្មភាពដល់សិស្ស ដែលសិស្សអាចពិភាក្សា និងធ្វើការជាក្រុម ។ ជាជាងបំពេញខួរក្បាលសិស្សជាមួយនឹងចំណេះដឹងគ្រូត្រូវបានលើកទឹកចិត្តឲ្យបំពេញខួរក្បាលសិស្សជាមួយនឹងសំណួរ ។ ហើយជាជាងប្រាប់សិស្សឲ្យអាននិងចងចាំឈ្មោះ កាលបរិច្ឆេទ និងការពិត គ្រូត្រូវបានលើកទឹកចិត្តឲ្យសួរសិស្សអំពីអ្វីដែលសិស្សគិតអំពីរឿងរ៉ាវរបស់ជនរងគ្រោះម្នាក់ ឬអំពើរបស់ជនដៃដល់ម្នាក់ ។ ក្រៅពីកម្មវិធីប្រវត្តិសាស្ត្រគម្រោងនេះមានបំណងបង្កើតឡើងនូវមនសិការ អប់រំថ្មីមួយ ។

ប៉ុន្តែ ការចាប់ផ្តើមទាំងអស់នេះ នៅមានកម្រិតតូចនៅឡើយ ។ ខណៈពេលដែលគ្រូរាប់ពាន់នាក់ទទួលបានការបណ្តុះបណ្តាល ហើយសៀវភៅជាងប្រាំសែនក្បាលត្រូវបានចែកចាយគ្រូជាងប្រាំពីរពាន់នាក់ផ្សេងទៀតមិនទាន់ទទួលបានការបណ្តុះបណ្តាលនៅឡើយទេ ហើយសៀវភៅចំនួនប្រាំសែនក្បាលបន្ថែមទៀត ត្រូវការជាចាំបាច់ដើម្បីឲ្យសិស្សទាំងអស់នៅទូទាំងប្រទេសមានសៀវភៅសម្រាប់សិក្សា ។ ហើយសូម្បីតែអ្នកដែលទទួលបានការបណ្តុះបណ្តាលរួចហើយ នៅតែមិនទាន់មានអារម្មណ៍ល្អជាមួយនឹងវិធីសាស្ត្របង្រៀនថ្មីទាំងនេះទេ ។ ដូចអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរមានសំណួរអំពីកេរដំណែលនៃកម្មវិធីស្តីអំពីការអប់រំពីអំពើប្រល័យពូជសាសន៍ ។

ពាក្យកេរដំណែល គឺជាពាក្យដ៏ពេញនិយមនៅក្នុងស្ថាប័នជាច្រើន ដែលធ្វើការទាក់ទងនឹងនីតិរដ្ឋនៅកម្ពុជា ។ ស្នងការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស ពណ៌នាពាក្យកេរដំណែលថាជាឥទ្ធិពលដែលគ្មានទីបញ្ចប់មួយរបស់តុលាការនៅក្នុងការលើកកម្ពស់នីតិរដ្ឋ ។ កេរដំណែលអាចក្រសោបទាំងការអប់រំ និងសកម្មភាពដោយផ្ទាល់ ហើយទាក់ទងនឹងការផ្សព្វផ្សាយអំពីការអប់រំ មានអង្គការក្រៅរដ្ឋាភិបាលជាច្រើនដែលរួមទាំងស្នងការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សដែរ ដែលបានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលអំពីព័ត៌មានសាធារណៈ និងការបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីធានាឲ្យបាននូវកេរដំណែលច្បាប់ជាវិជ្ជមានសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ជាងនេះទៅទៀត មកត្រឹមខែកញ្ញា ឆ្នាំ២០១២ នេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានធ្វើបទបង្ហាញទៅកាន់សិស្សនិស្សិតជាងប្រាំមួយម៉ឺននាក់នៅទូទាំងប្រទេស ហើយអ្នកទស្សនាជាង៥ម៉ឺននាក់ បានចូលរួមនៅក្នុងដំណើរការកាត់ក្តីករណី០០២តែមួយ ។

នាពេលថ្មីៗនេះដែរ នៅក្រោមស្លាកកេរដំណែល សកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបាននាំមកជាមួយគ្នានូវអ្នកជំនាញ អ្នកអនុវត្ត និងអ្នកតស៊ូមតិ សម្រាប់ការពិភាក្សាមួយអំពីថា តើដំណើរការកាត់ក្តីរឿងព្រហ្មទណ្ឌនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចរួម ចំណែកដល់ច្បាប់កម្ពុជាបានដោយរបៀបណា ។ នៅក្រោមការគ្រប់គ្រងរបស់ឯកឧត្តម យូ ប៊ុនឡេង លោកបណ្ឌិត ដេវីដ ប៊យល៍ បានចែកចាយរបាយការណ៍មួយដែលមានចំណងជើងថា «កេរដំណែលនៃដំណើរការកាត់ក្តីរឿងព្រហ្មទណ្ឌនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅក្នុងច្បាប់កម្ពុជា» ។ នៅក្នុងគោលបំណងកម្រិតការពិភាក្សាជុំវិញរបាយការណ៍នេះ សន្និសីទដែលរបាយការណ៍ត្រូវបានចែកចាយនៅក្នុងឱកាសនោះ បានផ្តោតទៅលើនិតិវិធីច្បាប់ទស្សនាទាន និងកត្តាជម្រុញ ទោះបីជាកេរដំណែលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងមានវិសាលភាពធំជាងនេះ

ឆ្ងាយក្តី ។

ហួសពីបទដ្ឋាននិងនីតិវិធីច្បាប់អន្តរជាតិ មានសេចក្តីសង្ឃឹមថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងដើរតួនាទីជាកត្តាជំរុញសម្រាប់ចលនាវប្បធម៌ធំធេងជាងមួយដែលគោរពដល់ប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងនីតិរដ្ឋ ។ នៅក្នុងន័យនេះ ខណៈពេលដែលកិច្ចខិតខំប្រឹងប្រែងផ្តោតទៅលើកេរដំណែលផ្លូវច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា យើងនឹងយកចិត្តទុកដាក់ដើម្បីទទួលស្គាល់ថា បញ្ជីនៃបំណងប្រាថ្នា មានទំហំធំធេងជាងនេះ ហើយដូចដែលអ្នកចូលរួមម្នាក់នៅក្នុងសន្និសីទនៅឯសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចកត់សម្គាល់បញ្ហាចម្បងចំពោះមុខគឺការអនុវត្ត ។

ការអនុវត្តគឺជាគ្រឿងផ្សំដែលបាត់បង់សម្រាប់ប្រព័ន្ធច្បាប់ជាច្រើន ។ មានប្រព័ន្ធច្បាប់ជាច្រើន ដែលស្ថិតនៅលើក្រដាសដែលប្រកាន់ខ្ជាប់នូវបទដ្ឋានខ្ពស់បំផុតនៃដំណើរការនិងសិទ្ធិតាមផ្លូវច្បាប់ ប៉ុន្តែនៅក្នុងការអនុវត្តកម្រអនុវត្តបានណាស់ ។ ការនាំចូល ឬសម្របសម្រួលវប្បធម៌តាមផ្លូវច្បាប់មួយតម្រូវឲ្យមានស្ថានភាពត្រឹមត្រូវ ។ សង្គមមួយត្រូវតែមានលទ្ធភាពទទួលបានច្បាប់យកមកអាន ហើយមនុស្សម្នាក់ត្រូវតែយល់ថា តើច្បាប់អាចជួយ ឬធ្វើឲ្យខ្លួនឈឺចាប់ដោយរបៀបណា សម្រាប់ឲ្យច្បាប់មួយមានប្រសិទ្ធភាព ។

ជាពិសេស វប្បធម៌មួយត្រូវបានជំនួសដោយច្បាប់ ហើយបញ្ហានៃការអនុវត្តពឹងផ្អែកទៅលើកាយវិការដ៏យឺតនៃកត្តាជំរុញនិងដំណើរការដែលអណ្តែតខ្ពស់ខ្លាំងពីលើលទ្ធភាពសម្រេចឲ្យបានសម្រាប់តុលាការឬស្ថាប័នណាមួយ ។ វាមិនគួរមានការងឿងឆ្ងល់នោះទេដែលថា វាបានចំណាយពេលរាប់សតវត្សរ៍សម្រាប់ទ្វីបអឺរ៉ុបដើម្បីប្រឆាំងទៅនឹងរាជានិយមរបស់ខ្លួន ហើយមានសង្គ្រាមស៊ីវិលមួយនិងការតស៊ូរាប់សតវត្សរ៍មុនពេលជនជាតិអាមេរិកាំងដើមកំណើតអាហ្វ្រិកអាចរំដោះខ្លួនរួចពីក្រោមជើងក្រុមវណ្ណៈស្បែកសនៅភាគខាងត្បូងប្រទេសអាមេរិក ។

មានការលើកឡើងថា រយៈពេលប្រជាធិបតេយ្យប្រកបដោយការសម្រេចចិត្តដែលបានកើតឡើងនៅបស្ចិមប្រទេសចេញមកពីការប្រព្រឹត្តមកលើដោយហ្មត់ចត់ជាលើកដំបូងនៃប្រជាពលរដ្ឋសាមញ្ញក្នុងនាមជាប្រធានបទសម្រាប់ជាតំណាងនៃអក្សរសាស្ត្រ ។ នៅពេលដែលដំណើរការនៃការចង់ដឹងចង់ឮមានឥទ្ធិពលទៅលើមហាជន ហើយឧបករណ៍នៃការចង់ដឹងចង់ឮ ក្លាយទៅជាស្ថានភាពនៃប្រជាពលរដ្ឋសាមញ្ញ នៅពេលនោះ ប្រព័ន្ធឋានានុក្រមស្ថិតនៅក្រោមការត្រួតពិនិត្យ និងទស្សនៈដែលត្រូវបានប្រកាន់ខ្ជាប់ ជាយូរមកហើយ ទៅលើរបៀបដែលសង្គមមួយអភិបាលខ្លួនឯង ចាប់ផ្តើមមានការផ្លាស់ប្តូរ ។

ដូចជាតុលាការ នូរ៉េមប៊ឺក និងតុលាការក្រោយៗមកទៀត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងបង្កើតជាកំណត់សម្គាល់របស់ខ្លួន ហើយបាត់ខ្លួន ។ កេរដំណែលផ្លូវច្បាប់របស់តុលាការនេះនឹងពិតជាផ្អែកទៅលើអ្វីដែលតុលាការសម្រេចបាននៅក្នុងជីវិតដ៏ខ្លីរបស់ខ្លួន ក៏ដូចជាកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយដែលតុលាការនេះបានធ្វើនៅថ្ងៃនេះ និងថ្ងៃអនាគត ។ ប៉ុន្តែកម្លាំងជំរុញសម្រាប់ការផ្លាស់ប្តូរសង្គមនឹងមិនកើតមានឡើងតាមរយៈការវិនិច្ឆ័យ និងបទបញ្ញត្តិដ៏តូចចង្អៀតរបស់តុលាការនេះទេ ។ រយៈកាលប្រកបដោយការសម្រេចចិត្តនេះ ដែលរយៈកាលនៃការអនុវត្តនឹងកើតឡើងនៅពេលដែលចលនាទូលំទូលាយជាងមួយដែលជាចលនាដែលមាននៅក្នុងមនុស្សសាមញ្ញ បកស្រាយនិងឆ្លើយតប ។ ប្រវត្តិសាស្ត្រគឺជាម្ចាស់ប្រកបដោយភាពច្រណែនមួយ ហើយការផ្លាស់ប្តូរពិតប្រាកដតម្រូវឲ្យមានដំណើរ ដែលពិតជាមានបញ្ហាកម្រត្រូវបានទស្សន៍ទាយ ហើយជាញឹកញាប់ត្រូវបានយល់ខុសនៅថ្នាក់មូលដ្ឋាន ។

វានៅក្នុងថ្នាក់មូលដ្ឋាន ឬនៅក្នុងករណីនេះ ការអនុវត្តការបង្រៀនប្រកបដោយភាពក័យខ្លាចរបស់គរុសិស្សស្រីវ័យក្មេងដែលយើងនឹងអាចរកឃើញកម្លាំងជំរុញសម្រាប់ការផ្លាស់ប្តូរ ។ នៅក្នុងន័យនេះ ការធ្វើបទបង្ហាញរបស់ ប៉ាំង ខាត់ ទៅលើប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ មិនមែនត្រឹមតែជាចំណុចចម្បងមួយសម្រាប់អនាគតនៃការអប់រំរបស់ប្រទេសមួយប៉ុណ្ណោះទេ ប៉ុន្តែជាកេរដំណែលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កេរដំណែលដែលត្រូវបានសរសេរនាពេលបច្ចុប្បន្នមួយជំហានម្តងៗប្រកបដោយភាពភ័យខ្លាចនៅក្នុងថ្នាក់រៀនជាច្រើន បន្ទប់តុលាការនិងក្នុងផ្ទះគ្រួសារនៅពេលដែលយើងនិយាយ ។

**គ្រីស ឌៀរីង**

# ការចងក្រងឯកសារក្រោយពីអំពើឃោរឃៅកើតឡើង

*(តចប់)*

### *១.២) ការពិភាក្សាដេញដោលជុំវិញអធិបតេយ្យភាព និងបេតិកភណ្ឌជាតិ*

ការចូលរួមរបស់អង្គការសហប្រជាជាតិ និងរដ្ឋាភិបាលបរទេសបានលើកឡើងបញ្ហាអធិបតេយ្យភាព និងបេតិកភណ្ឌវប្បធម៌ ។ មានការលើកឡើងករណីប្រទេសអ៊ីរ៉ាក់ជាទីដែលឯកសារមួយចំនួនត្រូវយកចេញពីប្រទេស ឬត្រូវរក្សាដោយអង្គការក្រៅរដ្ឋាភិបាល ។ ក្នុងអំឡុងពេលសង្គ្រាមឈូងសមុទ្រឆ្នាំ១៩៩០-៩១ ក្រុមឧទ្ទាមឃើតបានរឹបអូសយកកំណត់ត្រារដ្ឋជិតប្រាំបីតោនរបស់របបបាតទីសរបស់ សាដាម ហ៊ូសេន ។ បន្ទាប់ពីការផ្តួលរលំ សាដាម ហូសេន ដែលដឹកនាំដោយអាមេរិកក្នុងឆ្នាំ២០០៣ ទីតម្កល់ឯកសារជាច្រើនថែមទៀតត្រូវគេរកឃើញ ។ សូម្បីតែមុនការឈ្លានពាន ក្រុមឃ្លាំមើលសិទ្ធិមនុស្សបានសង្កត់ធ្ងន់ពីសារសំខាន់នៃការរក្សាសុវត្ថិភាពឯកសារភស្តុតាងនៃអំពើឃោរឃៅរបស់ ហ៊ូសេន ។ ខែមេសា ឆ្នាំដដែល ក្រុមឃ្លាំមើលសិទ្ធិមនុស្សបានអំពាវនាវជាសាធារណៈដល់កងកម្លាំងសហរដ្ឋអាមេរិកដើម្បីការពារឯកសាររដ្ឋាភិបាលអ៊ីរ៉ាក់ពីការបំផ្លិចបំផ្លាញដោយហៅឯកសារទាំងនោះថាជាភស្តុតាងសំខាន់នៃអំពើឃោរឃៅរយៈពេល២៥ឆ្នាំ សម្រាប់ការចោទប្រកាន់ពេលអនាគត ហើយក្រុមឃ្លាំមើលសិទ្ធិមនុស្សពោលអះអាងថា គ្រួសារជាច្រើននៅអ៊ីរ៉ាក់ចាំបាច់ទទួលឯកសារទាំងនោះចំពោះអ្វីដែលកើតឡើងលើសាច់ញាតិដែលបាត់ខ្លួនរបស់ខ្លួន ។

យោធាអាមេរិក និងបុគ្គលិកសម្ងាត់បានរកឃើញឯកសាររាប់លានទំព័រនៃរបបបាតទីស ហើយបញ្ជូនឯកសារទាំងនោះទៅសហរដ្ឋអាមេរិកដើម្បីអភិរក្ស ។ អង្គការក្រៅរដ្ឋាភិបាលបានចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងប្រមូលឯកសារនេះដែរ ដូចជា មូលនិធិចងចាំប្រទេសអ៊ីរ៉ាក់ ដែលដឹកនាំដោយជនជាតិអ៊ីរ៉ាក់រស់នៅអាមេរិក ។ ខណៈពេលដែលអាជ្ញាធរបណ្តោះអាសន្នចម្រុះអាមេរិកកំពុងគ្រប់គ្រងប្រទេសអ៊ីរ៉ាក់ មូលនិធិចងចាំប្រទេសអ៊ីរ៉ាក់បានទទួលឯកសារបីលានទំព័រពីបន្ទប់ក្រោមដីរបស់មន្ទីរបក្សបាអាត (Ba'ath Party Headquarters) នៅទីក្រុងបាដាត ព្រមទាំងឯកសារចំនួនជាងពីរលានបួនសែនទំព័រដែលក្រុមឧទ្ទាមឃើតយកក្នុងឆ្នាំ១៩៩១ និងឯកសារ៧៥០.០០០ទំព័រ ដែលត្រូវបានយកក្នុងប្រទេសគុយវែត បន្ទាប់ពីសេរីភាពក្នុងឆ្នាំ១៩៩១ ។

មានភាពមន្ទិលតិចតួច ដែលកងកម្លាំងយោធាកាន់កាប់មានអំណាចស្របច្បាប់រឹបអូសយកឯកសារ ប៉ុន្តែការចូលរួមរបស់មូលនិធិចងចាំអ៊ីរ៉ាក់ និងការបញ្ជូនឯកសារទៅសហរដ្ឋអាមេរិកបង្កជាភាពចម្រូងចម្រាស ។ លោក កាណាន់ មាគីយ៉ា ដើមកំណើតអ៊ីរ៉ាក់ដែលក្រោយមកទទួលបានសញ្ជាតិអង់គ្លេសបានទទូចថាគាត់បានទទួលឯកសារដោយស្របច្បាប់ ហើយទទួលបានការយល់ព្រមពីឧបនាយករដ្ឋមន្ត្រីអ៊ីរ៉ាក់ និងការិយាល័យនាយករដ្ឋមន្ត្រី ហើយលោកនិយាយថា រដ្ឋាភិបាលអ៊ីរ៉ាក់ថ្មីខ្វះសមត្ថភាពគ្រប់គ្រងឯកសារ ។ នាយកទីតម្កល់ឯកសារនិងបណ្ណាល័យជាតិអ៊ីរ៉ាក់ លោក សាអាត អីសខានឌ័រ បានលើកឡើងថា ការគ្រប់គ្រងមូលនិធិចងចាំប្រទេសអ៊ីរ៉ាក់ គឺជាការខុសច្បាប់ ហើយរំលោភច្បាប់អ៊ីរ៉ាក់ និងសន្ធិសញ្ញាអន្តរជាតិដែលចែងថា កំណត់ត្រាសាធារណៈគឺជាផ្នែកនៃបេតិកភណ្ឌជាតិ ។ មូលនិធិចងចាំប្រទេសអ៊ីរ៉ាក់បានចុះហត្ថលេខាបន្តបន្ទាប់លើការយល់ព្រមបញ្ជូនឯកសារជាមួយវិទ្យាស្ថានហ៊ូវ័ររបស់សាកលវិទ្យាល័យស្តេនហ្វត ជាទីដែលវិទ្យាស្ថាននេះរក្សាឯកសាររហូតដល់ទីតម្កល់ឯកសារដ៏សក្តិសមមួយនៅប្រទេសអ៊ីរ៉ាក់ត្រូវបានគេកំណត់ ។

ខែកុម្ភៈ ឆ្នាំ២០០៥ សមាគមបណ្ណាល័យអាមេរិកបានអនុម័តសេចក្តីសម្រេចដែលចែងថា ឯកសារហ្នឹង តំណាងឲ្យការចងចាំសង្គមអ៊ីរ៉ាក់ ហើយថ្កោលទោសការរឹបអូសយកឯកសារដោយសហរដ្ឋអាមេរិក និងគាំទ្រយ៉ាងពេញទំហឹងលើការប្រគល់ឯកសារត្រឡប់ទៅវិញភ្លាមៗ ឆ្នាំ២០០៨ ឯកសារបានមកដល់វិទ្យាស្ថានហ៊ូវ័រ ។ សមាគមក្រុមអ្នកប្រមូលឯកសារសង្គមអាមេរិក

និងសមាគមអ្នកប្រមូលឯកសារកាណាដាបានចេញសេចក្ដីថ្លែងការណ៍សាធារណៈដោយអំពាវនាវរដ្ឋាភិបាលអាមេរិកឲ្យដាក់ឯកសារឲ្យស្របជាមួយច្បាប់អាមេរិក ដោយត្រូវប្រគល់ឯកសារទាំងនោះទៅទីតម្កល់ឯកសារ និងបណ្ណាល័យជាតិអ៊ីរ៉ាក់តាមដែលអាចធ្វើទៅរួច ។ ក្រសួងវប្បធម៌អ៊ីរ៉ាក់មិនបានឆ្លើយតបលើបញ្ហានេះទេ ។ ក្រសួងបានយល់ព្រមលើការបញ្ជូនឯកសារបណ្ដោះអាសន្នរវាងមូលនិធិចងចាំប្រទេសអ៊ីរ៉ាក់ និងវិទ្យាស្ថានហូវ័រ ។ វិទ្យាស្ថានហូវ័រ បានសង្កត់ធ្ងន់លើការយល់ព្រមបណ្ដោះអាសន្ន និងអត្ថប្រយោជន៍សំរាប់ការអភិរក្សឯកសារ ។

មានការគិតខុសគ្នាតិចតួចទាក់ទិននឹងឯកសារបុរាណតូរាស់ និងឯកសាររបស់ជ្វីហ្វដ៏កម្រដែលរឹបអូសដោយរបបសាដាម ហូសេន ពីប្រជាពលរដ្ឋក្នុងប្រទេសអ៊ីរ៉ាក់ ។ កងកម្លាំងអាមេរិកបានរកឃើញឯកសារនៅក្រោមទឹកក្នុងបន្ទប់ក្រោមដីរបស់អគារភ្នាក់ងារសម្ងាត់ក្រុងបាដាតក្នុងឆ្នាំ២០០៣ ហើយបានបញ្ជូនឯកសារទាំងនោះទៅសហរដ្ឋអាមេរិកដោយក្រុមដែលមកពីអង្គភាពគ្រប់គ្រងកំណត់ត្រា និងឯកសារជាតិអាមេរិក ដែលក្រោយមកបានចំណាយលុយរាប់រយពាន់ដុល្លារអាមេរិកដើម្បីសម្ងួត និងរក្សាឯកសារទាំងនោះក្នុងអគារទីក្រុងតិចសាសដោយយល់ព្រមប្រគល់ឯកសារត្រឡប់ទៅវិញក្នុងឆ្នាំ២០០៥ ។ ពេលដែលកិច្ចព្រមព្រៀងអស់ប្រសិទ្ធភាព លោក អ៊ីសកានទ័រ បានលើកឡើងថា កំណត់ត្រាទាំងនោះគឺជាសម្បត្តិវប្បធម៌អ៊ីរ៉ាក់ ហើយជាកម្មសិទ្ធិរបស់ទីតម្កល់ឯកសារអ៊ីរ៉ាក់ ។ លោកគំរាមថា នឹងប្ដឹងតុលាការ ប្រសិនបើកិច្ចខិតខំផ្លូវទូតបរាជ័យ ។ ក្រុមអ្នករិះគន់មានមន្ទិលសង្ស័យនឹងសមត្ថភាព ការពារ និងរក្សាឯកសាររបស់អ៊ីរ៉ាក់ ហើយអះអាងថា ឯកសារទាំងនោះគឺជាសម្បត្តិរបស់សហគមន៍ជ្វីហ្វដែលគេរំលោភបំពានជាជាងរបស់រដ្ឋ ។ ឯកសារទាំងនោះមិនមែនជាកំណត់ត្រាសាធារណៈទេ ប្រសិនបើរបប សាដាម ហូសេន រឹបអូសឯកសារដោយខុសច្បាប់ប្រទេសអ៊ីរ៉ាក់បច្ចុប្បន្ន មិនមានអំណះអំណាងលើរឿងនេះទេ ។

ការស្ទង់មើលបញ្ហាអធិបតេយ្យភាព និងបេតិកភណ្ឌវប្បធម៌ទាក់ទិននឹងការថ្លឹងថ្លែងបញ្ហា ។ ជនបរទេស និងអង្គភាពមិនមែនរដ្ឋាភិបាលមានមូលដ្ឋានដ៏ប្រសើរក្នុងការបង្កើត និងរក្សាទីតម្កល់ឯកសារ ។ យោធាអាមេរិកនិងអ្នកជំនាញមកពីអង្គភាពគ្រប់គ្រងកំណត់ត្រា និងឯកសារជាតិអាមេរិក និងមូលនិធិ ចងចាំប្រទេសអ៊ីរ៉ាក់ និងវិទ្យាស្ថានហូវ័រ បានរួមចំណែកជាច្រើនដល់ការរក្សាឯកសារដែលអាចបាត់បង់ក្នុងភ្លើងសង្គ្រាម ។ ទោះបីជាយ៉ាងនេះក៏ដោយ ទីតម្កល់ឯកសារដ៏រៀបរយមិនមានតម្លៃទេប្រសិនបើប្រជាជនមិនអាចទទួលបាននូវឯកសារទាំងនោះ ។ បញ្ហាផ្លូវច្បាប់ផ្អែកទាំងស្រុងលើលក្ខណៈត្រៀមរបស់ប្រទេសអ៊ីរ៉ាក់ក្នុងការគ្រប់គ្រងឯកសារ ។

របាយការណ៍របស់ការិយាល័យឧត្ដមស្នងការសិទ្ធិមនុស្សកាលពីឆ្នាំ២០០៩ ផ្ដល់ជាអនុសាសន៍ថា លើកលែងតែមានករណីធ្ងន់ធ្ងរ ការរក្សាឯកសារក្នុងប្រទេសដើមគឺប្រសើរជាងយកឯកសារទៅរក្សានៅក្រៅប្រទេស ។ វាផ្អែកអំណះអំណាងនេះទាំងស្រុងលើគំនិតដែលថា ប្រទេសដើមត្រូវកសាងសមត្ថភាពដើម្បីឆ្លើយតបនឹងតម្រូវការការប្រមូលឯកសារ ។ មានការពិចារណាផ្សេងគ្នាដែរលើការគាំទ្រ និងមិនគាំទ្រការយកឯកសារចេញពីប្រទេស ។ ស្ថានភាពខ្លះ ការយកឯកសារចេញពីប្រទេស ទាក់ទាញចំណាប់អារម្មណ៍សាធារណៈដែលថាឯកសារជនបរទេសកាន់អំណាចយកឬមិនយក ។ ផ្ទុយទៅវិញ ពេលដែលរដ្ឋាភិបាលមួយអស់ជំនឿគ្រប់គ្រងឯកសារ ការយកឯកសារចេញពីប្រទេសកាន់តែសក្ដិសម ។ ប៉ុន្មានឆ្នាំថ្មីៗនេះ ទីតម្កល់ឯកសារនិងបណ្ណាល័យជាតិរបស់អ៊ីរ៉ាក់បានចាត់វិធានការជាច្រើន ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួនដោយមានជំនួយពីទីតម្កល់ឯកសារអង់គ្លេស និងដៃគូអន្តរជាតិផ្សេងៗ ។ ខណៈដែលឯកសារថតចម្លងត្រូវគេរក្សានៅសហរដ្ឋអាមេរិក មានការលើកឡើងកាន់តែខ្លាំងចំពោះការប្រគល់ឯកសារដើមត្រឡប់ទៅវិញ ។ ពេលដែលទីតម្កល់ឯកសារមានសមត្ថភាពគ្រប់គ្រងឯកសារឲ្យមានប្រសិទ្ធភាព កន្លែងនោះគឺជាមូលដ្ឋានឯកសារក្នុងការស្វែងរកការពិត ។

## ៣) ការរៀបចំ និងការរក្សាឯកសារ

ទាក់ទងនឹងអ្នកដែលទទួលឯកសារអំពើឃោរឃៅពីអតីតលក្ខណៈពិសេសនៃឯកសារចំពោះការទទួលខុសត្រូវ និងការចងចាំជាប្រវត្តិសាស្ត្រផ្អែកលើរបៀបដែលឯកសារត្រូវបានរៀបចំនិងរក្សា ។ ទាំងនេះមានន័យថា ការត្រួតពិនិត្យឯកសារ ការបង្កើតបញ្ជីសារពើភ័ណ្ឌច្បាស់ ការរៀបចំបានត្រឹមត្រូវ និងការការពារពីការ

ប្រើប្រាស់ខុស និងការខូចខាត ។ ទាំងនេះគឺជាកាតព្វកិច្ចសំខាន់ជាច្រើនដែលត្រូវធ្វើដោយផ្អែកលើចំនួនឯកសារ ។ របបដែលធ្វើការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ជានិច្ចកាលមិនអាចរក្សាឯកសារបានល្អទេ ។ ពិតប្រាកដណាស់ ឯកសារពាក់ព័ន្ធជាច្រើនដែលគេស្វែងរកប៉ុន្មានទសវត្សរ៍ថ្មីៗនេះត្រូវគេរកឃើញក្នុងគំនរធំលើធ្នើរឬជាន់ដែលពុកផុយ ឬក្នុងអគារបោះបង់ចោល ។ ពីមួយថ្ងៃទៅមួយថ្ងៃ ការផ្សារប្រមូលឯកសារមិនបានទាក់ទាញចំណាប់អារម្មណ៍សាធារណៈដូចរឿងសម្តែង ឬ ការលាតត្រដាងនៃគំហើញពិសេសរបស់បន្ទប់តុលាការនោះទេ ។ ប៉ុន្តែវាជាយុទ្ធសាស្ត្រមូលដ្ឋានស្នូលក្នុងការចងក្រងឯកសារ ។

**ក) ការរៀបឯកសារតាមលំដាប់ដើម និងការថែរក្សាឯកសារជាបន្តបន្ទាប់**

ការរៀបចំទីតម្កល់ឯកសារប្រវត្តិសាស្ត្រសិទ្ធិមនុស្សឲ្យមានប្រសិទ្ធភាព ចាប់ផ្តើមជាមួយការបង្កើតមាតិកាតាមរយៈដំណើរការធ្វើបញ្ជីសារពើភ័ណ្ឌដ៏ប្រុងប្រយ័ត្ន ។ ទីតម្កល់ឯកសារត្រូវរៀបចំឲ្យបានល្អ ដូច្នេះហើយ អ្នកស្រាវជ្រាវអាចរកឯកសារបាន ហើយត្រូវមានប្រព័ន្ធមួយដែលជឿទុកចិត្តបានក្នុងការស្វែងរកឯកសារបន្ទាប់ពីឯកសារទាំងនោះបានរក្សាទុក ។ ផ្ទុយទៅវិញ ឯកសារដែលមានព័ត៌មានបទឧក្រិដ្ឋអាចត្រូវគេផ្លាស់ប្តូរ ឬបាត់បង់យ៉ាងងាយដោយសារតែការបំផ្លាញដោយចេតនា ឬ ការរៀបឯកសារខុសដោយមិនប្រុងប្រយ័ត្ន ។ ជំហានទាំងនេះមានសារសំខាន់ ប្រសិនបើតុលាការ ឬគណៈកម្មាធិការបានវិនិច្ឆ័យថា ឯកសារនោះត្រឹមត្រូវ ឬប្រសិនបើឯកសារទាំងនោះមានឥទ្ធិពលដល់ការវិភាគប្រវត្តិសាស្ត្រ ។

អ្នកចងក្រងឯកសារត្រូវធ្វើតាមគោលការណ៍ត្រឹមត្រូវនៃការរៀបចំឯកសារដើម ។ គោលការណ៍នៃប្រភពដើមឯកសារចែងថា ឯកសារដែលមានប្រភពពីស្ថាប័នផ្សេងមិនត្រូវដាក់បញ្ចូលគ្នាទេ ។ ឯកសារទាំងនោះគួរត្រូវចាត់ថ្នាក់យោងលើស្ថាប័នដែលបង្កើតប្រមូល និងរក្សាឯកសារទាំងនោះ ។ គោលការណ៍នៃការរៀបឯកសារតាមលំដាប់ដើមចែងថា ឯកសារគួរតែត្រូវរៀបចំតាមលំដាប់ដើមតាមដែលអាចធ្វើទៅបាន ។ ការរៀបតាមលំដាប់ដើមជួយក្នុងការរក្សាឯកសារជាបន្តបន្ទាប់ ។ ក្រៅពីនេះ របៀបដែលអង្គភាពរដ្ឋចាត់ថ្នាក់ឯកសារឆ្លុះបញ្ចាំងពីទំនាក់ទំនងយ៉ាងសំខាន់រវាងឯកសារ និងរចនាសម្ព័ន្ធអង្គភាព និងនីតិវិធីរបស់អង្គភាព ។

របាយការណ៍របស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សក្នុងឆ្នាំ២០០៩ដដែលបាននិយាយបញ្ជៀសពីសារសំខាន់នៃការរៀបឯកសារតាមលំដាប់ដើម ខណៈដែលរបាយការណ៍នេះបរិយាយការប្រើប្រាស់កំណត់ត្រាក្នុងដំណើរស្វែងរកយុត្តិធម៌ក្នុងសម័យអន្តរកាល ។

> ជំហានដំបូងក្នុងការប្រើប្រាស់កំណត់ត្រា ក្នុងដំណើរស្វែងរកយុត្តិធម៌ក្នុងសម័យ អន្តរកាលគឺត្រូវយល់ថា តើរដ្ឋគាបសង្កត់ធ្វើការយ៉ាងដូចម្តេច ។ បន្ទាប់មកត្រូវ យល់ពីទិដ្ឋភាពបីយ៉ាងដែលអង្គភាពប្រើកំណត់ត្រាដូចជា រចនាសម្ព័ន្ធរបស់អង្គភាព តួនាទីរបស់អង្គភាព និងកំណត់ត្រាដែលប្រើសម្រាប់អនុវត្តតួនាទី ។ វាជាការពិតដែលឯកសារជាកម្មសិទ្ធិរបស់រដ្ឋាភិបាល ឬក្រុមប្រឆាំង ឬយោធា ។ ការយល់ដឹងពីរចនាសម្ព័ន្ធ និងតួនាទី ជួយឲ្យយើងអាចវិនិច្ឆ័យពីលក្ខណៈពិត និងជំនឿទុកចិត្តរបស់ឯកសារដែលអាចប្រើជាភ័ស្តុតាង ។

ការរក្សាឯកសារតាមលំដាប់ដើម ងាយស្រួលក្នុងការស្តែងឲ្យឃើញថា ឯកសារទាំងនោះគឺត្រឹមត្រូវពីព្រោះឯកសារដទៃដែលរៀបតាមលំដាប់ដើម បង្កភាពងាយស្រួលក្នុងការកត់សម្គាល់តាមរយៈការមើលឯកសារយោង ឬអក្សរដើមឬតារាងរៀបតាមអក្ខរាវិរុទ្ធ ។

គម្រោងចងក្រងឯកសារ មានវិធានការជាច្រើនដែលដាក់ឯកសារពាក់ព័ន្ធឲ្យនៅស្ថិតក្រោមការគ្រប់គ្រងរបស់ទីតម្កល់ឯកសារជាតិដែលមានជំនាញក្នុងការរៀបចំ ។ ពេលដែលគម្រោងចងក្រងឯកសារខ្វះសមត្ថភាព គម្រោងទាំងនោះត្រូវការអ្នកពិគ្រោះយោបល់និងអ្នកជំនាញពីបរទេស ឧទាហរណ៍ អ្នកជំនាញមកពីសកលវិទ្យាល័យយែល និងសាកលវិទ្យាល័យញូសោវែលនៃប្រទេសអូស្ត្រាលីបានជួយបង្កើតប្រព័ន្ធរៀបចំបញ្ជីសារពើភ័ណ្ឌ និងចាត់ថ្នាក់ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីទសវត្សរ៍៩០ ។

គន្លឹះសំខាន់ផ្សេងទៀត សម្រាប់ចងក្រងឯកសារឲ្យបានល្អទាក់ទងនឹងគោលការណ៍រៀបឯកសារតាមលំដាប់ដើមគឺពិពណ៌នា

ពីការរក្សាឯកសារជាបន្តបន្ទាប់ ។ ការថែរក្សាឯកសារមានស្ថានទម្ងន់ដល់ការប្រើប្រាស់ឯកសារក្នុងបន្ទប់សវនាការ គណៈកម្មាធិការ និងការងារមានខ្លឹមសារផ្សេងៗ ។ ការដែលមិនរក្សាឯកសារឲ្យបានល្អអាចបង្កឲ្យមានការបាត់បង់ភ័ស្តុតាង ។

គម្រោងរៀបចំទីតម្កល់ឯកសារប៉ូលីសរបស់ប្រទេសហ្កាតេម៉ាឡា ផ្តល់ជាគំរូដ៏ល្អពីរបៀបដែលគោលការណ៍នៃការចងក្រងឯកសារបង្កើតមូលដ្ឋានសម្រាប់ការចែកចាយឯកសារនាពេលអនាគតក្នុងបន្ទប់សវនាការ ។ ឆ្នាំ២០០៥ ព្រះរាជអាជ្ញាការពារសិទ្ធិមនុស្សរបស់ប្រទេសហ្កាតេម៉ាឡា លោក សឺជីអូ មូរ៉ាលេស អាល់វ៉ារ៉ាដូ បានឆ្លើយតបនឹងពាក្យបណ្តឹងរបស់ប្រជាជនក្នុងសង្កាត់មួយអំពីសារធាតុផ្ទុះដែលគេទុកក្នុងស្ថានីយ៍ប៉ូលីស ។ ប៉ូលីសយល់ព្រមយកអាវុធចេញ ហើយពេលដែលលោក មូរ៉ាលេស មកមើលការយកអាវុធចេញ គាត់បានរកឃើញឯកសាររបស់ប៉ូលីសជាតិហ្កាតេមេឡា ដែលជាអង្គភាពមួយជាប់ពាក់ព័ន្ធនឹងសង្គ្រាមស៊ីវិលឃោរឃៅរបស់ប្រទេសនោះចន្លោះឆ្នាំ១៩៦៦ ដល់ឆ្នាំ១៩៩៦ រួចហើយសមាជិកអង្គភាពក៏បានបែកខ្ញែកគ្នាចាប់ពីពេលនោះមក ។ ភ្លាមៗនោះ លោក មូរ៉ាលេស បានទទួលដីកាបង្គាប់របស់តុលាការដែលអនុញ្ញាតឲ្យគាត់ស្វែងរកឯកសារសម្រាប់ភ័ស្តុតាង ការរំលោភសិទ្ធិមនុស្ស ។ ការត្រួតពិនិត្យពីខាងដើមលើកឡើងថា ឯកសារមានព័ត៌មានស្តីពីការធ្វើឃាត និងការបាត់ខ្លួនយ៉ាងច្រើនក្នុងប្រទេសហ្កាតេម៉ាឡា ។

ឯកសារទាំងនោះស្ថិតក្នុងសភាពពុកផុយ ហើយអ្នកអង្កេតការសិទ្ធិមនុស្ស ខេតតេ ដូយលី ដែលបានជួយក្នុងគម្រោងនេះបានបរិយាយពីស្ថានភាពយ៉ាងជាក់ច្បាស់ថាៈ

> *មានគំនរឯកសារដុះផ្សិត និងសំណុំឯកសារនៅលាយឡំគ្នាក្រោមគំនរបាក់បែកបេតុង ។ ឯកសារទាំងនោះពុកផុយដោយសើម ដោយពុកផុយ ខ្លះភ្លើងឆេះ ដោយដុះផ្សិតនិងដោយស្មៅ ។ ឯកសារទាំងនោះមានក្លិនស្អុយណាស់ ។ ជុំវិញខ្លួនយើងសុទ្ធតែខ្មោច សត្វល្អិត ហើយនិងអាចម៍ប្រចៀវ រោមសត្វ អាចម៍សត្វស្លាប និងស្នាមកណ្តុរកកេរ ។ ចៃដន្យអីយើងក៏ជាន់លើគំនរសម្រាម ដោយក្រោយពីយើងពិនិត្យមើលឲ្យ ហ្មត់ចត់ ក៏ឃើញរូបថតស-ខ្មៅរាប់ពាន់សន្លឹក ។ បុគ្គលិករបស់ព្រះរាជអាជ្ញាក៏ប្រមូលដាក់ក្នុងថង់ផ្លាស្ទិកស្អាតមួយ ។*

ឯកសាររាប់លាននៅពាសពេញអគារស្ថិតក្នុងសភាពពុកផុយ និងគ្មានសណ្តាប់ធ្នាប់ ។ ការរកឃើញនោះធ្វើឲ្យទាក់ទាញអ្នកព័ត៌មានជាតិ ហើយជនរងគ្រោះបានស្រែកតវ៉ាចង់បានឯកសារទាំងនោះ ។ ក្រុមអ្នកឃ្លាំមើលសិទ្ធិមនុស្សក្នុងតំបន់ សុខចិត្តធ្វើជាអ្នកស្ម័គ្រចិត្តសំរាប់ការងារនេះ ហើយជំនួយបរទេសក៏បានជួយព្រះរាជអាជ្ញាជួលបុគ្គលិកបន្ថែម ។

ដោយបារម្ភថារដ្ឋាភិបាលនឹងបិទកន្លែងនោះ ឬពួកដែលចង់កប់ប្រវត្តិសាស្ត្រ និងបំផ្លាញឯកសារចោល ការិយាល័យរបស់ព្រះរាជអាជ្ញាបានដាក់អាទិភាពលើការស្វែងរកការរំលោភបំពានសិទ្ធិមនុស្ស ។ បុគ្គលិករបស់ព្រះរាជអាជ្ញាបានញែកសំណុំឯកសារជាពីរហើយរៀបតាមលំដាប់ដើម ។ អ្នកចងក្រងឯកសារជនជាតិហ្កាតេម៉ាឡា និងអតីតប្រធានអ្នកចងក្រងឯកសារជនជាតិអាមេរិក ទ្រូឌី ភីធ័រសិន បានបណ្តុះបណ្តាលបុគ្គលិកជាច្រើនខែដើម្បីយល់ដឹងពីគោលការណ៍ការរៀបឯកសារតាមលំដាប់ដើម ។ ទីតម្កល់ឯកសារក៏បានបង្កើតប្រព័ន្ធស្វែងរកឯកសារ និងរក្សាឯកសារផងដែរ ។

ទីប្រឹក្សារបស់គម្រោងទីតម្កល់ឯកសារប៉ូលីសហ្កាតេម៉ាឡា បានប្រើយុទ្ធសាស្ត្រជាមូលដ្ឋានដែលទទួលប្រាក់ឧបត្ថម្ភជាច្រើន ។ ខែតុលា ឆ្នាំ២០១០ ប៉ូលីសហ្កាតេម៉ាឡាពីរនាក់ ត្រូវជំនុំជម្រះក្តីពីបទចាប់ជំរិត និងការធ្វើឲ្យបាត់ខ្លួនរបស់ ហ៊័រណាន់ដូ ហ្គារសៀ ក្នុងឆ្នាំ១៩៨៤ ដែលជាសកម្មជនរបស់ក្រុមនិស្សិតពលករ និងជាសមាជិកគណបក្សពលករហ្កាតេម៉ាឡាខុសច្បាប់ ។ សវនាការរបស់ហ្គារសៀ ពឹងផ្អែកយ៉ាងសំខាន់លើភ័ស្តុតាងពីទីតម្កល់ឯកសារប៉ូលីសជាតិ ។ ដូយលី គឺជាសាក្សីជំនាញដែលពិពណ៌នាលម្អិតពីអ្វីដែលនាងយល់លើឯកសារទាំងនោះ ។ ដូយលី លើកឡើងថា ការសម្រេចចិត្តរក្សាឯកសារតាមលំដាប់ដើមពីសំណុំឯកសាររបស់ប៉ូលីស គឺមានសារសំខាន់ក្នុងការយល់ដឹងពីការងារផ្ទៃក្នុងរបស់ប្រព័ន្ធប៉ូលីសហ្កាតេម៉ាឡា ។ ការរៀបចំឯកសារតាមលំដាប់ដើមនេះធ្វើឲ្យទីតម្កល់ឯកសារប៉ូលីសហ្កាតេម៉ាឡាកាន់តែមានប្រយោជន៍សំរាប់ការស៊ើបអង្កេតប្រវត្តិសាស្ត្រនិងផ្លូវច្បាប់ ។

ប្រទេសជិតខាងហ្កាតេម៉ាឡា គឺប្រទេសម៉ិចស៊ិចកូ ផ្តល់នូវ

ឧទាហរណ៍ផ្ទុយគ្នា ។ ឆ្នាំ២០០២ ប្រធានាធិបតី វីហ្សង់តេ ហ្វុក បានបោះជំហានឆ្ពោះទៅមុខចំពោះការទទួលខុសត្រូវដោយបាន បញ្ចុះបញ្ចូលយោធាប៉ូលីសនិងភ្នាក់ងារសម្ងាត់របស់ម៉ិចស៊ិចកូឲ្យ ផ្សាយឯកសាររាប់លានច្បាប់ដែលមួយចំនួននៃឯកសារទាំងនោះ មានព័ត៌មានទាក់ទិននឹងការរំលោភសិទ្ធិមនុស្ស ។ របាយការណ៍ ក្រុមប្រឹក្សាអន្តរជាតិស្តីពីទីតម្កល់ឯកសារប្រវត្តិសាស្ត្ររបស់ អង្គការយូណេស្កូ លើកឡើងថា ច្បាប់របស់ម៉ិចស៊ិចកូ គឺជាគំរូសម្រាប់ ការតែងច្បាប់នៃសិទ្ធិស្វែងរកការពិត ។ ទោះបីជាយ៉ាងនេះក៏ដោយ ការចងក្រងឯកសារមិនបានរៀបតាមលំដាប់អក្សរទេ ហើយច្បាប់ ទទួលបានឯកសារទាំងនោះមិនបានធ្វើឡើងជាសាធារណៈឡើយ ។ ក្នុងបរិបទនេះ អ្នកស្រាវជ្រាវមានការលំបាកក្នុងការទទួលបាន ព័ត៌មានដែលមានប្រយោជន៍សម្រាប់ការស៊ើបអង្កេតសិទ្ធិមនុស្ស ។ ឧទាហរណ៍របស់ប្រទេសម៉ិចស៊ិចកូគឺជាការក្រើនរំលឹកថា បទបញ្ញត្ត ផ្លូវច្បាប់ក្នុងការផ្សព្វផ្សាយព័ត៌មានគឺមិនគ្រប់គ្រាន់ទេ ។ ការចងក្រង ឯកសារសំរាប់ការទទួលខុសត្រូវទាមទារឲ្យមានការងារប្រមូល ឯកសារដោយលម្អិត និងការអនុវត្តច្បាប់និងបទបញ្ញត្តដែលគាំទ្រ ការទទួលបានឯកសារ ។

## ១) ការអភិរក្សឯកសារ

ឯកសារចាំបាច់ត្រូវការពារពីការលួច និងការបំផ្លាញដោយ មនុស្ស ព្រមទាំងការខូចខាតខាងរូបវន្ត ភ្លើងឆេះ ទឹកជំនន់ និង ហានិភ័យផ្សេងៗ ។ ការដាក់ពិន័យខាងផ្លូវច្បាប់ត្រូវធ្វើឡើងដើម្បី រារាំងការលួច និងការបំផ្លាញដោយចេតនា ។ គោលការណ៍របស់ ប៉ុតនេត-អូរេនលីចច័រ អះអាងថា វិធានការល្អិតល្អន់ និងការដាក់ ពិន័យគួរតែត្រូវបានអនុវត្តដើម្បីការពារការយកឯកសារចេញ ការបំផ្លាញ ការលាក់កំបាំង ឬការក្លែងបន្លំឯកសារ ជាពិសេសការ រួចទោសរបស់ជនល្មើសពីបទរំលោភសិទ្ធិមនុស្ស និងច្បាប់មនុស្ស ធម៌ ។ ប្រទេសកូឡុំបៀបានអនុម័តច្បាប់បង្កើតឲ្យមានវិធានការ ការពារ ការបំផ្លាញ ការយកឯកសារចេញឬការបន្លំឯកសារ ។

ឯកសារចាំបាច់ត្រូវការពារខាងរូបវន្តផងដែរ ។ ជាធម្មតា មានន័យថា ដាក់ឯកសារក្នុងកន្លែងដែលមានសុវត្ថិភាព និងដាក់ ឯកសារចាស់ៗជាសំណុំ ឬដាក់ក្នុងទូដែលមានការការពារពីកត្តា ផ្សេងៗ ។ ពេលដែលឯកសារត្រូវគេរកឃើញក្នុងសភាពជោគ ដោយទឹក ឬពុកផុយ ឯកសារទាំងនោះ ចាំបាច់ត្រូវសម្អាត ឬប្រើ មធ្យោបាយពិសេសផ្សេងសំរាប់ការពារ ។ ដោយសារតែមិនអាច ទប់ស្កាត់ ការខូចខាតឯកសារខាងរូបវន្ត វិធីសាស្ត្រផ្សេងៗមាន សារសំខាន់ផងដែររួមមាន ការថតចំលងឯកសារ មៃក្រូហ្វីល ការថតរូបឯកសារ និងការរក្សាឯកសារនៅកន្លែងទីពីរដូចជា ក្រៅ ប្រទេសដើម្បីការពារពី ការផ្លាស់ប្តូរនយោបាយក្នុងស្រុក ។

ទីតម្កល់ឯកសារបានប្រើវិធីសាស្ត្រផ្សេងៗដើម្បីការពារ ឯកសាររបស់ខ្លួន ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានសហការជាមួយ សកលវិទ្យាល័យយែល និងដៃគូអន្តរជាតិផ្សេងដើម្បីបង្កើតរូបភាព មៃក្រូហ្វីមរបស់ឯកសារ និងរក្សាឯកសារថតចម្លងនៅបរទេស ។ បច្ចុប្បន្នមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងព្យាយាមឲ្យដៃគូកែឯកសារ ទាំងអស់ឲ្យទៅជាប្រពន្ធ័បច្ចេកវិទ្យាដើម្បីបង្ហោះលើគេហទំព័រ ។ មូលនិធិចងចាំប្រទេសអ៊ីរ៉ាក់បានធ្វើការកែឯកសារឲ្យជាប្រព័ន្ធ បច្ចេកវិទ្យាផងដែរ ។ ការទុកឯកសារចម្លងក្នុងទីតាំងទីពីរដ៏មាន ប្រសិទ្ធភាពគឺជាគោលនយោបាយត្រឹមត្រូវដោយរួមមានការប្រើ ប្រាស់ទីតាំងនៅបរទេសពេលដែលប្រទេសទំនងជារងហានិភ័យ នៃការប្រែប្រួលផ្នែកនយោបាយភ្លាមៗ ។ មូលដ្ឋានប្រមូលឯកសារ ស្តីពីការចងចាំចាំបាច់ត្រូវការការពារ ។ របាយការណ៍របស់ ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សក្នុងឆ្នាំ២០០៩ ក៏គាំទ្រ ទស្សនៈនេះដែរ ។ ទោះបីជារបាយការណ៍នោះស្នើឲ្យមានការរក្សា ឯកសារដើមក្នុងប្រទេសក៏ដោយ ក៏របាយការណ៍នោះកត់សម្គាល់ ដែរថា «ការយកឯកសារដើមចេញពីប្រទេសគឺជាបញ្ហាដាច់ដោយ ឡែកគ្នាពីការទុកឯកសារចម្លងនៅក្រៅប្រទេស» របាយការណ៍ គាំទ្រការប្រើប្រាស់ទីតាំងតម្កល់ឯកសារទីពីររួមមានទាំងក្នុង និង ក្រៅប្រទេស ។

កិច្ចខិតខំប្រឹងប្រែងរៀបចំឯកសារឲ្យទៅជាប្រព័ន្ធឌីជីថល ដែលជួយរក្សា និងចែកចាយឯកសារអាចជួយក្នុងដំណើរការ វិភាគឯកសារ ។ ការពិតគឺស្តែងឲ្យឃើញក្នុងសវនាការ ហ៊័រណាន់ដូ ហ្គារសៀ ។ លោក ដាញែល ហ្គោសមែន មកពីក្រុមវិភាគទិន្នន័យ សិទ្ធិមនុស្សបេនទីតិចបានផ្តល់សក្ខីកម្មជំនាញដោយបង្ហាញការ វិភាគតាមស្ថិតិដូចជាការថតចម្លងឯកសារដែលបង្ហាញពីភាគរយ ខ្ពស់នៃភាពលម្អៀងផ្នែកឯកសារទាក់ទងនឹងករណីរបស់ ហ្គារ សៀ

ដែលបានបញ្ជូនទៅឲ្យអង្គភាពទទួលខុសត្រូវផ្នែកដឹកនាំ និងសម្របសម្រួលរបស់ប៉ូលីសជាតិ ។ ការវិភាគនោះគាំទ្រការអះអាងរបស់ព្រះរាជអាជ្ញាដែលថា ប៉ូលីសបានដឹងយ៉ាងច្បាស់ពីផែនការចាប់ជំរិត ហ្គារសៀ ។ ដូច្នេះហើយ បច្ចេកវិទ្យាឌីជីថល អាចជួយស្វែងរកលក្ខណៈពិសេសរបស់ឯកសារ បើទោះបីជាវារក្សាឯកសារទាំងនោះក្តី ។

**ក) ការរក្សា និងការចែកចាយឯកសារ**

ទោះបីជាមានជំនួយផ្នែកបច្ចេកវិទ្យាដល់ការរៀបចំ និងរក្សាឯកសារឲ្យមានប្រសិទ្ធភាព បច្ចេកវិទ្យាទាំងនោះត្រូវការថវិកា និងពេលវេលាជាច្រើន ។ ថវិកា និងពេលវេលាដែលទាមទារក្នុងការប្រមូលឯកសារបង្ហាញពីភាពលំបាកក្នុងដំណាក់កាលដំបូង ។ ការផ្តោតលើការរៀបចំឯកសារលើកឡើងពីការប្រគល់ឯកសារទៅឲ្យអ្នកចង់ក្រងឯកសារដែលត្រូវគេបណ្តុះបណ្តាលដើម្បីត្រួតពិនិត្យ និងចាត់ថ្នាក់ឯកសារតាមវិធីសាស្ត្រដែលមិនលម្អៀង ។ ការផ្តោតលើការស្វែងរកព័ត៌មានអំពីបុគ្គលឬការរំលោភបំពានណាមួយ អាចនាំទៅរកយុទ្ធសាស្ត្រផ្សេង ដូចដែលអ្នកស្រាវជ្រាវកំពុងស្វែងរកឯកសាររួចហើយ ក៏ទាញយកឯកសារនោះ ។ អ្នកគាំទ្រសិទ្ធិមនុស្ស អ្នកកាសែត អ្នកអង្កេត ជនរងគ្រោះ និងគ្រួសាររបស់ជនរងគ្រោះ មានបំណងចង់បន្តស្វែងរកព័ត៌មាន ហើយជារឿយៗអ្នកទាំងនោះមានហេតុផលក្នុងការស្វែងរកព័ត៌មានទាំងនោះ ។

ការអនុញ្ញាតឲ្យទទួល និងផ្សព្វផ្សាយព័ត៌មានមានការទាក់ទាញចំណាប់អារម្មណ៍យ៉ាងខ្លាំង ។ វាបានបំពេញតម្រូវការរបស់ជនរងគ្រោះ ហើយបានបញ្ជូនសញ្ញាណដែលថា របបថ្មីនឹងអាចមិនលាក់អតីតកាលជាសម្ងាត់ឡើយ ។ ការផ្សព្វផ្សាយព័ត៌មានបង្ហាក់លទ្ធភាពពួកប្រឆាំងពីការបំផ្លាញឯកសារ និងការរារាំងការលាតត្រដាងរឿងពិតដែលជាសមាជិកនៃរបបចាស់ដែលការរំលោភបំពានក្នុងរបបនេះត្រូវគេពិពណ៌នា ។ ជាងនេះទៅទៀត ការអនុញ្ញាតឲ្យមានការផ្សព្វផ្សាយឯកសារសំខាន់អាចទាញចំណាប់អារម្មណ៍សាធារណៈចំពោះការចងក្រងឯកសារដែលជួយដល់ការរៃអង្គាសប្រាក់គាំទ្រទីតម្កល់ឯកសារ ។ ការអនុញ្ញាតឲ្យអ្នកសារព័ត៌មាន និងក្រុមអ្នកឃ្លាំមើលសិទ្ធិមនុស្សផ្សព្វផ្សាយឯកសារសំខាន់ជួយជំរុញលើកទឹកចិត្តអ្នកទាំងអស់ក្នុងការស្វែងរកឯកសារ ហើយវាបានជម្រុះចោលគំនិតអសកម្មដែលថា ក្រុមទាំងនោះត្រូវប្រគល់ឯកសាររកឃើញទៅអ្នកចងក្រងឯកសារ ។

ការផ្តល់សិទ្ធិទទួល និងការគាំទ្រការផ្សព្វផ្សាយព័ត៌មានជួបហានិភ័យជាច្រើន ។ ប្រសិនបើការផ្សាយទាំងនោះធ្វើឡើងដោយមិនបានគ្រប់គ្រងហ្មត់ចត់ ឯកសារទាំងអស់អាចនឹងបាត់បង់ ជាពិសេសវាអាចបង្កជារឿងនយោបាយ ។ សាធារណៈមតិយល់ថា ឯកសារទាំងនោះត្រូវគេប្រើដើម្បីជួយបក្សពួកមួយក្តាប់តូចដោយធ្វើឲ្យអន់ថយលើជំនឿទុកចិត្តឯករាជ្យភាពនៃការប្រមូលឯកសារ ។ យុទ្ធសាស្ត្រជាមូលដ្ឋានមិនបានបញ្ជាក់ថា ឯកសារមិនគួរត្រូវគេផ្សព្វផ្សាយក្នុងដំណើរការប្រមូលឯកសារ ឬក៏ថាអង្គភាពទទួលបន្ទុកប្រមូលឯកសារគួរតែហាមឃាត់សាធារណជនពីការទទួលបានឯកសារទាំងមូល ។ ការធ្វើបែបហ្នឹង លើកឡើងជាទស្សនៈដែលប្រព័ន្ធថ្មីគឺជាប្រព័ន្ធបិទបាំង ហើយដូចប្រព័ន្ធចាស់ដែលធ្លាប់មាន ។ យុទ្ធសាស្ត្រជាមូលដ្ឋានបញ្ជាក់ទៀតថា ការផ្សព្វផ្សាយព័ត៌មានត្រូវពិនិត្យដោយអាជ្ញាធរមានសមត្ថកិច្ចដើម្បីធានាថា ការព្រួយបារម្ភពីឯកជនភាព និងមូលដ្ឋានច្បាប់ដទៃចំពោះការមិនផ្សព្វផ្សាយព័ត៌មានត្រូវបានពិចារណា ។ ទាំងនេះមានន័យផងដែរថា ការលើកស្ទួយចំពោះការផ្ទេរឯកសាររបស់អ្នកកាសែត អ្នកឃ្លាំមើលសិទ្ធិមនុស្ស ឬប្រជាជនសាមញ្ញ ទៅអង្គភាពចងក្រងឯកសារតាមដែលអាចធ្វើទៅបាន ។

ករណីមួយក្នុងប្រទេសប៉ារ៉ាហ្គាយ ផ្តល់ជាឧទាហរណ៍នៃវិធីសាស្ត្រជាមូលដ្ឋានដ៏ប្រសើរ ។ ខែធ្នូ ឆ្នាំ១៩៩២ មេធាវី ម៉ាទីន អាល់មាដា និងចៅក្រម ចូសេ អាហ្គូសស៊ីន ហ្វ័រណាន់ដេស បានរកឃើញឯកសាររាប់ពាន់ច្បាប់ក្នុងស្ថានីយ៍ប៉ូលីសសម្ងាត់ក្នុងក្រុងអាសុនស្យុង (Asuncion) បន្ទាប់ពីប៉ូលីសមួយរូប បានប្រាប់ព័ត៌មានសម្ងាត់ ។ ឯកសារទាំងនោះរួមមានព័ត៌មានអំពីការធ្វើទោស ការបាត់ខ្លួន និងអំពើឃោរឃៅផ្សេងដែលប្រព្រឹត្តដោយរបបយោធារបស់ឧត្តមសេនីយ៍ អាល់ហ្វ្រេដូ ស្ត្រូសស្ន័រ ក្នុងប្រតិបត្តិការខុនដូ (Operation Condor) ។ តុលាការនៃប្រទេសប៉ារ៉ាហ្គាយ បានរឹបអូសយកឯកសារដោយបង្កឲ្យមានការស្រែកតវ៉ាយ៉ាងខ្លាំងពីជនរងគ្រោះ និងអ្នកគាំទ្រសិទ្ធិមនុស្សដែលបារម្ភថា ចៅក្រមពុករលួយនឹងបន្តលាក់កំបាំងរឿងពិតនិងអតីតកាលដូចដែលអង្គនីតិ

ប្រតិបត្តិនិងសហរដ្ឋអាមេរិកបានលើកឡើង ។

ដោយសារតែមានការគាំទ្រពីអង្គការយូណេស្កូ តុលាការកំពូលនៃប្រទេសប៉ារ៉ាហ្គាយបានបង្កើតមជ្ឈមណ្ឌលឯកសារស្តីពីការការពារសិទ្ធិមនុស្ស ។ មជ្ឈមណ្ឌលឯកសារស្តីពីការការពារសិទ្ធិមនុស្សបានបង្កើតទិន្នន័យរបស់ឯកសារស្តីអំពីអំពើឃោរឃៅហើយបាននាំយកអ្នកជំនាញខាងឯកសារមកចាត់ថ្នាក់ និងធ្វើបញ្ជីសារពើភ័ណ្ឌឯកសារ ។ តុលាការបានបោះជំហានក្នុងការរក្សាឯកសារចាត់ថ្នាក់ឯកសារ៦០,០០០ច្បាប់ កែឯកសារ៣០០,០០០ច្បាប់ឲ្យទៅជាប្រព័ន្ធបច្ចេកវិទ្យា ហើយក្រោយមកបានចែកចាយព័ត៌មានអំពីឯកសារទាំងនោះ ។ ឯកសារទាំងនោះបានក្លាយជាផ្នែកមួយនៃគម្រោងចងចាំពិភពលោក ហើយបានរួមចំណែកយ៉ាងសំខាន់ដល់ដំណើរស្វែងរកការពិត និងយុត្តិធម៌ក្នុងឆ្នាំ២០០៤ និងការលាតត្រដាងអំពីការរំលោភសិទ្ធិមនុស្សដោយរបបលោក ស្ត្រូសស្ន័រ និងរដ្ឋាភិបាលផ្សេង ។ មជ្ឈមណ្ឌលឯកសារស្តីពីការការពារសិទ្ធិមនុស្សធានាផងដែរថា ឯកសារប្រើក្នុងតុលាការគឺត្រឹមត្រូវ ។ ការធានាទាំងនោះរួមមានការវិភាគឯកសារខាងផ្លូវវិទ្យាសាស្ត្រ និងការរក្សាបញ្ជីសារពើភ័ណ្ឌដែលស្វែងរកឯកសារដោយផ្ទាល់ក្នុងអគារប៉ូលីសជាទីដែលឯកសារទាំងនោះត្រូវបានរកឃើញក្នុងឆ្នាំ១៩៩២ ។ កេរដំណែលនៃគម្រោងគឺឯកសារមួយចំនួនមានមូលដ្ឋានច្បាប់រឹងមាំ ។ ឯកសារស្តីអំពីអំពើឃោរឃៅត្រូវបានតុលាការកំពូលគ្រប់គ្រងយ៉ាងមានសុវត្ថិភាព ហើយមិនត្រូវបានយកមកដេញដោលក្នុងតុលាការទេ ឯកសារទាំងនោះត្រូវបានរៀបចំ និងរក្សាដើម្បីគាំទ្រការស្រាវជ្រាវប្រវត្តិសាស្ត្រ និងការស៊ើបអង្កេតពេលអនាគត ។

## ឃ) ការបង្កើតច្បាប់ទទួល និងផ្សព្វផ្សាយព័ត៌មាន

ឯកសារជាប្រវត្តិសាស្ត្រមានឥទ្ធិពលក្នុងការលើកស្ទួយការចងចាំនៃការរំលោភបំពានពីអតីត ។ ក្នុងទិដ្ឋភាពជាសាធារណៈ ឯកសារអាចបម្រើជាមូលដ្ឋានសម្រាប់ការផ្សាយមានខ្លឹមសារ ការតាំងបង្ហាញនៅសារមន្ទីរ ឬការធ្វើកំណែទម្រង់របស់សៀវភៅសិក្សា ។ តាមរយៈការផ្តល់ព័ត៌មានអំពីការរំលោភបំពាន ឯកសារទាំងនោះអាចជួយឆ្លើយសំណួរអំពីការព្រួយបារម្ភរបស់ជនរងគ្រោះ និងគ្រួសារ ។ ដូច្នេះហើយ គោលនយោបាយក្នុងការចែកចាយព័ត៌មាន គឺមានសភាពមុតមាំណាស់ ។ ទោះបីជាយ៉ាងនេះក៏ដោយ យុទ្ធសាស្ត្រ ជាមូលដ្ឋានបញ្ជាក់ពីការបង្កើតច្បាប់ទទួលបានព័ត៌មានដែលពិចារណាពីតម្រូវការសម្រាប់ការផ្សព្វផ្សាយព័ត៌មានស្របទៅនឹងផលប្រយោជន៍ផ្លូវច្បាប់ដទៃ ជាពិសេស សន្តិសុខឯកជន និងសន្តិសុខជាតិ ។ សេចក្តីតម្រូវរបស់ច្បាប់នេះអនុវត្តចំពោះទីតម្កល់ឯកសារ និងក្រុមអង្គការសិទ្ធិមនុស្សដែលពាក់ព័ន្ធ ។

មានហេតុផលពីរស្តីពីច្បាប់និងយុទ្ធសាស្ត្រក្នុងការថ្លឹងថ្លែងគោលដៅ ។ ខាងផ្លូវច្បាប់ សិទ្ធិស្វែងរកការពិតមិនកើតឡើងដោយឯកឯងទេ ។ ឯកជនភាពគឺជាសិទ្ធិមនុស្សស្នូលដែលដាក់តម្កល់ក្នុងច្បាប់អន្តរជាតិនិងរដ្ឋធម្មនុញ្ញជាតិ ហើយការផ្តល់នូវសន្តិសុខជាតិគឺត្រូវគេចាត់ទុកថាជាតួនាទីរបស់រដ្ឋដែលមិនពាក់ព័ន្ធការរំលោភសិទ្ធិមនុស្ស ។ ការពិចារណាឲ្យល្អិតល្អន់ពីបញ្ហាសន្តិសុខ និងឯកជនភាពជួយបង្អាក់ការជំទាស់ខាងនយោបាយលើកិច្ចប្រឹងប្រែងចងក្រងឯកសារ ។

## ង) បញ្ហាឯកជនភាព

ការបង្អាក់ផ្លូវច្បាប់ចំពោះការផ្សព្វផ្សាយព័ត៌មានទាក់ទិននឹងឯកជនភាព ជាពិសេសឯកជនភាពរបស់ជនរងគ្រោះនៃការរំលោភបំពានរបស់រដ្ឋ ។ ក្រៅពីមានការបញ្ជាក់ពីសាធារណមតិក្នុងស្រុកជាច្រើន សិទ្ធិឯកជនភាពផ្អែកលើលិខិតុបករណ៍អន្តរជាតិមួយចំនួន រួមមានសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងអនុសញ្ញាអ៊ឺរ៉ុបស្តីពីសិទ្ធិមនុស្ស ។

ទីតម្កល់ឯកសារមួយចំនួនមិនព្រមផ្តល់ឯកសារដល់សាធារណជន ដោយសារតែការបារម្ភអំពីឯកជនភាព ។ ឧទាហរណ៍ អង្គភាពស្វែងរកព័ត៌មានអន្តរជាតិដែលបង្កើតឡើងក្នុងទីក្រុងឡុងឆ្នាំ១៩៨៣ ហើយពីរឆ្នាំក្រោយបានផ្លាស់ប្តូរទីតាំងទៅអាល្លឺម៉ង់ដើម្បីជួយសាច់ញាតិជនរងគ្រោះណាហ្ស៊ី ស្វែងរកព័ត៌មានអំពីអ្នកជាទីស្រឡាញ់របស់ខ្លួន ។ អង្គភាពនេះបានផ្តល់ឯកសារជាច្រើនដល់សាធារណជនទូទៅអស់ពេលជាង៦១ឆ្នាំដោយបានលើកឡើងពីការព្រួយបារម្ភអំពីឯកជនភាពរបស់ជនរងគ្រោះ ។ មូលនិធិចងចាំប្រទេសអ៊ីរ៉ាក់ប្រឆាំងនឹងការផ្សព្វផ្សាយឯកសាររបស់ប្រទេសអ៊ីរ៉ាក់ដល់សាធារណជន ដោយលើកឡើងថា ការផ្សព្វផ្សាយនឹងធ្វើឲ្យមហន្តរាយដល់សន្តិសុខ ហើយរំលោភសិទ្ធិបុគ្គលរួមមាន សិទ្ធិឯកជនភាព ។ នៅ

ប្រទេសប៉ារ៉ាហ្គាយ ឯកសារមួយចំនួនក្នុងសំណុំឯកសារស្តីអំពីអំពើឃោរឃៅបានបង្កឲ្យមានការព្រួយបារម្ភចំពោះឯកជនភាពជាពិសេសអ្នកដែលប្រាប់ឈ្មោះអ្នកផ្តល់ព័ត៌មានសម្ងាត់របស់រដ្ឋាភិបាល និងជនសង្ស័យស្រឡាញ់ភេទដូចគ្នា ។ ច្បាប់ទទួលបានព័ត៌មានរបស់ប្រទេសប៉េរូ រួមមាន ការមិនទទួលបានសិទ្ធិព័ត៌មានបុគ្គលដែលអាចជ្រៀតជ្រែកឯកជនភាពបុគ្គល ឬគ្រួសារពេលដែលព័ត៌មានត្រូវផ្សព្វផ្សាយ ។ ច្បាប់នោះលើកឡើងពីព័ត៌មានសុខភាពជាពិសេស ហើយកត់សម្គាល់ថា មានតែចៅក្រមប៉ុណ្ណោះមានសិទ្ធិផ្សព្វផ្សាយព័ត៌មាននោះដោយអនុលោមតាមការកំណត់របស់រដ្ឋធម្មនុញ្ញ ។

ទោះបីជាមានការបញ្ជាក់ដែលថា ទីតម្កល់ឯកសារគួរតែពិចារណាពីឯកជនភាព ប៉ុន្តែនៅមានចំណុចពិភាក្សាដេញដោលពាក់ព័ន្ធនឹងថាតើឯកជនភាពជាអ្វី និងវិធានការដាក់ច្បាស់ដែលការពារសិទ្ធិឯកជនភាព ជាពិសេសនៅពេលដែលទីតម្កល់ឯកសារអាចលាតត្រដាងរឿងសម្ងាត់អំពីការរំលោភសិទ្ធិមនុស្ស ។ របាយការណ៍របស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សក្នុងឆ្នាំ២ ០ ០ ៩ បានសង្កត់ធ្ងន់ការទាមទាររបស់ច្បាប់ការពារទិន្នន័យ និងឯកជនភាពដែលទាក់ទងការប្រមូលឯកសារ ប៉ុន្តែរបាយការណ៍នោះមិនបានបញ្ជាក់ពីការកម្រិតព្រំដែនទេ ។ បទដ្ឋានឯកជនភាពមានដូចជាអត្តសញ្ញាណបុគ្គលក្នុងឯកសារប្រភេទទិន្នន័យដែលត្រូវបង្ហាញអត្តសញ្ញាណនៃភាគីដែលស្នើសុំព័ត៌មាន និងពេលវេលាចាប់តាំងពីឯកសារត្រូវបង្កើត ។

ការពិចារណាដំបូង គឺទាក់ទិននឹងអត្តសញ្ញាណបុគ្គលក្នុងឯកសារ ។ច្បាប់ និងរបាយការណ៍អន្តរជាតិ មាននិន្នាការការពារជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សពីការរំលោភឯកជនភាព ប៉ុន្តែពួកមន្ត្រីដែលធ្វើការឲ្យរបបជិះជាន់ ឬជាសហការីមិនទទួលបានការការពារបែបហ្នឹងទេ ។ គោលការណ៍ ចុតនេត-អូរេនលីចច័របានធ្វើការគូសបញ្ជាក់ផ្សេងគ្នាថា “ការទទួលបានព័ត៌មានគួរតែត្រូវបានគាំទ្រចំពោះផលប្រយោជន៍នៃការស្រាវជ្រាវប្រវត្តិសាស្ត្រដោយអនុលោមតាមការដាក់កំហិតសមហេតុផលក្នុងន័យការពារឯកជនភាពឬសន្តិសុខរបស់ជនរងគ្រោះនិងបុគ្គលផ្សេង” ។ ប្រសិនបើអានឲ្យស៊ីជម្រៅបទបញ្ញត្តិនេះ ពង្រីកវិសាលភាពការពាររហូតដល់អ្នកប្រព្រឹត្តអំពើល្មើសផងដែរ ទោះបីជា ពាក្យពេចន៍បានផ្តោតលើបុគ្គលផ្សេងដែលមិនបំរើការងាររដ្ឋ ។ របាយការណ៍ក្រុមប្រឹក្សាអន្តរជាតិស្តីពីទីតម្កល់ឯកសារប្រវត្តិសាស្ត្ររបស់អង្គការយូណេស្កូក្នុងឆ្នាំ២ ០ ០ ៩ ទាញចំណាប់អារម្មណ៍ជនរងគ្រោះជាច្រើនក្រុមដែលគួរទទួលបានការការពារឯកជនភាព ៖

> *គួរចាត់វិធានការដើម្បីបញ្ចៀសការបង្កគ្រោះថ្នាក់បន្ថែមដល់ជនរងគ្រោះ សាក្សី ឬបុគ្គលដទៃ និងដើម្បីបញ្ចៀសការបង្កើតហានិភ័យដល់សន្តិសុខជាពិសេសដើម្បីការពារសិទ្ធិឯកជនភាពរបស់ជនរងគ្រោះនៃការរំលោភផ្លូវភេទ និងការពារសិទ្ធិឯកជន ភាពរបស់កុមារ និងមនុស្សពេញវ័យដែលជាជនរងគ្រោះនៃក្រុមអ្នកលេងប្រដាប់អាវុធ ។*

ច្បាប់ស្តីពីទីតម្កល់ឯកសារសន្តិសុខជាតិរបស់ហុងគ្រី បានគូសបញ្ជាក់ភាពខុសគ្នាផងដែរ ។ ច្បាប់នោះមានការគ្រប់គ្រងលើឯកជនភាពយ៉ាងតឹងរ៉ឹងសម្រាប់ទីតម្កល់ឯកសារដែលរារាំងសាធារណជនពីការទទួលបានឯកសារលើកលែងតែមានការយល់ព្រមពីសាមីបុគ្គលឬចាំបាច់ក្នុងការកំណត់អត្តសញ្ញាណមន្ត្រីឬអ្នកជាប់ពាក់ព័ន្ធក្នុងរបបជិះជាន់ ។

ច្បាប់ចងចាំជាតិស្លូវ៉ាគីប្រព្រឹត្តដាក់ប្រជាជនសាមញ្ញខុសពីមនុស្សដែលបម្រើការក្នុងរបបគាបសង្កត់ ។ បទបញ្ញត្តិឯកជនភាពរបស់ច្បាប់នេះចែងថា ទីតម្កល់ឯកសារត្រូវលុបចោលទិន្នន័យផ្ទាល់របស់បុគ្គលរួមមាន ទិន្នន័យស្តីពីជីវិតឯកជនផ្ទាល់ និងគ្រួសាររបស់បុគ្គល ទិន្នន័យស្តីពីសកម្មភាពឧក្រិដ្ឋ និងលក្ខខណ្ឌសុខភាព និងទ្រព្យសម្បត្តិ ។ ច្បាប់នោះបន្ថែមថា “ប្រសិនបើឯកសារដែលត្រូវគេបង្ហាញ គឺជាឯកសារផ្ទាល់របស់សមាជិកអាជ្ញាធរសន្តិសុខ ទិន្នន័យទាំងអស់ស្តីពីបុគ្គលដែលក្រៅពីសកម្មភាពការងារមិនត្រូវបានបង្ហាញផងដែរ” ដូច្នេះហើយ ក្រោមច្បាប់ ហុងគ្រី និងស្លូវ៉ាគី ឯកជនភាពមិនបានការពារព័ត៌មានដែលចាំបាច់យល់ដឹងពីសកម្មភាពផ្លូវការរបស់បុគ្គលដែលបម្រើការងារឲ្យរដ្ឋគាបសង្កត់ ។ បទដ្ឋាននៃឯកជនភាព គឺមិនអាចប្រើជាការការពារការស៊ើបអង្កេតសិទ្ធិមនុស្សឡើយ ។

កត្តាទីពីរដ៏សំខាន់ក្នុងការថ្លឹងថ្លែងបញ្ហាឯកជនភាពទាក់ទងនឹងអត្តសញ្ញាណរបស់អ្នកស្នើសុំ ។ គោលការណ៍ ចុតនេត-អូរេនលីចច័រ បែងចែកយ៉ាងច្បាស់នូវភាគីផ្សេងៗដែលអាចស្នើសុំឯកសារ ។ គោលការណ៍ទី១ ៨ ចែងដូចខាងក្រោម ៖

> ការទទួលបានឯកសារគួរត្រូវទទួលការគាំទ្រដើម្បីឲ្យជនរងគ្រោះ និងសាច់ញាតិអះអាងសិទ្ធិរបស់ខ្លួន ។ ការទទួលបានឯកសារគួរត្រូវទទួលការគាំទ្រក្នុងករណីដែលបុគ្គលពាក់ព័ន្ធស្នើសុំដើម្បីធ្វើការការពារខ្លួន ។ ការទទួលបានឯកសារគួរត្រូវទទួលការគាំទ្រចំពោះផលប្រយោជន៍ការស្រាវជ្រាវប្រវត្តិសាស្ត្រដោយអនុលោមតាមការដាក់កំហិតក្នុងន័យការពារឯកជនភាព និងសន្តិសុខរបស់ជនរងគ្រោះ និងបុគ្គលដទៃ ។

ការលើកឡើងនេះ គឺថាអ្នកដែលត្រូវការឯកសារដើម្បីអះអាងពីសិទ្ធិស្របច្បាប់ទទួលបានកម្រិតនៃការទទួលព័ត៌មានច្រើនជាងអ្នកស្រាវជ្រាវប្រវត្តិសាស្ត្រ ។ គោលការណ៍នោះអះអាងថា តុលាការ ដំណើរការសួរចម្លើយមិនមែនតុលាការ និងអ្នកសង្កេតការណ៍អាចទទួលបានឯកសារពាក់ព័ន្ធនេះដែរ ។ ប៉ុន្តែឯកសារគួរតែប្រើក្នុងរបៀបមួយដែលគោរពបញ្ហាឯកជនភាព ដូចជា ការធានា ការលាក់កំបាំងដល់ជនរងគ្រោះ និងសាក្សីដទៃ ដែលជាបុរេលក្ខខណ្ឌនៃការផ្តល់សក្ខីកម្ម ។

របាយការណ៍ក្រុមប្រឹក្សាអន្តរជាតិស្តីពីទីតម្កល់ឯកសារប្រវត្តិសាស្ត្ររបស់អង្គការយូណេស្កូក្នុងឆ្នាំ២០០៩ បានចាត់ទុកអ្នកស្រាវជ្រាវប្រវត្តិសាស្ត្រថាជាអ្នកស្នើសុំឯកសារ ។ របាយការណ៍នោះ ថ្លែងក្នុងឯកសារសិទ្ធិមនុស្សថា “ជម្លោះដ៏ពិបាកបំផុតគឺរវាងសិទ្ធិឯកជនភាព និងសិទ្ធិស្រាវជ្រាវប្រវត្តិសាស្ត្រ” ហើយបន្ថែមថាៈ

> ការប្រើប្រាស់ឯកសារខាងវិទ្យាសាស្ត្រ និងប្រវត្តិសាស្ត្រជានិច្ចកាលត្រូវត្រួតពិនិត្យតាមរយៈការពារឯកជនភាពរបស់ជនរងគ្រោះពីការគាបសង្កត់ព្រមទាំងការការពារឯកជនភាពរបស់ជនទីបីដែលលើកឡើងក្នុងឯកសារ ។

ច្បាប់ហុងគ្រីដាក់បញ្ចូលការបង្គាប់លម្អិតផ្សេងៗទៀត ។ ច្បាប់នោះអនុញ្ញាតឲ្យអ្នកស្រាវជ្រាវវិទ្យាសាស្ត្រទទួលបានព័ត៌មានសុខភាពបុគ្គលក្នុងសំណុំឯកសារសាមសិបឆ្នាំ បន្ទាប់ពីបុគ្គលបានស្លាប់ ឬអនុញ្ញាតឲ្យអ្នកស្រាវជ្រាវវិទ្យាសាស្ត្រទទួលបានព័ត៌មានសុខភាពនិងប្រជារាស្ត្រក្នុងទម្រង់អនាមិក ។ អ្នកធ្វើទស្សនកិច្ចទូទៅអាចទទួលបានឯកសារទាំងអស់ក្នុងទម្រង់អនាមិក ប៉ុន្តែអាចទទួលបានទិន្នន័យស្តី ពីពូជសាសន៍ សញ្ជាតិ ជនជាតិ ជំនឿសាសនា ឬមនោគមន៍វិជ្ជា ទម្លាប់ និងចំណង់ផ្លូវភេទរហូតដល់រយៈពេលហុកសិបឆ្នាំក្រោយពីបុគ្គលបានស្លាប់ ។

ច្បាប់ហុងគ្រីនិយាយបញ្ចៀសដល់កត្តាទីបីនិងទីបួនផងដែរ ដូចជាប្រភេទឯកសារដែលស្វែងរក និងអត្ថបទស្តីពីពេលវេលា ។ ច្បាប់ឯកជនភាពជាធម្មតាពិពណ៌នាលម្អិតអំពីប្រភេទនៃឯកសារដែលស្របច្បាប់សម្រាប់ការពារដែលជាផ្នែកមួយនៃសិទ្ធិឯកជនភាព ។ បន្ទាប់ពីសង្គ្រាមនិយមន័យនេះ ជួនកាលរួមបញ្ចូលការពិពណ៌នាលំអិតហួសពីការពិពណ៌នាខាងវេជ្ជសាស្ត្រនិងហិរញ្ញវត្ថុ ។ ក្នុងសម័យអន្តរ កាលសមាជិកភាពក្នុងអង្គភាពប្រឆាំង ឬការទាក់ទងជាមួយមនុស្សដទៃអាចបង្កគ្រោះថ្នាក់ដល់អ្នក ។ ក្រោយៗមក រឿងនេះក៏សាបរលាប ។ ដូច្នេះហើយបញ្ហានៃអង្គហេតុដែលត្រូវលុបចោលគឺជាប់ទាក់ទងយ៉ាងស្អិតរមួតនឹងការកំណត់ពេលវេលា ។

ច្បាប់ទទួលបានព័ត៌មានជាច្រើនបង្កើតរយៈពេលនៃការប្រកាសឲ្យដឹង ។ របាយការណ៍អន្តរជាតិនិងសេចក្តីសម្រេចរបស់តុលាការផ្តោតលើសិទ្ធិស្វែងរកការពិតបានឆ្លុះបញ្ចាំងពីការអនុវត្តច្បាប់ដ៏ប្រសើរដែលទាក់ទងនឹងប្រភេទនៃឯកសារលម្អិត ។ របាយការណ៍ និងសេចក្តីសម្រេចនេះគួរតែផ្តោតលើប្រភេទព័ត៌មានដែលផ្សព្វផ្សាយនិងបរិបទរបស់សង្គមដោយសារតែហេតុផលការពារឯកជនភាពទាក់ទងនឹងគ្រោះថ្នាក់ដែលបុគ្គលអាចប្រឈម ប្រសិនបើការពិតមួយចំនួនត្រូវបានបង្ហាញ ។

ការការពារឯកជនភាពកាន់តែស្មុគស្មាញពេលដែលទាក់ទងនឹងសំណើរបស់អ្នកស្រាវជ្រាវដោយសារក្នុងដំណើរការច្បាប់ការការពារឯកជនភាពប្រឆាំងទៅនឹងបុគ្គលជាប់ពាក់ព័ន្ធពេលដែលពិចារណាថា បុគ្គលនោះមិនមែនជាភ្នាក់ងាររបស់រដ្ឋ ឬជនរងគ្រោះគ្មានកំហុស ។ ច្បាប់ពាក់ព័ន្ធក្នុងរដ្ឋាភិបាលបណ្តោះអាសន្នគូសបញ្ជាក់តិចតួចអំពីរបៀបចាត់ថ្នាក់បុគ្គលដែលមិនបម្រើការរដ្ឋ ប៉ុន្តែជាបុគ្គលមានទំនាក់ទំនងការងារជាមួយរដ្ឋ ។ ប្រការនេះធ្វើឲ្យមានការប្រឈមនៃការអនុវត្តផែនការការពារឯកជនភាព ។ ការការពារឯកជនភាពគឺមិនត្រឹមតែស្តីពីការសម្រេចចិត្តផ្សព្វផ្សាយ ឬមិនផ្សព្វផ្សាយព័ត៌មាននោះទេ ប៉ុន្តែវាទាមទារការងារជាច្រើននិងប្រព័ន្ធមួយសម្រាប់ធ្វើការសម្រេចចិត្តថាតើព័ត៌មានប្រភេទអ្វីចាំបាច់ត្រូវលុប ។

ដូច្នេះហើយឯកជនភាពបន្តផ្តោតលើបញ្ហាដែលបរិយាយ

ខាងលើ ។ អ្នកគាំទ្រសិទ្ធិមនុស្សចង់ឃើញព័ត៌មានត្រូវបានផ្សព្វផ្សាយទូលំទូលាយនិងរហ័សដើម្បីកាត់បន្ថយហានិភ័យដែលរដ្ឋាភិបាលនឹងធ្វើការគ្រប់គ្រងជាថ្មីម្តងទៀត ។ មធ្យោបាយងាយបំផុតក្នុងការធានាការផ្សព្វផ្សាយព័ត៌មានឲ្យបានរហ័សគឺត្រូវផ្សព្វផ្សាយព័ត៌មានដែលមានការលុបចោលតិចតួច ។ ការចងក្រងឯកសារសិទ្ធិមនុស្សចាំបាច់ត្រូវផ្អែកលើមូលដ្ឋានច្បាប់ និងសុជីវធម៌ដែលធម្មតាប្រឆាំងនឹងទម្រង់ផ្សព្វផ្សាយព័ត៌មានសាមញ្ញ ។ បច្ចេកវិទ្យាកុំព្យូទ័របង្កើនល្បឿននៃការប្រើប្រាស់ព័ត៌មាន និងការប្រើប្រាស់ព័ត៌មានខុស ។ ដោយសារតែបារម្ភពីសិទ្ធិឯកជនភាព របាយការណ៍ក្រុមប្រឹក្សាអន្តរជាតិស្តីពីទីតម្កល់ឯកសារប្រវត្តិសាស្ត្ររបស់អង្គការយូណេស្កូក្នុងឆ្នាំ២០០៩ ប្រឆាំងនឹងការបង្កើតសំណុំឯកសារលម្អិត តាមរយៈការប្រាប់ឈ្មោះមនុស្សក្នុងឯកសារ ។ របាយការណ៍កត់សម្គាល់ថា បច្ចេកវិទ្យាទំនើបដែលប្រើសម្រាប់ពិពណ៌នា និងរៀបចំឯកសារគួរតែគ្រប់គ្រងព័ត៌មានដែលស្ថិតក្នុងវេងនៃការការពារឯកជនភាព ។ នេះគឺជាចំណុចដ៏សំខាន់ពីព្រោះសំណុំឯកសារដែលងាយស្វែងរកតាមប្រព័ន្ធបច្ចេកវិទ្យាអាចបង្កជាហានិភ័យដល់បុគ្គលតាមរយៈព័ត៌មានដែលមិនគួរផ្សព្វផ្សាយ ។ សិទ្ធិឯកជនភាពភ្ជាប់យ៉ាងស្អិតទៅនឹងការផ្តល់ទិន្នន័យ *hebeas data* ដែលអាចឲ្យបុគ្គលដឹងថា តើព័ត៌មានស្តីពីរូបគាត់កើតឡើងយ៉ាងម៉េចក្នុងកំណត់ត្រា ហើយអាចឲ្យគាត់តវ៉ានឹងព័ត៌មានទាំងនោះ ។ របាយការណ៍គន្លឹះនិងគំហើញរបស់តុលាការស្តីពីសិទ្ធិស្វែងរកការពិតសំដៅលើសិទ្ធិដឹងពុរបស់បុគ្គលចំពោះព័ត៌មានដែលកើតឡើងចំពោះរូបគាត់ ។ ក្នុងប្រទេសរីកវរ ដូចជា ប្រទេសអាហ្សង់ទីន និងប្រទេសប្រេស៊ីល ការផ្តល់ទិន្នន័យ *hebeas data* និងច្បាប់ឯកជន ភាពទូទៅអាចឲ្យប្រជាជនធ្វើការតវ៉ាកែសម្រួល ឬសូម្បីតែលុបកំណត់ត្រាដែលមិនត្រឹមត្រូវ ។ គោលការណ៍ ចុតនេត-អូរេនលីចច័រ ពោលថា បុគ្គលមានសិទ្ធិដឹងពុថាតើឈ្មោះរបស់គេត្រូវបានកត់ត្រាក្នុងឯកសាររដ្ឋយ៉ាងម៉េច ហើយប្រសិនកើតមានដូច្នេះមែន តាមរយៈសិទ្ធិទទួលបានព័ត៌មាន បុគ្គលមានសិទ្ធិដេញដោលលក្ខណៈត្រឹមត្រូវនៃសារព័ត៌មានដែលជាការអនុវត្តសិទ្ធិឆ្លើយតប ។ គោលការ ចុតនេត-អូរេនលីចច័រ បានលើកឡើងយន្តការសាមញ្ញសម្រាប់ការតវ៉ា ដូចជា «ឯកសារដែលត្រូវតវ៉ាគួរដាក់បញ្ចូលនូវកំណត់សម្គាល់ឯកសារយោងដែលតវ៉ាប្រឆាំងនឹងភាពត្រឹមត្រូវរបស់ឯកសារ ហើយឯកសារទាំងពីរ ទាំងឯកសារយោង និងឯកសារដែលត្រូវតវ៉ា ត្រូវមានទាំងពីរ ពេលណាដែលឯកសារដែលត្រូវតវ៉ាត្រូវស្នើសុំ» ។

ការអនុញ្ញាតឲ្យជនជាប់ប្រកាន់រំលោភសិទ្ធិមនុស្សតវ៉ាកំណត់ត្រាឯកសារ គឺសមហេតុផល ដោយសារទង្វើនេះធ្វើឲ្យមានព័ត៌មានបន្ថែម និងគោរពសិទ្ធិជាមូលដ្ឋាន ។ ការអនុញ្ញាតឲ្យជនជាប់ប្រកាន់តវ៉ាតាមរយៈការសរសេរលិខិតផ្ញើទៅទីតម្កល់ឯកសារគឺមិនមែនជាគំនិតល្អទេ ។ ពេលដែលមន្ត្រីធ្វើការកត់ត្រា និងរក្សាកំណត់ត្រាសាធារណៈធ្វើការងារនេះក្រោមកាតព្វកិច្ចជំនាញដើម្បីកត់ត្រាព្រឹត្តិការណ៍ឲ្យបានត្រឹមត្រូវ ។ សំបុត្រតវ៉ាជាបន្តបន្ទាប់ពីអតីតមន្ត្រីមានមូលដ្ឋានជំនឿតិចតួចណាស់ ។ វាជារឿងដ៏ប្រសើរដែលផ្តល់ឱកាសក្នុងការតវ៉ាប្រឆាំងព័ត៌មានតាមរយៈយន្តការដូចជាដំណើរការស្វែងរកការពិតជាអចិន្ត្រៃយ៍ ។ ស្មារតីនៃការផ្តល់អនុសាសន៍ គឺជារឿងល្អ ទោះបីជាយ៉ាងនេះក៏ដោយ ទីតម្កល់ឯកសារផ្តល់មូលដ្ឋានល្អសម្រាប់ការស្វែងរកការពិតពេលដែលទីតម្កល់ឯកសារគាំទ្រសិទ្ធិជាមូល ដ្ឋានដោយមិនលម្អៀង ។

### ច) ការលើកលែងសន្តិសុខជាតិ

ទាក់ទងនឹងការបារម្ភខាងឯកជនភាពផលប្រយោជន៍សន្តិសុខជាតិ គឺជាហេតុផលគន្លឹះដែលជួយកំណត់វិសាលភាពនៃការផ្សព្វផ្សាយឯកសារ ។ សិទ្ធិរបស់រដ្ឋាភិបាលក្នុងការមិនផ្តល់ព័ត៌មានគឺជាកម្មវត្ថុការពិភាក្សាដេញដោលភាគច្រើន ។ អ្នករៀនសូត្រ និងអ្នកគាំទ្រសិទ្ធិមនុស្សមួយចំនួនបានខ្នះខ្នែងជម្រុញរបបមួយដែលរារាំងគ្រប់ទម្រង់ទាំងអស់នៃការផ្សព្វផ្សាយព័ត៌មាន ។ អ្នកផ្សេងអះអាងថា ការមិនផ្សព្វផ្សាយគឺអាចទទួលយកបានប្រសិនបើឆ្លើយតបនឹងលក្ខខណ្ឌដាក់កំហិត ។ គោលការណ៍ ចុតនេត-អូរេនលីចច័រ លើកឡើងករណីលើកលែងចំពោះសន្តិសុខជាតិក្នុងកថាខណ្ឌមួយដែលបរិយាយពីទំនាក់ទំនងរវាងមន្ទីរតម្កល់ឯកសារ និងតុលាការ និងដំណើរការសួរចម្លើយមិនមែនតុលាការ ។ គោលការណ៍នោះដាក់កំហិតខ្ពស់ចំពោះការពន្យល់ហេតុផលនៃការបដិសេធផ្សាយព័ត៌មានដោយអះអាងថា «ការទទួលបានព័ត៌មានមិនត្រូវបានបដិសេធដោយសំអាងលើសន្តិសុខជាតិ លុះត្រាតែក្នុងលក្ខខណ្ឌលើកលែងណាមួយដែលការដាក់កំហិតត្រូវបង្គាប់ដោយច្បាប់ ។

រដ្ឋាភិបាលបានគូសបញ្ជាក់ថា ការដាក់កំហិតមានសារសំខាន់ក្នុងសង្គមប្រជាធិបតេយ្យដែលការពារផលប្រយោជន៍សន្តិសុខជាតិ ហើយការបដិសេធចំពោះការផ្សព្វផ្សាយព័ត៌មានត្រូវអនុលោមតាមការត្រួតពិនិត្យរបស់តុលាការឯករាជ្យ ។

ច្បាប់ចងចាំប្រទេសស្លូវ៉ាគី មិនអនុញ្ញាតឲ្យមានការផ្សព្វផ្សាយព័ត៌មានក្នុងលក្ខខណ្ឌលើកលែងមួយចំនួន ។ ការមិនផ្សព្វផ្សាយព័ត៌មានទាមទារឲ្យមានការសន្មតជាមុនដែលការផ្សព្វផ្សាយឯកសារជាសាធារណៈអាចបង្កគ្រោះថ្នាក់ដល់ផលប្រយោជន៍សន្តិសុខប្រជាមានិតស្លូវ៉ាក់ក្នុងឆាកអន្តរជាតិ ឬនាំទៅរកការបាត់បង់អាយុជីវិតមនុស្ស ។ ដើម្បីសម្រេចបានការកំណត់នេះ មន្ទីរព័ត៌មានស្លូវ៉ាគី ឬក្រសួងការពារជាតិត្រូវដាក់សំណើសម្រាប់ការបដិសេធការផ្សព្វផ្សាយព័ត៌មានទៅគណៈកម្មាធិការពិសេសដែលចាត់តាំងដោយសភាស្លូវ៉ាក់ដែលមានរយៈពេល៦០ថ្ងៃ សម្រាប់បង្ហាញសេចក្តីសម្រេចរបស់ខ្លួន ។ គណៈកម្មាធិការដដែលមានកាតព្វកិច្ចត្រួតពិនិត្យមើលការផ្សព្វផ្សាយនិងធ្វើរបាយការណ៍ជាប្រចាំឆ្នាំទៅសភា ។

ក្នុងប្រទេសហុងគ្រី ច្បាប់ស្តីពីការផ្សព្វផ្សាយឯកសារសម័យកុម្មុយនីស្តមានការលើកលែងជាច្រើន ។ ឧទាហរណ៍ ឯកសារមិនត្រូវបានផ្សព្វផ្សាយប្រសិនបើឯកសារទាំងនោះទាក់ទិននឹងបុគ្គលដែលធ្វើការងារក្នុងភ្នាក់ងារសន្តិសុខចន្លោះឆ្នាំ១៩៩០ដល់២០០២ (ចន្លោះពេលបញ្ចប់សម័យកុម្មុយនីស្ត និងការអនុម័តច្បាប់) ។ ឯកសារមិនត្រូវបានផ្សព្វផ្សាយ ប្រសិនបើសន្និដ្ឋានថា ការផ្សព្វផ្សាយឯកសារនឹងនាំឲ្យមានការសងសឹកដែលបង្កគ្រោះថ្នាក់ដល់អាយុជីវិត ឬសេរីភាពបុគ្គលរបស់ជនល្មើស ឬគ្រួសារជនល្មើស ។ មានការលើកលែងផ្សេងទៀត ប្រសិនបើឯកសារបង្ហាញពីអត្តសញ្ញាណ ឬមធ្យោបាយយកការរបស់គិញហុងគ្រី ដែលផ្ទុយទៅវិញបង្កគ្រោះថ្នាក់ដល់ទំនាក់ទំនងបរទេស និងផលប្រយោជន៍សេដ្ឋកិច្ច ឬការការពារជាតិ ។

ការជំទាស់ការផ្សព្វផ្សាយព័ត៌មានដែលសំអាងលើសន្តិសុខជាតិត្រូវសម្រេចតិចតួចណាស់ ។ ការកំណត់ពេលវេលាត្រូវគេរក្សារយៈពេលខ្លីនិងបើកចំហចំពោះការតវ៉ា ។ ផ្សេងទៅវិញ ករណីលើកលែងខាងសន្តិសុខជាតិ គឺជារឿងកំប៉ិកកំប៉ុក ប៉ុន្តែមានឥទ្ធិពលដល់ការមិនទទួលខុសត្រូវ និងការរំលោភអំណាច ។ ហានិភ័យនៃការហាមឃាត់មនុស្សពីការស្វែងរកព័ត៌មានគឺជារឿងធ្ងន់ធ្ងរក្នុងការដោះស្រាយឯកសារសិទ្ធិមនុស្ស ។ សម្រាប់ហេតុផលនេះ ច្បាប់ជាតិមួយចំនួនចែងថា សន្តិសុខជាតិមិនមែនជាមូលដ្ឋានសម្រាប់ការចាត់ថ្នាក់ និងការហូតយកឯកសារនោះទេ ។ ប្រទេសអ៊ុយរ៉ាហ្គាយ បានអនុម័តច្បាប់ក្នុងឆ្នាំ២០០៩ ទាមទារឲ្យមានការផ្សព្វផ្សាយឯកសារទាក់ទងការរំលោភបំពានសិទ្ធិមនុស្សពីអតីត ។ ប្រទេសហ្គាតេម៉ាឡាបានអនុម័តច្បាប់ស្តីពីការទទួលបានព័ត៌មានសាធារណៈដោយសេរីក្នុងឆ្នាំ២០០៨ ដោយមានមាត្រាចែងថា «គ្មានករណីណាដែលព័ត៌មានទាក់ទងនឹងការរំលោភសិទ្ធិមនុស្សឬបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិត្រូវចាត់ជាព័ត៌មានលាក់កំបាំងឬរក្សាជាសម្ងាត់» ។ ច្បាប់សហព័ន្ធម៉ិចស៊ិចកូឆ្នាំ២០០២ ស្តីពីការទទួលបានព័ត៌មានដាក់បញ្ចូលកថាខណ្ឌដែលហាមឃាត់ការរក្សាឯកសារស្តីពីការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ហើយច្បាប់នោះអះអាងថា «ព័ត៌មានមិនត្រូវចាត់ទុកជាការសម្ងាត់ ពេលដែលមានការពាក់ព័ន្ធការស៊ើបអង្កេតការរំលោភបំពានសិទ្ធិជាមូលដ្ឋាន ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ» ។ របាយការណ៍របស់ក្រុមប្រឹក្សាអន្តរជាតិស្តីពីទីតម្កល់ឯកសារប្រវត្តិសាស្ត្ររបស់អង្គការយូណេស្កូធ្វើសេចក្តីសន្និដ្ឋានស្រដៀងគ្នា ដោយជំរុញឲ្យរដ្ឋបង្កើតច្បាប់ដែលរារាំងការការពារព័ត៌មានអំពីការរំលោភបំពានសិទ្ធិមនុស្សក្រោមស្លាកការរក្សាការសម្ងាត់របស់រដ្ឋ ។

ករណីលើកលែងខាងសន្តិសុខជាតិគឺមិនស្ថិតក្នុងការការពារឯកជនភាពទេ ហើយវាបែរជាសក្តិសមនឹងការរំលោភរបស់រដ្ឋទៅវិញ ។ សម្រាប់ហេតុផលនេះ ករណីលើកលែងនេះចាំបាច់ត្រូវកែសម្រួលហើយមានតែតុលាការឯករាជ្យទេ គួរតែត្រូវផ្តល់អំណាចដើម្បីធ្វើការកែសម្រួលចំពោះបទដ្ឋានដែលព័ត៌មានសិទ្ធិមនុស្សទទួលបានបុព្វសិទ្ធិស្តីពីសន្តិសុខជាតិ ។ តាមការអនុវត្ត រដ្ឋនឹងបន្តជំទាស់ការទាមទារឯកសាររបស់អ្នកអង្កេតការណ៍សិទ្ធិមនុស្ស ។ ប្រការនេះធ្វើឲ្យយើងនឹកដល់យុទ្ធសាស្ត្រជាមូលដ្ឋានដែលទាមទារឲ្យរដ្ឋធ្វើកំណត់ត្រា និងផ្សព្វផ្សាយកំណត់ត្រារបស់ខ្លួនទោះបីជាកំណត់ត្រាមួយចំនួនត្រូវគេរក្សាជាការសម្ងាត់ ។ ការធ្វើដូចនេះអាចឲ្យអ្នកស្រាវជ្រាវជៀសវាងគ្រោះ តុលាការចាត់ថ្នាក់ប្រភេទឯកសារដែល

មានក្នុងសំណុំឯកសាររបស់រដ្ឋ ដូច្នេះអ្នកទាំងនោះអាចតវ៉ាជំទាស់ការផ្សព្វផ្សាយដែលមិនសមហេតុ ។

## សេចក្តីសន្និដ្ឋាន

យុទ្ធសាស្ត្រជាមូលដ្ឋានត្រូវបានបង្កើតឡើងដើម្បីបង្កើតមូលដ្ឋានរឹងមាំក្នុងនីតិវិធីទទួលខុសត្រូវ និងការប្រាប់រឿងពិតព្រមទាំងគោលគំនិតនៃការចងចាំ ។ វាជាការលំបាកក្នុងដំណាក់កាលដំបូង ប៉ុន្តែវាជាការចូលរួមផ្នែកនយោបាយ និងហិរញ្ញវត្ថុដល់សង្គមដែលងើបចេញពីមហន្តរាយ ។

បន្ទាប់ពីការរំលោភបំពានធ្ងន់ធ្ងរ ព័ត៌មានដែលចងក្រងមានឥទ្ធិពលលើដំណើការទទួលខុសត្រូវដូចជា ការជំនុំជំរះឧក្រិដ្ឋជនដំណើរការស្វែងរកការពិត និងដំណើរការសួរចម្លើយ ។ លក្ខណៈពិសេសរបស់ព័ត៌មានដែលចងក្រងស្តែងឲ្យឃើញយ៉ាងច្បាស់ដោយសារឯកសារ និងកុនជាច្រើនបានរួមចំណែកយ៉ាងសំខាន់ក្នុងការចោទប្រកាន់ឧក្រិដ្ឋជនណាហ្ស៊ី នៅនូរ៉មប៊ឺក ។ ព្រះរាជអាជ្ញាអាមេរិក រ៉ូប៊ឺត ជែកសាន់ គាំទ្រឯកសារទាំងនោះជាងភស្តុតាងដទៃពីព្រោះគាត់ឃើញថា ឯកសារទាំងនោះមានមូលដ្ឋានរឹងមាំមិនអាចឲ្យអ្នកការពារក្តីបដិសេធ ។ ឯកសារចងក្រងមានសារសំខាន់ក្នុងករណីធ្ងន់ធ្ងរជាច្រើនដូចជា សវនាការរបស់ ហ្គារសៀ នៅប្រទេសហ្គាតេម៉ាឡា និងសវនាការមេដឹកនាំខ្មែរក្រហមនៅកម្ពុជាជាទីដែលឯកសារពីទីតម្កល់ឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជាមានសារសំខាន់ក្នុងការចោទប្រកាន់ ឌុច ដែលជាកម្មាភិបាលម្នាក់របស់ភ្នាក់ងារសន្តិសុខសម្ងាត់ ប៉ុល ពត ពីបទសម្លាប់មនុស្ស១២៥០០នាក់នៅចុងទសវត្សរ៍៧០ ។

ទីតម្កល់ឯកសារដែលផ្អែកលើមូលដ្ឋានរឹងមាំអាចជួយសង្គមស្តារ និងឆ្ពោះទៅមុខតាមរយៈគំនិតផ្តួចផ្តើមនៃការចងចាំ ។ ឧទាហរណ៍មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រើឯកសារដើម្បីរៀបរាប់គម្រោងអប់រំប្រល័យពូជសាសន៍របស់ខ្លួនជាមួយក្រសួងអប់រំ ដោយបោះពុម្ពផ្សាយសៀវភៅសិក្សាប្រវត្តិសាស្ត្រដូវការដែលដកស្រង់ពីឯកសារខ្មែរក្រហម ហើយបានដាក់ចេញនូវមុខវិជ្ជាសិក្សាសម្រាប់សិស្សវិទ្យាល័យទូទាំងប្រទេស ។ មជ្ឈមណ្ឌលច្បាប់មនុស្សធម៌នៅក្រុងប៊េលក្រាតបានប្រើប្រាស់ឯកសារដើម្បីបង្កើតកម្រងទិន្នន័យដែលហៅថា សៀវភៅចងចាំកូសូវ៉ូ រួមមានសេចក្តីលម្អិតអំពីជនជាតិអាល់បានី និងស៊ែបម្នាក់ដែលស្លាប់អំឡុងពេល ឬបន្ទាប់ពីសង្គ្រាមពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០០ ។ សារមន្ទីរនៅទីក្រុងខេបថោន ប្រទេសអាហ្វ្រិកខាងត្បូង សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនៅភ្នំពេញ សារមន្ទីរយុត្តិធម៌នៅប្រទេសប៉ារ៉ាហ្គាយ និងសារមន្ទីរផ្សេងៗបានដាក់តាំងបង្ហាញឯកសារប្រវត្តិសាស្ត្រ ។

ទីតម្កល់ឯកសារខ្លះបានជួលបុគ្គលិកមានសមត្ថភាពជាច្រើនដើម្បីប្រាប់ពីមូលហេតុ និងអ្វីដែលបានកើតឡើងអំឡុងពេលវឹកវរ ។ ទីតម្កល់ឯកសារខ្លះទៀតស្វាគមន៍ចំពោះការវិភាគខាងក្រៅ ។ នេះគឺជាផ្នែកដ៏សំខាន់នៃដំណើរការបង្កើតការចងចាំ ។ ឯកសារដើមមិនបង្ហាញរូបភាពទាំងមូលនោះទេ ។ ឯកសារទាំងនោះមិនកត់ត្រាព្រឹត្តិការណ៍ទាំងមូលទេ ជួនកាលកត់ត្រាដដែលៗដូច្នេះហើយ វាកត់ត្រាព្រឹត្តិការណ៍ដោយប្រយោល ហើយមិនតំណាងឲ្យសំណុំឯកសារដែលទាក់ទិនអំឡុងពេលនៃព្រឹត្តិការណ៍ ។ ការលាតត្រដាងរឿងពិតទាមទារច្រើនជាងការផ្សព្វផ្សាយព័ត៌មានដាក់លាក់អំពីជនរងគ្រោះវាទាមទារឲ្យមានដំណើរប្រវត្តិសាស្ត្រដែលឆ្លុះបញ្ចាំងពីការរំលោភបំពាន ។ ទោះបីជាទីតម្កល់ឯកសារចងក្រងប្រវត្តិសាស្ត្រក្នុងស្រុក ឬស្វាគមន៍ភ្ញៀវបរទេសយុទ្ធសាស្ត្រជាមូលដ្ឋានទាមទារភាពមិនលម្អៀង ។ ការបង្កើតការចងចាំគឺជាដំណើរការដែលជាប់ពាក់ព័ន្ធខាងនយោបាយ ហើយប្រជាធិបតេយ្យពិតមិនអាចឈរលើការបរិយាយប្រវត្តិសាស្ត្រមិនពិតនោះទេ ។

សរុបសេចក្តីមក យុទ្ធសាស្ត្រជាមូលដ្ឋានមានអត្ថប្រយោជន៍ជាច្រើន ប៉ុន្តែវាពាក់ព័ន្ធការថ្លឹងថ្លែង និងការវិនិច្ឆ័យដ៏លំបាកដែលពិបាកក្នុងការធ្វើសន្និដ្ឋានរួមក្នុងសង្គម ។ ការទាមទារសម្រាប់បុគ្គលមានការប្តេជ្ញាខ្ពស់ដើម្បីធ្វើការងារចងក្រងឯកសារជួបបញ្ហាប្រចាំដែលខាងធនធាននិងសមត្ថភាព ។ ការប្រឈមជាច្រើនដើម្បីប្រើយុទ្ធសាស្ត្រជាមូលដ្ឋានក្នុងការចងក្រងឯកសារគឺការប្រយ័ត្នប្រយែងការរៀបចំបានល្អ ការឆ្លើយតបនឹងបញ្ហាសុជីវធម៌ និងច្បាប់ ការប្រើប្រាស់ពេលវេលា និងលុយកាក់ ភាពអត់ធ្មត់ និងការគាំទ្រខាងនយោបាយ ។ ហេតុផលមួយក្នុងចំណោមគន្លឹះជាច្រើនចំពោះយុទ្ធសាស្ត្រជាមូលដ្ឋានគឺត្រូវធ្វើអ្នកជាប់ពាក់ព័ន្ធមានជំនឿលើតម្លៃនៃការចូលរួម ។ **ចន ឆរឆីអារី**

# ការបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សនៅតំបន់អាស៊ីអាគ្នេយ៍

***(តចប់)***

### ***ច) ការអាស្រ័យសិទ្ធិមនុស្សនៅក្នុងកិច្ចព្រមព្រៀងអាស៊ាន***

*លទ្ធភាពរបស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិមនុស្សបានក្លាយជាប្រធានបទដ៏ចម្បងក្នុងការពិភាក្សា នៅខណៈពេលដែលសមាគមចាប់ផ្តើមធ្វើការទៅលើសេចក្តីព្រាងនៃកិច្ចព្រមព្រៀងក្នុងការបង្កើតលើកដំបូង ។ មេដឹកនាំអាស៊ានចាប់ផ្តើមតែងតាំងក្រុមមនុស្សជាន់ខ្ពស់ក្នុងការប្រកាសសេចក្តីស្នើសុំសម្រាប់សេចក្តីព្រាងកិច្ចព្រមព្រៀង ។ ក្រុមមនុស្សជាន់ខ្ពស់ភាគច្រើន គឺបូករួមទាំងមន្ត្រីចូលនិវត្តន៍ដែលមានការលើកទឹកចិត្តជាមួយនឹងការគោរពសិទ្ធិមនុស្សជាជាងអ្នកដឹកនាំ ។ ក្រុមមនុស្សជាន់ខ្ពស់ផ្តល់ប្រឹក្សាទៅឲ្យអង្គការសង្គមស៊ីវិលក្នុងតំបន់ និងក្រុមក្រៅរដ្ឋាភិបាលផ្សេងៗដែលមានឥទ្ធិពលក្នុងការដាក់សិទ្ធិមនុស្សទៅក្នុងរបៀបវារៈ ។ ក្រុមទាំងនេះរួមបញ្ចូលវិទ្យាស្ថានស្តិតិ និងសិក្សាអន្តរជាតិអាស៊ាន អង្គការអន្តររដ្ឋសភាអាស៊ាន និងក្រុមការងាររយន្តការសិទ្ធិមនុស្សអាស៊ាន ។ ក្រុមមនុស្សជាន់ខ្ពស់ក៏បានប្រឹក្សាជាមួយនឹងក្រុមសាមគ្គីភាពទ្រទ្រង់ប្រជាពលរដ្ឋអាស៊ីដែលជាបណ្តាញក្រុមសង្គមស៊ីវិលទាំងសាមសិបដែលបង្កើតក្នុងឆ្នាំ២០០៦ ដើម្បីសម្របសម្រួល និងរួមបញ្ចូលនូវឥទ្ធិពលនៅក្នុងកិច្ចពិភាក្សាឆ្ពោះទៅកាន់កិច្ចព្រមព្រៀងអាស៊ាន ។*

*របាយការណ៍ក្រុមអ្នកជាន់ខ្ពស់ដែលបានចេញនៅក្នុងឆ្នាំ២០០៦ បានដាក់ការពិចារណាសង្កត់ធ្ងន់ទៅលើ «សិទ្ធិមនុស្ស និងមូលដ្ឋានសេរីភាព» ជំរុញនូវការអភិវឌ្ឍប្រជាធិបតេយ្យ និងស្នើសុំឲ្យមានការប្រឹក្សាជាផ្លូវការជាទៀងទាត់ជាមួយសង្គមស៊ីវិល និងក្រុមនៃរដ្ឋសភា ។ ជាមួយនឹងការគោរពនូវយន្តការសិទ្ធិមនុស្ស មានការស្នើសុំថា «គំនិតដ៏មានតម្លៃនេះគួរតែត្រូវបានបន្តទៅមុខទៀត ជាពិសេសនៅក្នុងការបញ្ជាក់ពីកម្រិតនៃយន្តការក្នុងតំបន់ដែលអាចនាំមកនូវភាពកាន់តែប្រាកដនៃការគោរព និងការការពារសិទ្ធិមនុស្សសម្រាប់រដ្ឋសមាជិកនីមួយៗ» ។*

*ភាសាមហិច្ឆតាទាំងនោះ ដែលរួមបញ្ចូលការសង្កត់ធ្ងន់ដាក់លាក់លើការការពារសិទ្ធិរបស់បុគ្គលនីមួយៗ បានធ្វើឲ្យអ្នកស្តាប់ក្រៅរដ្ឋាភិបាលមានការពេញចិត្តជាខ្លាំង ប៉ុន្តែមិនមែនជាពាក្យស្វាគមន៍ចំពោះអ្នកមូលធននិយមអាស៊ីអាគ្នេយ៍នោះទេ ។ ទោះបីជាសិទ្ធិមនុស្សបានសាយភាយទៅក្នុងកិច្ចពិភាក្សាអាស៊ាន និងបានបង្កប់រឹតតែជាផ្លូវការទៅក្នុងប្រព័ន្ធក្នុងស្រុកមួយចំនួនក៏ដោយ ក៏លក្ខខណ្ឌសិទ្ធិមនុស្សរបស់ប្រទេសនៅអាស៊ីអាគ្នេយ៍ ជាច្រើនបានបង្ហាញពីភាពប្រសើរឡើងតិចតួចបំផុត ។ តារាងពិន្ទុម្ចាស់ផ្ទះនៃសេរីភាព និងរង្វាស់គុណភាពរបស់នាយកដ្ឋានសហរដ្ឋអាមេរិក និងនិទោសកម្មអន្តរជាតិបានបង្ហាញពីដំណើរការដ៏គួរឲ្យកត់សម្គាល់នៅក្នុងប្រទេសឥណ្ឌូនេស៊ី ដោយឡែកឃើញថាប្រទេសនានាក្នុងតំបន់ពុំមានភាពប្រែប្រួលអ្វីទាល់តែសោះ ហើយថែមទាំងនៅតែប្រព្រឹត្តអំពើមិនគួរគប្បីដដែលៗនៅក្នុងករណីមួយចំនួនដូចជានៅប្រទេសថៃ និងហ្វីលីពីន ។ ដោយយោងទៅតាមរង្វាស់មួយចំនួនទៀត ការប្រព្រឹត្តក្នុងតំបន់មើលទៅហាក់បីដូចជាអ្វីដែលធ្លាប់កើតឡើងនៅក្នុងឆ្នាំ១៩៧៦ ។ ការព្រួយបារម្ភទៅលើនយោបាយក្នុងការជំរុញសិទ្ធិមនុស្សដែលអាចកើតមានជាបន្តបន្ទាប់ និងប្រជាធិបតេយ្យនៅតែស្ថិតក្នុងសភាពធ្ងន់ធ្ងរសម្រាប់រាជរដ្ឋាភិបាលអាស៊ីជាច្រើន ហើយជាពិសេសគឺប្រទេសកំពុងអភិវឌ្ឍទាំងបួនគឺកម្ពុជា ភូមា ឡាវ និងវៀតណាម ដែលមិនគាំទ្រទៅនឹងការបង្កើតគណៈកម្មាធិការទទួលបន្ទុកសិទ្ធិមនុស្សក្នុងតំបន់ ។*

*របាយការណ៍ក្រុមមនុស្សជាន់ខ្ពស់បានបង្កើតដំណាក់កាលសម្រាប់ការជជែកវែកញែកខាងការទូតទៅលើសិទ្ធិមនុស្សក្នុងកិច្ចព្រមព្រៀងអាស៊ាន ។ រាជរដ្ឋាភិបាលបានតែងតាំងក្រុមកម្លាំងកិច្ចការជាន់ខ្ពស់នៅក្នុងការធ្វើសេចក្តីព្រាងកិច្ចព្រមព្រៀង ហើយអ្នកតំណាងប្រទេសសិង្ហបុរីលោក ថមមី កូ បានអះអាងថា «គ្មានកិច្ចការណាមួយមិនទាមទារពេលវេលា ហើយគ្មានបញ្ហាណាមួយដែលមាន*

វាទប្បដិវាទ និងបែងចែកតាមកម្រិត ដូចជា បញ្ហាសិទ្ធិមនុស្សនោះទេ ។» ការគស៊ូមតិបានកើតឡើងស្របពេលជាមួយដែលអាស៊ានប្រឈមមុខសម្ពាធខាងក្នុងសម្រាប់កំណែទម្រង់ជាក់ស្តែងនៅក្នុងរបាយការណ៍ក្រុមមនុស្សជាន់ខ្ពស់ឆ្លងកាត់ក្រុមសាមគ្គីទ្រទ្រង់ប្រជាពលរដ្ឋអាស៊ី និងក្រុមសង្គមស៊ីវិលដែលមានជាប់ទាក់ទង ហើយព្រមទាំងឆ្លងកាត់ក្រុមគំនិតផ្តួចផ្តើមមួយចំនួនដូចជាក្រុមកិច្ចប្រជុំអន្តររដ្ឋសភារបស់ប្រទេសភូមាដែលជាក្រុមមួយដែលបានបង្កើតក្នុងឆ្នាំ២០០៤ ដើម្បីលើកស្ទួយកំណែទម្រង់សិទ្ធិមនុស្សរបស់រដ្ឋាភិបាលយោធា ។

សម្ពាធនយោបាយពីប្រទេសលោកខាងលិចបានជួយជំរុញចំណាប់អារម្មណ៍ក្នុងស្ថាប័នសិទ្ធិមនុស្សអាស៊ាន ។ ដំបូងគឺសហរដ្ឋអាមេរិក សហគមន៍អឺរ៉ុប និងអ្នកដទៃទៀតបានស្វែងរកនីតិវិធីក្នុងការដាក់តម្លៃដោយផ្ទាល់ទៅលើសមាជិកអាស៊ានពីភាពបរាជ័យនៅក្នុងការដោះស្រាយបញ្ហាសិទ្ធិមនុស្ស ។ ជាឧទាហរណ៍ច្បាស់នោះគឺថាសហរដ្ឋអាមេរិកនិងសហគមន៍អឺរ៉ុបបានប្រកាសថា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនឹងត្រូវបានបញ្ឈប់រហូតទាល់តែសមាគមអះអាងនឹងដោះស្រាយជាមួយរដ្ឋាភិបាលយោធាតំណាងឲ្យជនជាតិភូមា ។ ទោះបីជាយ៉ាងណា ក៏ភាពចាំបាច់នៃការដាក់ទណ្ឌកម្មនេះមិនគួរឲ្យហួសហេតុពេកទេ ។ ប្រទេសលោកខាងលិចគឺបានដាក់សម្ពាធមិនស្មើគ្នាទេឆ្លងកាត់តាមតំបន់ហើយមានទំនោរទៅរកការជ្រើសរើសតែបច្ចាមិត្ត ។ ក្តីបារម្ភទៅលើភេរវកម្មនិងឥទ្ធិពលនៃសេដ្ឋកិច្ចចិនបានបណ្តាលឲ្យសហរដ្ឋអាមេរិករឹតបន្តឹងចំណងពាណិជ្ជកម្ម និងកម្លាំងយោធាដើម្បីកាត់បន្ថយក្តីបារម្ភលើសិទ្ធិមនុស្សនៅខណៈពេលដែលយុទ្ធសាស្ត្រទូលំទូលាយនិងវិនិយោគសេដ្ឋកិច្ចស្ថិតនៅក្នុងហានិភ័យ ។

ប្រហែលជាមានអ្វីសំខាន់ជាជាងពាណិជ្ជកម្ម និងកម្លាំងជំនួយខាងយោធាគឺផលប៉ះពាល់នៃកិត្តិសព្ទដែលទិតៀនដោយប្រទេសលោកខាងលិចដែលធ្លាប់មានមកលើអាស៊ាន ។ សមាគមយ៉ាងហោចណាស់ក៏ប្រាថ្នាចង់បានឋានៈខ្ពស់ គឺជាសមាជិកអភិវឌ្ឍនៃសង្គមអន្តរជាតិ ។ វាក៏ជាប់ពាក់ព័ន្ធទៅនឹងមន្ត្រីរាប់រយនាក់ដែលស្វែងរកក្នុងការស្តារកិត្តិសព្ទអាស៊ាននៅក្នុងវង្វង់ការទូត ។ ការក្លាយជាគំរូចុងក្រោយគេលើសិទ្ធិមនុស្ស គឺជាទម្រង់សង្គមបន្ទុចបន្ទាក់និយមសម្រាប់បស្ចិមប្រទេស ហើយនឹងត្រូវបានតម្រូវឲ្យដើម្បីឲ្យមន្ត្រីអាស៊ានទាំងនោះធ្វើសកម្មភាព ។

រដ្ឋាភិបាលអាស៊ានដែលមានដំណើរការល្អជាងមុន និងអ្នករិះគន់ពីមជ្ឈិមប្រទេសនាំគ្នាពិភាក្សាពីសារសំខាន់របស់សមាគមទៅលើ «ភាពជាប់ទាក់ទង» និង «សេចក្តីជឿជាក់» ។ ពាក្យបច្ចេកទេសទាំងពីរនេះមិនទាន់ត្រូវបានគេកំណត់ឲ្យបានច្បាស់លាស់នៅឡើយទេ ក៏ប៉ុន្តែវាបាននាំមកនូវធាតុផ្សំដ៏រឹងមាំ ។ នៅក្នុងកិច្ចពិភាក្សាការទូតជុំវិញអាស៊ាន ពាក្យបច្ចេកទេស «ភាពជាប់ទាក់ទង» មានន័យទូទៅថា ការប្រមើលមើលពីសមត្ថភាពរបស់ស្ថាប័ននៅក្នុងការវិនិច្ឆ័យពីបញ្ហាប្រឈមដ៏សាំញ៉ាំភាគច្រើនរបស់អាស៊ី ។ ចំណែកឯពាក្យបច្ចេកទេស «សេចក្តីជឿជាក់» ជាទូទៅមានន័យថា ភាពជាម្ចាស់ទៅលើនយោបាយរួបរួមដ៏ជាក់លាក់ក្នុងការបន្តកិច្ចការអាស៊ានឆ្ពោះទៅរកគោលដៅរួម ។ការស្រពេចស្រពិលនៅក្នុងអត្ថន័យទាំងពីរនេះគឺជាការគំរាមកំហែងទៅលើជំហរសង្គមអន្តរជាតិរបស់អាស៊ាន ។ អ្នកការទូតក្រៅតំបន់មួយចំនួនទៀតបានចំណាយពេលវេលា និងធនធានទៅលើតែស្ថាប័នណាដែលខ្លួនគិតថាមានភាពជាប់ទាក់ទងនិងមានសេចក្តីជឿជាក់ ។ ឆ្លងកាត់បដិវត្តន៍ដឹកនាំដោយលោកសង្ឃនៅក្នុងប្រទេសភូមាក្នុងឆ្នាំ២០០៧ ពេលដែលជនភូមាផ្តាច់ការបានចាត់វិធានការលុបបំបាត់ទៅលើបាតុករដែលបង្កជាផ្សែងភ្លើងរិះគន់ពីសំណាក់អន្តរជាតិ ហើយអាស៊ានបានស្ថិតនៅក្នុងវិបត្តិនៃសេចក្តីជឿជាក់ ។

មន្ត្រីអាស៊ានមួយចំនួនបានបង្ហាញពីការព្រួយបារម្ភយ៉ាងខ្លាំងអំពីកិត្តិសព្ទរបស់អាស៊ាន និងឋានៈនៅក្នុងស្ថាប័នផ្សេងៗទៀតក្នុងតំបន់ ។ រដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ីលោក ម៉ាទីណា តាលេហ្គាវ៉ាមានប្រសាសន៍ថា៖

> *យើងគួរតែសំឡឹងមើលជុំវិញខ្លួនឯងដោយប្រៀបធៀបទៅនឹងប្រទេសកំពុងអភិវឌ្ឍផ្សេងទៀត ហើយមើលឲ្យឃើញថាយើងមិនអាចបណ្តែតបណ្តោយខ្លួនប្រសិនបើយើងចង់ទៅដល់ចំណុចកណ្តាលនោះ ។ ក្រឡេកមើលទៅប្រទេសអាហ្វ្រិក គេកំពុងតែប្រើយុទ្ធសាស្ត្រ និងការសំឡឹងមើលទៅឆ្ងាយនៅក្នុងការអភិវឌ្ឍយន្តការសិទ្ធិមនុស្សរបស់គេ ។ យើងមិនត្រូវបង្កើតនូវស្តង់ដារដែលមានកម្រិតទាបហួសហេតុនោះទេ ។*

បុព្វការីរបស់គាត់លោក អាលីអាឡាតាស ចោទសួរថា “តើយើងអាចជៀសវាងពីការមានស្ថាប័នសិទ្ធិមនុស្សដោយរបៀបណាក្នុងខណៈពេលដែលប្រទេសដទៃៗទៀតគេមានមួយរួចទៅហើយនោះ?” កត្តាទាំងនេះ មិនអាចមានឥទ្ធិពលជាសណ្ឋានឆ្លងកាត់តាមតំបន់នោះទេ ក៏ប៉ុន្តែជារួមវាអាចឲ្យមន្ត្រីជាច្រើនធ្វើការសន្និដ្ឋានថាសមាគមគឺត្រូវតែដោះស្រាយបញ្ហាសិទ្ធិមនុស្ស បើទោះជាសម្រាប់ហេតុផលនៃបទដ្ឋាន ឬមួយក៏ជាការការពារជំហររបស់សមាគមក៏ដោយ ។

មន្ត្រីរដ្ឋាភិបាលអាស៊ានជាច្រើននៅតែបន្សល់នូវមន្ទិលសង្ស័យ ។ យោងទៅតាមលោក ថមមី កូ ដែលជាអធិបតីក្នុងកិច្ចប្រជុំជាច្រើនរបស់ក្រុមកម្លាំងកិច្ចការជាន់ខ្ពស់ និងជាអ្នកដែលបានជ្ជុះជ្ជាក្នុងរឿងសិទ្ធិមនុស្សមានទំនោរនៅក្នុងការបែងចែកប្រទេសអាស៊ានទាំងអស់ទៅជាបីក្រុម ។ ក្រុមទីមួយគឺជាក្រុមដែលគ្មានការសាទរទៅលើសិទ្ធិមនុស្សរួមមានប្រទេសបួនគឺ កម្ពុជា ភូមា ឡាវ និងវៀតណាម ចំណែកឯប្រ៊ុយណេ និង សិង្ហបុរីវិញ គឺស្ថិតនៅក្នុងក្រុមទីពីរ ឬក្រុមកណ្តាល ។ ក្រុមកម្លាំងកិច្ចការជាន់ខ្ពស់បានជជែកវែកញែកគ្នាថាតើគួរតែបញ្ចូលឯកសារយោងលើសិទ្ធិមនុស្សទៅក្នុងកិច្ចព្រមព្រៀងដែរឬទេ ហើយនៅទីបំផុតដំណើរការនេះបានសម្រេចនិងយល់ព្រមឲ្យធ្វើទៅតាមនោះ ។

## ឆ) សិទ្ធិមនុស្សនៅក្នុងកិច្ចព្រមព្រៀងអាស៊ាន

ក្រុមកម្លាំងកិច្ចការជាន់ខ្ពស់បានរឹតបន្តឹងមកវិញទៅក្នុងមហិច្ឆតាស្នើសុំក្នុងរបាយការណ៍ក្រុមជនជាន់ខ្ពស់មួយចំនួន ។ កិច្ចព្រមព្រៀងនេះគឺសំដៅទៅលើឱកាសបួនទៅនឹង “សិទ្ធិមនុស្សនិងមូលដ្ឋានសេរីភាព” ដែលជាជំហានមួយដ៏សំខាន់នៅក្នុងប្រវត្តិរបស់សមាគម ។ លើសពីនេះទៅទៀតដោយយោងតាមមូលដ្ឋានសេរីភាពនៃកិច្ចព្រមព្រៀងនេះគឺចង្អុលបង្ហាញទៅលើសិទ្ធិស៊ីវិល និងនយោបាយដែលអាស៊ានមានភាពខ្មាសអៀនក្នុងការទទួលយក ។

ទោះបីជាយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងនេះមិនរួមបញ្ចូលនូវគោលការយោងច្បាស់ដែលមានភាពស្រដៀងទៅនឹងសិទ្ធិបុគ្គលនីមួយៗក្នុងការទទួលបាននោះទេ ប៉ុន្តែវាគឺបញ្ជាក់ទៅលើបរិបទ និងអាស្រ័យលើធម្មជាតិរបស់សិទ្ធិមនុស្សខ្លាំងជាងអ្វីដែលមាននៅក្នុងរបាយការណ៍ក្រុមមនុស្សជាន់ខ្ពស់ ។ ការចាត់ចែងទាក់ទងនឹងសិទ្ធិមនុស្សមានតុល្យភាព លុះណាតែមានសកម្មភាពលើកស្ទួយនូវគោលការណ៍នៃភាពគ្មានការជ្រៀតជ្រែក និងតាមការទូតនៃ “ផ្លូវរបស់អាស៊ាន” ។ ជាឧទាហរណ៍ តាមលំនាំដើមបានពណ៌នាអំពីសញ្ញាកិច្ចព្រមព្រៀងដូចជា “ការប្រកាន់ខ្ជាប់នូវគោលការណ៍ប្រជាធិបតេយ្យ និងវិធាននៃច្បាប់ និងអភិបាលកិច្ចល្អដោយគោរពនិងការពារសិទ្ធិមនុស្ស និងមូលដ្ឋានសេរីភាព ។” ប៉ុន្តែអ្វីដែលគួរឲ្យភ្ញាក់ផ្អើលមួយរំពេចនោះ គឺឃ្លាមួយនោះបែរជាបញ្ជាក់ថា “ការគោរពទៅលើមូលដ្ឋាន សារសំខាន់នៃមិត្តភាពសហប្រតិបត្តិការ និងគោលការណ៍អធិបតេយ្យភាព សមភាព បូរណភាពទឹកដី ភាពគ្មានសិទ្ធិក្នុងការជ្រៀតជ្រែកមតិរួម និងឯកភាពនានា ។”

នៅក្នុងមាត្រាទី១៧ បានបង្ហាញពីសិទ្ធិមនុស្សគឺជាគោលដៅជាក់ស្តែងរបស់សមាគម ប៉ុន្តែគោលដៅនេះបានដាក់បន្ទុកល្បឿននៃភាពតានតឹងសម្រាប់ទិសដៅជាមួយនឹងសិទ្ធិត្រួតត្រាសមាជិកនីមួយៗ ។ គោលដៅដែលបានប្រកាន់យកគឺការពង្រឹងប្រជាធិបតេយ្យ ការបង្កើនអភិបាលកិច្ចល្អ និងវិធានច្បាប់ ព្រមទាំងការលើកស្ទួយនិងការការពារសិទ្ធិមនុស្ស និងមូលដ្ឋានសេរីភាពដោយគោរពទៅតាមសិទ្ធិ និងទំនួលខុសត្រូវរបស់បណ្តារដ្ឋសមាជិកនីមួយៗរបស់អាស៊ាន ។” ដូច្នេះកិច្ចព្រមព្រៀងគឺបានចាត់ទុកសិទ្ធិមនុស្សដូចជាបទដ្ឋាននៅក្នុងការជ្ជុះជ្ជា និងជាតុល្យភាពប្រឆាំងនឹងបទដ្ឋាននៃអធិបតេយ្យភាព និងភាពគ្មានសិទ្ធិក្នុងការជ្រៀតជ្រែក ។ កិច្ចព្រមព្រៀងនេះ ត្រូវបានប្រុងប្រយ័ត្នណាស់ក្នុងការប្រើប្រាស់ពាក្យពេចន៍ជៀសវាងការយល់ច្រឡំអំពីសិទ្ធិមួយពឹងផ្អែកលើសិទ្ធិមាត្រាផ្សេងៗទៀត និងការចាប់អារម្មណ៍របស់ជាតិ និងការបង្គាប់បញ្ជាផ្សេងទៀត ។ ជំនួសមកវិញ ទាំងនេះគឺបានចង្អុលបង្ហាញពីការលំបាកនៃសិទ្ធិប្រឆាំងនឹងសិទ្ធិ ។

កិច្ចព្រមព្រៀងនេះ ក៏បានគ្រោងយកសិទ្ធិមនុស្សជាគោលដៅរបស់សមាគម ប៉ុន្តែមិនបានបញ្ជាក់ពីមធ្យោបាយច្បាស់លាស់ណាមួយដែលថាគោលដៅនេះនឹងត្រូវទទួលបានជោគជ័យ ឬថាការដាក់ទណ្ឌកម្មទៅលើ អ្នកដែលមិនគោរពតាម ។ យោងតាមអ្នកចូលរួមម្នាក់មានយោបល់ថា បញ្ហានៃស្ថាប័នសិទ្ធិមនុស្សគឺជាការជជែកវែកញែក “ប្រកបដោយវិបត្តិនិងមានភាពតឹងតែង” ក្នុងអំឡុងពេលដំណើរការនៃសេចក្តីព្រាងនេះ ។ ប្រទេសបួនគឺកម្ពុជា ភូមា ឡាវ និង

វៀតណាម និងសមាជិកដទៃៗ ទៀតបានធ្វើការបែងចែកក្នុង អំឡុងពេលគន្លឹះនៃការផ្សះផ្សាការបែងចែកយុទ្ធសាស្ត្ររួម នៅទីបញ្ចប់ អ្នកបង្កើតសេចក្តីព្រាងកិច្ចព្រមព្រៀងយល់ព្រមធ្វើការពិចារណាក្នុងកម្រិតមួយ ។ កិច្ចព្រមព្រៀងនេះគ្រាន់តែបានធ្វើការថ្លែងការណ៍ថា អាស៊ាននឹងបង្កើត "ក្រុមសិទ្ធិមនុស្ស" ទុកឲ្យបែបបទរបស់ក្រុមត្រូវបានសម្របសម្រួលដោយរដ្ឋមន្ត្រីការបរទេសអាស៊ាន ។

**៣) ពិការភាពនៃការបង្កើតគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស**

ក្នុងខែកក្កដាឆ្នាំ២០០៨ រដ្ឋមន្ត្រីការបរទេសអាស៊ានបានតែងតាំងក្រុមគណៈវិនិច្ឆ័យជាន់ខ្ពស់នៃមន្ត្រីរាជរដ្ឋាភិបាលក្នុងការពិភាក្សារកដំណោះស្រាយដើម្បីភាពជោគជ័យនៃក្រុមសិទ្ធិមនុស្សនៅក្នុងកិច្ចព្រមព្រៀងនេះ ។ នៅក្នុងចំណុចនេះ ការពិភាក្សាបានធ្វើការផ្លាស់ប្តូរពីប្រធានបទនៃគណៈកម្មាធិការសម្រាប់សិទ្ធិស្ត្រីនិងកុមារ ទៅជាការនិយាយពីក្រុមទូទៅដោយសារតែអ្នកគាំទ្រសិទ្ធិមនុស្ស និងមន្ត្រីដំណើរការអាស៊ានគឺបានផ្តល់អាទិភាពទៅលើបញ្ហាទូលំទូលាយទាំងពីរ ។ ឈ្មោះរបស់ក្រុមជាប្រធានបទក្នុងការកែប្រែនិងវែកញែកជាមួយនឹងសមាជិកដែលនាំទៅរកអំណាចនៃការសម្រេចចិត្តឯករាជ្យតិចឬច្រើន ។ "ក្រុមប្រឹក្សា" ឬមួយជា "គណៈកម្មាធិការ" គឺមានសំឡេងអំណាចត្រួតត្រាជាជាង "យន្តការ" ឬ "វេទិកា" ។

ព្រំដែននៃក្រុមអាជ្ញាធរក៏ត្រូវបានជជែកវែកញែកជាមួយនឹងប្រទេសកម្ពុជា ភូមា ឡាវ ហើយ វៀតណាមចាត់ទុកថា ជាប្រទេសដែលត្រូវយកចិត្តទុកដាក់លើក្រុមសិទ្ធិមនុស្សជាងគេ ។ មន្ត្រីអាស៊ានខិតខំស្វែងរកនូវការត្រៀមលក្ខណៈពីការរំពឹងទុក ។ លោក ទើមសាក់ឆេល័មផាឡានុផាប ដែលជាមន្ត្រីជាន់ខ្ពស់នៃលេខាធិការដ្ឋានអាស៊ានបានអះអាងថា "នយោបាយចម្រុះ" របស់អាស៊ានបានបង្កើតនូវ "ភាពមិនប្រាកដនៃការសាកល្បងចាប់ផ្តើមសហប្រតិបត្តិការសិទ្ធិមនុស្ស និងចន្លុលបង្ហាញពីលក្ខណៈខ្លឹមសារថ្មីដែលជាការរៀបចំផែនការដ៏មានសារសំខាន់" ។ គាត់បានបន្ថែមថាៈ

> *ទំគ្រោះនៃការប្រឈមរបស់រដ្ឋសមាជិកអាស៊ាន និងក្រុមគណៈវិនិច្ឆ័យជាន់ខ្ពស់គឺរបៀបនៃការផ្សះផ្សាតថភាពនយោបាយជាតិជាមួយនឹងកាតព្វកិច្ចថ្មីក្នុងតំបន់ក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស ។ ក្រុមសិទ្ធិមនុស្សរបស់អាស៊ានគឺត្រូវបានរំពឹងទុកថាមាន "ភាពជាក់លាក់" "សេចក្តីដែលអាចទុកចិត្តបាន" "ដែលអាចប្រើការបាន" "មានប្រសិទ្ធភាព" "មានភាពជាប់ទាក់ទិន" និងអ្វីដែលសំខាន់ជាងគេនោះគឺរដ្ឋសមាជិកទាំងអស់ "អាចទទួលយកបាន" ដូចជាក្រុមសិទ្ធិមនុស្សដែលមិនមានជំហរឯករាជ្យតែឯង ហើយមិនខ្វល់ពីអ្នកឃ្លាំមើលឯករាជ្យជាមួយនឹង "ធ្មេញដ៏មុតស្រួច" ។*

រដ្ឋមន្ត្រីការបរទេសសិង្ហបុរីលោក ចច អ៊ីវ បានស្នើសុំថា ក្រុម "យ៉ាងហោចណាស់គួរតែមានអណ្តាត ហើយដែលជាអណ្តាតដែលអាចប្រើការបាន" ។

ក្នុងខែតុលា ឆ្នាំ២០០៩ រដ្ឋមន្ត្រីការបរទេសអាស៊ានបានបង្ហាញពីសមិទ្ធផលគឺក្រុមគោលការណ៍យោងសម្រាប់គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស ។ ប្រមុខរដ្ឋអាស៊ាននៅក្នុងកិច្ចប្រជុំជួរការលើកទី១៥របស់សមាគមបានសរសើរពីគណៈកម្មាធិការថ្មីក្នុងការប្រកាសពី "ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ" របស់គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស និង "ម៉ាស៊ីនសម្រាប់ដំណើរការអភិវឌ្ឍសង្គម និងយុត្តិធម៌" និង "ឥទ្ធិពលរបស់ស្ថាប័នក្នុងទំនួលខុសត្រូវលើការលើកស្ទួយនិងការពារសិទ្ធិមនុស្សក្នុងតំបន់អាស៊ាន" ។ ក្រោយពីវោហារសាស្ត្រដ៏ខ្ពង់ខ្ពស់នេះ ទោះបីជាយ៉ាងណាក៏ដោយក្រុមគោលការណ៍យោងបានបង្កើតស្ថាប័នមួយដែលមានកម្រិតប៉ុណ្ណោះ ។

ក្រុមគោលការណ៍យោងបានបង្កើតនូវមូលដ្ឋានបទដ្ឋានដូចគ្នាទៅនឹងបទដ្ឋានការពុះពារសង្គ្រាមដែលបានកើតឡើងក្នុងកិច្ចព្រមព្រៀងអាស៊ាន ។ ក្នុងមាត្រា១បានបញ្ជាក់អំពីគោលបំណងគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សគឺដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្សហើយនិងមូលដ្ឋានសេរីភាពរបស់ប្រជាពលរដ្ឋអាស៊ាន" ។ ទោះបីជាយ៉ាងណាក៏ដោយ វាគ្រាន់តែជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងជាច្រើនទៀតក្នុងការ "លើកស្ទួយស្ថេរភាព និងសុខដុមរមនាក្នុងតំបន់" នៅខណៈពេលដែល "ត្រូវតែគិតគូរអំពីលក្ខណៈពិសេសរបស់ជាតិ និងក្នុងតំបន់ ហើយនិងការគោរពទៅលើប្រវត្តិសាស្ត្រ វប្បធម៌ និងសាសនាផ្សេងៗគ្នា ព្រមទាំង

ធ្វើឲ្យមានតុល្យភាពរវាងសិទ្ធិនិងទំនួលខុសត្រូវ" ។ ក្នុងមាត្រា២ គឺបញ្ជាក់ពីគណៈកម្មាធិការទទួលបន្ទុកលើកស្ទួយ និងការពារសិទ្ធិមនុស្សនៅក្នុងឥរិយាបថមួយដែលគោរពតាមបទដ្ឋាននៃភាពគ្មានសិទ្ធិជ្រៀតជ្រែក និងការគោរពលើទំនួលខុសត្រូវជាមូលដ្ឋានរបស់រដ្ឋ និងជៀសវាងនូវស្តង់ដារទ្វេនិងការធ្វើនយោបាយនីយកម្ម ដែលជាស្បែកគ្របមុខរបស់លោកខាងលិច ។ ជំនួសមកវិញ អាស៊ាននឹងបន្តនូវ "នីតិវិធីនៃការស្តាបនា និងការមិនប្រទល់មុខ" ហើយនឹងសង្កត់ធ្ងន់លើ "សហប្រតិបត្តិការ" រួមទាំងសំដៅយក "នីតិវិធីនៃការវិវត្ត" ។

គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សក៏ត្រូវបានបង្កើតឡើងជាមួយនឹងទម្រង់ដែលបង្ខំឲ្យមានការទប់ទល់ទៅនឹងសមត្ថភាពរបស់វានៅក្នុងការតបត និងការអនុវត្តសិទ្ធិមនុស្សរបស់អាស៊ាន ។ រាជរដ្ឋាភិបាលអាស៊ាន ជាពិសេសគឺអ្នកដែលគោរពលើសិទ្ធិសេរីភាពតិចតួចជាងគេនៅក្នុងសមាគមគឺបានដឹងច្បាស់ពីសក្តានុពលភាពនៃក្រុមសិទ្ធិមនុស្សដែលបង្កើតឲ្យមានសម្ពាធដែលពួកគេមិនចង់បាន ។ ដូច្នេះរដ្ឋាភិបាលអាស៊ានបានសម្របសម្រួលគណៈកម្មាធិការនៅក្នុងឥរិយាបថដែលអាចទប់ទល់ទៅនឹងការរឹតបន្តឹងសកម្មភាព និងការកំណត់ការលោតសន្ទឹងរបស់រាជរដ្ឋាភិបាលទៅលើសម្ពាធបញ្ហាសិទ្ធិមនុស្ស ។

### ក) ភាពទន់ខ្សោយនៃអាជ្ញាធរឯករាជ្យ

នៅពេលអាជ្ញាធរឯករាជ្យត្រូវបានផ្តល់ឲ្យនូវឯករាជ្យភាពគ្រប់គ្រាន់នោះ និងត្រលប់ទៅរកនយោបាយ រឹងមាំសមរម្យមួយ ខ្លឹមសារនៃសិទ្ធិមនុស្សក្នុងតំបន់នឹងបានបំពេញតួនាទីជាអ្នកកាត់សេចក្តីឯករាជ្យមួយជាគណៈកម្មាធិការប្រតិបត្តិ និងជាអ្នកបង្កើតបទដ្ឋានមួយដែលផ្តល់នូវសក្តានុពលភាពសម្រាប់ការអភិវឌ្ឍ និងការបាចសាចនូវគោលការណ៍សិទ្ធិមនុស្ស ។ តុលាការសិទ្ធិមនុស្សនៃទ្វីបអឺរ៉ុប និងគណៈកម្មការអន្តរអាមេរិកកាំង រួមទាំងតុលាការសិទ្ធិមនុស្ស គឺប្រហែលជាឧទាហរណ៍នៃស្ថាប័នដ៏ល្អនៅក្នុងតំបន់ ។ តុលាការទាំងពីរនេះគឺអាចសង្កេតលើករណីជាច្រើនដែលនាំយកមកដោយពលរដ្ឋសម្ងាត់និងអ្នកស៊ុកវិនិច្ឆ័យពីបញ្ហាប្រឆាំងនឹងរដ្ឋ ។ អ្នកខ្លះបានតវ៉ាថា ទ្វីបអាស៊ីក៏បានទទួលបាននូវតុលាការក្នុងតំបន់ដែលមានលក្ខណៈស្រដៀងគ្នាដែលអាចផ្តល់ឲ្យអ្នកដែលរស់នៅទ្វីបអាស៊ីទទួលបាននូវសម្លេងយុត្តិធម៌ជាជាងអ្នកដទៃដែលទទួលបាននៅតំបន់របស់ខ្លួន ។ ទោះបីជាយ៉ាងណាក៏ដោយ គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សនៅតែស្ថិតនៅឆ្ងាយពីគំរូទាំងនៅក្នុងលក្ខខណ្ឌនយោបាយឯករាជ្យ និងអំណាចស្ថាប័ន ។

ការរចនារបស់គណៈកម្មាធិការបានចង្អុលបង្ហាញពីគុណភាពរបស់គណៈកម្មាធិការអន្តររដ្ឋាភិបាល ។ គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សគឺសមាគមរាជរដ្ឋាភិបាលដ៏ចាំបាច់មួយដូចជា អាស៊ានផ្ទាល់ ។ ក្រុមគោលការណ៍យោងរបស់គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សបានធ្វើការបញ្ជាក់ច្បាស់ថា វាគឺជា "ក្រុមប្រឹក្សា" នៅពេលដែលការសម្រេចចិត្តត្រូវបានបង្កើតឡើងដោយផ្អែកលើការអនុវត្តទូទៅខាងការទូតអាស៊ានស្តីពី "ការប្រឹក្សានិងការព្រមព្រៀង" ឬមួយក៏មានពាក្យមួយទៀតគឺថា សមាជិករដ្ឋនីមួយៗអាចមានសិទ្ធិបដិសេធទៅលើសេចក្តីសម្រេចរបស់ទីភ្នាក់ងារ សូម្បីតែសេចក្តីសម្រេចចិត្តដែលជាប់ទាក់ទងនឹងបទអាក្រក់របស់រដ្ឋ ។

ការទាមទារការយល់ព្រមគឺជាស្ថានការណ៍ដ៏មានសក្តានុពលភាព ដោយសារតែមន្ត្រីដែលមានទីភ្នាក់ងារ គឺជារដ្ឋាភិបាលដែលត្រូវបានចាត់តាំងជាទូទៅមកពីក្រសួងការបរទេស និងមានទំនួលខុសត្រូវទៅកាន់រដ្ឋាភិបាលម្ចាស់ផ្ទះ ។ រដ្ឋាភិបាលម្ចាស់ផ្ទះត្រូវបានហៅថាជា "អ្នកតំណាង" ច្រើនជាជាង "ទីភ្នាក់ងារ" ដែលផ្តល់នូវការសង្កត់ធ្ងន់ទៅលើភាពស្មោះត្រង់របស់ខ្លួនទៅកាន់ម្ចាស់ផ្ទះមូលធន ។ អ្នកតំណាងពីររូបមកពីប្រទេសឥណ្ឌូនេស៊ីលោក រ៉ាហ្វិនឌី ចាស៊្មិន និងមកពីប្រទេសថៃលោកស្រី ប្រាផាពិតធីរ៉ាម៉េសរេ ត្រូវបានបោះឆ្នោតឲ្យដោយក្រុមឯករាជ្យក្នុងប្រទេសរបស់ខ្លួនបន្ទាប់ពីបង្ហាញពីភាពច្បាស់លាស់នៃដំណើរការដែលអនុញ្ញាតសម្រាប់បទដ្ឋានសាធារណៈ ប៉ុន្តែចំណែកឯអ្នកផ្សេងវិញជាទូទៅត្រូវបានតែងតាំងដោយរដ្ឋាភិបាលរបស់ខ្លួនទៅវិញ ។

គណៈកម្មាធិការរដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សពុំមានលេខាធិការអចិន្ត្រៃយ៍ទេ ។ អ្នកតំណាង គឺមិនត្រឹមតែគ្មានភាពអចិន្ត្រៃយ៍ ថែមទាំងគ្មានភាពលះបង់ការិយាធិបតេយ្យ ។ ជំនួសមកវិញ អ្នកតំណាងទាំងអស់នោះធ្វើការក្នុងការិយាល័យនៅប្រទេសរបស់ខ្លួនហើយនឹងរាយការណ៍ទៅឲ្យរដ្ឋមន្ត្រីការបរទេសដែលភាគច្រើនគឺមានទំនាក់ទំនងនឹងគ្នា ។ អ្នកតំណាងធ្វើការប្រជុំយ៉ាងហោច

ណាស់ពីរដងក្នុងមួយឆ្នាំ នៅឯលេខាធិការដ្ឋានអាស៊ានក្នុងទីក្រុងចាកាតា ឬមួយក៏នៅក្នុងទីក្រុងប្រទេសដែលជាតំណាងអាស៊ានប្រចាំឆ្នាំ ។ ការបង្កើតបែបនេះ មិនទំនងជាធ្វើឲ្យអ្នកតំណាងនិងបុគ្គលិកសមាជិករបស់ពួកគេអភិវឌ្ឍនូវឆន្ទៈក្នុងការបង្កើតសញ្ញាណឯករាជ្យ ឬចំណងទាក់ទងរវាងបុគ្គលតាមទារនូវការបង្កើតបទដ្ឋានដ៏រឹងមាំ ។

គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានសិទ្ធិមនុស្សក៏មានចំណុចខ្សោយដែរ ។ គណៈកម្មាធិការបានរាយការណ៍ទៅកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន ដូច្នេះហើយវាអាចមានភាពបត់បែនទៅតាមកាលៈទេសៈ ដែលបញ្ជាក់ដោយអ្នកដឹកនាំសមាគម ។ វាគឺខ្វះលទ្ធភាពនៅក្នុងការទទួលដឹងពូនូវករណីមួយចំនួននិងការផ្តួចផ្តើមសង្កេតការណ៍ឯករាជ្យទៅលើលក្ខណៈពិសេសការរំលោភបំពានសិទ្ធិ ។ ថ្វីបើអញ្ចឹងក៏ដោយ ដីការបស់គណៈកម្មាធិការបានរួមបញ្ចូលនូវបញ្ជីតារាងគោលដៅនយោបាយដែលអាចទទួលយកបាន ។ គោលដៅទាំងនេះរួមមាន ការអភិវឌ្ឍយុទ្ធសាស្ត្ររួម ការធ្វើឲ្យប្រសើរឡើងនូវសេចក្តីប្រកាសសិទ្ធិមនុស្សក្នុងតំបន់ ការអប់រំជាសាធារណៈ ការផ្តល់ឲ្យនូវជំនួយបច្ចេកទេស និងជំនួយសម្រាប់កសាងសមត្ថភាព ការលើកស្ទួយគោលការណ៍ និងឧបករណ៍សិទ្ធិមនុស្សអន្តរជាតិ ការទទួលយកនូវព័ត៌មាន និងការចូលរួមសន្ទនារវាងរដ្ឋាភិបាល និងសង្គមស៊ីវិលក្នុងការអភិវឌ្ឍ «មុខងារនិងយុទ្ធសាស្ត្រទូទៅ» ។

ការផ្តោតលើស្ថាប័ននេះគឺសម្រេចលើការលើកស្ទួយសិទ្ធិមនុស្សជាជាងការការពារ ។ ជម្រើសដ៏មានមនសិការនេះបានឆ្លុះបញ្ចាំងនូវកិច្ចខិតខំបន្តឲ្យសមាជិកទាំងអស់ចូលរួមអនុវត្ត ។ មន្ត្រីអាស៊ានជាន់ខ្ពស់ លោក ទើមសាក់ ឆេល័មជាឡានុជាប បានពន្យល់ថា «អាស៊ានគឺជាមូទ័រដ៏ពិតប្រាកដមួយ» «ហើយវាត្រូវតែមានភាពប្រាកដនិយម វាមិនមែនជាចំណង់ក្នុងការព្យាយាមលើកស្ទួយសហប្រតិបត្តិការសិទ្ធិមនុស្សនៅលើមូលដ្ឋាននៃ «តំហយរបស់សមាជិកអាស៊ាន» ។

ការការពារដ៏រឹងមាំនឹងតម្រូវឲ្យមានការហ៊ឹកហាត់អាជ្ញាធរសមាជិករដ្ឋទល់មុខគ្នាក្នុងការប្រតិបត្តិកាតព្វកិច្ច សិទ្ធិមនុស្ស និងការពារសិទ្ធិបុគ្គលនីមួយៗ ។ នៅក្នុងទ្រឹស្តីវាគឺអាចទៅរួច ។ សមាជិកអាស៊ានទាំងដប់ប្រទេសព្យាយាមអនុវត្តសកម្មភាពជាផ្លូវការដើម្បីឆ្ពោះទៅរកបទដ្ឋានសិទ្ធិមនុស្សដ៏ពិតប្រាកដ ។ ប្រទេសទាំងដប់បានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ និងអនុសញ្ញានៃការលុបបំបាត់រាល់ទម្រង់រើសអើងប្រឆាំងនឹងស្ត្រីភេទ សូម្បីតែមានការបម្រុងនៅក្នុងករណីខ្លះក៏ដោយ ។ ចាប់តាំងពីឆ្នាំ២០០៨មក សមាជិកអាស៊ានបានសរុបពីសេចក្តីថ្លែងការណ៍គូសបញ្ជាក់ពីសកម្មភាពរបស់ពួកគេនៅក្នុងការលុបបំបាត់អំពើហិង្សាប្រឆាំងនឹងស្ត្រី ការរារាំងនូវការជួញដូរសិទ្ធិមនុស្សជាពិសេសគឺលើស្ត្រីនិងកុមារ និងលើកស្ទួយសិទ្ធិកម្មករអន្តោប្រវេសន៍ ។ ឧបករណ៍ទាំងនេះនឹងផ្តល់ឲ្យនូវសារប្រយោជន៍នៃចំណុចចាប់ផ្តើមសម្រាប់ការពារសិទ្ធិមនុស្សនៅក្នុងតំបន់ដែលប្រជាពលរដ្ឋទទួលការរងគ្រោះ ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមគោលការណ៍យោងនៃគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សផ្តល់ឲ្យគណៈកម្មាធិការនូវអំណាចប្រតិបត្តិមិនជាក់លាក់ ។ គណៈកម្មាធិការនេះ ជំនួសដោយការភ្ជាប់ជាមួយសេចក្តីព្រាងសេចក្តីថ្លែងការណ៍ក្នុងតំបន់ ការផ្តល់ប្រឹក្សា និងការចេញនូវរបាយការណ៍ទូទៅអំពីលក្ខខណ្ឌសិទ្ធិមនុស្សក្នុងតំបន់ ។ របាយការណ៍ទាំងនោះពុំមែនជាឧបករណ៍អ្វីដែលប្លែកនោះទេ ហើយវានឹងបន្តធ្វើដរាបណាតែមានការព្រមព្រៀងជាឯកច្ឆន្ទ ។

### ១) ផ្លូវចង្អៀតសម្រាប់ទិសដៅដាក់គំនាប

វិធីទីពីរសម្រាប់កំណែទម្រង់ខ្លឹមសារសិទ្ធិមនុស្សក្នុងតំបន់គឺការផ្តល់ជាវេទិកាសម្រាប់រដ្ឋាភិបាលអនុវត្តទិសដៅដាក់គំនាប ។ គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សដូចដែលអាស៊ានផ្ទាល់គឺត្រូវបានបង្កើតឡើងក្នុងលក្ខខណ្ឌនិងបទដ្ឋានប្រឈមទៅនឹងគំនាបទាំងខាងក្នុងតំបន់និងខាងក្រៅតំបន់ ។ ក្រុមគោលការណ៍យោងបានអនុញ្ញាតអ្នកតំណាងគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សធ្វើការប្រឹក្សាជាមួយស្ថាប័នសិទ្ធិមនុស្សជាតិ ក្នុងតំបន់ និងអន្តរជាតិ ប៉ុន្តែគ្មានការផ្តល់អំណាចក្នុងការពាក់ព័ន្ធជាមួយនឹងមន្ត្រីការបរទេស និងវេទិកាអន្តរជាតិផ្សេងៗទេ ។ ក្រុមទីភ្នាក់ងារអន្តររដ្ឋាភិបាលអាស៊ានកំណត់ពីវិសាលភាពនៃឥទ្ធិពលខាងក្រៅឆ្លងតាមបណ្តាញមូលនិធិ ។ កម្មវិធីមួយចំនួនដែលបានបង្កើតឡើងដោយអាស៊ានទាក់ទងទៅនឹងសិទ្ធិមនុស្សគឺត្រូវបានផ្តល់មូលនិធិដោយអ្នកឧបត្ថម្ភខាងបស្ចិមប្រទេស ក៏ប៉ុន្តែក្រុមគោលការណ៍យោងបានធ្វើការចាត់ចែងថា «រាល់មូលនិធិនិងធនធានដទៃទៀតដែលទទួលបានមកពីប្រទេសដែលមិនមែនជា

សមាជិកអាស៊ានគួរតែត្រូវបានប្រើប្រាស់សម្រាប់ការលើកស្ទួយសិទ្ធិមនុស្ស ការកសាងសមត្ថភាព និងការអប់រំ» ។ ដូច្នេះហើយ មូលនិធិពីខាងក្រៅមិនអាចបញ្ចូនទៅក្នុងជម្លោះកិច្ចខិតខំប្រឹងប្រែងការពារសិទ្ធិមនុស្សបន្ថែមទៀតបាន ទេ ។

ប្រទេសសមាជិកអាស៊ានអាចដាក់គំនាបទៅក្នុងទម្រង់ការបញ្ចុះបញ្ចូលនិងការលើកទឹកចិត្តប្រសិនបើរដ្ឋទាំងនោះមានចិត្តដូចគ្នារួមមានប្រទេសឥណ្ឌូនេស៊ី និងប្រហែលជាប្រទេសថៃ និងហ្វីលីពីនឲ្យតស៊ូនិងដាក់សិទ្ធិមនុស្សខិតទៅចំណុចខ្ពស់នៅក្នុងរបៀបវារៈរបស់ខ្លួន ។ ក្នុងអំឡុងពេលឆាប់ៗខាងមុខនេះវាអាចទៅរួចថាប្រទេសទាំងនេះនឹងយល់ពីការខិតលំទោននៃការបញ្ចុះបញ្ចូលនិងសម្លេងនៃការព្រួយបារម្ភទៅលើសិទ្ធិមនុស្សជាអាទិភាព ។ នៅក្នុងការណែនាំពីគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស នាយករដ្ឋមន្ត្រីថៃ អាភីស៊ិត វីចាជីវ៉ា បានមានប្រសាសន៍ថា «បញ្ហាសិទ្ធិមនុស្សគឺមិនមែនជាការដាក់ទណ្ឌកម្មនោះទេ តែជាការភ្ញាក់រឭកការផ្តល់អំណាចនិងការធ្វើឲ្យប្រសើរឡើង» ។ ទស្សនៈវិជ្ជមានរបស់ប្រទេសឥណ្ឌូនេស៊ីថ្មីៗនេះគឺបានបង្ហាញពីការផ្លាស់ប្តូរយ៉ាងសំខាន់ក្នុងតំបន់ប៉ុន្តែវាស្ថិតនៅក្នុងកម្រិតនៃការទូទាត់ទៅលើអំពើដែលបានប្រព្រឹត្តនៅក្នុងប្រទេសថៃនិងហ្វីលីពីន ។ អតីតកាលរបស់ប្រទេសចិនដែលធ្លាប់បានកើតឡើងក្នុងតំបន់បានជួយឲ្យសមាជិករបស់ខ្លួនស្ថិតនៅឆ្ងាយពីការរិះគន់ ជាឧទាហរណ៍ ទីក្រុងប៉េកាំងបានស្វែងរកយុទ្ធសាស្ត្រចំណេញដោយការផ្តល់ជំនួយសព្វាវុធដល់មន្ត្រីធ្វើរដ្ឋប្រហារដែលមិនព្រមទទួលយកដោយប្រទេសជិតខាងដែលកាន់សេរីភាព និងប្រទេសលោកខាង លិច ។

ការដាក់គំនាបក៏អាស្រ័យទៅលើបទដ្ឋានបច្ចុប្បន្ន ។ បទដ្ឋានដ៏រឹងមាំរបស់អាស៊ានគឺភាពគ្មានសិទ្ធិក្នុងការជ្រៀតជ្រែកនិងការយល់ព្រមដោយពឹងលើផ្លូវការទូតគឺនៅតែជារបាំងសម្រាប់អន្តររដ្ឋក្នុងការគាំទ្រសិទ្ធិមនុស្ស ។ គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សបង្កើតបទដ្ឋានទាំងនេះឡើងដែលវាបានគូសបង្ហាញពីរដ្ឋដែលគ្មានសេរីភាពនៅក្នុងការសន្ទនា ប៉ុន្តែបែរជាសោកស្តាយនិងការពារពីការរិះគន់ ។ នៅក្នុងកម្រិតមួយអ្នកដឹកនាំអាស៊ានត្រូវបានគេវិនិច្ឆ័យថាមានការព្យាយាមគេចវេះហួសហេតុពីការរិះគន់ ហើយថាបានទទួលផលប្រយោជន៍ពីការចងចំណងមិត្តភាព និងការរក្សានូវទំនាក់ទំនងសន្តិភាពទៅវិញ ។ ទោះបីជាយ៉ាងណាក៏ដោយ ជារឿយៗយុទ្ធវិធីនេះអាចផ្តល់នូវការវាយប្រហារពីក្រោយខ្នង និងវិធីការពារខ្លួនរបស់ខ្លួនពីការរិះគន់ ។ លទ្ធភាពនៃការដាក់គំនាបគឺអាស្រ័យយ៉ាងខ្លាំងទៅនឹងទំនាក់ទំនងនៃកម្លាំងប្រឹងប្រែងដែលល្អនៅអាស៊ីជាយូរមកហើយ ។

### គ) ការញែកចេញពីតម្រូវការសាធារណៈ

យុទ្ធសាស្ត្រទីបីសម្រាប់ការផ្លាស់ប្តូរគោលនយោបាយគឺអាចមកពីថ្នាក់ក្រោមវិញ ។ ខ្លឹមសារនៃសិទ្ធិ មនុស្សក្នុងតំបន់អាចបម្រើជាប្រកឡារធំដែលឆ្លងកាត់ដោយសង្គមស៊ីវិល និងសមាជិកសាធារណៈក្នុងការដាក់សម្ពាធទៅលើរដ្ឋាភិបាល ។ ក្រុមសង្គមស៊ីវិលក្នុងតំបន់និងពលរដ្ឋដទៃទៀត ឬអ្នកប្រមូលផ្តុំគឺអាចផ្លាស់ប្តូរពីការគិតគូរទៅលើសារប្រយោជន៍នៃអ្នកដឹកនាំជាតិរបស់ខ្លួន បើសូម្បីតែផ្លាស់ប្តូរនូវជំនឿបទដ្ឋានរបស់អ្នកដឹកនាំទៅ នឹងកិច្ចការហួសប្រមាណ ។

កិច្ចព្រមព្រៀងអាស៊ានរួមបញ្ចូលទាំងគោលដៅនៃការបង្កើត «សមាគមមជ្ឈមណ្ឌលប្រជាជន» ហើយគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សត្រូវបានពាក់ព័ន្ធទៅនឹង «ការសន្ទនានិងការប្រឹក្សា» ជាមួយស្ថាប័នអាស៊ានដទៃទៀត និងផ្តល់ជំនឿទុកចិត្តដល់ស្ថាប័នសង្គមស៊ីវិល ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកដឹកនាំគ្មានសេរីភាពក្នុងទ្វីបអាស៊ី ជាទូទៅមើលឃើញពីសម្ពាធខ្លាំងរបស់សង្គមស៊ីវិលហាក់បីដូចជាបណ្តាសាទៅលើផលចំណេញរយៈពេលខ្លី ។ នេះគឺជាការជួយពន្យល់ពីហេតុផលដែលគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សត្រូវបានបង្កើតសម្រាប់សង្គមស៊ីវិល និងចំណងទាក់ទងសាធារណៈ ។

គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សបានរុញច្រានចោលនូវលិខិតបទដ្ឋានផ្សេងៗដោយក្រុមសង្គមស៊ីវិលក្នុងការពាក់ព័ន្ធទៅនឹងការពិភាក្សានីតិវិធីច្បាប់របស់ទីភ្នាក់ងារ ។ នៅក្នុងកិច្ចប្រជុំអាស៊ានជាផ្លូវការ បានប្រកាសពីការបង្កើតគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សក្នុងខែតុលា ឆ្នាំ២ ០ ០ ៩ អ្នកតំណាងមកពីក្រុមសង្គមស៊ីវិលមួយចំនួនបានដើរចេញពីកិច្ចប្រជុំ បានតវ៉ាថាគណៈកម្មាធិការគឺខ្វះភាពឯករាជ្យ សិទ្ធិអំណាច និងតម្លាភាព ។ អ្នកឃ្លាំមើលសិទ្ធិមនុស្សមិនព្រមទទួលនូវកម្រិតទំនាក់ទំនងរបស់គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ាន

ទទួលបន្ទុកសិទ្ធិមនុស្សទៅនឹងសង្គមស៊ីវិល ។ អ្នកឃ្លាំមើលសិទ្ធិមនុស្ស លោក ប្រេត អាដាម បានត្អូញត្អែរថា«គណៈកម្មាធិការអន្តររដ្ឋាភិបាល គឺតែងតែជាតួអង្គសំខាន់ទីពីរ ក៏ប៉ុន្តែបើស្ថាប័នអន្តររដ្ឋាភិបាលដែលមិនគិតគូរសូម្បីតែពលរដ្ឋរបស់ខ្លួននោះគឺជារឿងកំប្លែង និងជារឿងដែលឥតបានការ» ។

នៅក្នុងឆ្នាំដំបូងនៃប្រតិបត្តិការគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស ក្រុមសិទ្ធិមនុស្សបានចោទប្រកាន់សមាជិកខ្លួនថារួញរាក្នុងការបង្កើតនីតិវិធីច្បាប់ដូចជាការបិទទ្វារខ្លួនឯងទៅនឹងសង្គមស៊ីវិល ហើយនឹងការចៀសវាងនូវការបន្តពិភាក្សាទៅលើបញ្ហាសិទ្ធិមនុស្ស ។ នីតិវិធីច្បាប់ត្រូវបានបង្កើតនៅឯកិច្ចប្រជុំគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សលើកទី៤ក្នុងខែកុម្ភៈ ឆ្នាំ២០១១ហើយនឹងត្រូវបានហៅថាជា «សេចក្តីណែនាំសម្រាប់ប្រតិបត្តិការរបស់គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស» ។ ការផ្លាស់ប្តូរពីពាក្យច្បាប់ទៅជាសេចក្តីណែនាំប្រហែលជាកិច្ចខិតខំប្រឹងប្រែងដ៏ប៉ិនប្រសប់ដែលសង្កត់ធ្ងន់លើការប្រឹក្សារបស់គណៈកម្មាធិការដែលក្រៅផ្លូវការច្បាប់ ។ បើទោះបីជាមានការស្នើសុំពីក្រុមសាមគ្គីភាពទ្រទ្រង់ប្រជាពលរដ្ឋអាស៊ីដើម្បីឲ្យផ្សព្វផ្សាយចេញសេចក្តីណែនាំជាសាធារណៈក៏ដោយគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សមិនបានចែកចាយវាឲ្យបានទូលំទូលាយចាប់តាំងពីពេលដែលវាបានបង្កើតឡើង ។ ការបន្តការមិនពេញចិត្តរបស់អ្នកតំណាងជាច្រើនក្នុងការជួបជាមួយក្រុមសង្គមស៊ីវិលដែលរិះគន់នូវគោលនយោបាយរបស់ខ្លួននិងការបន្តការលុបលើកិច្ចសន្ទនាក្នុងកិច្ចប្រជុំជាបន្តបន្ទាប់របស់គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សជាការបង្ហាញថាសេចក្តីណែនាំផ្តល់ផលប្រយោជន៍តិចតួច ប្រសិនបើមិនមានកន្លែងសម្រាប់វត្តមានរបស់សង្គមស៊ីវិល ។

ភាពអសមត្ថភាពក្នុងការទទួលបាននិងសកម្មភាពក្នុងការដោះស្រាយទៅលើការត្អូញត្អែររបស់ជនរងគ្រោះ ឬអ្នកគាំទ្រគឺជាពិការភាពរបស់ស្ថាប័នយ៉ាងពិតប្រាកដ ។ ទម្រង់នោះពិតជាបានធ្វើឲ្យអន្តរាយដល់កេរ្តិ៍ឈ្មោះរបស់គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សរួចទៅហើយ ។ នៅចុងឆ្នាំ២០០៩ ប្រជាពលរដ្ឋ៥៦នាក់រួមមានទាំងអ្នកកាសែតជាច្រើន និងគ្រួសាររបស់បេក្ខជនដែលប្រឆាំងនឹងនយោបាយក្នុងស្រុកត្រូវបានសម្លាប់យ៉ាងឃោរឃៅនៅក្នុងខេត្តម៉ាគូអ៊ីនដាណាវ ខាងត្បូងប្រទេសហ្វីលីពីន ។ ក្រុមគ្រួសារជនរងគ្រោះបានដាក់លិខិតទៅកាន់គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សដើម្បីឲ្យជួយរកយុត្តិធម៌ និងសងដល់អ្នកទាំងនោះវិញពីរដ្ឋាភិបាលហ្វីលីពីន ។ រដ្ឋាភិបាលហ្វីលីពីននៅតែទទូចថាបញ្ហានេះគឺជាកិច្ចការផ្ទៃក្នុង ហើយថាគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សពុំមានកាតព្វកិច្ចក្នុងការឈឺឆ្អាលទៅលើរឿងនេះទេ ។ អ្នកតំណាងប្រទេសឥណ្ឌូនេស៊ីលោក រ៉ាហ៊ុនឌី ចាស្មីន បានបង្ហាញការសោកស្តាយ និងពន្យល់ថាៈ

*ប្រសិនបើខ្ញុំមានសិទ្ធិ ខ្ញុំនឹងដោះស្រាយវាភ្លាមៗ ។ ប៉ុន្តែគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សមានដប់ប្រទេសឯណោះ ។ ដូច្នេះវាត្រូវការពេលវេលាក្នុងការពិភាក្សាជាពិសេសគឺការពិភាក្សាដើម្បីស្វែងរកនីតិវិធីក្នុងការដោះស្រាយជាមួយនឹងការត្អូញត្អែរទាំងនោះ ។ ខ្ញុំអាចគ្រាន់តែនិយាយបានថា ខ្ញុំនឹងព្យាយាមដោះស្រាយឲ្យអស់ពីសមត្ថភាពដើម្បីពង្រឹងនូវតួនាទីរបស់គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស និងអំណាចរបស់យើង ។ ប៉ុន្តែដាក់ស្តែងវានឹងទាមទារពេលវេលាយូរបន្តិចហើយ» ។*

អ្នកគាំទ្រជនរងគ្រោះហ្វីលីពីនបានតវ៉ាថា អភ័យឯកសិទ្ធិរបស់រដ្ឋាភិបាលហ្វីលីពីននឹងរារាំងពីការដាក់បណ្តឹងក្នុងស្រុក ។ ការសម្រេចរបស់គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សនឹងបន្សល់ទុកជាមួយនឹងបណ្តឹងគ្មានការសើរើ ។ វិចារណកថាក្នុងតំបន់ស្រែកថ្ងូរថា «ក្តីសង្ឃឹមខ្ពស់សម្រាប់គណៈកម្មាធិការគឺបានធ្លុះបញ្ចាំងភាពដែលនៅមិនបានយូរ» ។ ដោយសារតែឧប្បត្តិហេតុនៅក្នុងខេត្តម៉ាគូអ៊ីនដាណាវ ជនរងគ្រោះដទៃទៀតដែលតែងតែពោលពីការរំលោភបំពានសិទ្ធិមនុស្សបានបញ្ជូនពាក្យត្អូញត្អែរទៅកាន់គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានសិទ្ធិមនុស្ស ។

និទោសកម្មអន្តរជាតិបានចេញការរិះគន់យ៉ាងដំណំទៅលើគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សឆ្លើយតបទៅនឹងអ្នកដាក់លិខិតបណ្តឹងនៅខេត្តម៉ាគូអ៊ីនដាណាវ ហើយ

ជំរុញឲ្យគណៈកម្មាធិការប្រើប្រាស់អំណាចរបស់ខ្លួនដែលរួមបញ្ចូលទាំងការការពារសិទ្ធិមនុស្សឲ្យនៅលើបន្ទាត់នៃច្បាប់អន្តរជាតិ និងមានស្តង់ដារ ។ បើពុំដូច្នេះទេ គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សនឹងប្រថុយប្រថានទៅលើការខាតបង់ទៅនឹងអ្វីដែលមិនជាប់ទាក់ទងនឹងការអនុវត្តគ្មានខ្លឹមសារនៅក្នុងទំនាក់ទំនងសាធារណៈ ។ ហើយវារឹតតែអាក្រក់ជាងនេះទៅទៀតគឺ ប្រសិនបើគណៈកម្មាធិការនេះគ្រាន់តែធ្វើឲ្យជនមួយចំនួន និងអ្នកអង្កេតការណ៍ខាងក្រៅស្កប់ចិត្តទេនោះ វាប្រហែលជាធ្វើឲ្យគម្របច្បាប់មានស្រទាប់ស្តើងសម្រាប់បន្តនូវការរំលោភបំពានតទៅទៀត ។ នេះគឺជាញាណដែលការបង្កើតសិទ្ធិមនុស្សគឺមានន័យប្រហាក់ប្រហែលទៅនឹងការដាក់គុកដោយឥតជញ្ជាំង ។

## ៤) ការបន្ថែមគណៈកម្មាធិការអាស៊ានទទួលបន្ទុកលើកស្ទួយ និងការពារស្ត្រី និងកុមារ

### ក) ការញែកដាច់ពីគ្នានៃទម្រង់ការអនុវត្ត

សូម្បីតែមុនការបង្កើតគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស ក្រុមគាំទ្រស្ត្រីបានធ្វើការប្រជុំនៅក្នុងទីក្រុងបាងកក ហើយនឹងគាំទ្រការត្រឡប់ទៅរកគម្រោងស្ថាប័នដោះស្រាយ ជាពិសេសតែលើសិទ្ធិស្ត្រី និងកុមារ ។ អ្វីដែលជួយបន្តិចការសម្ភោធគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សបានផ្តល់ជាកាតាលីករក្នុងការចាប់ផ្តើមឡើងវិញនូវការពិភាក្សាដែលស្ងប់ស្ងាត់យូរមកហើយទៅលើគណៈកម្មាធិការដែលសុបិនដូចទៅនឹងអ្នកជំនាន់មុនរបស់គេ ។ ប្រាំមួយខែក្រោយមកគណៈកម្មាធិការអាស៊ាន ទទួលបន្ទុកលើកស្ទួយនិងការពារស្ត្រី និងកុមារត្រូវបានបង្កើតគឺនៅក្នុងខែមេសាឆ្នាំ២០១០ ហើយនឹងមានទម្រង់ស្រដៀងគ្នាមួយចំនួនទៅនឹងគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានសិទ្ធិមនុស្ស ។ ដូចគ្នាទៅនឹងគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សស្ថាប័ននេះគឺជាស្ថាប័នប្រឹក្សាអន្តររដ្ឋាភិបាលដោយពុំមានលេខាធិការអាជ្ញាកណ្តាល ឬមួយក៏អាជ្ញាធរមានសមត្ថកិច្ច ។ រដ្ឋសមាជិកអាស៊ាននីមួយៗបានបញ្ជូនអ្នកតំណាងពីររូបដែលម្នាក់ផ្តោតទៅលើសិទ្ធិស្ត្រីនិងម្នាក់ទៀតផ្តោតលើសិទ្ធិកុមារទៅក្នុងការជួបប្រជុំពីរដងក្នុងមួយឆ្នាំ ។ ក្រុមគោលការណ៍យោងនិងអ្នកដឹកនាំគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានលើកស្ទួយសិទ្ធិមនុស្សរួមមាន ការព្រមានជាច្រើនសង្កត់ធ្ងន់ទៅលើតួនាទីបឋមរបស់រដ្ឋាភិបាលជាតិ និងការទាមទារ "ការប្រឹក្សានិងការព្រមព្រៀង" "ការជៀសវាងនូវស្តង់ដារទ្វេនិងនយោបាយនីយកម្ម" ហើយនិង "ការស្ថាបនាភាពមិនតទល់មុខដាក់គ្នា និងនីតិវិធីនៃសហប្រតិបត្តិការ" ។

ទោះបីជាយ៉ាងណាក៏ដោយ គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សនិងគណៈកម្មាធិការអាស៊ានទទួលបន្ទុកលើកស្ទួយ និងការពារស្ត្រី និងកុមារមានភាពខុសប្លែកពីគ្នាយ៉ាងសន្ធឹក ។ ទីមួយគណៈកម្មាធិការអាស៊ានទទួលបន្ទុកលើកស្ទួយ និងការពារស្ត្រី និងកុមារបានតភ្ជាប់នូវអំណាចរបស់វាទៅនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ និងអនុសញ្ញានៃការលុបបំបាត់រាល់ទម្រង់រើសអើងប្រឆាំងនឹងស្ត្រី និងគណៈកម្មាធិការអង្គការសហប្រជាជាតិដែលទទួលខុសត្រូវទៅលើការអនុវត្ត ។ ការបោះយុថ្កាកិច្ចការងារគណៈកម្មាធិការអាស៊ានទទួលបន្ទុកលើកស្ទួយនិងការពារស្ត្រីនិងកុមារទៅក្នុងកាតព្វកិច្ចនៃសន្ធិសញ្ញាអាចធ្វើឲ្យគណៈកម្មាធិការមានភាពងាយស្រួលសម្រាប់គាំទ្រកិច្ចព្រមព្រៀង ទោះបីជាមានការបម្រុងជាច្រើនអាស្រ័យការអ្នកចុះហត្ថលេខា អាស៊ានទៅក្នុងការអនុវត្តសកម្មភាពលម្អិតណាមួយនោះ ។ ភាពខុសគ្នាទីពីរគឺគណៈកម្មាធិការអាស៊ានទទួលបន្ទុកលើកស្ទួយ និងការពារស្ត្រីនិងកុមារលេចឡើងក្នុងរូបភាពដែលមានចំណងទាក់ទងតិចតួចជាងទៅនឹងការពាក់ព័ន្ធនៃការការពារសិទ្ធិមនុស្សទូទៅ ។ នៅក្នុងចំណោមផ្នែកផ្សេងទៀត ក្រុមគោលការណ៍យោងរបស់វាមានសមត្ថកិច្ច "គាំទ្រតំណាងឲ្យស្ត្រីនិងកុមារ" លើកស្ទួយការអនុវត្តនូវច្បាប់ដែលជាប់ពាក់ព័ន្ធហើយនឹងដាក់ចំពោះមុខនូវគោលនយោបាយនិងកម្មវិធីនានាក្នុងការការពារសិទ្ធិ ។ អំណាចនៃការការពារដ៏រឹងមាំនៃគណៈកម្មាធិការអាស៊ានលើកស្ទួយ និងការពារស្ត្រី និងកុមារដែលបណ្តាលមកពីការរំពឹងទុកលើសិទ្ធិស្ត្រីនិងកុមារគឺមានការងាយរងគ្រោះតិចជាជាងសិទ្ធិប្រឆាំងនឹងគោលនយោបាយ ។

### ខ) ការពាក់ព័ន្ធនឹងស្ថាប័នគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស

ការបង្កើតនូវគណៈកម្មាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រកបដោយភាតរភាពបានបង្ហាញពីភាពជោគជ័យនៃការសាមគ្គីរួមប៉ុន្តែដោយឈរលើគោលជំហរនៃការគោរពយ៉ាងជាក់លាក់ ។

កិច្ចព្រមព្រៀងសំដៅទៅលើខ្លឹមសារសិទ្ធិមនុស្សទោលមិនមែនជាដៃគូនោះទេ ។ នៅពេលដែលគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សត្រូវបានបង្កើតអតីតលេខាធិការជាន់ខ្ពស់ លោក អ៊ុង កេងយុង បានលើកឡើងថា "ស្ថាប័ននេះ ជាដំបូងផ្តោតទៅលើសិទ្ធិស្ត្រី កុមារ និងកម្មករអន្តោប្រវេសន៍ ហើយនឹងដោះស្រាយជាមួយនឹងផ្នែកផ្សេងៗ ទៀតដែលត្រូវបានលើកឡើងនិងធ្វើការឯកភាពដោយសមាជិក" ។ ដូច្នេះការបង្កើតគណៈកម្មាធិការអាស៊ានលើកស្ទួយ និងការពារស្ត្រី និងកុមារគឺលើកយកនូវគណៈកម្មាធិការពីរដែលដោះស្រាយទៅនឹងបញ្ហាស្រដៀងគ្នាក្នុងការអនុវត្តដើម្បីធ្វើឲ្យប្រសើរឡើងជាបន្តបន្ទាប់ ។

គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សជាផ្លូវការគឺ "គ្របដណ្តប់ស្ថាប័នសិទ្ធិមនុស្សក្នុងអាស៊ាន" ហើយគណៈកម្មាធិការអាស៊ានទទួលបន្ទុកលើកស្ទួយនិងការពារស្ត្រី និងកុមារ គឺទាមទារការសហការជាមួយនឹងគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សទៅលើបញ្ហាដែលជាប់ពាក់ព័ន្ធនឹងស្ត្រី និងកុមារ ក៏ប៉ុន្តែស្ថាប័ននេះមិនរណបទៅនឹងស្ថាប័នគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សនោះទេ ។ នេះគឺជាការបង្ហាញពីអ្វីដែលមន្ត្រីអាស៊ានបានហៅថាជា "ផ្លូវនៃបញ្ហា" ប៉ុន្តែអ្នកវិភាគមួយចំនួនទៀតពណ៌នាថាជា "ទីលានចម្បាំង" ។ យោងទៅតាមប្រភពមួយរបស់ក្រុមអាជ្ញាធរ ស្ថាប័នទាំងពីរ នេះអាចប្រកួតប្រជែងគ្នាក្នុងការទទួលបានជំនួយហិរញ្ញវត្ថុដូចដែលពួកគេត្រូវបានអនុញ្ញាតឲ្យស្វែងរកប្រភពចំណូលទាំងមូលនិធិខាងក្នុងនិងខាងក្រៅ ។ ប្រសិនបើស្ថាប័នទាំងពីរនេះធ្វើអ្វីឲ្យហួសពីតម្រូវការនោះ ម្នាក់ឬក៏ទាំងពីរអាចធ្វើឲ្យបាត់បង់នូវជំនួយពីអ្នកឧបត្ថម្ភ ។ គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស និងទីភ្នាក់ងារអាស៊ានលើកស្ទួយនិងការពារស្ត្រី និងកុមារ មិនបានប្រជុំរួមគ្នាទេរហូតដល់កិច្ចប្រជុំលើកទី៧របស់គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សដែលបានធ្វើឡើងខែធ្នូឆ្នាំ ២០១១ ។ កិច្ចប្រជុំនោះ បានបង្កើតនូវសេចក្តីថ្លែងការណ៍ដ៏សមស្របដែលទទួលស្គាល់ទាំងភាគីសងខាង និងការធ្វើសច្ចាប្រណិធាននៅក្នុងការសហការ ។ ទោះបីជារដ្ឋមន្ត្រីការបរទេសអាស៊ាន និងក្រុមគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស និងគណៈកម្មាធិការអាស៊ានទទួលបន្ទុកលើកស្ទួយ និងការពារស្ត្រី និងកុមារបានធ្វើការអះអាងពីការអនុវត្ត"តាមលំដាប់" អាទិភាពក៏ដោយ ក៏ពុំមានគម្រោងដ៏ជាក់លាក់ណាមួយត្រូវបានលេចចេញជារូបរាងនៅឡើយទេ ។

## ៤) សេចក្តីសន្និដ្ឋានៈ ការវិវត្តរបស់ស្ថាប័ននាពេលអនាគត

គំនិតនៃការង្កើតស្ថាប័ន គឺការចាប់យកនូវជ្រុងពីរសំខាន់នៃការជម្នះរបស់អាស៊ានលើការដោះស្រាយបញ្ហាសិទ្ធិមនុស្សដែលអាចជាការគំរាមកំហែងទៅដល់ចំណាប់អារម្មណ៍អ្នកកំពុងកាន់តំណែង និងជាក្រុមបទដ្ឋានដែលអាចជួយឲ្យសមាគមអភិវឌ្ឍការរស់នៅរបស់ប្រជាពលរដ្ឋបានប្រសើរ ។ ទាំងនេះគឺជាកញ្ចក់ឆ្លុះបញ្ចាំងពីការពិតរបស់ស្ថាប័នទាំងពីរ ។ នៅក្នុងទម្រង់បច្ចុប្បន្នគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សហាក់បីដូចជាមិនទំនងជាមានឥទ្ធិពលអ្វីខ្លាំងក្លាទៅលើសិទ្ធិសេរីភាពនយោបាយនិងស៊ីវិលនៅក្នុងសមាជិករដ្ឋអាស៊ាននោះទេ ។ រចនាសម្ព័ន្ធ និងច្បាប់សម្រេចរបស់ស្ថាប័នអាចរឹបអូសនូវអំណាចស្ថាប័ន "ពីថ្នាក់ខ្ពស់មកទាប" និងអាចដាក់បន្ទុកក្នុងការទប់ទល់ទៅលើសម្ពាធមជ្ឈដ្ឋានជុំវិញឬអាចប្រឈមមុខពី "ថ្នាក់ទាបទៅខ្ពស់" ដែលមកពីសង្គម ស៊ីវិល និងសាធារណៈ ។ ស្ថាប័ននេះរួមជាមួយនឹងគណៈកម្មាធិការអាស៊ានទទួលបន្ទុកលើកស្ទួយ និងការពារសិទ្ធិស្ត្រី និងកុមារទំនងជាផ្តោតលម្អិតទៅលើផ្នែកបន្ទាប់បន្សំដែលមានគំនាបនយោបាយតិចតួចបំផុតទៅកាន់រដ្ឋាភិបាលអាស៊ានដូចដែលស្ថាប័នស្វែងរកនូវការការពារលើស្ត្រី កុមារ និងកម្មករអន្តោប្រវេសន៍ ។

យ៉ាងណាក៏ដោយ ទីភ្នាក់ងារទាំងពីរនេះគឺត្រូវបានទទួលស្គាល់ជារួមដោយប្រមុខរដ្ឋអាស៊ានដែលថា ប្រជាពលរដ្ឋរបស់ខ្លួនគឺមានសិទ្ធិក្នុងការទទួលបានការការពារជាក់លាក់ ។ ច្រកទ្វារនៃរបបសិទ្ធិមនុស្សឥឡូវនេះ ត្រូវបានបើកចំហ ហើយចំពោះអ្នកដែលគាំទ្រមុខតែនឹងធ្វើឲ្យទ្វារមួយនេះបើកចំហកាន់តែធំ ។ ជនខាងក្រៅនិងសង្គមស៊ីវិលក្នុងតំបន់កំពុងតែរង់ចាំក្នុងការទាញផលប្រយោជន៍ពីឱកាសនេះ ។ រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក លោកស្រីហ៊ីលឡារី គ្លីនតុន មានប្រសាសន៍ថា "គាំទ្រយ៉ាងពេញទំហឹង" សម្រាប់គណៈកម្មាធិការនេះ ហើយទាំងសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុបត្រូវបានស្នើសុំឲ្យមកទស្សនាជាផ្លូវការដោយអ្នក

តំណាងគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស និងបុគ្គលិកនៅចុងឆ្នាំ២០១០ ។ អាស៊ានទំនងជាត្រូវបានទទួលរង្វាន់ពីប្រទេសលោកខាងលិចប្រសិនបើគណៈកម្មាធិការបន្តអនុវត្តតាមរបៀបវារៈ ។

គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស និងគណៈកម្មាធិការអាស៊ានទទួលបន្ទុកលើកស្ទួយ និងការពារសិទ្ធិស្ត្រី និងកុមារត្រូវបានបង្កើតឡើងដើម្បីបង្កើននូវបណ្តាញស្ថាប័នរួមដែលរួមបញ្ចូលទាំងគណៈកម្មាធិការក្នុងតំបន់ផ្សេងៗទៀតដូចជានៅក្នុងទ្វីបអាហ្វ្រិក អាមេរិកឡាទីន និងវេទិកាអាស៊ីប៉ាស៊ីហ្វិក នៃស្ថាប័នជាតិសិទ្ធិមនុស្ស ។ បញ្ជាក់បន្ថែមគឺការរួមបញ្ចូលគណៈកម្មាធិការជាតិមួយចំនួនមកពីទ្វីបអាស៊ីនិងស្ថាប័ននានាលើសកលលោក ។ ការិយាល័យក្នុងតំបន់របស់អង្គការសហប្រជាជាតិសម្រាប់គណៈកម្មាធិការជាន់ខ្ពស់លើសិទ្ធិមនុស្សមានទីតាំងនៅក្នុងទីក្រុងបាងកក និងរដ្ឋអាស៊ីពីរទៀតគឺប្រទេសម៉ាឡេស៊ី និងប្រទេសថៃដែលថ្មីៗនេះទទួលបានសម្លេងគាំទ្រជាក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ។ ការធ្វើអន្តរកម្មជាមួយក្រុមទាំងនេះមិនបានធានាឲ្យអាស៊ាននូវយុទ្ធវិធីក្នុងការផ្លាស់ប្តូរទៅលើបញ្ហាសិទ្ធិមនុស្សភ្លាមៗខាងមុខនេះទេ ក៏ប៉ុន្តែវាបានបង្ហាញពីឱកាសយ៉ាងច្បាស់សម្រាប់អាស៊ានក្នុងការស្វែងយល់ និងការសាយភាយបទដ្ឋាននានា ។

អ្នកតំណាងគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស និងគណៈកម្មាធិការអាស៊ានទទួលបន្ទុកលើកស្ទួយ និងការពារសិទ្ធិស្ត្រី និងកុមារ ជាពិសេសអ្នកដែលបង្កើតវាមានអំណាចនៅមានកម្រិត នៅក្នុងការពាក់ព័ន្ធជាមួយនឹងសង្គមស៊ីវិល ប៉ុន្តែត្រូវបានអនុញ្ញាតនៅក្នុងការប្រឹក្សា ។ ក្នុងការប្រតិបត្តិការឆ្នាំដំបូងគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សបានទទួលការរាយការណ៍ចំនួន១៦ករណី ពីការរំលោភបំពានលើសិទ្ធិមនុស្ស ។ ថ្វីបើមានកង្វះទៅនឹងការឆ្លើយតបដូចជាការត្អូញត្អែរនឹងត្រូវតែបានបន្តដើម្បីគៀនឲ្យអាស៊ាន និងសមាជិករដ្ឋាភិបាលរបស់វាធ្វើការឆ្លើយតប ។ គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សផ្តល់ជាវេទិកាសម្រាប់ឲ្យអ្នកគាំទ្រអាចបញ្ចេះបញ្ចូលការព្រួយបារម្ភលើសិទ្ធិមនុស្សក្នុងកម្រិតតំបន់ ហើយក្នុងករណីខ្លះទៀតគឺទាមទារនូវការអាណិតច្រើនជាងអ្វីដែលពួកគេមានក្នុងតំបន់ ។ កិច្ចប្រជុំនិងរបាយការណ៍របស់ស្ថាប័នមិនត្រូវការការសម្រេចចិត្តដែលចង់រឹតសមាជិករបស់វាឲ្យក្លាយជាឧបករណ៍ចាំបាច់ក្នុងការផ្គត់ផ្គង់នូវការផ្លាស់ប្តូររបស់ប្រជាពលរដ្ឋនិងការប្រឆាំងទៅនឹងការកែប្រែដែលជារឿយៗត្រូវបានញុះញង់ដោយ ជនសង្គមស៊ីវិល និងអ្នកនយោបាយមួយចំនួនក្នុងប្រព័ន្ធអាស៊ីក្នុងស្រុក ។ ចុងបញ្ចប់គំនាបពី "ថ្នាក់ក្រោមទៅថ្នាក់លើ" នឹងក្លាយជាយានសម្រាប់ការផ្លាស់ប្តូរការអនុវត្តសិទ្ធិមនុស្សក្នុងតំបន់អាស៊ីអាគ្នេយ៍ ។

បន្ថែមពីលើឥទ្ធិពលមកពីខាងក្រៅ និងគំនាបពីថ្នាក់ក្រោមទៅថ្នាក់លើការដឹកនាំជាតិស្ថិតក្នុងក្របខណ្ឌអាស៊ានអាចជាគន្លឹះក្នុងការវិវត្តរបស់ស្ថាប័ន ។ អាស៊ានតែងតែព្យាយាមក្នុងការពង្រឹងសមាជិកដែលស្ថិតនៅក្រោយគេឲ្យមានលំនឹង ។ ទោះបីជាយ៉ាងណាក៏ដោយ មានពេលខ្លះរដ្ឋាភិបាលអាស៊ានបង្ហាញពីកំហឹងទៅលើការវិវត្តយឺតនៃការផ្លាស់ប្តូរ ។ ប្រទេសឥណ្ឌូនេស៊ីដែលត្រូវបានគេចាត់ទុកអំពីបញ្ហាសិទ្ធិមនុស្សប្រហែលជា៤០ភាគរយនៃចំនួនប្រជាជនក្នុងតំបន់ តែឥឡូវនេះគឺជាប្រទេសមានការការពារសិទ្ធិមនុស្ស និងការជំរុញឲ្យមានការយល់ដឹងលើសិទ្ធិមនុស្សដែលវាជារឿងដ៏គួរឲ្យភ្ញាក់ផ្អើលជាហេតុនាំឲ្យអ្នកជំនាញចោទសួរថាវាជា "ការហួសប្រមាណរបស់អាស៊ាន" ហើយធ្វើឲ្យមានគំនាបទៅកាន់សមាជិកតូចៗដទៃទៀត ។ ការរក្សានូវ "ការជឿជាក់" និង "អ្វីដែលពាក់ព័ន្ធ" គឺជាការបង្ហាញពីលទ្ធភាពនៅក្នុងការសរុបរបស់អាស៊ាន ។

រដ្ឋអាចដឹកនាំ ដោយការកោះហៅក្រុមគណៈកម្មាធិការឲ្យមកធ្វើការអង្កេតលើការប្រព្រឹត្តរបស់ខ្លួនដែលឆ្លុះបញ្ចាំងពីសកម្មភាពជាក់ស្តែង ឬមួយក៏ការបង្កើតកម្មវិធីអប់រំនានា ក្នុងទិសដៅលើកស្ទួយឥទ្ធិពលរបស់ក្រុមទីភ្នាក់ងារ ។ រដ្ឋាភិបាលហ្វីលីពីនត្រូវបានគេប្រគល់តួនាទីជាលេខាធិការគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ាន ទទួលបន្ទុកសិទ្ធិមនុស្សរួចទៅហើយដែលតួនាទីនេះត្រូវបានប្រគល់ជូនដោយលោកស្រី ក្លូរៀ ម៉ាកាផាល អារ៉ូយ៉ូ និងអ្នកដឹកនាំក្រោយលោកស្រីគឺលោក ណយណយ អាហ្គីណូ ។ រដ្ឋាភិបាលប្រទេសឥណ្ឌូនេស៊ី ក្រោមការដឹកនាំរបស់លោក ស៊ូស៊ីលឡូ បាមបាំងយូដូយោណូ ក៏ទទួលបាននូវការពេញចិត្តក្នុងការអភិវឌ្ឍលើគណៈកម្មាធិការទទួលបន្ទុកសិទ្ធិមនុស្សរបស់ខ្លួន ហើយបានបង្ហាញពីចំណាប់

អារម្មណ៍ក្នុងការធ្វើជាតំណាងគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស ។ ប្រទេសមួយក្នុងចំណោមបីប្អូនប្រទេសដែលមានឥទ្ធិពលជាងគេនៅក្នុងការអភិវឌ្ឍគំរូគណៈកម្មាធិការនឹងមានប្រសិទ្ធភាពក្នុងការវិវត្តរបស់ស្ថាប័ន ។ ក្រុមគណៈកម្មាធិការជាតិដែលពឹងផ្អែកលើតែការគិតដូចជាប្រទេសសិង្ហបុរី ហើយជារឿយៗត្រូវបានគេចាត់ទុកជាទំពមុខប្រកបដោយប្រាជ្ញាសម្រាប់ "ការយល់ឃើញរបស់អាស៊ាន" នឹងនាំមកនូវឥទ្ធិពលដ៏ខ្លាំងក្លាថែមទៀត ។

ការបង្កើតការផ្លាស់ប្តូរនេះមិនមែនកើតឡើងតែមួយយប់សម្រាប់គណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស និងគណៈកម្មាធិការអាស៊ានទទួលបន្ទុកលើកស្ទួយ និងការពារសិទ្ធិស្ត្រីនិងកុមារទេ ស្ថាប័នក្នុងតំបន់មិនអាចធ្វើអ្វីឲ្យហួសពីសមត្ថភាពរបស់ខ្លួនដែលអាចនាំមកនូវមហន្តរាយ ។ ស្ថាប័នដែលអាចអភិវឌ្ឍនូវគណៈកម្មាធិការរបស់ខ្លួនយ៉ាងពិតប្រាកដ ដូចជាតុលាការសហគមន៍អឺរ៉ុបនៃសិទ្ធិមនុស្សក្រុមគណៈកម្មាធិការអន្តរអាមេរិកកាំង និងតុលាការសិទ្ធិមនុស្ស គឺទាមទារនូវការវិវត្តសន្សឹមៗ ទើបអាចទទួលបានជោគជ័យ ហើយគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស និងគណៈកម្មាធិការអាស៊ានទទួលបន្ទុកលើកស្ទួយ និងការពារសិទ្ធិស្ត្រី និងកុមារក៏ទាមទារយ៉ាងដូច្នេះដែរ ។

នៅក្នុងការសរសេរអ្នកតំណាងគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សបានធ្វើសេចក្តីព្រាងស្តីពីសេចក្តីថ្លែងការណ៍អំពីសិទ្ធិមនុស្សដែលបានដាក់ឲ្យបញ្ចប់ឲ្យបាននៅក្នុងឆ្នាំ ២០១១ តែត្រូវពន្យាររហូតដល់កិច្ចប្រជុំគណៈរដ្ឋមន្ត្រីអាស៊ាននៅខែកក្កដា ឆ្នាំ២០១២ទៅវិញ ។ អ្នកតំណាងគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សបានធ្វើសេចក្តីព្រាងមានលក្ខណៈអសាធារណៈដែលជាការស្តីបន្ទោសពីក្រុមសង្គមស៊ីវិលអ្នកដែលទាមទារនូវឱកាសអធិប្បាយជាសាធារណៈ ។ ឥទ្ធិពលឆាប់ៗនេះនៃសេចក្តីថ្លែងការណ៍នឹងមានភាពសមរម្យដូចនឹងដំណាក់កាលដទៃទៀតនៃការវិវត្តរបស់អាស៊ានឆ្ពោះទៅរករបបសិទ្ធិមនុស្ស ។ លោកសុរិន្ទ ពិតសុវណ្ណ ជាអ្នកគាំទ្រសំខាន់នៃគណៈកម្មាធិការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស និងគណៈកម្មាធិការអាស៊ានទទួលបន្ទុកលើកស្ទួយនិងការពារសិទ្ធិស្ត្រី និងកុមារ បានធ្វើការសរុបពីតំណែងរបស់គាត់គឺជាលេខាធិការដាន់ខ្ពស់ឆ្នាំ២០១២ ហើយនឹងអ្នកបន្តតំណែងរបស់គាត់ថាជាក្អាក់ងារដ៏សំខាន់ ។ ហើយអ្នកដែលពាក់ព័ន្ធទាំងអស់នឹងមានសិទ្ធិផ្លាស់ប្តូរអធិបតីតំណាងអាស៊ាន ។ ក្នុងឆ្នាំ២០១០កម្ពុជាគឺជាតំណាងអធិបតីហើយនឹងបន្តបន្ទាប់ទៀតគឺប្រទេសប្រ៊ុយណេ និងប្រទេសភូមាដែលប្រទេសទាំងពីរនេះមានភាពវៃឆ្លាតទៅនឹងយុទ្ធវិធីសិទ្ធិមនុស្សជាមួយនឹងការប្រុងប្រយ័ត្នខ្ពស់ ។ ស្ថិតនៅក្រោមក្រុមឯកសារយោងគណៈកម្មាធិការនឹងត្រូវបានគេត្រួតពិនិត្យនិងបន្តរ៉ាប់រងនៅក្នុងខួបគម្រប់លើកទី៥របស់ពួកគេ ។ អ្វីដែលមិនគួរឲ្យជឿគឺថារបបសិទ្ធិមនុស្សអាស៊ាននឹងត្រូវបានលូតលាស់ឡើង ប៉ុន្តែវាគួរតែជាការងើបឡើងដោយលទ្ធភាព និងសមត្ថភាពផ្ទាល់របស់អាស៊ាន ។ **ចន ឆរឆីអារី**

# ដំណឹងស្វែងរកប្អូន

នាងខ្ញុំឈ្មោះ ហង្ស ហួន និងប្តីឈ្មោះ សរ មឿន រស់នៅភូមិត្រពាំងសំរិត សង្កាត់គងនយ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ នាងខ្ញុំសូមប្រកាសរកប្អូនពីរនាក់ គឺ ៖ ◆ ប្អូនស្រី ហង្ស ហ៊ីម និងប្តីឈ្មោះ មុំ ភីន ។ អ្នកទាំងពីរមានកូនបួននាក់ ទី១) ស្រីញឹប, ទី២) សុភី, ទី៣) សុផាត និង ទី៤) អាចក់ ◆ ប្អូនប្រុស ហង្ស សំណាង ហៅ គ្រីម និងប្រពន្ធឈ្មោះ សយ ឃឿន ។ អ្នកទាំងពីរមានកូនពីរនាក់ ទី១) ណាក់ និង ទី២) ណូត ។

សូមបញ្ជាក់ថា គ្រួសារប្អូនៗទាំងពីរបែកគ្នាជាមួយនាងខ្ញុំនៅម្តុំអូរបែកក្អមក្នុងឆ្នាំ១៩៧៥ ក្រោយពេលដែលខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញ ។ មួយរយៈក្រោយមកនាងខ្ញុំឮដំណឹងថា គ្រួសារប្អូនទាំងពីរត្រូវខ្មែរក្រហមជម្លៀសទៅខេត្តបាត់ដំបង ប៉ុន្តែមិនដឹងថាទៅនៅភូមិ ស្រុកអ្វីនោះទេ ហើយក៏ បាត់ដំណឹងរហូតមកដល់ពេលនេះ ។

អាស្រ័យហេតុនេះ បើបងប្អូនណាបានដឹង និងស្គាល់ឈ្មោះដែលបានរៀបរាប់ខាងលើសូមទំនាក់ទំនងមកតាមរយៈអាសយដ្ឋានផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ, រាជធានីភ្នំពេញ ឬតាមរយៈទូរស័ព្ទលេខៈ ០១៦ ៨៩៦ ៦៩២ ។ ***សូមអរគុណ!***

# ក្បង់ទឹកទន្លេ

## ខ្សែភាពយន្តឯកសារទទួលពានរង្វាន់នៅមហោស្រពខ្សែភាពយន្តសាន់ដេនឆ្នាំ២០១៣



ម៉ម កល្យាណី

ខ្ញុំមកដល់ប្រទេសកម្ពុជដំបូងនៅឆ្នាំ១៩៩៨ បន្ទាប់ពីរយៈពេល១៧ឆ្នាំដែលគ្រួសាររបស់ខ្ញុំបានរត់គេចពីប្រទេសដែលហែកហួរដោយសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ។ ខ្ញុំមានអារម្មណ៍រន្ធត់នូវអ្វីដែលខ្ញុំបានឃើញដូចជា ភាពក្រីក្រ ភាពអស់សង្ឃឹម អំពើពុករលួយ ដែលបានញាំញីប្រទេសកម្ពុជា ។ ប៉ុន្តែខ្ញុំជាប់ចិត្តជាមួយសម្រស់ធម្មជាតិជុំវិញខ្លួនដូចជា សម្រស់ទឹកដីកម្ពុជា ប្រជាជន វប្បធម៌បុរាណ និងស្នាមញញឹមដែលស្វាគមន៍រូបខ្ញុំចំពោះការធ្វើដំណើរមួយនេះ ។

រយៈពេលជាងមួយទសវត្សរ៍ក្រោយមក សកលភាវូបនីយកម្មបានកែប្រែទឹកដីកម្ពុជា ។ ផ្លូវលំជាច្រើនត្រូវបានជំនួសដោយមហាវិថីធំៗ និងសំណង់អាគារខ្ពស់ៗពាសពេញទីក្រុង ។ វិថីតូចៗក្នុងក្រុងភ្នំពេញ ពោរពេញទៅដោយចរាចរណ៍ ដែលរថយន្តស្ព័រដ៏សង្ហាបើកបរលើវិថីតូចៗ មើលទៅហាក់ដូចជាមិនសក្តិសមទាល់តែសោះ ហើយនៅឯរោងចក្រកាត់ដេរឯណោះវិញ សម្បូរទៅដោយកម្មការនីក្មេងៗ ដែលកំពុងដេរខោខូវប៊យ និងម៉ូតខោអាវនាំចេញទៅសហរដ្ឋអាមេរិក ។

ក្នុងដំណើរប្រកួតប្រជែងជាសកលរបស់ប្រទេសកម្ពុជាដែលមានកម្មករទទួលប្រាក់កម្រៃទាបនិងភាពសម្បូរបែបខាងធនធានធម្មជាតិ ប្រទេសកម្ពុជាបានប្រែក្លាយវប្បធម៌រស់នៅដែលពឹងផ្អែកលើកសិកម្មតាមលក្ខណៈបុរាណរបស់ខ្លួនដើម្បីប្រកួតប្រជែងជាសកលក្នុងការទាក់ទាញវិនិយោគទុនបរទេស ។ ខ្ញុំថតខ្សែភាពយន្តឯកសារនេះដើម្បីចងក្រងតម្លៃរបស់ជនជាតិកម្ពុជាចំពោះការប្រែប្រួល "ក្បង់ទឹកទន្លេ" នេះ ហើយដើម្បីបង្ហាញមុខមាត់ប្រជាជនមួយនេះដែលផ្អែកលើការចិញ្ចឹមជីវិតតាមលក្ខណៈប្រពៃណីដល់សកលលោក ដែលការចិញ្ចឹមជីវិតរបស់ជនជាតិមួយនេះងាយនឹងបាត់បង់ជារៀងរហូត ។

ដោយមានម៉ាស៊ីនថតខ្សែភាពយន្ត និងឧបករណ៍ជាច្រើនឡេង រតនៈ និងរូបខ្ញុំបានធ្វើដំណើរទៅកាន់តំបន់បីផ្សេងគ្នាក្នុងប្រទេសកម្ពុជាដែលជាព្រៃដាច់ស្រយាលក្នុងខេត្តរតនគិរីនៅភាគឦសានប្រទេស ភូមិតាមដងទន្លេសាបក្នុងខេត្តកំពង់ឆ្នាំង និងតំបន់ជនបទក្នុងខេត្តស្វាយរៀងដើម្បីថតចងក្រងឯកសារអំពីជីវិតរបស់ប្រជាជនកម្ពុជាបីរូប និងគ្រួសាររបស់ប្រជាជនកម្ពុជាបីរូបនេះ ។

### ◆ *សាវ សាមួន រស់នៅក្នុងព្រៃដាច់ស្រយាលនៅភាគឦសាននៃប្រទេសកម្ពុជា*

នៅភាគឦសានប្រទេសកម្ពុជា យើងបានជួលម៉ូតូប្រាំបួនគ្រឿងដែលផ្ទុកទៅដោយសម្ភារ ស្បៀងអាហារ ទឹក និងម៉ាស៊ីនភ្លើងខ្នាតតូចសម្រាប់ផ្តល់ថាមពលដល់ក្រុមការងារថតខ្សែភាពយន្តរបស់យើង ។ ក្រុមការងារបានលើកម៉ូតូដាក់ទៅលើទូក រួចជិះឆ្លង



សារ៉ សាមួន

កាត់ផ្លូវទឹកទន្លេមេគង្គ ហើយបានបន្តធ្វើដំណើរឆ្លងកាត់ភ្នំចំនួនប្រាំបួនដើម្បីទៅដល់កន្លែងរស់នៅរបស់ សាមួន និងក្រុមគ្រួសារនៅក្នុងព្រៃជ្រៅ ។ ក្រុមការងារធ្វើដំណើរកាត់ព្រៃក្រាស់ ឆ្លងទឹកអូរ ហើយដេកក្នុងខ្ទមតូចដែលគ្រួសារ សាមួន ប្រើសម្រាប់ផ្ទុកស្រូវ និងសម្រាប់ចិញ្ចឹមមាន់ ។ ក្រុមការងាររបស់យើងបានក្រោកឡើងនៅម៉ោងបួនទៀបភ្លឺ នៅពេលមាន់រងាវ ដែលមេឃនៅមិនទាន់ភ្លឺនៅឡើយ ។ យើងបានឆ្លងទឹកអូរនៅពេលរសៀល ហើយរៀបចំគ្រែសម្រាកប្រហែលម៉ោងប្រាំពីរយប់ នៅពេលដែលមានតែពន្លឺផ្កាយចែងចាំងពាសពេញលំហមេឃ ។

សាមួន គឺជាជនជាតិចារ៉ាយ ជាជនជាតិមួយក្នុងចំណោមជនជាតិភាគតិចទាំង២៤ ដែលមានភាសា និងវប្បធម៌ផ្សេងៗគ្នារស់នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ហើយបានពឹងផ្អែកការចិញ្ចឹមជីវិត និងស្បៀងអាហាររបស់ខ្លួនលើដីកសិកម្ម និងព្រៃឈើ ។ សាមួន និងក្រុមគ្រួសារមិនមានភ្លើងអគ្គិសនីសម្រាប់ប្រើប្រាស់ទីផ្សារសម្រាប់ទិញឥវ៉ាន់ ឬសូម្បីតែការអប់រំបណ្ដុះបណ្ដាល ។ ការធ្វើដំណើរទៅកាន់ផ្ទះរបស់ សាមួន គឺជាពេលវេលាដំបូងដែល សាមួន និងក្រុមគ្រួសារមិនធ្លាប់ឃើញម៉ាស៊ីនថតខ្សែភាពយន្ត ដូច្នេះក្រុមការងាររបស់យើងបានបើកម៉ាស៊ីនមួយភ្លាមដើម្បីថតសកម្មភាពនេះរបស់គ្រួសារ សាមួន ។

ជាដំបូង ខ្សែភាពយន្តឯកសារនេះ បានថតកូនស្រីម្នាក់របស់ សាមួន មានឈ្មោះថា «ចា» ដែលកំពុងកាប់អំពៅ ។ ខ្ញុំចាំយ៉ាងច្បាស់ចំពោះថ្ងៃ ដែលក្រុមការងារយើងថតទិដ្ឋភាពនេះ ។ ក្រុមការងាររបស់យើងថតក្មេងស្រី «ចា» តាមជម្រាលភ្នំរហូតដល់ព្រៃល្បាស់ដែលហ៊ុំព័ទ្ធដោយចម្ការចេក និងចម្ការអំពៅ ។ នៅពេលដែលកុមារីតូចម្នាក់នេះកាន់អំពៅនៅនឹងដៃ ហើយចាប់ផ្ដើមកាប់នោះ ខ្ញុំចងចាំទិដ្ឋភាពនោះយ៉ាងច្បាស់ ។ ខ្ញុំមិនដែលឃើញក្មេងអាយុប្រាំបីឆ្នាំ មានភាពក្លាហាន ឆ្លៀវឆ្លាត ក្លៀវក្លា នៅក្នុងជីវិតរបស់ខ្ញុំនោះឡើយ ។ នៅពេលដែលខ្លួនកាប់អំពៅ កុមារី «ចា» បានសម្លឹងមកកាមេរ៉ាម្ដង ហើយខ្ញុំបានដឹងថា កុមារីតូចម្នាក់នេះមិនបានក្រឡេកមើលមករូបខ្ញុំនោះទេ ។ កុមារតូចនេះបានផ្ដោតការសម្លឹងមើលចូលក្នុងអារម្មណ៍របស់ក្រុមការងារទាំងអស់គ្នា ។

ជីវិតរបស់ សាមួន និងក្រុមគ្រួសារផ្លាស់ប្ដូរយ៉ាងលឿនដូចផ្លេកបន្ទោរ ។ ទោះបីជា សាមឿន មិនអាចចាប់យកឱកាសនៃការប្រែប្រួលនេះក៏ដោយ ខ្ញុំដឹងថា សាមឿន អាចរងឥទ្ធិពលនៃការប្រែប្រួលនេះ ។ គ្រាដំបូងដែលខ្ញុំសម្ភាសន៍ សាមួន បានអង្គុយនៅក្នុងខ្ទមតូចដែលហ៊ុំព័ទ្ធទៅដោយវាលស្រែមានពណ៌ដូចមាស និងព្រៃនៅពីខាងក្រោយ ។ ភ្លៀងបានធ្វើឲ្យចុះអ័ព្ទយ៉ាងក្រាស់ ហើយកូនស្រីរបស់ សាមួន ឈ្មោះ យុន បានដកសក់ស្កូវចេញពីក្បាលរបស់គាត់ ។ ភ្លៀងបានធ្លាក់ជាលើកដំបូងក្នុងរយៈពេលជាច្រើនខែ ហើយ សាមួន បានដឹងថាការប្រមូលផលច្រូតកាត់មិនបានល្អឡើយនៅក្នុងឆ្នាំនោះ ។ ខ្ញុំសួរ សាមួន ថាតើហេតុអ្វីបានជាអាកាសធាតុហួតហែងម៉្លេះ? សាមួន បាននិយាយថា មនុស្សចាស់បានដាក់បណ្ដាសារដល់ការកាប់ព្រៃឈើ ។

### ◆ សារី ម៉ាត់ រស់នៅលើបឹងទន្លេសាប

ទន្លេសាប គឺជាទន្លេធំមួយក្នុងចំណោមទន្លេដែលមានផ្លូវទឹកជាច្រើននៅពិភពលោក ។ សារី និងក្រុមគ្រួសាររស់នៅក្នុងភូមិ



សារី ម៉ាត់

បណ្តែតទឹកដ៏តូចមួយ នៅតាមដងទន្លេសាប ។ នៅពេលដែលខ្ញុំជួប សារី ជាលើកដំបូង សារី មានអាយុ១៤ឆ្នាំ ។ ខ្ញុំពិតជាចាប់អារម្មណ៍ ចំពោះការធំដឹងក្តីមុនអាយុ ការយល់ឃើញ និងលក្ខណៈល្អរបស់ សារី ។ សារី បាននាំយើងទៅកាន់វិហារអ៊ីស្លាមបណ្តែតទឹកមួយ ដោយបន្ទាប់មកចាប់យកគម្ពីរគូរ៉ាន់ និងចាប់ផ្តើមសូត្រធម៌ ។ យើងបានចំណាយពេលវេលាដែលនៅសេសសល់ទៅលេងផ្ទះ របស់សារី ហើយបន្ទាប់មកជិះទូកទៅកាន់ត្រើយចុងបឹងដើម្បី ស្វែងរកផ្កាកំប្លោក ។ ក្រុមការងារ មិនឃើញផ្កាកំប្លោកនោះឡើយ ប៉ុន្តែក្នុងដំណើរផ្លូវនោះ សារី បានប្រាប់យើងអំពីរឿងរ៉ាវនៅក្នុង គ្រួសារ ក្តីសុបិន្តក្នុងការទៅសាលារៀន ការចង់បានការងារល្អ និងការតបស្នងសងគុណចំពោះឪពុកម្តាយ ។

ពីរឆ្នាំក្រោយមក យើងបានត្រឡប់ទៅកាន់ភូមិដដែល នោះវិញ ហើយចាប់ផ្តើមជាប់ចិត្តចំពោះការប្រែប្រួលជីវិតរបស់ សារី ចាប់តាំងពីពេលដែលយើងបានជួបពីដំបូង ។ គ្រាបន្ទាប់មក សារី មានអាយុ១៦ឆ្នាំ ហើយបានឈប់រៀនដើម្បីជួយឪពុក ធ្វើនេសាទត្រី ។ សារី បានចែវទូកដឹកប្អូនៗរបស់ខ្លួនទៅសាលារៀន ជារៀងរាល់ព្រឹក ហើយចំណាយពេលពេញមួយថ្ងៃនេសាទត្រី ជាមួយឪពុកនៅក្នុងបឹងទន្លេសាប ។ ពេលខ្វះកន្លែងដែលធ្លាប់រក ត្រីលែងសម្បូរត្រី សារី និងក្រុមគ្រួសារត្រូវចាកចេញពីផ្ទះ នៅម៉ោង៣ទៀបភ្លឺ ដោយត្រូវវាយមង និងសារមង បន្ទាប់ពីរង់ចាំ ពីរឬបីម៉ោង ។ នៅពេលដែល សារី សារមង ឪពុករបស់ សារី បាន បង្ហាញត្រីដែលខ្លួនចាប់បាន ហើយបានចង្អុលទៅត្រីដែលនឹងជិត ផុតពូជ ។ ឪពុករបស់ សារី បាននិយាយអំពីរបៀបចម្អិនត្រីនោះ ហើយបន្ទាប់មកនិយាយអំពីមូលហេតុដែលពូជត្រី នឹងដាច់ពូជ ឧទាហរណ៍ដូចជាការអនុញ្ញាតឲ្យធ្វើការនេសាទត្រីទ្រង់ទ្រាយធំ ការដាក់លបចាប់ត្រីទ្រង់ទ្រាយធំ ការកើនឡើងការនេសាទខុស ច្បាប់ រួមមានការបោកគ្រាប់បែកសម្លាប់ត្រី ។

ក្រៅពីសាលារៀន និងការនេសាទត្រី អត្តសញ្ញាណ វប្បធម៌ និងសាសនារបស់ សារី មានលក្ខណៈសំខាន់សម្រាប់សាច់ រឿងនេះ ។ សារី និងក្រុមគ្រួសារគឺជាជនជាតិចាមដែលជាជនជាតិ ភាគតិចមួយ និងមានលក្ខណៈខុសប្លែកនៅក្នុងប្រទេសកម្ពុជា ហើយដែលកាន់សាសនាអ៊ីស្លាម ។ ខ្ញុំបានចំណាយពេលអស់ពីរឆ្នាំ ដើម្បីចូលថតទិដ្ឋភាពខាងក្នុងវិហារអ៊ីស្លាម ។ ប៉ុន្តែនៅពេលដែលខ្ញុំ ចូលក្នុងវិហារអ៊ីស្លាម ខ្ញុំបានដឹងថា សាសនា និងវប្បធម៌របស់ សារី មានទំនាក់ទំនងទៅនឹងជីវិត និងការនេសាទត្រី ។ អស់រយៈពេល រាប់រយឆ្នាំ ដែលអ្នកភូមិបណ្តែតទឹកទាំងនេះពឹងផ្អែកលើការនេសាទ ត្រីដើម្បីចិញ្ចឹមជីវិត ។ នៅពេលដែលត្រីបាត់បង់ តំបន់នេះ វប្បធម៌ និងសាសនា ដែលចងភ្ជាប់ជីវិតទាំងអស់ ក៏អាចនឹងបាត់បង់ដែរ ។

### ◆ ខៀវ មុំក ជនបទ និងរាជធានីភ្នំពេញ



ខៀវ មុំក

រឿងរ៉ាវរបស់ ខៀវ ប្រហែលជាសាច់រឿងដ៏គួរឲ្យហួងហែងបំផុតដើម្បីពិពណ៌នាដោយសារជីវិតរបស់ ខៀវ ផ្លាស់ប្តូរពី សង្គមជនបទ ទៅសង្គមទីក្រុងហើយវិលទៅវិលមកដូចទឹកទន្លេ ដែលហូរចុះហូរឡើង ។ ខ្ញុំចងចាំថា ពេលល្ងាចដំបូងដែលខ្ញុំត្រូវ បានណែនាំឲ្យស្គាល់ ខៀវ ប្អូនស្រីពីរនាក់ ប្អូនប្រុសម្នាក់ និងបង ថ្លៃម្នាក់នោះ ។ អ្នកទាំងអស់គ្នារស់នៅក្នុងបន្ទប់ដែលមានទំហំប៉ុន ចន្លោះទ្វារ ។ កាលណោះ ខៀវ ធ្វើការក្នុងរោងចក្រស្បែកជើង ។ ខៀវ ធ្វើការនៅរោងចក្រស្បែកជើងដដែលអស់រយៈពេល៥ឆ្នាំ ហើយចាប់ផ្តើមឈឺចាប់ដើមទ្រូង និងមានបញ្ហាខាងប្រព័ន្ធរំលាយ អាហារ ។ ខៀវ បានប្រាប់ខ្ញុំថា រោងចក្រខ្វះខ្យល់ចេញចូល ហើយ មិនត្រូវបានផ្តល់ម៉ាស់ពាក់ដើម្បីការពារផ្សែងពុលនោះឡើយ ។

ពីរឬបីសប្តាហ៍បន្ទាប់ពីខ្ញុំចាប់ផ្តើមថត ខៀវ នៅក្នុងបន្ទប់ ជួល ។ ខៀវ បានសម្រេចចិត្តថា ខ្លួននឹងត្រឡប់ទៅផ្ទះវិញដើម្បី ព្យាបាលជំងឺ ។ ខៀវ គឺជាកូនម្នាក់ក្នុងចំណោមកូនប្រាំបីនាក់ ដែល មានម្តាយជាស្ត្រីមេម៉ាយ ខំចិញ្ចឹមកូនដោយខ្លួនឯង ។ ម្តាយរបស់ ខៀវ បានចាកចេញពីប្តីដែលបានរំលោភបំពានសិទ្ធិរបស់ខ្លួន

ហើយម្តាយរបស់ ខៀវ បានហៅប្តីរបស់ខ្លួនទៅតុលាការដើម្បីលែងលះតាមផ្លូវច្បាប់ និងទាមទារសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិរួម ដែលនេះមិនមែនជារឿងសាមញ្ញចំពោះស្ត្រីកម្ពុជាដែលរស់នៅតាមជនបទនោះឡើយ ។ ប៉ុន្តែ ម្តាយរបស់ ខៀវ នៅតែទទួលបានទ្រព្យតិចតួចសម្រាប់ចិញ្ចឹមជីវិត ។ គ្រួសាររបស់ ខៀវ ចាប់ផ្តើមពីបាតដៃទទេ ដោយទិញដីថ្មី និងសង់ផ្ទះថ្មី ដូច្នេះហើយ ខៀវ និងក្រុមគ្រួសារជាប់ជំពាក់បំណុលជាច្រើន ។

ខៀវ រស់នៅផ្ទះឯជនបទអស់រយៈពេលប្រាំមួយខែ បន្ទាប់ពីបានសម្រេចចិត្តត្រឡប់ទៅទីក្រុងភ្នំពេញវិញ ហើយស្វែងរកការងារនៅក្នុងរោងចក្រកាត់ដេរ ។ ខៀវ អន្ទះសារចង់មកទីក្រុងណាស់ នៅពេលដែលខ្លួនសម្រាកព្យាបាលនៅផ្ទះឯជនបទ ។ ខៀវ មិនធ្វើអ្វីនោះទេនៅផ្ទះ ហើយជនបទក៏មិនមានផ្សារសម្រាប់ទិញឥវ៉ាន់ មិនមានភ្លើងអគ្គិសនី មិនមានអំពូល និងទូរទស្សន៍សម្រាប់មើលឡើយ ។ បំណុលកាន់តែធ្ងន់ធ្ងរឡើង ហើយ ខៀវ ចាំបាច់ត្រូវការស្វែងរកការងារដើម្បីផ្គត់ផ្គង់ការអប់រំរបស់ប្អូនប្រុសរបស់ខ្លួន ។ ចុងបញ្ចប់ ខៀវ ចាកចេញទៅទីក្រុងភ្នំពេញ ប៉ុន្តែបានត្រឡប់មកផ្ទះនៅឯជនបទសាជាថ្មី ក្នុងពេលដែលម្តាយរបស់ខ្លួនរអ៊ូរទាំចំពោះការងារធ្ងន់ដែលរ៉ាប់រងនៅផ្ទះតែម្នាក់ឯង ។

ដំបូងខ្ញុំសន្ទាបចិត្តចំពោះការថតសាច់រឿងរបស់ ខៀវ ដោយធ្វើដំណើរត្រឡប់ទៅត្រឡប់មកពីជនបទទៅទីក្រុងហើយមិនមានផែនការច្បាស់លាស់ ។ ប៉ុន្តែ ការមិនអាចសម្រេចចិត្តរបស់ ខៀវ មិនបានកើតឡើងតែឯងនោះឡើយ ។ សាច់រឿងរបស់ ខៀវ តំណាងឲ្យជីវិតរបស់កម្មករកាត់ដេរដែលបានញាំញី ដោយជីវិតគ្រួសារ និងឱកាសធ្វើការនៅទីក្រុង ។ ការមិនអាចសម្រេចចិត្តនេះពិពណ៌នាអំពីការចង់ឲ្យមានជីវិតរស់នៅបែបទីក្រុងកើតឡើងក្នុងភូមិរបស់ខ្លួន ។ ប្រសិនបើរោងចក្រអាចត្រូវបានកសាងនៅក្នុងភូមិ ជីវិតរបស់ប្រជាជនជនបទនឹងប្រសើរឡើង ហើយ ខៀវ នឹងមិនចាកចេញពីម្តាយ គ្រួសារ និងភូមិរបស់ខ្លួន ដើម្បីស្វែងរកការងារនៅទីក្រុងឡើយ ។ នៅពេលដែលរោងចក្រត្រូវបានកសាងឡើងពិតណាស់ ផ្លូវថ្នល់ ទីផ្សារ និងភ្លើងអគ្គិសនី នឹងកើតមានឡើង ។

ការលើកឡើងរបស់ ខៀវ បានបង្ហាញចេញពីចិត្ត និងបង្ហាញពីភាពសាំញ៉ាំ ការប្រឈមចំពោះការអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា និងសកលលោក ។ យើងទាំងអស់គ្នាខិតខំធ្វើឲ្យជីវិតប្រសើរឡើងជាមួយឱកាស និងបច្ចេកវិទ្យា ។ ទោះបីជាយ៉ាងនេះក្តី ក្នុងការកែប្រែជីវិត យើងត្រូវតែសួរខ្លួនឯងថាតើវាជះឥទ្ធិពលដល់ជីវិតផ្ទាល់ខ្លួន ជីវិតរបស់អ្នកដទៃ បរិស្ថាន និងសកលលោកដែលយើងរស់នៅដោយរបៀបណា?

សាច់រឿងរបស់ ខៀវ, សារី និង សាមឿន ឆ្លុះបញ្ចាំងពីបញ្ហាប្រឈមនៅពេលបច្ចុប្បន្ន ។ សាច់រឿងនោះ ស្តីអំពីបញ្ហាបរិស្ថាន ដូចជា ការកាប់បំផ្លាញព្រៃឈើ ការនេសាទត្រីហួសកំណត់ ជីវចម្រុះ និងការអភិរក្ស ។ ជាងនេះទៅទៀត សាច់រឿង ស្តីពីបញ្ហាមនុស្ស ដូចជា ការអភិវឌ្ឍ ការចំណាកស្រុក សកលភាវូបនីយកម្ម និងបំណុល ។ ប៉ុន្តែ សាច់រឿងសំខាន់គឺស្តីពីការតស៊ូ ការរស់រានមានជីវិត ការស្រឡាញ់គ្រួសារ និងក្តីសង្ឃឹម ។

ខៀវ, សារី និង សាមឿន បានបង្ហាញខ្ញុំនូវការប្រឹងប្រែង និងជំនឿដើម្បីកំណត់ជោគវាសនា និងអនាគតរបស់ខ្លួន ។ វគ្គមួយក្នុងចំណោមឈុតឆាកសំខាន់នៅក្នុងខ្សែភាពយន្តឯកសារនេះ គឺនៅចុងបញ្ចប់នៃសាច់រឿងនៅពេលដែល សាមឿន ពាក់មួក ហើយសម្លឹងមើលទៅអនាគតដោយទឹកមុខមាំ និងការតាំងចិត្ត ។ ក្រុមហ៊ុននឹងមក ហើយព្រៃឈើនឹងត្រូវកាប់បំផ្លាញ ប៉ុន្តែជីវិតរបស់ សាមឿន និងក្រុមគ្រួសារនឹងតស៊ូចំពោះរឿងហេតុនោះជានិច្ច ។ ប្រការនេះហើយ គឺជាការតស៊ូដែលធ្វើឲ្យក្រុមគ្រួសារជាច្រើនអាចរស់រានមានជីវិតក្នុងរបបខ្មែរក្រហម រួមមាន រូបខ្ញុំផ្ទាល់ ដែលនេះផ្តល់ឲ្យខ្ញុំនូវក្តី សង្ឃឹមសម្រាប់ប្រទេសកម្ពុជា ។

នេះគឺជាឱកាសសម្រាប់ប្រទេសកម្ពុជា និងសកលលោក ។ តើយើងអាចធ្វើឲ្យមានតុល្យភាពរវាងការភិវឌ្ឍ និងការបំផ្លាញយ៉ាងដូចម្តេច? តើយើងធ្វើការអភិវឌ្ឍដោយគ្មានការបំផ្លាញដោយរបៀបណា? ដោយចង់ស្វែងយល់ពីជីវិតរបស់ក្រុមគ្រួសារដែលរងការប៉ះពាល់ដោយផ្ទាល់តាមរយៈការអភិវឌ្ឍ និងសកលភាវូបនីយកម្ម យើងសង្ឃឹមថា ខ្សែភាពយន្ត “ក្បង់ទឹកទន្លេ” នេះនឹងធ្វើឲ្យអ្នកទស្សនាចូលរួមសួរសំណួរដែលទាមទារឲ្យមានការត្រិះរិះពិចារណាឲ្យច្បាស់លាស់ និងការស្តែងឲ្យឃើញតាមសកម្មភាពមិនមែនគ្រាន់តែគូសបញ្ជាក់សេចក្តីសន្និដ្ឋាននោះឡើយ ។

**ម៉ម កល្យាណី**

# អតីតកាលដែលនឹកស្មានមិនដល់

ក្រោយរបបខ្មែរក្រហមដួលរលំ ប្រជាពលរដ្ឋខ្មែរស្ទើរទាំងអស់ បានបាត់បង់ញាតិមិត្ត បងប្អូន ឪពុកម្តាយ ជីដូនជីតា និងមនុស្សជាទីស្រឡាញ់របស់ខ្លួន ។ ជាក់ស្តែង អ៊ំស្រី អ៊ុក ហាន ក៏បានបាត់បង់អ្នកជិតខាងជាទីស្រឡាញ់របស់គាត់ម្នាក់ដែរ ម្នាក់នោះ គឺ អ៊ុច សាមិន ដែលត្រូវចាប់ខ្លួនមកមន្ទីរស-២១ ឬគុកទួលស្លែង ។ ទោះបីជា ហាន មិនមានជាប់សាច់ឈាមនឹងគ្នាក៏ដោយ ប៉ុន្តែការរាប់អាន និងមនោសញ្ចេតនារបស់អ្នកទាំងពីរបីដូចជាញាតិមិត្តបង្កើតអ៊ីចឹងព្រោះគាត់ឃើញ និងរស់នៅក្បែរខាងជាមួយគ្រួសារសាមិន តាំងពីនាងកើតមកម្ល៉េះ ។

ធ្វើដំណើរពីចម្ងាយមកពីស្រុកកំចាយមារ ខេត្តព្រៃវែង អ៊ុក ហាន វ័យ៦៣ឆ្នាំ និងក្រុមគ្រួសាររបស់ សាមិន បានមកទស្សនាសារមន្ទីរទួលស្លែងជាលើកដំបូង ។ ដើរមើលរូបថតជនរងគ្រោះបណ្តើរ ហាន រំឭកពីអតីតកាលដ៏រីករាយរបស់គាត់ជាមួយ សាមិន បណ្តើរ ។ ជាមួយនឹងទឹកមុខក្រៀមក្រំ ហាន បានរៀបរាប់ថា គាត់រាប់អាន អ៊ុច សាមិន ដូចជាក្មួយបង្កើតអ៊ីចឹង ទោះមានអ្វីបន្តិចបន្តួច ក៏ចែករំលែកគ្នាទៅវិញទៅមកដែរ ។ ស្ថិតក្នុងវ័យ១៦ នាពេលនោះ សាមិន គឺជាកូនស្រីម្នាក់ក្នុងគ្រកូលកសិករដែលមានបងប្អូនប្រុសស្រីចំនួនប្រាំបីនាក់រាប់ទាំងពេលបច្ចុប្បន្ន ។ សាមិន គឺជាក្មេងស្រីសុភាពរាបសា មិនចេះនិយាយស្តីអ្វីផ្តេសផ្តាសទេ ទោះបីជាមិត្តភក្តិធ្វើបាបយ៉ាងណាក្តី ក៏នាងមិនតបនោះឡើយ ដោយសុខចិត្តយំតែម្នាក់ឯង ។ ក្នុងសម័យខ្មែរក្រហម គ្រួសាររបស់ ហាន ក៏ដូចជាគ្រួសាររបស់ សាមិន មិនត្រូវបានជម្លៀសទៅណានោះទេ អ្នកទាំងពីរត្រូវអង្គការចាត់តាំងឲ្យធ្វើការនៅរោងបាយដោយមានតួនាទីបុកស្រូវ ធ្វើល្អី និងកន្ទេល ទៅទីនោះរហូតដល់ថ្ងៃដែល សាមិន ត្រូវចាប់ខ្លួន ។ ហាន ចាំច្បាស់ថា នៅខែធ្នូ ឆ្នាំ១៩៧៨ ប្រហែលម៉ោង៣រសៀល អង្គការបានមកហៅ សាមិន ដោយប្រាប់ទៅប្រជុំដើម្បីផ្លាស់ទៅធ្វើការនៅរោងចក្រ ប៉ុន្តែមិនបានប្រាប់ថាទៅធ្វើការនៅរោងចក្រណានោះទេ ។ ពេលដែល សាមិន ចេញដំណើរ គ្រួសាររបស់នាងក៏បានឃាត់មិនឲ្យទៅដែរ តែនាងប្រាប់វិញថា នាងត្រូវតែទៅព្រោះនេះជាការចាត់តាំងរបស់អង្គការមិន



អ៊ុក ហាន នៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង (អតីតមន្ទីរស-២១) កាលពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២

អាចជិតាស់បានទេ ។ ចាប់តាំងពីពេលនោះមក ហាង ក៏ដូចជាគ្រួសាររបស់ សាមិន មិនដែលទទួលដំណឹងអ្វីពី សាមិន ឡើយ មិនដឹងថាទៅរស់នៅកន្លែងណា ឬធ្វើការនៅទីណាទេ ។ ជាង១ម្ភៃឆ្នាំក្រោយមក អំឡុងឆ្នាំ២០០០-២០០១ មានជនជាតិអាល្លឺម៉ង់ម្នាក់ឈ្មោះ វៀត កាលហៀន បាននាំយករូបថតរបស់ សាមិន ដែលថតនៅមន្ទីរស-២១ ឬគុកទួលស្លែង ទៅបង្ហាញដល់ក្រុមគ្រួសារ សាមិន ទើបអ្នកទាំងអស់គ្នាដឹងថាមនុស្សជាទីស្រឡាញ់ និងជាអ្នកដែលពួកគាត់ទន្ទឹងរង់ចាំការត្រឡប់មកវិញរាល់ថ្ងៃនោះ ត្រូវបានយកមកធ្វើទារុណកម្ម និងសម្លាប់នៅគុកទួលស្លែង ។

ម្នាក់ៗបានមកសម្លឹងមើលរូបថតនោះ ហាក់ដូចជាបង្ហាញនូវភាពស្និទ្ធស្នាល និងក្តីស្រឡាញ់ពោរពេញដោយភាពអាណិតអាសូរក្នុងចិត្ត ។ គ្រប់គ្នាយល់ថា សាមិន ប្រហែលជាត្រូវយកទៅសម្លាប់ជាមួយនឹងអ្នកឯទៀតនៅក្នុងព្រៃក្បែរភូមិ គ្មាននរណាម្នាក់ដឹងថាមានរឿងអ្វីកើតឡើងចំពោះ សាមិន នោះទេ ប៉ុន្តែការពិត គឺវាផ្ទុយពីអ្វីដែល ហាង ក៏ដូចជាគ្រួសាររបស់ សាមិន ធ្លាប់គិតពីមុនមក ។ អ្នកទាំងអស់គ្នាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងពេលដែលឃើញរូបថតរបស់ សាមិន ព្រមទាំង មិនដឹងសោះថា អ្វីទៅជាមន្ទីរស-២១ ឬគុកទួលស្លែង ។

ជាក់ស្តែងពេលនេះ ហាង និងគ្រួសាររបស់ សាមិន ត្រូវលោក វៀត កាលហៀន ដែលជាអ្នកធ្លាប់យករូបថតរបស់ សាមិន ទៅជូនដល់ផ្ទះ នាំមកទស្សនានៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងជាលើកដំបូង ជាទីដែល សាមិន ត្រូវបានសម្លាប់ ។

ឈានជើងចូលដល់បន្ទប់ដែលតាំងរូបថតជនរងគ្រោះជាច្រើន ហាង មានអារម្មណ៍ក្រៀមក្រំ ខ្លោចផ្សាក្នុងចិត្តជាខ្លាំង ។ គាត់មើលទៅរូបទាំងនោះដោយក្តីអាណិតអាសូរ មិនដឹងថាអ្នកទាំងនោះមានកំហុសអ្វីបានជាត្រូវយកមកទីនេះ តើអ្នកទាំងនោះលំបាកវេទនាយ៉ាងណាទៅនៅពេលនោះ? ជាពិសេស នឹកអាណិតទៅដល់ សាមិន ដែលគាត់ស្រឡាញ់ដូចក្មួយបង្កើត ។ និយាយដោយខ្សឹកខ្សួល «ខ្ញុំមិនយល់សោះ តើមានរឿងអ្វីកើតឡើងចំពោះ សាមិន? ហេតុអ្វីបានជានាងត្រូវបញ្ជូនមកសម្លាប់នៅទីនេះ នាងគឺជាមនុស្សស្រគត់ស្រគំ និយាយស្តីទន់ភ្លន់ មិនដែលប៉ះពាល់ដល់អ្នកណាទេ តែបែរជាត្រូវបញ្ជូនមកសម្លាប់ទីនេះ» ។

សាមិន គឺជាអតីតកាលដ៏រីករាយមួយដែលខ្ញុំបំភ្លេចមិនបាន» ។ **ធាវ សារៈមុនិន្ទ**

# ដំណឹងស្វែងរកបងប្អូន



នាងខ្ញុំ ញ៉ៅប ម៉ៅ អាយុ ៦៨ឆ្នាំ និងប្អូនស្រី ញ៉ៅប រ៉េត ហៅ ម៉េវ ជាកសិករ មានស្រុកកំណើតនៅភូមិត្រពាំងស្រងែ ឃុំខ្នាររនា ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ សព្វថ្ងៃរស់នៅភូមិយាងជើង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ យើងខ្ញុំទាំងពីរ សូមប្រកាសរកប្អូនប្រុសប្អូនស្រី ដែលបានបែកគ្នាក្នុងរបបខ្មែរក្រហមនៅចន្លោះឆ្នាំ១៩៧៥-៧៩ ដែលមានឈ្មោះ ១) ប្អូនស្រី ញ៉ៅប រ៉ែន បច្ចុប្បន្នអាយុប្រហែល៥៦ឆ្នាំ កាលពីសម័យខ្មែរក្រហមត្រូវអង្គការចាត់តាំងឲ្យទៅធ្វើនៅកងចល័តនៅស្រុកបរិបូរណ៍ ចាប់តាំងពីពេលនោះមកក៏បានដំណឹងរហូត ២) ប្អូនប្រុស ញ៉ៅប យ៉ុង បច្ចុប្បន្នអាយុប្រហែល៥១ឆ្នាំ កាលពីសម័យខ្មែរក្រហមធ្វើជាយោធាខ្មែរក្រហម ក្រោយរំដោះឆ្នាំ១៩៧៩ ក៏បាត់ដំណឹងរហូត ។

អាស្រ័យហេតុនេះ ប្រសិនបើបងប្អូនណាបានស្គាល់ និងដឹងដំណឹងពីឈ្មោះទាំងពីរខាងលើ សូមទាក់ទងអាសយដ្ឋានផ្ទះលេខ ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ ឬតាមរយៈទូរស័ព្ទផ្ទាល់របស់នាងខ្ញុំលេខ ០៨៨ ៤២ ៤៤ ២៣៦ ឬ ០១៦ ៨៧៦ ៦៩២ ។

**សូមអរគុណ**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម




មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។




***សូមផ្តល់ព័ត៌មានដូចខាងក្រោម៖***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។




ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល សហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 157, January 2013 ◆ Funded by USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.